# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកោះកុង**

# របាយការណ៍

# ស្តីពី

# ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង

# ប្រចាំឆ្នាំ២០២៣

ព.ស.២៥៦៧ ឆ្នាំ២០២៣

# មាតិកានុក្រម

ទំព័រ

សេចក្តីផ្តើម ........ ១
ផ្នែកទី១៖សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ........ ២
១.១-ការងាររដ្ឋបាល ........ ២
១.១.១-ការងាររបៀប និងឯកសារ ........ ២
១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន ........ ២
១.១.៣-ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ........ ៣
១.១.៤-ការងារសរុប និងព័ត៌មាន ........ ៥
១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា ........ ៦
១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា ........ ៦
១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ........ ៧
១.២-ការងារផែនការ និងវិនិយោគ ........ ៨
១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ........ ៨
១.២.២-ការគាំទ្រមូលដ្ឋាន ........ ៩
១.២.៣-ការវិនិយោគ ........ ១០
១.២.៤-ការងារសេវាសង្គម ........ ១១
១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប. ........ ១១
១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា ........ ១៣
១.៣-ការគ្រប់គ្រងធនធានមនុស្ស ........ ១៤
១.៣.១-ការងារគ្រប់គ្រងបុគ្គលិក ........ ១៤
១.៣.២-ការងារកសាងសមត្ថភាព ........ ១៥
១.៤-ការងារអន្តរវិស័យ ........ ១៦
១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច ........ ១៦
១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ ........ ១៧
១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ........ ១៧
១.៤.៤-ការងារគ្រប់គ្រងកាកសំណល់ ........ ១៧
១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ ........ ១៨
១.៦-ការងារការិយាល័យប្រជាពលរដ្ឋ(សម្រុះសម្រួលដោះស្រាយបណ្តឹង) ........ ១៨
១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត ........ ១៩
១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន ........ ១៩
១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ ........ ១៩
១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន ........ ១៩
១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ) ........ ១៩
១.៨.៤-ការផ្លាស់ប្តូរទំនិញ ........ ១៩
១.៨.៥-កិច្ចសហប្រតិបត្តិការ ........ ២០
១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ២០

១.៩.១-ការងារហិរញ្ញវត្ថុ ..................................................................................................២០
១.៩.២-ការងារគណនេយ្យ ................................................................................................២១
១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ ........................................................................................២១
១.១០-ការងារលទ្ធកម្ម ......................................................................................................២១
១.១១-ការងារសុខាភិបាល ..................................................................................................២៣
១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល...........................................................................២៤
១.១៣-ការងារផ្សេងៗ..........................................................................................................២៥
ផ្នែកទី២៖សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ..................................................២៥
២.១-ផ្នែកសេដ្ឋកិច្ច...........................................................................................................២៥
២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..................................................................២៥
២.១.២-ការងារធនធានទឹក និងឧតុនិយម ...........................................................................៣២
២.១.៣-ការងារអភិវឌ្ឍជនបទ ............................................................................................៣៣
២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ...........................................៣៤
២.១.៥-ការងាររ៉ែ និងថាមពល .............................................................................................៣៥
២.១.៦-ការងារពាណិជ្ជកម្ម ..................................................................................................២៣
២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ.....................................................................៣៦
២.១.៧.១-ការងារហិរញ្ញវត្ថុ ................................................................................................៣៧
២.១.៧.២-ការងារពន្ធដារ ....................................................................................................៣៧
២.១.៧.៣-ការងារគយ និងរដ្ឋាករ ........................................................................................៣៧
២.១.៨-ការងារទេសចរណ៍ ..................................................................................................៣៨
២.១.៩-ការងារផែនការ .......................................................................................................៤០
២.១.១០-ការងារផ្សេងៗ .......................................................................................................៤០
២.១.១០.១-ការងារសាខាធនាគារជាតិ.....................................................................................៤០
២.១.១០.២-ការងាររតនាគារ...................................................................................................៤១
២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ......៤១
២.២-ផ្នែកសង្គមកិច្ច............................................................................................................៤២
២.២.១-ការងារអប់រំ យុវជន និងកីឡា ..................................................................................៤២
២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា .....................................................៤៦
២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ........................................៤៨
២.២.៣.១-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ..............................................................................៤៨
២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម ..........................................................................៤៩
២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ ................................................................................៥០
២.២.៥-ការងារព័ត៌មាន ......................................................................................................៥១
២.២.៦-ការងារកិច្ចការនារី ....................................................................................................៥១
២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ..................................................៥៤
២.២.៨-ការងារធម្មការ និងសាសនា .......................................................................................៥៤
២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ......................................................................៥៥

២.២.១០-ការងារមុខងារសាធារណៈ ........................................................................................................ ៥៦
២.២.១១-ការងារផ្សេងៗ.................................................................................................................. ៥៩
២.២.១១.១-ការងារសាលាដំបូងខេត្ត ......................................................................................... ៥៩
២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ..................... ៦០
២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី .................................................... ៦០
២.៣.២-ការងារបរិស្ថាន ............................................................................................................. ៦១
២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន .................................................................................. ៦២
២.៣.៤-ការងារផ្សេងៗ ............................................................................................................... ៦៤
២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ...................................................................... ៦៤
២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ............................................ ៦៤
២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ ..................................................... ៦៨
២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត ................................................................................... ៧០
២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ ............................................................................................ ៧២
២.៤.៥-ការងារផ្សេងៗ ............................................................................................................... ៧៤
ផ្នែកទី៣៖បញ្ហាប្រឈម និងសំណើដោះស្រាយ.......................................................................................... ៧៤
ផ្នែកទី៤៖ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់.................................................................. ៧៥
ផ្នែកទី៥៖សេចក្តីសន្និដ្ឋាន .................................................................................................................. ៩១
ឧបសម្ព័ន្ធ
ឧបសម្ព័ន្ធទី១៖ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំឆ្នាំ២០២៣
ឧបសម្ព័ន្ធទី២៖ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំឆ្នាំ២០២៣
ឧបសម្ព័ន្ធទី៣៖វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនៃរដ្ឋបាលខេត្តប្រចាំឆ្នាំ២០២៣ (ថវិកាវិភាជន៍ពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**

លេខ ៣៧៤/២៣ រ.ប.ក

ថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កោះកុង ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

# របាយការណ៍

## ស្តីពី

## ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង ប្រចាំឆ្នាំ២០២៣

### សេចក្តីផ្តើម

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៩០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺនិងខេត្តព្រះសីហនុ ខាងលិចនិងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប ១០.០៤៥,៥៨គ.ម២ មានក្រុង១ ស្រុក៦ ឃុំ២៦ សង្កាត់៣ និងមានភូមិសរុបចំនួន១១៩ភូមិ។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៧៥២ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៩ ត្រាស់បង្គាប់ទទួលស្គាល់សមាជិកក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៣។ ក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៣ មានសមាសភាព១៩រូប ស្រី២រូប ប្រធាន១រូប(ប្រុស) និងមានគណៈកម្មាធិការកាតព្វកិច្ចចំនួន៤រួមមាន៖ ១).គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ២).គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ៣).គណៈកម្មាធិការលទ្ធកម្ម និង ៤).គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម។

ដោយមានស្ថានភាពភូមិសាស្ត្រអំណោយផលពីធម្មជាតិ នាំឱ្យខេត្តកោះកុង មានសក្តានុពលដ៏សម្បូរបែបអាចបម្រើដល់វិស័យជាច្រើន ជាពិសេសវិស័យទេសចរណ៍ រួមមាន ៖ តំបន់ធម្មជាតិដ៏ស្រស់ត្រកាលគ្របដណ្តប់ដោយព្រៃភ្នំជ្រលងជងអូរ តំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំ១២.០០០ហិកតា តំបន់ព្រំដែនមានសណ្ឋាគារលំដាប់ផ្កាយ៥ជាប់មាត់សមុទ្រ តំបន់សេដ្ឋកិច្ចពិសេសកោះកុង តំបន់កោះទាំង២៣ មានប្រជុំកោះ៩ ដែលមានផ្កាថ្មដ៏ស្រស់ស្អាត និងតំបន់ឆ្នេរសមុទ្រមានប្រវែង២១៧គីឡូម៉ែត្រ លាតសន្ធឹងពីចំណុចជ្រោយស្វាយ ស្រុកស្រែអំបិល រហូតដល់ចំណុចចាំយាម ស្រុកមណ្ឌលសីមា ស្មើនឹង៥៤,៤% នៃប្រវែងឆ្នេរសមុទ្រ៤៤០គីឡូម៉ែត្រ នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់វិស្សមកាលតារាសាគរកោះស្តេចដែលមានទីលានវាយកូនហ្គោលខ្នាតអន្តរជាតិ តំបន់កសិ-ឧស្សាហកម្មចម្រុះ និងទំនប់វារីអគ្គិសនីចំនួន៤កន្លែង។ ក្រៅពីនេះខេត្តកោះកុង មានដៃព្រែកធំៗចំនួន៥ បានរួមចំណែកក្នុងការរុញច្រានកំណើនសេដ្ឋកិច្ចខេត្ត រួមមាន ព្រែកកោះប៉ោះ ព្រែកតាតៃ ព្រែកត្រពាំងរូង ព្រែកអណ្តូងទឹក និងព្រែកស្រែអំបិល។

ក្រុមប្រឹក្សាខេត្ត រួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០២០-២០២៤) ក្នុងការលើកកម្ពស់អភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិនានា ដោយផ្តោតលើគោលដៅអភិវឌ្ឍន៍ដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ លូ ស្ពាន សួនច្បារ សួនកម្សាន្ត សំណង់អគាររមណីយដ្ឋានទេសចរណ៍ អគ្គិសនី ទឹកស្អាត វប្បធម៌ សាសនា និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

# ផ្នែកទី១÷សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត

## ១.១-ការងាររដ្ឋបាល

### ១.១.១-ការងាររបៀប និងឯកសារ

- បានរៀបចំកែសម្រួលបញ្ជីទុកដាក់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការណែនាំរបស់គណៈអភិបាលខេត្ត
- បានកត់ត្រា និងដំណើរការចរន្តឯកសាររដ្ឋបាល ជូនថ្នាក់ដឹកនាំ និងមន្ទីរ អង្គភាពពាក់ព័ន្ធបានល្អប្រសើរ
- ទំនាក់ទំនង សម្របសម្រួល និងតាមដានរាល់លិខិតចេញ ចូល របស់រដ្ឋបាលខេត្ត ជាប់ជាប្រចាំ។

តារាងទី១៖លិខិតបទដ្ឋាន និងឯកសារប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | 0 | ៤៨ | ៤៨ |
| ២ | សេចក្ដីសម្រេចដែលបានដាក់ចេញ | 0 | ៨១ | ៨១ |
| ៣ | លិខិតដែលបានដាក់ចេញ | 0 | ៣.២២៤ | ៣.២២៤ |
| ៤ | លិខិតចូល | 0 | ៣.០២៧ | ៣.០២៧ |
| ៥ | ឯកសារដែលបានធ្វើនីត្យានុកូលកម្ម | 0 | ៦២ | ៦២ |
| ៦ | អនុស្សរណៈឬកិច្ចព្រមព្រៀង | 0 | 0 | 0 |
| ៧ | សៀវភៅគ្រួសារ | 0 | ៧១៧ | ៧១៧ |
| ៨ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 0 | ១២.២៤៦ | ១២.២៤៦ |

### ១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន

- បានស្រាវជ្រាវពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬខូច ដោយយថាហេតុ តាមរយៈការស្នើសុំរបស់សាមីខ្លួន ចំនួន១៣០នាក់ (ក្រុងខេមរភូមិន្ទ ស្រុកបូទុមសាគរ ស្រុកមណ្ឌលសីមា ស្រុកកោះកុង និងស្រុកគិរីសាគរ)
- បានស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈមេឃុំ ចៅសង្កាត់ បានចំនួន៤៩០នាក់ (ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកកោះកុង ស្រុកថ្មបាំង និងស្រុកបូទុមសាគរ)
- បានបញ្ជូនដីកាសម្រេចកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានពីសាលាដំបូងខេត្តកោះកុងទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃចំនួន៥៦ច្បាប់
- បានបញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រង ឯកសារ (www.crdepartment.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋបានចំនួន៧៤ច្បាប់។

តារាងទី២៖ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | គ្រួសារសរុប | ៣៥.៦២៦ | |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៤.០២៥ | |
| ៣ | គ្រួសារបណ្ដោះអាសន្ន | ១.៦០១ | |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៤ | ស្ត្រីជាមេគ្រួសារ | ៧.២១១ | |
| ៥ | ប្រជាពលរដ្ឋសរុប | ១៥១.៣៤៨ | ៧៥.៣០៤ |
| ៦ | កុមារអាយុក្រោម៦ឆ្នាំ | ១៥.១៩៦ | ៧.៨១៤ |
| ៧ | កុមារអាយុពី៦ឆ្នាំដល់១៨ឆ្នាំ | ៣៩.៧៤៩ | ១៩.៧៤៦ |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៩៧.៣៩៧ | ៤៩.៨៥៣ |
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | ៥.៣៦៤ | ២.៣៧៤ |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | ១.៣៨៧ | ៥៧៩ |

តារាងទី៣៖អត្រានុកូលដ្ឋាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ស្ថិតិចុះបញ្ជីកំណើត | 0 | ១.៩៧៤ | ១.៩៧៤ |
| ២ | បញ្ជាក់កំណើត | 0 | ៣.០៦៤ | ៣.០៦៤ |
| ៣ | បញ្ជីមរណភាព | 0 | ៤៤៣ | ៤៤៣ |
| ៤ | អាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | 0 | ១.៣៩០ | ១.៣៩០ |
| ៥ | អាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | 0 | ៧ | ៧ |

**១.១.៣-ការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ**

- បានដឹកនាំប្រតិភូខេត្តកោះកុង ទៅសួរសុខទុក្ខ និងជូនពរថ្នាក់ដឹកនាំខេត្តកាម៉ៅ និងខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន វៀតណាម
- បានដឹកនាំប្រតិភូខេត្តកោះកុង ទៅចូលរួមប្រជុំជាមួយប្រតិភូខេត្តត្រាត ដើម្បីពិភាក្សាការងារចាំបាច់មួយចំនួន នៅទីរួមខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៍
- បានជួបប្រជុំពិភាក្សាការងារ ស្តីពីការពិនិត្យកែតម្រូវលើសេចក្តីព្រាង កិច្ចព្រមព្រៀងនៃការបង្កើតរដ្ឋខេត្តបងប្អូន រវាងរដ្ឋកេរ៉ាឡា នៃសាធារណរដ្ឋឥណ្ឌា និងខេត្តកោះកុង នៃព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- បានចូលរួមពិធីបើកការប្រកួតកីឡាដើម្បីអប់រំក្នុងកម្មវិធី(A-MATH) ខ្រសវើដ ស៊ូដូកុ ខាំខុម ហ្គេមស៍ លើកទី៧ នៅសាលារៀនខ្លងយៃវិទ្យាគម ស្រុកខ្លងយៃ ខេត្តត្រាត ប្រទេសថៃ
- បានទទួលជួបគណៈប្រតិភូ នៃស្ថានអគ្គកុងស៊ុលវៀតណាម ប្រចាំខេត្តព្រះសីហនុ ប្រតិភូខេត្តកាម៉ៅ និងខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម អញ្ជើញមកជួបសំណេះសំណាល និងជូនពរថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជាជនខេត្តកោះកុង ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំ២០២៣ នៅសាលាខេត្តកោះកុង
- បានចូលរួមព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មព្រំដែនភាគខាងកើត ឆ្នាំ២០២៣ "សេដ្ឋកិច្ចថ្មី" និងការផ្គូផ្គងពាណិជ្ជកម្មរវាងសហគ្រិនថៃ និងសហគ្រិនកម្ពុជា ក្នុងការធ្វើជាដៃគូពាណិជ្ជកម្មអន្តរជាតិ នៅខេត្តអយុធ្យា នៃព្រះរាជាណាចក្រថៃឡង់ដ៍
- បានសម្របសម្រួលដល់ប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ធ្វើទស្សនកិច្ចសិក្សានៅតាមតំបន់អភិវឌ្ឍសេដ្ឋកិច្ចផ្សេងៗ របស់ខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងគោលបំណងសិក្សាលើភាពខ្លាំង ភាពខ្សោយ និងកាលានុវត្តភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចខេត្តជាប់ព្រំដែន

- ក្រុមលេខាធិការនៃគណៈកម្មាធិការព្រំដែនយោធភូមិភាគទី៣ បានចូលរួមកិច្ចប្រជុំក្រុមលេខា ជាមួយក្រុមលេខានៃកងបញ្ជាការការពារព្រំដែនច័ន្ទបុរី-ត្រាត លើកទី២៥(RBC.25)នៅខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃឡង់ដ៍
- គណៈកម្មាធិការព្រំដែនយោធភូមិភាគទី៣ បានចូលរួមកិច្ចប្រជុំគណៈកម្មការនៃគណៈកម្មាធិការព្រំដែនយោធភូមិភាគកម្ពុជា-ថៃ និងថៃ-កម្ពុជាលើកទី២៥ (RBC.25) ជាមួយកងបញ្ជាការការពារព្រំដែនច័ន្ទបុរី-ត្រាត នៅខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃឡង់ដ៍
- គណៈកម្មការជំនាញខេត្តកោះកុង បានចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូគណៈកម្មការជំនាញខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការចុះហត្ថលេខាលើកំណត់ហេតុប្រគល់-ទទួលនូវអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្ត និងជំនាញការវៀតណាម ដែលពលីកាលពីសម័យសង្គ្រាមនៅកម្ពុជា នៅលើទឹកដីខេត្តកោះកុង សម្រាប់រដូវប្រាំង ឆ្នាំ២០២២-២០២៣ នៅសាលប្រជុំសាលាខេត្តកោះកុង
- បានចូលរួមជាមួយប្រតិភូសភាពាណិជ្ជកម្មខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងដំណើរទស្សនា និងធ្វើទស្សនកិច្ចសិក្សាជកស្រង់បទពិសោធន៍សិក្សាឈ្វេងយល់ពីសក្តានុពលផ្សេងៗ នៅកំពង់ផែទេសចរណ៍ និងទំនិញរាយជងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំផ្គូផ្គងពាណិជ្ជកម្ម សេដ្ឋកិច្ចក្នុងស្រុក និងតំបន់ព្រំដែន រវាងសហគ្រិន និងតំណាងវិស័យឯកជនថៃ ជាមួយសហគ្រិន និងតំណាងវិស័យឯកជនកម្ពុជា
- បានចូលរួមកិច្ចប្រជុំពិភាក្សា និងផ្តល់យោបល់ លើករណីសំណើសុំការអនុញ្ញាតជាគោលការណ៍ពិសេស សម្រាប់ភ្ញៀវទេសចរថៃដែលមិនបានយកលិខិតឆ្លងដែនមកជាប់តាមខ្លួន (មានតែអត្តសញ្ញាណប័ណ្ណសញ្ជាតិថៃ) អាចចូលមកកម្សាន្តទេសចរណ៍រយៈពេលខ្លី ក្នុងតំបន់ទេសចរណ៍សំខាន់ៗ ក្នុងខេត្តកោះកុង
- ក្រុមការងារ BLOកោះកុង និងBLOខ្លងយៃ បានរៀបចំកិច្ចប្រជុំរួមគ្នាជាលើកទី២ ឆ្នាំ២០២៣ នៅសាលាស្រុកខ្លងយៃ ខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៍
- បានទទួលស្វាគមន៍ គណៈប្រតិភូកងទ័ពជើងទឹក យោធភូមិភាគទី១ ស្រុកសាត់តាហិប ខេត្តឈុនបុរី នៃព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងកម្មវិធីផ្តល់សម្ភារសិក្សា សម្ភារកីឡា និងសម្ភារផ្សេងៗទៀត ដល់វិទ្យាល័យប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានចូលរួមកម្មវិធីមនុស្សធម៌ (CSA) ដែលត្រូវបានរៀបចំដោយប្រតិភូស្ថានទូតថៃ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាល័យប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានជួបពិភាក្សាជាមួយប្រតិភូនៃវិទ្យាស្ថានអភិវឌ្ឍជំនាញ៣៣ត្រាត ខេត្តត្រាត នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីកំណត់វគ្គបណ្តុះបណ្តាលតម្រូវការផ្នែកការងារបង្កើនជំនាញ និងចំណេះដឹងដល់កម្មករ កម្មការិនីនៅក្នុងខេត្តកោះកុង នៅសាលប្រជុំ(ខ)សាលាខេត្ត
- បានទទួលស្វាគមន៍ និងសម្តែងការគួរសមជាមួយឯកឧត្តម Dominic William ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងប្រតិភូអមដំណើរ ដែលបានអញ្ជើញមកបំពេញបេសកកម្មក្នុងខេត្តកោះកុង
- បានទៅទទួលរថយន្តក្រុងចំនួន៩គ្រឿង ពីក្រុមហ៊ុន ប៉ូយ៉ុង ខ្មែរ II ខូអិលធីឌី នៅខេត្តព្រះសីហនុ
- បានជួបប្រជុំពិភាក្សាវាយតម្លៃពីស្ថានភាពជាក់ស្តែង នៃការគ្រប់គ្រង ការពារសំណង់ស្តូបអនុស្សាវរីយ៍មិត្តភាពកម្ពុជា-វៀតណាម នៅសាលាខេត្តកោះកុង
- បានជួបប្រជុំពិភាក្សាការងារជាមួយក្រុមការងារវិទ្យាស្ថានស្រាវជ្រាវដំណាំត្រូពិច-ក្វាងស៊ី ជាមួយក្រុមការងារតំបន់សេដ្ឋកិច្ចពិសេសចេជាំង ស្តីពីការស្វែងរកឱកាស និងស្វែងយល់ពីសក្តានុពលផ្សេងៗរបស់ខេត្តសម្រាប់ធ្វើការវិនិយោគក្នុងការដាំដុះដំឡូងមីដើម្បីផ្គត់ផ្គង់ទៅលើទីផ្សារប្រទេសចិន
- បានចូលរួមសម្របសម្រួលដល់ក្រុមការងារបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ថៃ ចុះពិនិត្យបង្គោលព្រំដែនលេខ៧៣ ចំណុចTU 71831 89149 (ចាំយាម-ហាតឡេក) ស្ថិតក្នុងព្រំដែនខេត្តកោះកុង និងខេត្តត្រាតប្រទេសថៃចំនួន២លើក

- បានចូលរួមកិច្ចប្រជុំស្តីពីការរុករក ការជីកគាស់ ការធ្វើមាតុភូមិនិវត្តន៍ នូវអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្ត និងជំនាញការវៀតណាមដែលពលីកាលពីសម័យសង្គ្រាមនៅកម្ពុជា សម្រាប់ដំណាក់កាលXXIII (រដូវប្រាំង២០២៣-២០២៤) រវាងគណៈកម្មការជំនាញខេត្តកោះកុង នៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការជំនាញខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម
- បានចូលរួមក្នុងកិច្ចប្រជុំតភ្ជាប់ច្រករបៀងសេដ្ឋកិច្ច ខាងកើតទៅនឹងសេដ្ឋកិច្ចសកល ការលើកកម្ពស់ពាណិជ្ជកម្មរវាងសេដ្ឋកិច្ចក្នុងស្រុកដល់កម្រិតអន្តរជាតិ ដោយការផ្សារភ្ជាប់ពាណិជ្ជកម្មតាមព្រំដែន (២០២៣មុនឆ្នាំសារពើពន្ធ) និងចូលរួមសិក្ខាសាលា ស្តីពីការតភ្ជាប់ច្រករបៀងសេដ្ឋកិច្ចខាងកើតទៅនឹងសេដ្ឋកិច្ចសកលដោយភ្ជាប់ទៅលើនយោបាយលើកកម្ពស់សេដ្ឋកិច្ចភាគខាងកើត និងទំនាក់ទំនងពាណិជ្ជកម្មតាមព្រំដែន ការជំរុញការវិនិយោគពាណិជ្ជកម្ម និងទេសចរណ៍ រវាងប្រទេសថៃខាងកើត និងប្រទេសជិតខាង ដើម្បីភ្ជាប់ជាមួយច្រករបៀងសេដ្ឋកិច្ចខាងកើត
- បានចូលរួមប្រជុំបូកសរុបលទ្ធផល នៃកិច្ចសហប្រតិបត្តិការឆ្នាំ ២០១៨-២០២២ និងលើកទិសដៅសហប្រតិបត្តិការសម្រាប់ឆ្នាំបន្ត រវាងខេត្តកោះកុង នៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

តារាងទី៤៖ការងារទំនាក់ទំនងសាធារណៈ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សាធារណជនមកទំនាក់ទំនងសាលាខេត្ត | 0 | ២.៨៣១ | ២.៨៣១ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | 0 | ១២ | ១២ |

**១.១.៤-ការងារសរុប និងព័ត៌មាន**

- បានរៀបចំសេចក្តីព្រាងរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២៣
- បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្ត ប្រចាំខែ មុននឹងដាក់ឆ្លងក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំបូកសរុបរបាយការណ៍ ស្តីពីសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ និងព្រឹត្តិការណ៍សំខាន់ៗក្នុងខេត្តប្រចាំថ្ងៃ ជូនលោកជំទាវអភិបាលខេត្ត និងឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
- បានរៀបចំផ្សព្វផ្សាយព័ត៌មានតាមបណ្តាញផ្សព្វផ្សាយនានារបស់រដ្ឋបាលខេត្ត
- បានផ្តិតយករូបភាពសកម្មភាពថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ

តារាងទី៥៖ការផ្សព្វផ្សាយព័ត៌មាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | វិទ្យុ | 0 | ១៩៥ | ១៩៥ |
| ២ | ទូរទស្សន៍ | 0 | ២៥៨ | ២៥៨ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | 0 | ៣៨ | ៣៨ |
| ៤ | បណ្តាញសង្គម (គេហទំព័ររដ្ឋបាលខេត្ត) | 0 | ៨.១០៤ | ៨.១០៤ |
| ៥ | ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី និងសារព័ត៌មាន | 0 | ៣២០ | ៣២០ |

### ១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា

- បានសម្របសម្រួលដំណើរការកិច្ចប្រជុំ និងរៀបចំសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំសេចក្តីព្រាងរបៀបវារៈកិច្ចប្រជុំ និងលិខិតអញ្ជើញសម្រាប់កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- បានចាត់ចែងទុកដាក់ និងថែរក្សារាល់ឯកសារដែលបានអនុម័តរួចដោយក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលរាល់លិខិត និងឯកសារនានាដែលចរាចរចេញ ចូលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាបានទាន់ពេលវេលា។

តារាងទី៦៖ការរៀបចំវេទិកា (ពុំមាន)

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | ថ្ងៃទី២៣/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកស្រែអំបិល | ២៧៤ | ៤៨ |
| ២ | ថ្ងៃទី២៤/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកបូទុមសាគរ | ២៦៥ | ៧៥ |
| ៣ | ថ្ងៃទី២៥/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកគិរីសាគរ | ២១៤ | ៦០ |
| ៤ | ថ្ងៃទី២៦/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកកោះកុង | ២៩៦ | ៩៨ |
| ៥ | ថ្ងៃទី២៧/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកថ្មបាំង | ១៧២ | ៤៨ |
| ៦ | ថ្ងៃទី៣០/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅស្រុកមណ្ឌលសីមា | ២៤៨ | ៨១ |
| ៧ | ថ្ងៃទី៣១/១០/២០២៣ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅក្រុងខេមរភូមិន្ទ | ២៧៨ | ៨៥ |

### ១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា

#### ក)-ការងារគណៈអភិបាល

**១. អភិបាល នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅក្រៅប្រទេសសរុបចំនួន១៧២លើក ។

**២. អភិបាលរង នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន៨០៩លើក។

តារាងទី៧៖កិច្ចប្រជុំគណៈអភិបាល

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ០ | ៤ | ៤ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ០ | ១ | ១ |
| ៣ | កិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាល | ០ | ១៦ | ១៦ |

**ខ)-ការងារគណៈកម្មាធិការនានា**

តារាងទី៨៖កិច្ចប្រជុំគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ០ | ១០ | ១០ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ | ០ | ៦ | ៦ |
| ៣ | កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ០ | ៣ | ៣ |
| ៤ | កិច្ចប្រជុំក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ០ | ៤ | ៤ |
| ៥ | ផ្សេងៗ...... | ០ | ២០ | ២០ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ០ | ៦ | ៦ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ០ | ៧ | ៧ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ០ | ៧ | ៧ |

**១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

- បានដំណើរការកិច្ចប្រជុំសាមញ្ញចំនួន១២លើក របស់ក្រុមប្រឹក្សាខេត្ត
- បានពិនិត្យ និងអនុម័តលើឯកសារពាក់ព័ន្ធនានាតាមរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញចំនួន១២លើក អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត
- បានដំណើរការកិច្ចប្រជុំសាមញ្ញចំនួន១២លើក របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត
- បានដំណើរការកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម ចំនួន២៧លើក។

តារាងទី៩៖កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ០ | ១២ | ១២ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០ | ២ | ២ |

| | | | | |
|---|---|---|---|---|
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ០ | ១២ | ១២ |
| ៦ | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | ០ | ២៧ | ២៧ |
| ៧ | ផ្សេងៗ............ | ០ | ២ | ២ |

## ១.២-ការងារផែនការ និងវិនិយោគ

### ១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

- **ក្រុមការងារកសាងផែនការខេត្ត៖**
    - បានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៣-២០២៥ ប្រតិទិនស្ដីពីដំណើរការ នៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៤-២០២៦ និងសេចក្ដីណែនាំស្ដីពីដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៤-២០២៦ ខេត្តកោះកុង
    - បានរៀបចំវគ្គបណ្ដុះបណ្ដាលតម្រង់ទិសជូនក្រុមប្រឹក្សាខេត្ត និងអ្នកពាក់ព័ន្ធ ស្ដីពីវិធីសាស្ត្រក្នុងការពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលមានអ្នកចូលរួមសរុបចំនួន២៥នាក់ ស្រី៣នាក់
    - បានរៀបចំកិច្ចប្រជុំជាមួយ មន្ទីរអង្គភាពជំនាញ ដើម្បីពិនិត្យ និងកែសម្រួលការវិភាគស្ថានភាពខេត្ត និងគម្រោងសកម្មភាពអាទិភាពសម្រាប់រៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៤-២០២៦
    - បានរៀបចំ វេទិកាពិគ្រោះយោបល់ ស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៤-២០២៦ របស់រដ្ឋបាលខេត្ត និងផ្សព្វផ្សាយសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិល នៅថ្នាក់ក្រុង ស្រុក សម្រាប់ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមចំនួន១១០នាក់ ស្រី២៤នាក់ នៅសាលមហោស្រពខេត្តកោះកុង
- បានបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៣-២០២៥ ចំនួន១៦៥ក្បាល និងសៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំ ២០២០-២០២៤ ចំនួន១០ក្បាល
- បានរៀបចំកិច្ចប្រជុំគណៈអភិបាលខេត្ត និងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងបញ្ជីគម្រោងវិនិយោគជាអាទិភាពដែលគ្រោងប្រើប្រាស់ថវិកាខេត្ត ឆ្នាំ២០២៤-២០២៦ ដែលមានសមាសភាពចូលរួមសរុប ចំនួន៦៧នាក់ ស្រី១៣នាក់
- បានសម្របសម្រួលកិច្ចប្រជុំជូនក្រុមប្រឹក្សាខេត្ត ក្នុងការពិនិត្យ និងអនុម័តលើសេចក្ដីព្រាងបញ្ជីគម្រោងវិនិយោគជាអាទិភាពដែលគ្រោងប្រើប្រាស់ថវិកាខេត្ត ឆ្នាំ២០២៤-២០២៦ ដោយសំឡេងចំនួន១៩លើ១៩សំឡេង។

តារាងទី១០៖ការអនុវត្តគម្រោងវិនិយោគ(មានការគាំទ្រ)

| ល.រ. | ផ្នែក | សរុប | តម្លៃគម្រោង (លានរៀល) | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|---|
| | | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ១៤ | ២០.៦២៦ | ០ | ០ | ១៤ |
| ២ | សង្គមកិច្ច | ១៤ | ១.១០០,៤៥ | ០ | ០ | ១៤ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ១ | ២១៩ | ០ | ០ | ១ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ | ២ | ២៣៣ | ០ | ០ | ២ |
| **សរុប** | | **៣១** | **២២.១៧៨,៤៥** | **០** | **០** | **៣១** |

### ១.២.២-ការគាំទ្រមូលដ្ឋាន

- បានសម្របសម្រួលឯកសារជូនថ្នាក់ដឹកនាំក្នុងការផ្តល់អនុលោមភាព លើផែនការអភិវឌ្ឍន៍៥ឆ្នាំ ២០២៣-២០២៧ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ អណត្តិទី៥ បានចំនួន២៩ឃុំ សង្កាត់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបំពេញកម្រងសំណួរឃុំ សង្កាត់ ក្នុងប្រព័ន្ធកូបូ(KoBo)ដល់មន្ត្រីពាក់ព័ន្ធនៅរដ្ឋបាលឃុំ សង្កាត់ លើការតាមដានការអនុវត្តសេចក្តីណែនាំលេខ០២៥ ស.ជ.ណ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុម័ត ថវិកាឃុំ សង្កាត់ ដែលរៀបចំនៅសាលមហោស្រពខេត្តកោះកុង មានអ្នកចូលរួមចំនួន១១០នាក់ ស្រី១៤នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសេចក្តីណែនាំបច្ចេកទេសលើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ ជូនដល់រដ្ឋបាលឃុំ សង្កាត់ អាណត្តិទី៥ ដែលមានសមាសភាពចូលរួមចំនួន១៦៦នាក់ ស្រី៣៤នាក់ នៅសាលមហោស្រពខេត្តកោះកុង
- បានរៀបចំវគ្គបណ្តុះបណ្តាលលើសៀវភៅណែនាំស្តីពី ការអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព"ចំនួន២វគ្គ ដល់មន្ត្រីជំនាញមកពីរដ្ឋបាលខេត្ត ស្នងការដ្ឋាននគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ សរុបចំនួន២០០នាក់ ស្រី៣៨នាក់ នៅសាលមហោស្រពខេត្តកោះកុង
- បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ក្រោមជាតិ លើសៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ដែលរៀបចំដោយអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ និងឧបត្ថម្ភថវិកាដោយអង្គការ UNICEF ដល់ប្រធានការិយាល័យគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក មកពីខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ សរុប៧៤នាក់ ស្ត្រី៥នាក់ នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង
- បានចុះគាំទ្រ និងសម្របសម្រួលលើការរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគ៣ឆ្នាំរំកិល(២០២៤-២០២៦) នៅថ្នាក់ក្រុង ស្រុក ដែលមានអ្នកចូលរួមចំនួន៣៧៩នាក់ ស្រី៥៤នាក់ ក្នុងនោះ គម្រោងក្រុង ស្រុក ដែលបានស្នើឡើងមានចំនួន៦១៨គម្រោង និងទទួលបានការគាំទ្រចំនួន៦៧គម្រោង ស្មើនឹង៩,៧៣% និងឃុំ សង្កាត់មានចំនួន១.៨០៤គម្រោង ហើយទទួលបានគាំទ្រចំនួន៦១០គម្រោង ស្មើនឹង៣៣,៨១%
- បានរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល(២០២៤-២០២៦) របស់រដ្ឋបាលខេត្តកោះកុង។

#### ១.២.២.១-ការគាំទ្ររដ្ឋបាលក្រុង ស្រុក

- ចំនួនគម្រោងដែលបានស្នើឡើងក្នុងឆ្នាំចំនួន១១គម្រោង
- គម្រោងដែលបានអនុវត្តបញ្ចប់១០០%ចំនួន១១គម្រោង។

តារាងទី១១៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក

| ល.រ | ការបរិយាយ | ចំនួនក្រុង ស្រុក | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ៧ | ០ |
| ២ | ជំហានទី២ | ៧ | ០ |
| ៣ | ជំហានទី៣ | ០ | ០ |

តារាងទី១២៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងក្រុង ស្រុក

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |

| | | | | | |
|---|---|---|---|---|---|
| ១ | សេដ្ឋកិច្ច | ៩ | ៩ | ៩ | ៩ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២ | ២ | ២ | ២ |
| **សរុប** | | **១១** | **១១** | **១១** | **១១** |

### ១.២.២.២-ការគាំទ្ររដ្ឋបាលឃុំ សង្កាត់

- ការគាំទ្រការអនុវត្តគម្រោងឃុំ សង្កាត់ ឆ្នាំ២០២៣
  - គម្រោងឃុំ សង្កាត់ដែលបានស្នើឡើងមានចំនួន៣៨គម្រោង
  - គម្រោងដែលបានបញ្ចប់ការសិក្សាមានចំនួន៣៨គម្រោង
  - គម្រោងដែលបានដេញថ្លៃរួចមានចំនួន៣៧គម្រោង
  - គម្រោងដែលបានចុះកិច្ចសន្យារួចមានចំនួន៣៤គម្រោង ក្នុងនោះ៖
    - ចំនួនកិច្ចសន្យាអនុវត្តបាន ១០០% ចំនួន១៣គម្រោង
    - ចំនួនកិច្ចសន្យាអនុវត្តបាន ៥០% ចំនួន១៧គម្រោង
    - ចំនួនកិច្ចសន្យាមិនទាន់បានអនុវត្ត ចំនួន៤គម្រោង។

តារាងទី១៣៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

| ល.រ. | ការបរិយាយ | ចំនួនឃុំ សង្កាត់ | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ២៩ | ០ |
| ២ | ជំហានទី២ | ២៩ | ០ |
| ៣ | ជំហានទី៣ | ០ | ០ |

តារាងទី១៤៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ៣៧ | ៣៧ | ៣៧ | ៣៤ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ១ | ០ | ០ | ១ |
| **សរុប** | | **៣៨** | **៣៧** | **៣៧** | **៣៥** |

### ១.២.៣-ការវិនិយោគ

- បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន មន្ត្រីជំនាញនៃមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរស្រុក ឃុំ ចុះពិនិត្យ និងសិក្សាទីតាំងជាក់ស្តែងលើករណីស្នើសុំបូមដីចាក់បំពេញតំបន់ដីលិចទឹក និងបោះបង្គោលព្រំប្រទល់ដី ចូលក្នុងទីតាំងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចចំនួន២គម្រោង ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតនៅកោះចម្ការដូង ភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល។ ជាលទ្ធផល ក្រុមការងារបានគាំទ្រលើការបោះបង្គោលព្រំប្រទល់ដីចំនួន២គម្រោង តែមិនឯកភាពលើការបូមខ្សាច់ចូលទីតាំងគម្រោងទេ

- បានចូលរួមជាមួយប្រតិភូក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត ស្រុក និងឃុំ ចុះពិនិត្យការអនុវត្តគម្រោង វិនិយោគរបស់ក្រុមហ៊ុនមួយចំនួនដែលបានចុះកិច្ចសន្យាជួលកោះផ្ទេរ និងម្ចាស់ដីយដ្ឋាននានាជាមួយរាជរដ្ឋាភិបាល នៅស្រុកគិរីសាគរ ខេត្តកោះកុង។ កោះដែលក្រុមការងារបានចុះពិនិត្យជាក់ស្តែង មានដូចជា កោះទទឹង កោះអំពិល កោះស្មាច់ និងកោះម្នាស់។ ដោយឡែកកោះម្នាស់ពុំទាន់បានអនុវត្តការងារសាងសង់គម្រោងទេ។ ក្រុមការងារបានសំណូមពរដល់ក្រុមហ៊ុនដែលស្នើសុំវិនិយោគ ត្រូវតែអនុវត្តឱ្យទាន់ពេលវេលា និងស្របតាមកិច្ចសន្យាដែលបានកំណត់ ដើម្បីបានទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងជាការលើកស្ទួយវិស័យទេសចរណ៍ក្នុងខេត្តកោះកុង
- បានចុះពិនិត្យ និងសិក្សាទីតាំងជាក់ស្តែងលើសំណើសុំវិនិយោគវារីវប្បកម្មបែបធម្មជាតិ កសិ-ទេសចរណ៍ និងអេកូទេសចរណ៍លើទំហំផ្ទៃដី៧.១២៦,៩៣ហ.ត ស្ថិតក្នុងឧទ្យានជាតិបទុមសាគរ និងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ក្នុងភូមិសាស្ត្រឃុំតានូន ឃុំថ្មស និងឃុំអណ្តូងទឹក។ ជាលទ្ធផល ក្រុមការងារបានឯកភាពគ្នា នឹងរៀបចំកំណត់ហេតុ និងរបាយការណ៍រួមមួយសម្រាប់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ពិនិត្យនិងសម្រេច
- បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន ចុះពិនិត្យទីតាំងជាក់ស្តែងលើករណីស្នើសុំជួលទីតាំងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិពីក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD ( UDG ) និងករណីស្នើសុំវិនិយោគលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ចំនួន៥គម្រោងក្នុងភូមិសាស្ត្រ នៅស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ក្រុមការងារបានឯកភាពគ្នា នឹងរៀបចំកំណត់ហេតុ និងរបាយការណ៍រួមមួយសម្រាប់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ពិនិត្យនិងសម្រេច។

### ១.២.៤-ការងារសេវាសង្គម

- បានរៀបចំកិច្ចប្រជុំសាមញ្ញប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខេត្ត មានចំនួន១២លើក
- បានរៀបចំប្រជុំវិសាមញ្ញប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខេត្ត មានចំនួន៥លើក
- ថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើកិច្ចប្រជុំប្រចាំឆ្នាំ២០២៣ចំនួន៤.០០០.០០០រៀល ចំណាយជាក់ស្តែងអស់ចំនួន៣.៥៩៥.៥០០រៀល
- ថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើការអនុវត្តគម្រោងឆ្នាំ២០២៣ ចំនួន១៨.៦០០.០០០រៀល ចំណាយជាក់ស្តែងចំនួន២១.៦៦៣.០០០រៀល។

### ១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប

- បានទទួលការឯកភាព លើសេចក្តីសម្រេចរួមស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប )
- បានទទួលការឯកភាព លើការបញ្ចប់សេចក្តីសម្រេចរួមស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ២០២២ ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប )
- បានរៀបចំ និងសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានាលើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី១ របស់រដ្ឋបាលខេត្តកោះកុង លើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ របស់គ.ជ.អ.ប.ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលសម្រេចបានក្នុងផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី១ ២០២១-២០២៥ ( ផអ៥ទី១ ) ដែលបានកំណត់ដោយលេខាធិការដ្ឋាន គ.ជ.អ.ប.
- បានរៀបចំ និងសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានា លើការរៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់គ.ជ.អ.ប.ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីសម្រេចរួមឆ្នាំ២០២៤ រវាង គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំ និងសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានាលើការ

រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកោះកុងលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០២៣ របស់គ.ជ.អ.ប. ដើម្បីឆ្លុះបញ្ចាំងលើលទ្ធផលសម្រេចបានក្នុងផែនការអនុវត្តរយៈពេល៥ឆ្នាំ ជំណាក់កាលទី១ ២០២១-២០២៥ (ផអ៥ទី១) ដែលបានកំណត់ដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ។

តារាងទី១៥៖លទ្ធផលសម្រេចបាន

| ល.រ | ឈ្មោះលទ្ធផល | ស្ថានភាព | % សម្រេច | % ចំណាយ |
|---|---|---|---|---|
| ១ | ការពង្រឹងយន្តការដឹកនាំកំណែទម្រង់ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការរីកចម្រើនទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | កំពុងអនុវត្ត | ៩៥% | ៩៥% |
| ២ | ការផ្សព្វផ្សាយចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | បានអនុវត្ត | ១០០% | ១០០% |
| ៣ | ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | បានអនុវត្ត | ១០០% | ១០០% |
| ៤ | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង/ស្រុក ឃុំ/សង្កាត់ | បានអនុវត្ត | ១០០% | ១០០% |
| ៥ | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | បានអនុវត្ត | ១០០% | ១០០% |
| ៦ | ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ៧ | ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ៨ | ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | បានអនុវត្ត | ១០០% | ១០០% |
| ៩ | ការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ១០ | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ១១ | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ១២ | ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹងនិងកំណត់យ៉ាងច្បាស់លាស់ | បានអនុវត្ត | ១០០% | ១០០% |
| ១៣ | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បានអនុវត្ត | ១០០% | ១០០% |
| ១៤ | ការពិនិត្យ កែលម្អ និងពង្រឹង ការអនុវត្តយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយ | បានអនុវត្ត | ១០០% | ១០០% |

| | | | | |
|---|---|---|---|---|
| | ស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | |
| ១៥ | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | បានអនុវត្ត | ១០០% | ១០០% |
| ១៦ | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | បានអនុវត្ត | ១០០% | ១០០% |

**១.២.៦.-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា**

- ក្រុមអ្នកវាយតម្លៃថ្នាក់ខេត្តសម្រាប់គម្រោងអាហារូបត្ថម្ភនៅកម្ពុជាខេត្តកោះកុង (Cambodia Nutrition Project - CNP) បាន៖
  - ចុះវាយតម្លៃភាពត្រៀមរួចជាស្រេច តាមបណ្តាក្រុង ស្រុករួមមាន នៅក្រុងខេមរភូមិន្ទ ស្រុកស្រែអំបិល និងស្រុកមណ្ឌលសីមា ដោយទទួលបានលទ្ធផលពិន្ទុ១០០%
  - ចុះវាយតម្លៃជាប្រចាំនៅស្រុកថ្មបាំង ដោយទទួលបានលទ្ធផលពិន្ទុ១០០%
- បានចុះទៅតាមបណ្តាក្រុង ស្រុក ដើម្បីសម្របសម្រួលហ្វឹកហ្វឺនដល់ក្រុមការងារអនុវត្តគម្រោងអាហារូបត្ថម្ភថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធនៅរដ្ឋបាលឃុំ សង្កាត់ អំពីដំណើរការរៀបចំផែនការសកម្មភាព និងផែនការថវិកា នៅរដ្ឋបាលស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកមណ្ឌលសីមា
- បានពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះក្រុមការងារ CNP របស់រដ្ឋបាលថ្នាក់ក្រុង/ស្រុក ឃុំ/សង្កាត់ និងក្រុមទ្រទ្រង់សុខភាពភូមិ និងផ្ញើជូនទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្ត លេខ១០៣/២៣សជណ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការប្រមូលទិន្នន័យ និងព័ត៌មានអំពីលទ្ធផលការអនុវត្តមូលនិធិគាំទ្រការផ្តល់សេវាឃុំ/សង្កាត់(Commune/Sangkat-Service Delivery Grant - C/S-SDG) នៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ ឆ្នាំ២០២២ ទៅដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- បានចុះតាមដាន និងផ្តល់ការប្រឹក្សាយោបល់ដល់ក្រុមទ្រទ្រង់សុខភាពភូមិចុះស្រង់ទិន្នន័យ ព័ត៌មានគ្រួសារអំឡុងពេល១.០០០ថ្ងៃដំបូងនៃជីវិត និងការចុះផ្តល់ប្រឹក្សាអំពីសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភតាមខ្នងផ្ទះនៅតាមបណ្តា ឃុំ សង្កាត់
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភនៅ
  - ស្រុកបូទុមសាគរ ចំនួន២លើក ដែលមានអ្នកចូលរួម៦៤នាក់ ស្រី៤៥នាក់
  - ស្រុកស្រែអំបិល ចំនួន២លើក ដែលមានអ្នកចូលរួម៨៨នាក់ ស្រី៦៦នាក់
- អ្នកសម្របសម្រួលថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ខេត្ត ក្រុង ស្រុក និងមណ្ឌលសុខភាព បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ ក្នុងក្របខ័ណ្ឌគម្រោងអាហារូបត្ថម្ភនៅកម្ពុជា នៅសាលាខេត្តពោធិ៍សាត់
- ក្រុមការងារអ្នកវាយតម្លៃថ្នាក់ខេត្តចំនួន២រូប ក្រុមការងារអ្នកវាយតម្លៃថ្នាក់ក្រុង ស្រុក ក្នុង១ក្រុង ស្រុកចំនួន៤រូប និងអ្នកសម្របសម្រួល១រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការហ្វឹកហ្វឺនសម្រាប់មូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ សម្រាប់គម្រោងអាហារូបត្ថម្ភនៅកម្ពុជាខេត្តកោះកុងនៅរដ្ឋបាលខេត្តពោធិ៍សាត់
- ក្រុមអ្នកវាយតម្លៃថ្នាក់ខេត្តចំនួន៣រូប នៃក្រុមការងារដឹកនាំការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា បានចុះវាយតម្លៃជាប្រចាំនៃការអនុវត្តមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ តាមបណ្តាក្រុង ស្រុក ទាំង៧ សម្រាប់ឆមាសទី១

ឆ្នាំ២០២៣ ជាលទ្ធផល រដ្ឋបាលក្រុងស្រុកទាំង៧ បានអនុវត្តការវាយតម្លៃ រដ្ឋបាលឃុំ/សង្កាត់ទៀងទាត់ និងរៀបចំដាក់របាយការណ៍វាយតម្លៃរដ្ឋបាលឃុំ/សង្កាត់មករដ្ឋបាលខេត្តកោះកុងទាន់ពេលវេលា

- ក្រុមអ្នកវាយតម្លៃថ្នាក់ខេត្តចំនួន២រូប នៃក្រុមការងារដឹកនាំការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជាបានចុះតម្រង់ទិសស្តីពីរបៀបរបប និងវិធីសាស្រ្ត នៃការរៀបចំផែនការហ្វឹកហ្វឺន ដល់ក្រុមការងារអនុវត្តគម្រោងនៅស្រុកថ្មបាំង ស្រុកបូទុមសាគរ ស្រុកគិរីសាគរ និងស្រុកស្រែអំបិល
- ក្រុមការងារដឹកនាំការអនុវត្តគម្រោងអាហារូបត្ថម្ភខេត្ត បានជួបប្រជុំជាមួយគណៈប្រតិភូថ្នាក់ជាតិ ក្នុងគោលបំណងពិភាក្សាអំពីវឌ្ឍនភាព និងវាយតម្លៃការអនុវត្តពាក់កណ្ដាលអាណត្តិគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ដំណាក់កាលទី១ និងដំណាក់កាលទី២ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់ធនាគារពិភពលោកនៅសាលាខេត្តកោះកុង
- ក្រុមការងារដឹកនាំការអនុវត្តគម្រោងអាហារូបត្ថម្ភខេត្តចំនួន៣រូប បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យលទ្ធផលប្រចាំឆ្នាំ២០២៣ របស់គម្រោងអាហារូបត្ថម្ភនៅកម្ពុជា នៅសណ្ឋាគារ សុខាល័យអង្គរ ខេត្តសៀមរាប
- ក្រុមការងារដឹកនាំការអនុវត្តគម្រោងអាហារូបត្ថម្ភខេត្ត បានចូលរួមសិក្ខាសាលាស្តីពីការពិគ្រោះយោបល់ និងការផ្សព្វផ្សាយផែនការចូលរួមរបស់ជនជាតិដើមភាគតិច និងការអនុវត្តសុវត្ថិភាពបរិស្ថាន និងសង្គមនៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ដំណាក់កាលទី១ និងដំណាក់កាលទី២ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម។

- **ការអនុវត្តការងារផ្សេងៗ**
  - បានចូលរួមវគ្គបណ្តុះស្តីពីការប្រែប្រួលអាកាសធាតុ រៀបចំដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព ស្របទៅតាមសៀវភៅណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យលើគម្រោងវិនិយោគ នៅថ្នាក់រាជធានី-ខេត្ត ដែលបានរៀបចំឡើងនៅសាលាខេត្តកំពត ក្នុងគោលបំណងជួយបណ្តុះស្មារតី ចំណេះដឹងថ្មីៗ ច្បាប់បទដ្ឋាន ការពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគ នៅថ្នាក់ក្រោមជាតិ
  - បានចូលរួមសិក្ខាសាលា ចែករំលែកបទពិសោធន៍ លើគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ ហៅកាត់ថា (LEAP) នៅសណ្ឋាគារភ្នំប្រុសខេត្តកំពង់ចាម។

## ១.៣-ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១-ការងារគ្រប់គ្រងបុគ្គលិក

- បានរៀបចំបេសកកម្មជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីសាលាខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត ក្នុងឆ្នាំ២០២៣ សរុបចំនួន១.៩៦០លេខ
- បានរៀបចំដីកា ចំនួន៣៩លេខ សម្រាប់ឆ្នាំ២០២៣ ក្នុងនោះ៖
  - ដីកាស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន១៦លេខ
  - ដីកាស្តីពីការលុបឈ្មោះមន្ត្រីរាជការ ចំនួន២លេខ
  - ដីកាស្តីពីការតាំងស៊ប់មន្ត្រីរាជការ ចំនួន១លេខ
  - ដីកាស្តីពីការផ្ទេរមន្ត្រីរាជការ ចំនួន៨លេខ
  - ដីកាស្តីពីការផ្ទេរបញ្ចូលមន្ត្រីរាជការ ចំនួន២លេខ
  - ដីកាស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនអតីតភាព ជូនមន្ត្រីរាជការ ចំនួន២លេខ
  - ដីកាស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការ ចំនួន១លេខ

- ដីកាស្តីពីការផ្លាស់ប្តូរ និងទទួលស្គាល់មន្ត្រីជាប់កិច្ចសន្យា សម្រាប់ឆ្នាំ២០២៣ ចំនួន៣លេខ
- ដីកាស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន២លេខ
- ដីកាស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ចំនួន១លេខ
- ដីកាស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន១លេខ

តារាងទី១៦៖ស្ថិតិក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា(ចំនួនក្រុមប្រឹក្សាដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត) | ១៩ | ២ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៤ | អភិបាល | ១ | ១ |
| ៥ | អភិបាលរង | ១០ | ២ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ៤ | ១ |
| ៨ | នាយកទីចាត់ការ/ប្រធានអង្គភាព | ៧ | ០ |
| ៩ | ប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ១ | ០ |
| ១០ | នាយករងទីចាត់ការ/អនុប្រធានអង្គភាព | ១៤ | ៣ |
| ១១ | អនុប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ៣ | ១ |
| ១២ | ប្រធានការិយាល័យ | ១៥ | ៣ |
| ១៣ | អនុប្រធានការិយាល័យ | ១៣ | ៦ |
| ១៤ | មន្ត្រីការិយាល័យ | ១៤ | ៧ |
| ១៥ | បុគ្គលិកកិច្ចសន្យា | ៣៩ | ២៣ |

- **ស្ថិតិការិយាល័យប្រជាពលរដ្ឋខេត្ត**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ១ |
| ៣ | ប្រធានផ្នែក | ២ | ០ |
| ៤ | អនុប្រធានផ្នែក | ៤ | ០ |
| ៥ | មន្ត្រី | ០ | ០ |

- **ស្ថិតិបុគ្គលិកមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**

| ល.រ | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានមជ្ឈមណ្ឌល | ១ | ០ |
| ២ | មន្ត្រីជាប់កិច្ចសន្យា | ១ | ១ |

### ១.៣.២-ការងារកសាងសមត្ថភាព

- បានរៀបចំលិខិតសម្របសម្រួលចំនួន១២លិខិត ដល់សាស្ត្រាចារ្យ និស្សិត នៃសាកលវិទ្យាល័យន័រតុន សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង និងសាលាភូមិន្ទរដ្ឋបាល ដើម្បីចុះសិក្សាស្រាវជ្រាវ ធ្វើ

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ចុះកម្មសិក្សា បើកវគ្គបណ្ដុះបណ្ដាល សិក្សាស្រាវជ្រាវបញ្ចប់គម្រោង និងផ្សព្វផ្សាយនៅតាមបណ្ដាក្រុង ស្រុក ឃុំ សង្កាត់

- បានរៀបចំលិខិតចាត់បញ្ជូនសិស្សានុសិស្ស និងមន្ត្រីរាជការចំនួន៥រូប ទៅសិក្សានៅសាកលវិទ្យាល័យបញ្ញាជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងសាលាភូមិន្ទរដ្ឋបាល
- បានសម្របសម្រួលរៀបចំលិខិតជូនដំណឹងចំនួន៧លិខិត ដល់អភិបាលរងខេត្ត អភិបាលក្រុង ស្រុក ប្រធានមន្ទីរជំនាញជុំវិញខេត្ត មន្ត្រីរាជការ និងសិស្សានុសិស្ស
- បានរៀបចំរបាយការណ៍វគ្គបណ្ដុះបណ្ដាលចំនួន៣វគ្គ ដល់មន្ត្រីរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធ
- បានរៀបចំរបាយការណ៍បណ្ដុះបណ្ដាលប្រចាំឆ្នាំ២០២២ ប្រចាំឆមាសទី១ ឆ្នាំ២០២៣ និងរបាយការណ៍ប្រចាំឆ្នាំ២០២៣ ជូនលេខាធិការដ្ឋាន គ.ជ.អ.ប និងសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
- បានរៀបចំសំណើសុំសិស្សមន្ត្រីចំនួន៦រូប នៃសាលាភូមិន្ទរដ្ឋបាលមកបំពេញការងារនៅរដ្ឋបាលខេត្តកោះកុង
- បានចុះពិនិត្យផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនៅតាមអង្គភាពផ្ដល់សេវាទាំង៣ ដើម្បីស្នើសុំថ្មី និងសហការសម្របសម្រួលរៀបចំពិធីប្រកាសចូលកាន់តំណែងអភិបាលរងក្រុង ស្រុក នាយករដ្ឋបាល ស្មៀនឃុំ ។

តារាងទី១៧៖ការកសាងសមត្ថភាព

| ល.រ | ឈ្មោះវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា ទស្សនកិច្ចសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | វគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញ ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដល់មន្ត្រីបង្គោលក្រុង ស្រុក និងអ្នកពាក់ព័ន្ធ | ១២ | ២០៩ | ៥៩ | មន្ត្រីបង្គោលគណនេយ្យភាពសង្គម |
| ២ | វគ្គបណ្ដុះបណ្ដាលស្ដីពីគោលការណ៍បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិកថ្នាក់ក្រោមជាតិដល់រដ្ឋបាលខេត្ត ក្រុង ស្រុក មន្ទីរសុខាភិបាល និងមន្ទីរជំនាញនានាក្នុងខេត្ត | ១ | ១១៩ | ២៩ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស |
| សរុប | | ១៣ | ៣២៨ | ៨៨ | |

## ១.៤-ការងារអន្តរវិស័យ

### ១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ អង្គភាពជុំវិញខេត្ត មានចំនួន២៧លេខ
- បានទទួល និងពិនិត្យសំណើពីបុគ្គលឯកជន និងក្រុមហ៊ុននានា មានចំនួន១៣លេខ។

- **មជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**
  - **ស្ថានភាពមជ្ឈមណ្ឌល**
    - បានទទួលមើលថែក្មេងកំព្រាក្នុងមណ្ឌលតាមភារកិច្ច
    - បានរៀបចំឯកសារធ្វើសមាហរណកម្មកុមារចំនួន៥នាក់ ស្រី១នាក់ ចេញពីមជ្ឈមណ្ឌល ក្នុងនោះរៀននៅភ្នំពេញ ៣នាក់ នៅកោះកុង២នាក់
    - បានបញ្ជូនកុមារចំនួន៣នាក់ទៀត ទៅចូលរួមការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅអង្គការ PSE រាជធានីភ្នំពេញ និងកុមារ១នាក់ទៀត ទៅរៀនធ្វើជាងជួសជុលឡាន

- ការចូលរួមពីមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
    - ស.ស.យ.ក. វិស័យសាលាខេត្ត បាននាំយកអំណោយជាថវិកា និងគ្រឿងឧបភោគបរិភោគចែកជូនកុមារកំព្រា ជាបន្តបន្ទាប់
    - គណៈកម្មាធិការរណៈសិរ្សអភិវឌ្ឍន៍មាតុភូមិកម្ពុជា ខេត្តកោះកុង បានចុះសួរសុខទុក្ខ និងចែកអំណោយដល់កុមារកំព្រាចំនួន១៣នាក់។

**១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**

- បានទទួល និងពិនិត្យសំណើចុះបញ្ជី បណ្ដឹងទំនាស់ដីធ្លី រវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋជាមួយក្រុមហ៊ុនអភិវឌ្ឍន៍នានា មានចំនួន៥៣លេខ
- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន៣៥លេខ។

**១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ**

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន១២លេខ
- បានទទួល និងពិនិត្យសំណើពីក្រុមហ៊ុនឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានមានចំនួន៨លេខ។

តារាងទី១៨៖ការដោះស្រាយវិវាទ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| | | ០ | ២៨ | ២៨ |
| | | **០** | **២៨** | **២៨** |

**១.៤.៤-ការងារគ្រប់គ្រងកាកសំណល់**

- រដ្ឋបាលខេត្តបានចេញសេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនខេត្តកោះកុង ក្នុងគោលបំណងជានាប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យលេខ ១១៣ អនក្រ.បក របស់រាជរដ្ឋាភិបាល និងជាយន្តការជំរុញលើកទឹកចិត្តដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សំដៅគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការរក្សា បរិស្ថានអនាម័យក្នុងភូមិ ឃុំ-សង្កាត់ប្រកបដោយប្រសិទ្ធភាព
- លេខាធិការនៃគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនខេត្តកោះកុង បានដឹកនាំកិច្ចប្រជុំរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ ដើម្បីស្នើសុំគម្រោងគាំទ្រទៅគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម នៃក្រសួងបរិស្ថាន។ អង្គប្រជុំបានសម្រេចជ្រើសរើសគម្រោងពាក់ព័ន្ធនឹងការរៀបចំយន្តការគ្រប់គ្រងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់ លើដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព
- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្ដីពី"ការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន" ជូនដល់សមាជិកសរុប ១២០នាក់ ស្រី១៧នាក់ នៅសាលមហោស្រពខេត្តកោះកុង។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលដៅ ដើម្បីឆ្លើយតបទៅនឹងការអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រងសំណល់រាវ ប្រព័ន្ធលូ ទឹកកខ្វក់ ការរៀបចំទីលានទុកដាក់សំរាម និងគ្រប់គ្រងសំរាមនៅតាមស្ថាប័នរដ្ឋ ទីតាំងអាជីវកម្មឯកជន ទីតាំងសាធារណៈ និងមូលដ្ឋានឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព
- ក្រុមការងារនៃគណៈកម្មាធិការរៀបចំ និងគ្រប់គ្រង ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនខេត្តកោះកុង បានចុះជួបប្រជុំ សិក្សា និងពិនិត្យជាក់ស្ដែង លើទីតាំងដីដែលកំពុងប្រើប្រាស់ ឬបានត្រៀមទុកសម្រាប់រៀបចំជាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ជាមួយរដ្ឋបាលស្រុក ឃុំ និងស្ថាប័នពាក់ព័ន្ធ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ នៃខេត្តកោះកុង។

## ១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ

- បានពង្រឹងមន្ត្រីជួរមុខ និងជួរក្រោយ យកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ
- បានផ្តល់សេវាជូនប្រជាពលរដ្ឋ មានដូចតារាងខាងក្រោម៖

**តារាងទី១៩៖ស្ថានភាពចំនួនសេវា និងចំណូល**

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ចំនួនថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| | | នាក់ | ស្ត្រី | | |
| ១ | នីត្យានុកូលកម្ម(ថតចម្លង) | ៦៣ | ១៤ | ៩៥៨.000 | |
| ២ | ការងាររដ្ឋបាល | ៣.៦៥៨ | ២.១៤៩ | ៨៥.៨២៧.៥00 | |
| ៣ | សុខាភិបាល | ១៨ | ១0 | ៥.៩៩0.000 | |
| ៤ | ទេសចរណ៍ | ៤៨ | ២៦ | ១៧.៥៩0.000 | |
| ៥ | សាធារណការ និងដឹកជញ្ជូន | ៥៩៥ | ១0៧ | ១0២.១៥៧.៨00 | |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ១ | 0 | ២00.000 | |
| ៧ | ព័ត៌មាន | ៦0 | ២២ | ៥៨.៣២0.000 | |
| ៨ | បរិស្ថាន | 0 | 0 | 0 | |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៣៧ | ១២ | ៦.៩៨0.000 | |
| ១0 | រ៉ែ និងថាមពល | ៤៨ | ៣៣ | ៤.000.000 | |
| ១១ | ពាណិជ្ជកម្ម | ១ | 0 | ២00.000 | |
| ១២ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ក)+(ខ) | ៣.៩៨៧ | ៨២៤ | ១.៧៩១.៩៤៨.0៧៩ | |
| | (ក) សំណង់ | ៤៥ | ១២ | ១២៣.៩៦៩.៩00 | |
| | (ខ) សុរិយោដី | ៣.៩៤២ | ៨១២ | ១.៦៦៧.៩៧៨.១៧៩ | |
| ១៣ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧៩៧ | ៣៨៦ | ២៩.0១៩.១00 | |
| ១៤ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣ | 0 | ២៤0.000 | |
| **សរុបរួម** | | **៩.៣១៦** | **៣.៥៨៣** | **២.១0៣.៤៣0.៤៧៩** | |

## ១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

- បានទទួលពាក្យបណ្តឹងក្នុងសមត្ថកិច្ចចំនួន១៧ករណី ក្នុងនោះ តាមរយៈមកជួបផ្ទាល់ចំនួន៤ករណី តាមរយៈប្រអប់សំបុត្រចំនួន៨កណី តាមរយៈទូរស័ព្ទចំនួន២ករណី និងតាមរយៈតេលេក្រាមចំនួន៣ករណី
- បានទទួលពាក្យបណ្តឹងក្រៅសមត្ថកិច្ចចំនួន១៤ករណី ក្នុងនោះ តាមរយៈមកជួបផ្ទាល់ចំនួន២ករណី និងតាមរយៈប្រអប់សំបុត្រចំនួន១២កណី
- បានទទួលព័ត៌មានផ្សេងៗទាំងក្នុងសមត្ថកិច្ច និងក្រៅសមត្ថកិច្ច ជាការសសើរ សំណូមពរ និងជាការសាកសួរព័ត៌មាន សរុបចំនួន២0៣ករណី ក្នុងនោះ តាមរយៈមកជួបផ្ទាល់ចំនួន៧៩ករណី តាមរយៈប្រអប់សំបុត្រចំនួន១១៦កណី និងតាមរយៈទូរស័ព្ទចំនួន៨ករណី។

តារាងទី២0៖ការដោះស្រាយបណ្តឹង

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | បណ្តឹងដែលទទួលបាន(ក្នុង និងក្រៅសមត្ថកិច្ច) | 0 | ៣១ | ៣១ |
| ១.១ | បណ្តឹងស្ថិតក្នុងសមត្ថកិច្ច | 0 | ១៧ | ១៧ |

| | | | | |
|---|---|---|---|---|
| | - បញ្ចប់ការដោះស្រាយ | ០ | ១៧ | ១៧ |
| | - កំពុងដោះស្រាយ (នៅសល់) | ០ | ០ | ០ |
| ១.២ | បណ្តឹងក្រៅសមត្ថកិច្ច | ០ | ១៤ | ១៤ |
| ២ | ព័ត៌មានផ្សេងៗ | ០ | ២០៣ | ២០៣ |
| **សរុបរួម(១+២)** | | **០** | **២៣៤** | **២៣៤** |

## ១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បានចូលរួមពិនិត្យ និងកែសម្រួលសេចក្តីព្រាងកំណត់ហេតុរួម ស្តីពីកិច្ចសហការរវាងរដ្ឋបាលខេត្ត និងទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ(ទីស្នាក់ការឡាំដាំ) នៅសាលប្រជុំ(ក) សាលាខេត្ត
- បានចូលរួមពិនិត្យ និងកែសម្រួលសេចក្តីព្រាងដីកា ស្តីពីការផាកពិន័យអន្តរការណ៍ពាក់ព័ន្ធការចិញ្ចឹម និងការគ្រប់គ្រងសត្វពាហនៈដោយខ្ជីខ្ជា នៅសាលប្រជុំ(ក)សាលាខេត្ត ។

## ១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

### ១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ

- មានច្រកទ្វារព្រំដែនអន្តរជាតិចំនួន១កំពុងដំណើរការ គឺទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម។

### ១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន

- បញ្ហាសន្តិសុខ៖ (ពុំមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់)។
- សណ្តាប់ធ្នាប់៖ បានរៀបចំសណ្តាប់ធ្នាប់ និងសម្អាតអនាម័យបរិស្ថាននៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមជាប្រចាំ។

### ១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ)

- អំពីមនុស្ស៖
  - ពលរដ្ឋខ្មែរចូល៖ ចំនួន៦៩.១៥៥នាក់ ស្រី៣៥.០៨០នាក់
  - ជនបរទេសចូល៖ ចំនួន៥៣.៨៣៥នាក់ ស្រី១៣.៩៩៤នាក់ មាន៨០សញ្ជាតិ
  - ពលរដ្ឋខ្មែរចេញ៖ ចំនួន៧១.៥០៤នាក់ ស្រី៣៥.៥៧៦នាក់
  - ជនបរទេសចេញ៖ ចំនួន៥៦.០៦៦នាក់ ស្រី ១៥.៦២៣នាក់ មាន៨៩សញ្ជាតិ។
- អំពីមធ្យោបាយ៖
  - រថយន្តចូល៖ ចំនួន២៩.៤៣១គ្រឿង
  - ទោចក្រយានយន្តចូល៖ ចំនួន៣៩៩គ្រឿង
  - រថយន្តចេញ៖ ចំនួន២៨.៩៧៦គ្រឿង
  - ទោចក្រយានយន្តចេញ៖ ចំនួន៣៣៥គ្រឿង។

### ១.៨.៤-ការផ្លាស់ប្តូរទំនិញ

- ទំនិញនាំចូល ៖ កូនឈើ កូនផ្កា ផ្លែឈើចម្រុះ ត្រី សាច់ បន្លែ ភេសជ្ជៈ ជ័រប្លាស្ទីក ម៉ូតូ គ្រឿងអេឡិចត្រូនិច និងគ្រឿងសំណង់ ។ល។
- ទំនិញនាំចេញ ៖ ផលនេសាទ។

### ១.៨.៥-កិច្ចសហប្រតិបត្តិការ

- សហការទំនាក់ទំនងល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាការណែនាំរបស់អាជ្ញាធរខេត្ត។ មន្ត្រីជំនាញដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានផ្តល់សេវាងាយស្រួលដល់ភ្ញៀវជាតិ អន្តរជាតិ ទាំងចូល-ចេញបានល្អប្រសើរ
- សហប្រតិបត្តិការជាមួយប្រទេសជិតខាង ឈរលើគោលជំហរគោរពបូរណភាពទឹកដីនៃប្រទេសទាំងពីរក្នុង តំបន់ព្រំដែន
- បានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋប្រកបរបរស្របច្បាប់ប្រចាំថ្ងៃតាមព្រំដែន។

## ១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១.៩.១-ការងារហិរញ្ញវត្ថុ

- ការអនុវត្តចំណូល និងចំណាយរបស់រដ្ឋបាលខេត្តប្រចាំឆ្នាំ២០២៣ ទីចាត់ការហិរញ្ញវត្ថុ សម្រេចបានការងារប្រមូលចំណូល និងចំណាយដែលមានទឹកប្រាក់ដូចខាងក្រោម៖

តារាងទី២១៖ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | ច្បាប់ដើមឆ្នាំ | ច្បាប់កែតម្រូវ | អនុវត្ត | ភាគរយ |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=3/2 |
| **ផ្នែកចំណូល** | | | | | |
| 70 | ចំណូលសារពើពន្ធ | ៨.៦៣៧.000.000 | ៨.៦៣៧.000.000 | ៩.៩៨២.២៨៥.៩៥២ | ១១៥% |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ៦៥៨.៣00.000 | ៦៥៨.៣00.000 | ៤៤៨.៧៥៧.៦៨0 | ៦៨% |
| 73 | ផលទុនលើការលក់-ជួលទ្រព្យ | ១.៨៩0.៩00.000 | ១.៨៩0.៩00.000 | ២.៣២៤.៤៣៣.៦0៦ | ១២៣% |
| 74 | ផលពីការពិន័យ និងការដាក់ | ៣៧.៨00.000 | ៣៧.៨00.000 | ៤៤.២២0.៤៨៩ | ១១៧% |
| 75 | ការឧបត្ថម្ភធន(អំណោយ) | ១៣.0២0.000.000 | ១៣.0២0.000.000 | ១៣.៦៦0.១00.000 | ១0៥% |
| 76 | ផលហិរញ្ញវត្ថុ | - | - | - | - |
| 77 | ផលផ្សេងៗ និងផលពិសេស | - | - | - | - |
| **សរុបរួមចំណូល** | | **២៤.២៤៤.000.000** | **២៤.២៤៤.000.000** | **២៦.៤៥៩.៧៩៧.៧២៧** | **១0៩%** |
| **ផ្នែកចំណាយ** | | | | | |
| 60 | ការទិញ | ១.៤៧៩.000.000 | ១.៤៧២.000.000 | ១.៤៧១.៩៥១.៥0៧ | ១00% |
| 61 | សេវាកម្ម | ១0.៥២៨.000.000 | ១១.២៥0.000.000 | ១១.២៤៧.១៩២.00៥ | ៩៩.៩៨% |
| 62 | អត្ថប្រយោជន៍សង្គម | ៥៤0.000.000 | ៥៣៧.000.000 | ៥៣៦.៩៣១.000 | ៩៩.៩៩% |
| 63 | ពន្ធ និងអាករ | ១.000.000 | ១.000.000 | - | 0% |
| 64 | បន្ទុកបុគ្គលិក | ៣.៧0៥.000.000 | ៣.៧0៥.000.000 | ៣.៧0៥.000.000 | ១00% |
| 65 | ឧបត្ថម្ភធននិងជំនួយសង្គម | ២១៩.000.000 | ១.៦៣៩.000.000 | ១.៦៣៩.000.000 | ១00% |
| 66 | បន្ទុកហិរញ្ញវត្ថុ | - | - | - | - |
| 67 | បន្ទុកពិសេស | - | - | - | - |
| 68 | ទាយជ្ជទានឱ្យដល់រំលស់អចលកម្ម | - | - | - | - |
| 69 | ចំណាយមិនបានគ្រោងទុក | ៧១២.000.000 | - | - | 0% |
| 20 | អចលកម្មអរូបី | - | - | - | - |
| 21 | អចលកម្មរូបី | ៦.000.000.000 | ១0.000.000.000 | ៩.៩៩២.000.000 | ៩៩.៩0% |
| 23 | អចលកម្មកំពុងដំណើរការ | - | - | | |
| **សរុបចំណាយ** | | **២៣.១៨៤.000.000** | **២៨.៦0៤.000.000** | **២៨.៥៩២.0៧៤.៥១២** | **៩៩.៩៦%** |

### ១.៩.២-ការងារគណនេយ្យ

- បានរៀបចំអាណត្តិបើកបៀវត្សប្រចាំខែនីមួយៗ ឆ្នាំ២០២៣ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងមន្ត្រីជាប់កិច្ចសន្យារួចរាល់
- បានទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

### ១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ

តារាងទី២២៖ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ. | ការបរិយាយ | ឯកតា | ចំនួន | | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង | |
| ១-អចលនទ្រព្យ | | | | | | |
| ១ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម$^2$ | ១៩.០៤៧ | ០ | ១៩.០៤៧ | |
| | អគារ | ខ្នង | ៣ | ០ | ៣ | |
| ២ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម$^2$ | ១១.៤០៣ | ០ | ១១.៤០៣ | |
| | អគារ | ខ្នង | ១ | ០ | ១ | |
| ៣ | ដី ភូមិ១ ស្មាច់មានជ័យ | ម$^2$ | ៤.៩៣៩ | ០ | ៤.៩៣៩ | |
| | អគារ | ខ្នង | ១ | ០ | ១ | |
| ៤ | ដី ភូមិ៣ ស្មាច់មានជ័យ | ម$^2$ | ៤.១១៧ | ០ | ៤.១១៧ | |
| | អគារ | ខ្នង | ២ | ០ | ២ | |
| ៥ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម$^2$ | ៩.៨០១ | ០ | ៩.៨០១ | |
| | អគារ | ខ្នង | ៣ | ០ | ៣ | |
| ២-ឧបករណ៍ សម្ភារ និងបរិក្ខារ( យានយន្ត ម៉ាស៊ីន តុ ...) | | | | | | |
| ១ | ម៉ាស៊ីនភ្លើង | គ្រឿង | ៣ | ០ | ៣ | |
| ២ | ទូបញ្ជាម៉ាស៊ីនភ្លើង | គ្រឿង | ១ | ០ | ១ | |

### ១.១០-ការងារលទ្ធកម្ម

- បានបញ្ចប់សុពលភាពធានាគុណភាពសំណង់ឆ្នាំ២០២១ ចំនួន៦គម្រោង
- បានបញ្ចប់សុពលភាពធានាគុណភាពសំណង់ឆ្នាំ២០២២ ចំនួន៣គម្រោង
- បានរៀបចំឯកសារសេចក្តីជូនដំណឹងដេញថ្លៃចំនួន១៣គម្រោង
- បានបើកឯកសារដេញថ្លៃលទ្ធកម្មទំនិញ និងសំណង់ចំនួន១៣គម្រោង
- បានរៀបចំផែនការលទ្ធកម្មកែតម្រូវចំនួន៤គម្រោង
- បានប្រជុំចរចាថ្លៃលទ្ធកម្មសំណង់ចំនួន៤គម្រោង
- បានចុះពិនិត្យការងារសំណង់ចំនួន៤គម្រោង
- បានរៀបចំកិច្ចប្រជុំចរចាថ្លៃការងារពង្រីកផ្លូវបេតុងសរសៃដែក(ដោយពង្រីកទទឹង១ម៉ែត្រ) កម្រាស់០,២ម៉ែត្រ និងក្រាលកៅស៊ូAC មានប្រវែង២.៣៥០ម៉ែត្រ ទទឹង៧ម៉ែត្រ កម្រាស់០,០៧ម៉ែត្រ និងចាក់ចិញ្ចើមក្រួសក្រហម ចំនួន១ម៉ែត្រសងខាងផ្លូវនៅលើវិថីតាធែមយាយយិប ស្ថិតក្នុងភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ សម្រាប់ឆ្នាំ២០២៣ ជាមួយនាយកដ្ឋានស្ថាបនា និងវិស្វកម្មនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ។
- បានរៀបចំកិច្ចប្រជុំបើកឯកសារដេញថ្លៃលទ្ធកម្មសំណង់ចំនួន៥គម្រោង សម្រាប់ឆ្នាំ២០២៣
- បានប្រជុំចរចាថ្លៃការងារសាងសង់អគារសាលាខេត្តកោះកុង(ជំហានទី៥) ដែលមានបណ្តោយ៤២ម ទទឹង ១៤,៥ម និងច្រកចូលខាងមុខ(២,៥មx៦ម) ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងការងារ

ជួសជុលផ្លូវដោយចាក់បេតុងអាមេប្រវែង១.០៩០ម ទទឹង៦ម កម្រាស់១៥០ម.ម ចិញ្ចើមក្រួសក្រហម០,៥០ម សងខាងផ្លូវ និងដាក់លូមូលកាត់ផ្លូវប្រវែង៩ម អង្កត់ផ្ចិត០,៦០ម ចំនួន៤កន្លែង ស្ថិតនៅភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល សម្រាប់ឆ្នាំ២០២៣ ជាមួយនាយកដ្ឋានវិស្វកម្មអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ

- បានប្រជុំចរចាថ្លៃការងារស្ថាបនា និងជួសជុលចំនួន២គម្រោង
- បានប្រជុំបញ្ចប់សុពលភាពធានាគុណភាពសំណង់ការងារជួសជុលផ្លូវក្រាលកៅស៊ូ(AC)ចំនួន៣ខ្សែ
- បានចុះត្រួតពិនិត្យ ការងារពង្រីកផ្លូវបេតុងសរសៃដែក (ដោយពង្រីកទទឹង១ម សងខាង)កម្រាស់០,២ម និងក្រាលកៅស៊ូAC ប្រវែង២.៣៥០ម ទទឹង៧ម កម្រាស់០,០៧ម និងចាក់ចិញ្ចើមក្រួសក្រហមចំនួន១ម សងខាងផ្លូវនៅលើវិថីតាឆែម យាយយិប ស្ថិតក្នុងភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ សម្រាប់ឆ្នាំ២០២៣ ដែលស្ថាបនាដោយនាយកដ្ឋានស្ថាបនា និងវិស្វកម្ម នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ
- បានបញ្ចប់សុពលភាពធានាគុណភាពសំណង់ការងារសាងសង់អគារសាលាខេត្តកោះកុងថ្មី(ជំហាន៣) ដែលមានបណ្តោយ៤២ម ទទឹង១៤,៥ម និងច្រកចូលខាងមុខ(២,៥មX៦ម) ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្នុងឆ្នាំ២០២២ ដែលស្ថាបនាដោយនាយកដ្ឋានវិស្វកម្ម នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងការពារជាតិ
- បានបញ្ចប់សុពលភាពធានាគុណភាពសំណង់លើ៖
    - ការងារជួសជុលរង្វង់មូលស្តូបចាក់ចិញ្ចើមផ្លូវបេតុងរៀបខឿនបេតុងជុំវិញសួនច្បារធ្វើផើងផ្កា ដាំផ្កា និងជួសជុលស្តូប លាបថ្នាំថ្មីសរុប២.៧៣៥ម$^{2}$
    - ការងារសាងសង់សួនច្បារចិញ្ចើមផ្លូវចាក់បេតុងចំនួន១កន្លែង ប្រវែងសរុប១១៥ម ទទឹង៣៤ម និងរៀបខឿនបេតុងជុំវិញប្រវែង២៤០ម
    - កាងារជួសជុលសួនច្បារក្នុងបរិវេណសាលមហោស្រពខេត្តកោះកុងទំហំ៤.៤០២ម$^{2}$ (សាងសង់របងប្រវែង២៥៩ម, ចាក់សាបជុំវិញអគារទំហំ៣.៨៦៥ម$^{2}$, កែលម្អសួនច្បារ និងដាំផ្កាទំហំ៥៣៧ម$^{2}$, ធ្វើប្រព័ន្ធលូរំដោះទឹកប្រវែង១៨៨ម ទំហំលូខាងក្នុង០,៤ម, តបណ្តាញអគ្គិសនីប្រវែង២៨០ម, ដំឡើងអំពូលហ្វាលើបង្គោលរបងចំនួន៣ និងដំឡើងបង្គោលដងគោមហ្វាអំពូល៣ កម្ពស់១១ម, សាងសង់បន្ទប់ទឹកប្រវែង១៣,៧ម ទទឹង៥ម៉ែត្រ
    - ការងារជួសជុលសួនកម្សាន្តសម្រាប់កុមារបណ្តោយ៤៤ម ទទឹង២៦ម និងសាងសង់ព័ន្ធជុំវិញប្រវែង១៤០ម
    - ការងារជួសជុលផ្លូវបេតុងចំនួន១ខ្សែ ប្រវែង៨២០ម ទទឹង៧ម កម្រាស់១១៥ម និងសាងសង់លូជ្រុងក្លោះបណ្តោយ១០ម ទទឹង៦,៥ម កម្ពស់២ម
    - ការងារសាងសង់លូមូលដោះទឹកចំនួន២ខ្សែ ប្រវែង២.២០៤ម អង្កត់ផ្ចិត០,៨ម និងអណ្តូងលូ (រ៉ឺហ្គា) ចំនួន៨៨កន្លែង ក្នុងឆ្នាំ២០២២ ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- បានប្រជុំចរចាថ្លៃលើការងារជួសជុលផ្លូវបេតុងអាមេ១ខ្សែ ប្រវែង២២៨ម ទទឹង៦ម កម្រាស់០,១៥ម ស្ថិតនៅភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីមា សម្រាប់ឆ្នាំ២០២៣
- បានប្រគល់ទទួលការងារសាងសង់អគារសាលាខេត្តកោះកុង (ជំហាន៥) ពីនាយកដ្ឋានវិស្វកម្ម នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុក្រសួងការពារជាតិ និងការងារជួសជុលផ្លូវដោយចាក់បេតុងអាមេប្រវែង១.០៩០ម ទទឹង៦ម ចំនួន៤កន្លែង ស្ថិតនៅភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល ដែលស្ថាបនាដោយនាយកដ្ឋានវិស្វកម្មនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងការពារជាតិ
- បានចុះពិនិត្យការងារចំនួន២គម្រោង៖
    - **<u>គម្រោងទី១</u>៖** ការងារជួសជុលផ្លូវបេតុងអាមេ១ខ្សែ ប្រវែង២.១៥០ម ទទឹង៧ម កម្រាស់០,១៥មស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

- **គម្រោងទី២**៖ ការងារសាងសងសួនច្បារចិញ្ចើមផ្លូវដោយចាក់បេតុង ចំនួន១កន្លែង ប្រវែង៣១៧ម ទទឹង ៣៤ម កម្រាស់០,១៥ម និងរៀបខឿនបេតុងជុំវិញប្រវែង៩៩៦ម ជិតសាខាកាកបាទក្រហមកម្ពុជាខេត្ត កោះកុង និងការងារសាងសង់លូមូលដោះទឹកចំនួន២ខ្សែ ប្រវែងសរុប១.២០២ម។

## ១.១១-ការងារសុខាភិបាល

- បានពិនិត្យ និងពិគ្រោះជំងឺក្រៅសរុបចំនួន៧.៣០៤៨ករណី (ករណីថ្មីចំនួ៦៦.៩៧៩ករណី) ជូនប្រជាជន ដូចខាងក្រោម ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៤៣.៤២១ករណី
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ១៨.៥៨៨ករណី
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ៧.៦២៦ករណី
  - ករណីលើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន៣.៤១៣ករណី
- ករណីអ្នកជំងឺសម្រាកពេទ្យ សរុបចំនួន៩.២០៧នាក់ រួមមាន ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៥.៥០៤ករណី
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ២.៥៧៤ករណី
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ៩៦៤ករណី
  - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន១៦៥ករណី
- ការសម្រាលកូនសរុបចំនួន២.៣១៩នាក់(សម្រាលនៅមណ្ឌលសុខភាពចំនួន៨៧៩នាក់)មានដូចខាងក្រោម៖
  - បង់លុយដោយខ្លួនឯងមានចំនួន១.២១៩ករណី
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ៥៦០នាក់
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ៤៩៩នាក់
  - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជដ្ឋាភិបាលមានចំនួន៤១ករណី
- បានផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះសរុបចំនួ៣.៧២២ដូស
- ស្ត្រីបានមកពិនិត្យផ្ទៃពោះមុនសម្រាលសរុបចំនួន១២.៩២៩លើក
- ស្ត្រីបានមកពិនិត្យផ្ទៃពោះក្រោយសម្រាលកូនចំនួន៣.៤៤៦លើក
- កុមារបានចាក់ថ្នាំបង្ការ១១មុខគ្រប់ចំនួន១.៩៩៩នាក់
- ស្ត្រីបានពន្យារកំណើតបន្តសរុបចំនួ២.០៩០នាក់
- ក្រុមការងារចត្តាឡីស័កប្រចាំការនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមបានអនុវត្តការងារ ដូចខាងក្រោម ៖
  - បានពិនិត្យកម្តៅលើអ្នកបើកបររថយន្តដឹកទំនិញចូលខេត្តកោះកុង សរុបចំនួន២០.៧១១នាក់ ស្រី៧០៧នាក់
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តដឹកទំនិញចូលខេត្តកោះកុង សរុបចំនួន២០.៧១១គ្រឿង
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តទេសចរណ៍ចូលខេត្តកោះកុង សរុបចំនួន៩.៨០៧គ្រឿង
  - បានពិនិត្យកម្តៅអ្នកធ្វើដំណើរចេញពីខេត្តកោះកុង សរុបចំនួន១២៩.៧៩៥នាក់ ស្រី៥០.៦១០នាក់

- បានពិនិត្យកម្តៅអ្នកធ្វើដំណើរចូលខេត្តកោះកុង សរុបចំនួន១២៦.៧៩៥នាក់ ស្រី៥០.៦១០នាក់
- បានពិនិត្យកម្តៅពលករខ្មែរចូលខេត្តកោះកុង សរុបចំនួន៣០២នាក់ ស្រី៩៩នាក់
- បានពិនិត្យកម្តៅកុមារមកជាមួយពលករខ្មែរចូលខេត្តកោះកុង សរុបចំនួន១៤នាក់ ស្រី៩នាក់
- បានពិនិត្យអ្នកជំងឺដឹកចេញពីខេត្តកោះកុង សរុបចំនួន១នាក់ប្រុស
- បានពិនិត្យអ្នកជំងឺដឹកចូលខេត្តកោះកុង សរុបចំនួន៣នាក់ប្រុស
- បានពិនិត្យសពដឹកចូលខេត្តកោះកុង សរុបចំនួន១២នាក់ ស្រី៣នាក់
- បានពិនិត្យសពដឹកចេញខេត្តកោះកុង សរុបចំនួន១នាក់ប្រុស

– ចំនួនចាក់វ៉ាក់សាំងកូវីដ-១៩៖

| ចំនួនអ្នកបានចាក់វ៉ាក់សាំងកូវីដ-១៩ ប្រចាំខែ | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្រុមអាយុ | ដូសទី១ | | ដូសទី២ | | ដូសទី៣ | | ដូសទី៤ | | ដូសទី៥ | | ដូសទី៦ | | សរុបរួម | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ៣-៥ឆ្នាំ | ៣៣៥ | ១៧៥ | ១៤៨ | ៨៣ | ១៨២ | ៩១ | ៦៤ | ៣០ | | | | | ៧២៩ | ៣៧៩ |
| ៥ឆ្នាំ | ១២៣ | ៥៦ | ១២៥ | ៦៧ | ២៨១ | ១៤៧ | ១៨២ | ១០១ | ១១ | ១០ | | | ៧២២ | ៣៨១ |
| ៦-១១ឆ្នាំ | ១៤៩ | ៥៥ | ២០៥ | ១០៤ | ១០២០ | ៥១៥ | ១៦៧៧ | ៨៨២ | ២០២៩ | ១០៨៨ | | | ៥០៨០ | ២៦៤៤ |
| ១២-១ឆ្នាំ | ៥៤ | ២៤ | ៦៣ | ៣០ | ៤៨៤ | ២៤៨ | ១៥៣៥ | ៨០១ | ២៦៤៦ | ១៥៣០ | ២៥៨ | ១៥៤ | ៥០៤០ | ២៧៨៧ |
| ≥១៨ឆ្នាំ | ៣៦៨ | ២២៧ | ២៧៦ | ១៨១ | ១៥៨៥ | ៩៨៨ | ៣៤៤២ | ១៤៦៨ | ១៨៩៩ | ១២០០ | ២៦៩០ | ៧៦៥ | ១០២៦០ | ៤៨២៩ |
| សរុប | ១០២៩ | ៥៣៧ | ៨១៧ | ៤៦៥ | ៣៥៥២ | ១៩៨៩ | ៦៩០០ | ៣២៨២ | ៦៥៨៥ | ៣៨២៨ | ២៩៤៨ | ៩១៩ | ២១៨៣១ | ១១០២០ |

– ចំនួន និងអត្រានៃការចាក់វ៉ាក់កូវីដ-១៩ ចាប់ពីអាយុ៣ឆ្នាំឡើង គិតចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ក្នុងខេត្តកោះកុង៖

- ដូសទី១ សរុបចំនួន១៤០.៥៨៦នាក់ ស្មើនឹង១០៧,២៧%
- ដូសទី២ សរុបចំនួន១៣២.០៧៥នាក់ ស្មើនឹង១០០,៧៧%
- ដូសទី៣ សរុបចំនួន៩៨.១២០នាក់ ស្មើនឹង៧៤,៨៦%
- ដូសទី៤ សរុបចំនួន៤១.៣៦៩នាក់ ស្មើនឹង៣១,៥៦%
- ដូសទី៥ សរុបចំនួន១៤.៤៦២នាក់ ស្មើនឹង១១,០៣%
- ដូសទី៦ សរុបចំនួន២.៩៤៨នាក់ ស្មើនឹង២,២៥%។

## ១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

– តាមរយៈសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ នៃរដ្ឋសភា និងដោយមានកិច្ចសហការជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យការរក្សាសន្តិសុខសណ្តាប់ធ្នាប់ ការងារសេដ្ឋកិច្ច សង្គម និងការដោះស្រាយបញ្ហា មានភាពល្អប្រសើរ។ សមិទ្ធផលដែលសម្រេចបានអាស្រ័យដោយក្រុមការងារគ្រប់ថ្នាក់បានយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការអនុវត្តបទបញ្ជា សេចក្តីណែនាំ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជាមួយកិច្ចសហការគាំទ្រទៅវិញទៅមក ក្នុងគោលដៅច្បាស់លាស់ ធ្វើឱ្យការដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋ នៅតាមមូលដ្ឋានទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្ត បានពុះពារជម្នះបញ្ហាប្រឈមជាច្រើនដោយមានការឧបត្ថម្ភគាំទ្រពី សម្តេចពិជ័យសេនា ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ព្រមទាំងក្រុមការងារខេត្ត ក្រុង ស្រុក និងអាជ្ញាធរមូលដ្ឋាន ធ្វើឱ្យរដ្ឋបាលខេត្តអាចអនុវត្តបានដោយជោគជ័យនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន រួមជាមួយនឹងការសម្រេចបាននូវសមិទ្ធផល សំខាន់ៗជាច្រើន។

- **ការរៀបចំកិច្ចប្រជុំផ្ទៃក្នុង៖**
  - ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានបើកកិច្ចប្រជុំដើម្បីត្រួតពិនិត្យ និងពិភាក្សាលើលទ្ធផលការងារ បញ្ហាដីធ្លី ការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ ខេត្តកោះកុង ការជួសជុលសាងសង់ទីលានផ្នូរសពយុទ្ធជន ការអភិវឌ្ឍក្នុងមូលដ្ឋាន និងកិច្ចប្រជុំផ្សេងៗជាច្រើនទៀត
- **ការចូលរួមសកម្មភាពក្នុងព្រឹត្តិការណ៍នានានៅមូលដ្ឋាន៖**
  - ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានចូលរួមក្នុងពិធីបើកការដ្ឋាន និងសម្ពោធសមិទ្ធផលនានា ព្រមទាំងចុះធ្វើការជួសជុលសាងសង់ទីលានផ្នូរសពយុទ្ធជន ជាពិសេស ការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ ខេត្តកោះកុង ចុះសិក្សាស្រាវជ្រាវទីតាំងប្រវត្តិសាស្ត្រតស៊ូរបស់ **សម្តេចពិជ័យសេនា** និងទីតាំងតំបន់អភិវឌ្ឍវិស្សមកាល **សម្តេចពិជ័យសេនា** ជាច្រើនលើក
- **ការចុះជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ៖**
  - ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានចូលរួមសកម្មភាពនានា នៅតាមមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សួរសុខទុក្ខ នាំយកអំណោយចែកជូនប្រជាពលរដ្ឋ ចុះដោះស្រាយបញ្ហាដីធ្លី ចុះពិនិត្យមើលការស្ថាបនានានា ចុះបណ្តុះបណ្តាលអំពីបច្ចេកទេសដាំដំណាំកសិកម្ម ការចិញ្ចឹមសត្វ ការកែច្នៃផលិតផល ចូលរួមពិធីបុណ្យសាសនា ជួយច្រូតកាត់ប្រមូលផល ចុះចែកអត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ប័ណ្ណក្រីក្រ ជូនប្រជាពលរដ្ឋ និងសកម្មភាពនានាជាច្រើនផ្សេងទៀត
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចេញសេចក្តីសម្រេច ស្តីពីការចាត់តាំងសមាសភាពថ្មីសរុបចំនួន១១៨រូប ដោយមាន **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ** ជាប្រធាន និងមានអនុប្រធានចំនួន៦រូប
- រាជរដ្ឋាភិបាលកម្ពុជាចេញ បានចេញសេចក្តីណែនាំ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការចុះបំពេញការងារនៅតាមមូលដ្ឋាននានា។

### ១.១៣-ការងារផ្សេងៗ

- (ពុំមាន)។

## ផ្នែកទី២:-សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ

### ២.១-ផ្នែកសេដ្ឋកិច្ច

### ២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក. ការងារកសិកម្ម**

- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចំនួន២៩វគ្គ មានអ្នកចូលរួមចំនួន៦៦១នាក់ ស្រី៣០០នាក់ ក្នុងនោះរួមមាន៖ ប្រព័ន្ធកសិកម្មចម្រុះ បច្ចេកទេសដាំដុះដំណាំបន្លែលក្ខណៈគ្រួសារ បច្ចេកទេសផលិតជីកំប៉ុស្តិ៍គោក បច្ចេកទេសដាំបន្លែ(ប្រព័ន្ធដំណក់ទឹក) បច្ចេកទេសដាំដុះដំណាំចេក បច្ចេកទេសមុននិងក្រោយប្រមូលផល (ត្រសក់ទ្រើង) ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម បច្ចេកទេសចិញ្ចឹមគោ/ក្របី បច្ចេកទេសចិញ្ចឹមសត្វលក្ខណៈគ្រួសារ ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ ប្រើប្រាស់ជី ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព ប្រើប្រាស់ជីលើដំណាំស្រូវ ពង្រឹងសមត្ថភាព( សហគមន៍កសិកម្ម )និងការអភិវឌ្ឍ ការការពារកុមារនិងការបញ្ជ្រាបយេនឌ័រ
- ចុះផ្សព្វផ្សាយ និងណែនាំបច្ចេកទេសកសិកម្មចំនួន២៣លើក មានអ្នកចូលរួមចំនួន៨០៦នាក់ ស្រី២៦៦នាក់ ក្នុងនោះរួមមាន៖ ច្បាប់ស្តីពីសុខភាពសត្វ និងផលិកម្មសត្វ ដុំពកស្បែកលើសត្វគោ ចិញ្ចឹមគោ/ក្របីឱ្យមានការគ្រប់គ្រងត្រឹមត្រូវ ការការពារ និងព្យាបាលជំងឺអុតក្តាម(ក្របី) ច្បាប់ស្តីពីការគ្រប់គ្រងជីកសិកម្ម ថ្នាំកសិកម្ម ភ្នួរ

រាស់ប្រើប្រាស់គ្រឿងយន្តកសិកម្ម ស្រង់ទិន្នន័យគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ ការទប់ស្កាត់និងបង្ក្រាបបទល្មើស(លបកន្ទុយកណ្ដុរ) និងការអភិរក្សអណ្ដើកសមុទ្រ និងប្រភេទសត្វជិតផុតពូជ

- បានសហការជាមួយរដ្ឋបាលស្រុក និងអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យវាយតម្លៃផលប៉ះពាល់ និងខូចខាតដោយជំនន់ទឹកភ្លៀង ជំងឺ និងសត្វល្អិតបំផ្លាញលើដំណាំរបស់ប្រជាកសិករ ក្នុងនោះរួមមាន ដំណាំស្រូវ ដំណាំបន្លែ និងដំណាំឈើហូបផ្លែ
- ស្ថិតិគ្រឿងយន្តកសិកម្មក្នុងខេត្តសរុបចំនួន៣.៨៤៧គ្រឿង ក្នុងនោះៈ
    - គោយន្ត ចំនួន ២.០៣៦ គ្រឿង
    - ម៉ាស៊ីនបូមទឹក ចំនួន ៣៣៤ គ្រឿង
    - ម៉ាស៊ីនស្ទូង ចំនួន ៤៦ គ្រឿង
    - ម៉ាស៊ីនច្រូតស្រូវ ចំនួន ១៦ គ្រឿង (ម៉ាស៊ីនច្រូតផ្ដួលជាជួរ ៧គ្រឿង)
    - ម៉ាស៊ីនបាញ់ថ្នាំ ចំនួន ៨៥០ គ្រឿង
    - ម៉ាស៊ីនបោកស្រូវ ចំនួន ៤៧ គ្រឿង
    - ម៉ាស៊ីនកិនស្រូវ ចំនួន ៤២០ គ្រឿង។
- ផ្ទៃដីដាំកៅស៊ូគ្រួសារលក្ខណៈគ្រួសារ មានចំនួនសរុប១.៦៦៩,៤០ហិកតា ក្នុងនោះៈ
    - ផ្ទៃដីប្រមូលផលមានចំនួនសរុប១.៦៤៩,៤០ហិកតា
    - ផលិតកម្មជ័រចានសរុបចំនួន១១.១៣៦,៤០តោន
    - ទិន្នផលជាមធ្យម០,៦៧តោន/ហិកតា
    - តម្លៃជ័រចាន២.៦០០៛/គីឡូក្រាម។
- បានចុះតាមដាន ផ្ដល់បច្ចេកទេស និងជំរុញការដាំដុះដំណាំបន្លែដល់កសិករ ចំនួន៤លើក ដល់កសិករចំនួន៤៥គ្រួសារ នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង
- បានចុះបង្ហាញពីរបៀបកម្ចាត់សត្វល្អិតចង្រៃស៊ីបំផ្លាញដំណាំស្រូវរដូវវស្សា និងការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព ចំនួន១លើក បានចំនួន១០គ្រួសារ នៅឃុំដងពែង ស្រុកស្រែអំបិល
- បានចុះអង្កេត ដើម្បីស្ទង់ទិន្នផលស្រូវរដូវវស្សាចំនួន៤លើក បានចំនួន១៦គ្រួសារ នៅស្រុកកោះកុង ស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- បានចុះត្រួតពិនិត្យកន្លែងតាំងលក់សាច់ និងផលិតផលមានដើមកំណើតពីសត្វចំនួន៥លើក បានចំនួន៦៤កន្លែង នៅក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល
- បានចុះតាមដានត្រួតពិនិត្យការចរាចរណ៍ជី-ថ្នាំកសិកម្ម ចំនួន៣លើក នៅក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ពុំបានជួបប្រទះបទល្មើសនោះឡើយ
- បានចុះតាមដានត្រួតពិនិត្យដេប៉ូលក់ជីកសិកម្ម និងថ្នាំកសិកម្ម និងណែនាំផ្ទាល់មាត់ដល់អាជីវករ ឱ្យដាក់តាំងលក់ស្របតាមបទដ្ឋានបច្ចេកទេស ចំនួន៧លើក លើទីតាំងដេប៉ូចំនួន២៩ដេប៉ូ ដោយបានចែកខិត្តប័ណ្ណ ស្ដីពីសុវត្ថិភាពនៃការទិញថ្នាំកសិកម្ម និងផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំកសិកម្មខុសបច្ចេកទេស ជូនដល់អាជីវករ បានចំនួន៤០ផ្ទាំង នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង
- បានចុះត្រួតពិនិត្យ និងតាមដានជំងឺជ្រុះស្លឹកកៅស៊ូ ចំនួន៤លើក លើទីតាំងចម្ការកៅស៊ូគ្រួសារចំនួន១២ទីតាំង នៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- បានចុះសម្របសម្រួលមហាសន្និបាតប្រចាំឆ្នាំ២០២២ របស់សហគមន៍កសិកម្មសាមគ្គីធម៌ សហគមន៍អង្គរភ្នំខ្លុង និងសហគមន៍ដំណាំម្រេចអារ៉ែង ចំនួន៣លើក នៅស្រុកស្រែអំបិល និងស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន៩៣នាក់ ស្រី៣៦នាក់

- បានចុះពិនិត្យធនធានឈើដាំ(អាកាស្យា) របស់ក្រុមហ៊ុន CAMAGRA INVESTMENT GROUP Co,.Ltd ស្ថិតនៅឃុំដងពែង ស្រុកស្រែអំបិល ដែលបានដាក់ពាក្យស្នើសុំបន្តសុពលភាពសុំគោលការណ៍ នាំចេញឈើកែច្នៃសម្រាប់ឆ្នាំ២០២៣-២០២៥ ក្នុងនោះឃើញថា ក្រុមហ៊ុនមានឈើអាកាស្យាដែលអាចប្រមូលផលដើម្បីកែច្នៃចំនួន៨២០ហិកតា
- បានសហការជាមួយក្រុមការងារក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចុះតាមដាន ត្រួតពិនិត្យ ការអនុវត្តអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច លើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំង៧ ក្នុងមូលដ្ឋានខេត្តកោះកុង
- បានចុះពិនិត្យសំណើសុំឈូសឆាយដីព្រៃ និងធ្វើសារពើភណ្ឌប៉ាន់ស្មានធនធានព្រៃឈើលើផ្ទៃដីទំហំ៦៣៦,៣០ហិកតា របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច CN ASIA AGRICULTURE COMPANY LIMITED ស្ថិតនៅស្រុកបូទុមសាគរ ខេត្តកោះកុង
- បានចុះពិនិត្យ និងតាមដានការអនុវត្តការងារ និងវឌ្ឍនភាពក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៤លើក លើឯកសារពាក់ព័ន្ធមួយចំនួនដូចជា ផែនការមេ គោលការណ៍វិនិយោគ កិច្ចសន្យា ការចុះបញ្ជីដី ថ្លៃឈ្នួលសម្បទាន លិខិតអនុញ្ញាតឈូសឆាយ និងរបាយការណ៍ផ្សេងៗ បានចំនួន៣ក្រុមហ៊ុន រួមមាន៖ ក្រុមហ៊ុន ស៊ី អិន អេស៊ា អេហ្គ្រីខលឈ័រ ក្រុមហ៊ុន កោះកុង រ៉ាប់ប៊ើរ ផ្លេនថេសិន ខូអិលធីឌី និងក្រុមហ៊ុន លឹម លុង ខូអិលធីឌី
- បានសហការជាមួយក្រុមការងារដើរដ្ឋថ្នាក់ខេត្ត ចុះសិក្សាប្រមូលទិន្នន័យ កំណត់និយាមកា ធ្វើអត្តសញ្ញាណកម្មអ្នកកាន់កាប់ដី ក្នុងទីតាំងដីស្នើសុំចុះបញ្ជីទំហំ៤.១៥០ហិកតា របស់ឈ្មោះ រតនៈ សម្បត្តិ និងដីរបស់ឈ្មោះ លីវនី ហ្គីល លើសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន CAMAGRA INVESTMENT LIMITED ស្ថិតក្នុងភូមិសាស្ត្រភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល
- បានចុះពិនិត្យទីតាំង និងស្រាវជ្រាវអត្តសញ្ញាណជនប្រព្រឹត្តបទល្មើស លួចកាប់រានដុត ហ៊ុមព័ទ្ធកាន់កាប់ដី ក្នុងដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វ្រីនរិច គ្រុប ស្ថិតក្នុងភូមិសាស្ត្រឃុំជ្រោយប្រស់ ស្រុកកោះកុង
- ចលនាដឹកនាំសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖
    - ជ្រូកសាច់នាំចូល ចំនួន ៧.៨៤៥ក្បាល
    - សាច់គ្រួចនាំចូល ចំនួន ៩៧៥គ.ក្រ
    - មាន់រស់នាំចូល ចំនួន ២៥.៦៨៤ក្បាល
    - ប្រហិតនាំចូល ចំនួន ១.៨២៥គ.ក្រ
    - ជ្រូករស់នាំចេញ ចំនួន ២០ក្បាល។
- ចាក់ថ្នាំការពារសត្វសរុបបានចំនួន៤២.៣៦៤ក្បាល ក្នុងនោះ៖
    - គោ ចំនួន ៦.៥០០ក្បាល (ជំងឺ ៣មុខ)
    - ក្របី ចំនួន ៦.៣៧៧ក្បាល (ជំងឺ ៣មុខ)
    - ពពែ ចំនួន ៤៨ក្បាល (ជំងឺ ៣មុខ)
    - ជ្រូក ចំនួន ៧.៦០០ក្បាល (ជំងឺ ៧មុខ)
    - ឆ្កែ ចំនួន ៤៣៣ក្បាល (ជំងឺ ៧មុខ)
    - ឆ្មា ចំនួន ៨២ក្បាល (ជំងឺ ៤មុខ)
    - សត្វស្លាប ចំនួន ២១.៣២៤ក្បាល (ជំងឺ ៣មុខ)
- ព្យាបាលសត្វសរុបបានចំនួន៣.៥១០ក្បាល ក្នុងនោះ៖
    - គោ ចំនួន ៤៥៨ក្បាល
    - ក្របី ចំនួន ២៥៣ក្បាល

- ជ្រូក ចំនួន ៦៦០ក្បាល
- ឆ្កែ ចំនួន ៣៦៥ក្បាល
- សត្វស្លាប ចំនួន ១.៧៧៤ក្បាល

- សត្វងាប់ដោយជំងឺសរុបមានចំនួន៥.៤២១ក្បាល ក្នុងនោះ៖
  - គោ ចំនួន ៧ក្បាល
  - ក្របី ចំនួន ១៨ក្បាល
  - ជ្រូក ចំនួន ១២០ក្បាល
  - ឆ្កែ ចំនួន ១៥៩ក្បាល
  - សត្វស្លាប ចំនួន ៥.១១៧ក្បាល
- ស្ថិតិពិឃាដសត្វសរុបមានចំនួន៤៨.៧០៦ក្បាល ក្នុងនោះ៖
  - គោ ចំនួន ៧៧៩ក្បាល
  - ក្របី ចំនួន ៤១៣ក្បាល
  - ជ្រូក ចំនួន ១០.៣៧២ក្បាល
  - មាន់ ចំនួន ៣៧.១៤២ក្បាល
- ការច្រូតកាត់ប្រមូលផលស្រូវអនុវត្តបានសរុបចំនួន១០.០១៥,៩៥ហ.ត បរិមាណផលសរុប២៧.០២៨,៦៧តោន និងទិន្នផលមធ្យម២,៦៩តោន/ហ.ត
- ការភ្ជួររាស់អនុវត្តបានសរុបចំនួន៩.៦០៨ហ.ត
- សំណាបអនុវត្តបានសរុបចំនួន១៩១ហ.ត
- ដំណាំស្រូវអនុវត្តបានសរុបចំនួន១០.១៩៤ហ.ត
- ដំណាំបន្លែអនុវត្តបានសរុបចំនួន២៥៤ហ.ត
- ដំណាំឈើហូបផ្លែអនុវត្តបានសរុបចំនួន៤២៦ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៣១៧ហ.ត
- បរិមាណផលដំណាំនានានាំចេញ និងប្រើប្រាស់ក្នុងខេត្តសរុបបានចំនួន៧.៩៦៦តោន និងផ្លែដូងចំនួន៤៣.៨០០ផ្លែ
- សហការជាមួយអង្គការ Save the Children (គម្រោងស្ទៀរ = STEER) បាន៖
  - ចុះយកសំណាក(ទឹក-ដី) បានចំនួន៨សំណាក នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
  - ចុះតាមដានកសិករគម្រោង ដើម្បីពង្រឹងផលិតកម្មកសិកម្មចំនួន១៧លើក លើគ្រួសារកសិករចំនួន២០៥គ្រួសារ នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង
  - ចុះសម្ភាសន៍ជាមួយកសិករគំរូក្រុមអ្នកផលិតរបស់គម្រោងស្ទៀរ ដើម្បីពង្រឹងសមត្ថភាពលើបច្ចេកទេសកសិកម្ម ផ្នត់គំនិតអាជីវកម្ម និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង បានចំនួន២២នាក់ ស្រី៥នាក់
  - ចុះវាយតម្លៃដំណើរការអនុវត្តរបស់ក្រុមកសិករអ្នកផលិតចំនួន១លើក លើក្រុមកសិករអ្នកផលិតចំនួន៣១ក្រុម នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង
  - ចុះសម្របសម្រួលកិច្ចប្រជុំប្រចាំខែក្រុមកសិករអ្នកផលិតរបស់គម្រោងស្ទៀរចំនួន១៤លើក នៅស្រុកបូទុមសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន៣៦១នាក់ ស្រី២២៩នាក់
  - ចុះវាយតម្លៃក្រុមស្ត្រីផលិតស្រកីដូងចំនួន១លើក បានចំនួន១កន្លែង នៅស្រុកស្រែអំបិល

- ចុះតាមដានអាជីវករប្រមូលទិញ និងលក់ជាតុចូលកសិកម្មរបស់គម្រោងស្មៀរចំនួន៣លើក បានចំនួន ៣២ទីតាំង នៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- សម្របសម្រួលវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ជនបង្គោលអំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការកត់ត្រាបញ្ជីស្នាម ចំនួន៦វគ្គ នៅស្រុកស្រែអំបិល និងស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន១៩៩នាក់ ស្រី៦៦នាក់
- សម្របសម្រួលវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ជនបង្គោល អំពីបច្ចេកទេសកសិកម្ម ចំនួន២វគ្គ មានអ្នកចូលរួមសរុបចំនួន៥៥នាក់ ស្រី១៤នាក់ នៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល។

**ខ.ការងារខណ្ឌរដ្ឋបាលជលផល**

- បានចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែនសមត្ថកិច្ចចំនួន១១៧លើក អនុវត្តបានចំនួន៤៣ករណី ក្នុងនោះ៖ ដកហូតបំផ្លាញចោលលបកន្ទុយកណ្តុរចំនួន៦០៨ខ្សែ ប្រវែង៤.៨២៤ម៉ែត្រ រឹបអូសអាគុយ៤០អំពែ ចំនួន១គ្រឿង ក្បាលឆក់ចំនួន១គ្រឿង ដងឆក់ចំនួន២គ្រឿង ដកហូតឈ្នាងអួសគ្រែងឈាមចំនួន១៨ឈ្នាង រុះរើដកបង្គោលស៊ុមគ្រែងឈាមអនាធិបតេយ្យចំនួន៥១បង្គោល អប់រំណែនាំកុំឱ្យប្រើប្រាស់ឧបករណ៍នេសាទអូសគ្រែងឈាមក្នុងតំបន់ហាមឃាត់ រុះរើចេញរបាំងស្បៃមុងប្រវែង១២០ម៉ែត្រ លូស្បៃមុងចំនួន៤មាត់ រុះរើចេញរបាំងសាច់អួនប្រវែង៥០ម៉ែត្រ លូសាច់អួនចំនួន១មាត់ និងបង្គោលសរុបចំនួន១៧០ដើម លែងខ្យងសចូលក្នុងសមុទ្រវិញ ចំនួន១៦.៣២០គ.ក្រ ធ្វើកិច្ចសន្យាបញ្ឈប់ និងដកហូតឈ្នាងអួសខ្យងសចំនួន១៦ឈ្នាង ធ្វើកិច្ចសន្យាបញ្ឈប់នេសាទលបកន្ទុយកណ្តុរចំនួន១គ្រឿង ឃាត់ចាប់ និងធ្វើកិច្ចសន្យាបញ្ឈប់ការប្រើប្រាស់ទូកយន្តចំនួន៩គ្រឿង និងដកហូតដងឈិបយន្តចំនួន៩គូ សាច់ឈិបចំនួន៩ចូរ ទូកអួនអូសនៅក្រៅតំបន់អនុញ្ញាតចំនួន៦គ្រឿង ទូកអួនអូសនៅក្រៅតំបន់អនុញ្ញាតចំនួន២គ្រឿង និងពិន័យជាប្រាក់ចំនួន៤លានរៀល ពិន័យជាប្រាក់ទូកដឹកខ្យងសចំនួន៣លានរៀល និងលែងខ្យងសចំនួន៣.០០០គ.ក្រ ឃាត់ចាប់ទូកអួនអូសគូ ចំនួន១គ្រឿង និងពិន័យជាប្រាក់ចំនួន៨លានរៀល ឃាត់ចាប់ទូកអួនអូសដោយគ្មានលិខិតអនុញ្ញាតឱ្យធ្វើនេសាទ ចំនួន១គ្រឿង និងពិន័យជាប្រាក់ ចំនួន២លានរៀល កាយយកខ្សាច់នៅក្នុងដែននេសាទ ដោយគ្មានលិខិតអនុញ្ញាត និងពិន័យជាប្រាក់ចំនួន ១០លានរៀល ករណីបូមខ្សាច់នៅក្នុងតំបន់គ្រប់គ្រងអណ្តើកហ្លួង ឬអណ្តើកសរសៃ និងក្រពើត្រី ឃាត់ចាប់ទូកនេសាទដោយប្រើឧបករណ៍អួនអូសចំនួន១គ្រឿង ឃាត់ចាប់ទូកយន្តចំនួន១គ្រឿងនេសាទដោយប្រើឧបករណ៍នេសាទឈ្នាងអួសខ្យងស ធ្វើពីសាច់មង ក្រឡាញឹក ឃាត់ចាប់ទូកយន្តចំនួន១គ្រឿងនេសាទដោយប្រើឧបករណ៍ទំនើប(ឈ្នាងអួសខ្យងស) និងលែងខ្យងស ចំនួន១.៥០០គីឡូក្រាម។
- ផលនេសាទទឹកសាបអនុវត្តបានចំនួន១០៦តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន៤៥.៨២១តោន (សិប្បកម្មចំនួន៣៩.៦៥៧តោន)
- ការកែច្នៃផលិតផលជលផលអនុវត្តបានចំនួន១.៦៩៩តោន និងផលិតទឹកត្រីអនុវត្តបាន២៨.១០០លីត្រ
- ផលវារីវប្បកម្មអនុវត្តបានចំនួន៥.៩០២តោន
- ការចរាចរផលនេសាទទៅតាមបណ្តារាជធានី/ខេត្តសរុបចំនួន១៧.៨៨១តោន
- ដាក់មេក្តាមពងចូលក្នុងធនាគារក្តាម ចំនួន៣៩២ក្តាម ស្មើនឹង៣៦,៧គីឡូក្រាម
- បណ្តុះកូនកោងកាងបានចំនួន២២.៣០០ដើម
- ដាំកូនកោងកាងបានចំនួន២២.៣០០ដើម
- បានលែងអណ្តើកសមុទ្រ(ក្រាស់) ចូលក្នុងព្រែកធម្មជាតិវិញចំនួន១ក្បាល ទម្ងន់៥គីឡូក្រាម ដែលប្រជានេសាទចាប់បាននៅក្នុងប្រព័ន្ធព្រែក ស្ថិតនៅភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ
- បានសហការជាមួយមន្ត្រីរដ្ឋបាលជលផលថ្នាក់កណ្តាល ចុះផ្សព្វផ្សាយ និងបំពាក់ប្រព័ន្ធតាមដាននាវានេសាទ VMS ចំនួន៣លើក លើនាវានេសាទចំនួន៧៥គ្រឿង នៅក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកគិរីសាគរ

- បានចុះអង្កេតទូកនេសាទដោយប្រើប្រាស់កម្មវិធីស្មាតធូល(SMART TOOL) និងណែនាំម្ចាស់ទូកនេសាទ ឱ្យដាក់ពាក្យស្នើសុំធ្វើអាជីវកម្មដែននេសាទសម្រាប់ឆ្នាំ២០២៣ ចំនួន១លើក លើទូកនេសាទចំនួន៣៥ទូក នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការធ្វើអាជីវកម្មនេសាទ និងការបង់ថ្លៃឈ្នួលដែននេសាទ សម្រាប់រដូវនេសាទឆ្នាំ២០២៣ ដល់ប្រជានេសាទ ចំនួន៤លើក នៅស្រុកមណ្ឌលសីមា ស្រុកគិរីសាគរ និងស្រុកបូទុមសាគរ
- បានចុះផ្សព្វផ្សាយជំរុញ និងលើកទឹកចិត្ត ដល់ប្រជានេសាទឱ្យប្រើប្រាស់ឧបករណ៍នេសាទដែលមានក្នុងប្រកាសអនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន៦លើក នៅឃុំថ្មស ស្រុកបូទុមសាគរ មានអ្នកចូលរួមសរុបចំនួន៩៤នាក់ ស្រី៣៨នាក់
- សហការជាមួយមន្ត្រីរដ្ឋបាលជលផល ចុះផ្សព្វផ្សាយស្តីពី ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទ និងការបាញ់ស្លាកលេខទូកនេសាទនៅតាមផែ ចំនួន១លើក នៅឃុំថ្មស ស្រុកបូទុមសាគរ មានអ្នកចូលរួមសរុបចំនួន២១នាក់ ស្រី៨នាក់។

**គ. ការងារខណ្ឌរដ្ឋបាលព្រៃឈើ**

- បានចែកចាយកូនឈើគគីរចំនួន៣៧៥ដើម ជូនសាលាឃុំ សាលាស្រុក វត្តអារាម និងមន្ទីរអង្គភាពនានាជុំវិញខេត្ត
- បានសហការជាមួយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះពិនិត្យផលិតផល និងសិក្សាការកែច្នៃដើមចន្ទន៍ក្រស្នា របស់ក្រុមហ៊ុន ខ អេស អាហ្គ្រោ-អ៊ីនដាសស្ទ្រី ដែលមានប្រភពវត្ថុធាតុដើមពីព្រៃឯកជនទំហំ២៨០ហិកតា ដែលកំពុងផលិតប្រេងចន្ទន៍ក្រស្នា ដោយមានឆ្នាំងចំហុយចំនួន៣៥ឆ្នាំង ស្ថិតនៅភូមិអន់ឆ្អើត ឃុំដីខក្រោម ស្រុកស្រែអំបិល
- បានសហការជាមួយក្រុមការងាររដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះពិនិត្យ សិក្សាវាយតម្លៃធនធានឈើដាំប្រភេទអាកាស្យារបស់ក្រុមហ៊ុន ខេអេចសឹនសាន អេនធើប្រាយ ឯ.ក ដែលបានស្នើសុំគោលការណ៍នាំចេញសាកល្បងទៅកាន់ប្រទេសកូរ៉េ ដោយបានធ្វើការប្រមូលទិញឈើប្រភេទអាកាស្យា ពីចម្ការឈើដាំលក្ខណ:គ្រួសាររបស់ប្រជាពលរដ្ឋ លើផ្ទៃដីទំហំ ៣,៥ហិកតា នៅភូមិនាពិសី ឃុំដីខក្រោម ស្រុកស្រែអំបិល។ តាមការចុះពិនិត្យជាក់ស្តែងឃើញថា ក្រុមហ៊ុនមានធនធានឈើដាំប្រភេទអាកាស្យាសម្រាប់ នាំចេញសាកល្បងចំនួន៤.៨៣៤ដើម ស្មើនឹង៣១៨ម៣៥៦៣ ឬស្មើនឹង៤៧៧,៦០៦ស្ទែរ
- បានចុះពិនិត្យវាយតម្លៃសិប្បកម្មឡចំហុយដើមចន្ទន៍ក្រស្នាចំនួន១កន្លែង ដែលបានស្នើសុំបន្តសុពលភាពអាជីវកម្មសម្រាប់ឆ្នាំ២០២៤ របស់ឈ្មោះ ឡា យ៉ាស់យ៉ា ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។ ជាលទ្ធផលសង្កេតឃើញថា រោងសិប្បកម្មបានធ្វើការចំហុយយកប្រេងចន្ទន៍ក្រស្នាសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញទៅក្រៅប្រទេស ដោយប្រើប្រាស់វត្ថុធាតុដើមមានប្រភពពីចម្ការឈើដាំចន្ទន៍ក្រស្នារបស់ប្រជាពលរដ្ឋដាំជាលក្ខណ:គ្រួសារលើដីកម្មសិទ្ធិឯកជន នៅតាមបណ្តាក្រុង/ស្រុកនានាក្នុងខេត្ត
- បានចុះត្រួតពិនិត្យរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទតូចដែលបានដាក់ពាក្យស្នើសុំបន្តសុពលភាពអាជីវកម្ម សម្រាប់ឆ្នាំ២០២៣-២០២៤ ចំនួន១កន្លែង របស់ឈ្មោះ ធេ លី ភេទប្រុស អាយុ៦២ឆ្នាំ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
- បានសហការជាមួយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ចុះត្រួតពិនិត្យទីតាំងស្នើសុំច្បាប់អនុញ្ញាតថែរក្សាសត្វត្រចៀកកាំជាលក្ខណ:គ្រួសារ ចំនួន២លើក បានចំនួន៥ទីតាំង ស្ថិតនៅក្រុងខេមរភូមិន្ទ និងស្រុកបូទុមសាគរ
- បានសហការជាមួយកងវិស្វកម្មលេខ១៧៨ ស្ពាន-ថ្នល់ នាយកដ្ឋានវិស្វកម្ម នៃក្រសួងការពារជាតិ ចុះរៀបចំពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៣ នៅតំបន់ប្រវត្តិសាស្ត្រ សម្តេចពិជ័យសេនា ទៀ បាញ់ ស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង។ ទិវានេះ បានធ្វើការដាំកូនឈើគគីរ ចំនួន២.០០០ដើម សងខាងផ្លូវបេតុងចូលទៅកាន់ទីតាំងភ្នំពិជ័យសេនា និងដាំព័ទ្ធជុំវិញបរិវេណជើងភ្នំពិជ័យសេនា

- បានចុះទប់ស្កាត់ និងធ្វើបច្ចុប្បន្នភាពការសាងសង់ខ្ទមអនាធិបតេយ្យ ពីសំណាក់ប្រជាពលរដ្ឋលើដីចម្ការឈើអាកាស្យាចំនួន៨លើក ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានសហការជាមួយក្រុមការងារជំនាញថ្នាក់ស្រុក ចុះពិនិត្យវាស់វែង និងសិក្សាផលប៉ះពាល់លើទីតាំងដី១កន្លែង ដែលស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីដី របស់ឈ្មោះ ម៉ី រដ្ឋា ភេទប្រុស ស្ថិតនៅភូមិ បានទៀត ឃុំដងពែង ស្រុកស្រែអំបិល ត្រង់ចំណុចនិយាមកា (៣០៤៦៩៧-១២៣១១២២) ផ្ទៃដីទំហំ៥០.៦៣៦ម$^{២}$ កាត់ឆ្វៀលចេញពីតំបន់ការពារធម្មជាតិ
- សហការជាមួយក្រុមការងារជំនាញថ្នាក់ខេត្តបាន៖
  - ចុះពិនិត្យជាក់ស្តែងទីតាំងដីស្នើសុំចុះបញ្ជីទំហំ៤.១៥០ហិកតា របស់ឈ្មោះ រតនៈ សម្បត្តិ និងឈ្មោះ លីវ នី ហ្គីល ក្នុងភូមិសាស្ត្រភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន២០នាក់
  - ចុះអនុវត្តវិធានការរដ្ឋបាល រុះរើខ្ទមអនាធិបតេយ្យ បានចំនួន៧៥ខ្ទម ដកបង្គោលរបងចំនួន៥៦០បង្គោល និងបំផ្លាញចោលដំណាំចម្រុះ ចំនួន៦៥០ដើម ស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ និងភូមិកោះកុង ក្នុងឃុំត្រពាំងរូង ស្រុកកោះកុង
  - ចុះពិនិត្យទីតាំងដីស្នើសុំចុះបញ្ជីធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ប្រជាពលរដ្ឋចំនួន៨ទីតាំង ស្ថិតនៅភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល។ ជាក់ស្តែងពិនិត្យឃើញថា ទីតាំងដីស្នើសុំខាងលើ ស្ថិតក្នុងផ្ទៃដីកាត់ឆ្វៀលចេញពីតំបន់ការពារធម្មជាតិ តាមអនុក្រឹត្យលេខ៣០ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២១។
- បានចុះល្បាត បង្ក្រាប និងស្រាវជ្រាវ បទល្មើសព្រៃឈើ និងសត្វព្រៃ បានចំនួន៣៤លើក ជួបប្រទះបទល្មើសចំនួន៧ករណី ក្នុងនោះ៖
  - សហការជាមួយកម្លាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ឃាត់ខ្លួនជនសង្ស័យ ២នាក់ មានទីលំនៅស្រុកបូទុមសាគរ ជាប់ចោទពីបទប្រើប្រាស់រណាយន្តអារឈើ ដោយគ្មានលិខិតអនុញ្ញាត។ វត្ថុតាងបទល្មើសរួមមាន៖ រណាយន្តធុនតូចចំនួន១គ្រឿង, ម៉ូតូហុងដាចំនួន២គ្រឿង និងកាំបិតផ្គាក់ចំនួន១ដើម។
  - សហការជាមួយកម្លាំងឧទ្យាននុរក្ស នៃឧទ្យានជាតិបទុមសាគរ កម្លាំងកងរាជអាវុធហត្ថ និងមានការសម្របសម្រួលពីព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកោះកុង បានឃាត់ចាប់រថយន្តចំនួន ១គ្រឿង និងមនុស្ស៣នាក់។ វត្ថុតាងរួមមាន៖ ចំណិតវល្លិ៍មៀតស្ងួតទម្ងន់៥០គីឡូក្រាម និងវល្លិ៍មៀតស្រស់ ចំនួន១២បាច់។
  - ដាក់ពាក្យប្តឹងទៅអយ្យការអមសាលាដំបូងខេត្តកោះកុងចំនួន១ករណី ពីបទសង់លំនៅដ្ឋានថ្មីលើដីចម្ការឈើអាកាស្យារបស់រដ្ឋ ប្រព្រឹត្តិឡើងដោយជនឈ្មោះ៖
    ១. ហាក់ ម៉េងហ៊ាង ឈ្មោះហៅក្រៅ កុងយ៉យ ភេទប្រុស មុខរបរកម្មករ ប្រពន្ធឈ្មោះ លឹម ឆេងងី មានទីលំនៅបច្ចុប្បន្នភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ វត្ថុតាងរួមមាន សង់ផ្ទះថ្មថ្មីទំហំ ៦មx១៥ម លើដីចម្ការឈើទំហំ៨មx៣០ម ខុសច្បាប់។
    ២. ហ៊ាង ជាវិទ្ធ ឈ្មោះហៅក្រៅ អាចារ្យ ភេទប្រុស អាយុ៤៨ឆ្នាំ មុខរបរលក់ដូរនៅផ្សារដងទង់ ប្រពន្ធឈ្មោះ ឈិន ស៊ីណាត មានទីលំនៅបច្ចុប្បន្នភូមិ១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ។ វត្ថុតាងរួមមាន សង់ផ្ទះថ្មី វីឡា២ជាន់ ទំហំ១០ម x ១៤ម លើដីចម្ការឈើទំហំ ២០ម x ៦០ម (របងថ្មព័ទ្ធជុំវិញ) ខុសច្បាប់។

- ○ បានសហការជាមួយកម្លាំងគណៈបញ្ជាការឯកភាពស្រុកបូទុមសាគរ ក្រុមការងារចម្រុះបានចុះដកហូតវត្ថុតាងល្មើស នៅលើដីកាប់រានដោយខុសច្បាប់១កន្លែង ទំហំផ្ទៃដី៦២ហិកតា ស្ថិតនៅចំណុចព្រែកសង្កែ ភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ○ ផ្នែករដ្ឋបាលព្រៃឈើអណ្តូងទឹក បានទទួលវត្ថុតាងនៃបទល្មើសដឹកជញ្ជូនផលអនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាតចំនួន១ករណី ពីកងរាជអាវុធហត្ថស្រុកបូទុមសាគរ និងអធិការនគរបាលស្រុកបូទុមសាគរ ដែលបានចាប់ឃាត់ ចំណុចចំណោតផ្លូវសោយភូថង ភូមិដីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ○ ក្រុមការងារខណ្ឌរដ្ឋបាលព្រៃឈើកោះកុង បានចងក្រងសំណុំរឿងបទល្មើសសម្លាប់សត្វឈ្លូសចំនួន១ក្បាល ពីគណៈកម្មការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិខេត្ត ចំនួន១ករណី ដើម្បីស្នើសុំសេចក្តីសម្រេចពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ
- ○ បានសហការជាមួយកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកបូទុមសាគរ ចុះពិនិត្យទីតាំងកាប់រានហ៊ុមព័ទ្ធកាន់កាប់ដីព្រៃវាតយកដីធ្វើកម្មសិទ្ធិ ចំនួន១កន្លែង ផ្ទៃដីទំហំប្រមាណ៥ហិកតា ស្ថិតត្រង់ ចំណុចនិយាមកា UTM (៣៣០០៥២; ១២៤០៧៥៦) ស្ថិតក្នុងភូមិសាស្ត្រភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង។

## ២.១.២-ការងារធនធានទឹក និងឧតុនិយម

- បានចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ
- បានប្រមូលទិន្នន័យឧតុនិយមនៅតាមបណ្តាក្រុង ស្រុក ដើម្បីចងក្រងបញ្ជូនទៅក្រសួង
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃបឹងព្រាវ ប្រវែង៤.០០០ម ស្ថិតក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតានី ប្រវែង២.០០០ម ស្ថិតក្នុងដីខលើ ស្រុកស្រែអំបិល សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃកណ្តោល ប្រវែង៦.២០០ម ស្ថិតក្នុឃុំកណ្តោល ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតាំកន់ ប្រវែង៦.៦៥០ម ស្ថិតក្នុឃុំកណ្តោល ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃដីមាល ប្រវែង៣.៤៨៩ម ស្ថិតក្នុឃុំអណ្តូងទឹក ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃដីត្រេះ ប្រវែង៧.៨០០ម ស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានជួសជុលទំនប់ការពារដងពែង២(ជំហ៊ាន១) ប្រវែង២.៥០០ម ស្ថិតក្នុងឃុំដងពែង ស្រុកស្រែអំបិល សម្រេចបាន១០០%
- បានជួសជុលក្រាលក្រួសក្រហមលើខ្នងប្រឡាយដោះទឹកជំនន់ទំនប់ការពារទឹកប្រៃដីមាល ប្រវែង១.៤៥០ម ស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានស្តារប្រឡាយដោះទឹកជំនន់តាមបណ្តោយទំនប់ការពារទឹកប្រៃផ្តោង ប្រវែង៣.១០០ម ស្ថិតក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល សម្រេចបាន១០០%។

## ២.១.៣-ការងារអភិវឌ្ឍជនបទ

- បានចូលរួមប្រជុំស្តីពីការកំណត់ទំហំផ្លូវសម្រាប់ធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ ជាមួយអាជ្ញាធរភូមិ ឃុំ និងស្រុក(ផ្លូវបឹងព្រាវ-ជ្រោយស្វាយ)១ខ្សែ ប្រវែង១៩.៨៣៧ម ទទឹង១០ម ស្ថិតនៅឃុំបឹងព្រាវ និងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ចំនួន១លើក
- បានសហការជាមួយគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ ក្រោមហិរញ្ញប្បទានរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ចុះសិក្សាពីផលប៉ះពាល់បរិស្ថាន និងសង្គម ផ្លូវថ្មបាំង ពីចំណុចផ្លូវជាតិលេខ៤៨ ទៅដល់សាលាស្រុកថ្មបាំង ១ខ្សែ ប្រវែង៣៨.០០០ម ទទឹង៨ម ដើម្បីសាងសង់ពីផ្លូវក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ ចំនួន១លើក
- បានចុះសិក្សាគម្រោងផ្លូវក្រាលក្រួសក្រហមចំនួន២៦ខ្សែ ប្រវែងសរុប១៦.០០០ម ទទឹង៩ម ស្ថិតនៅតំបន់អភិវឌ្ឍរៀបរយ និងតំបន់វិស្សមកាលក្រសួងការពារជាតិក្នុងភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុងចំនួន១លើក
- បានចុះធ្វើបច្ចុប្បន្នភាពផ្លូវជនបទដើម្បីរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទចំនួន៦០ខ្សែប្រវែងសរុប៣០០.៩០៥ម លូមូល១១២កន្លែង លូប្រអប់៣១កន្លែង ស្ពាន៧កន្លែង និងសំណង់បង្ហៀរ៤កន្លែង ចំនួន១២លើក
- បានចុះរាប់ចរាចរណ៍យានយន្តលើដងផ្លូវជនបទចំនួន១០ខ្សែ ប្រវែងសរុប៩០.៨១០ម នៅក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង ចំនួន៧លើក
- បានចុះត្រួតពិនិត្យតាមដានការងារសាងសង់ស្ពានបេតុង១កន្លែង បណ្តោយ៧៥ម ទទឹង៨ម កម្ពស់៨,៥ម សាងសង់នៅចំណុចព្រែកកន្ទាយ ស្ថិតក្នុងភូមិកំលត ឃុំជីផាត ស្រុកថ្មបាំង ចំនួន១លើក
- បានចុះត្រួតពិនិត្យគម្រោងជួសជុលបន្ទាន់ និងផ្លូវថែទាំជាលក្ខណៈខួប និងប្រចាំចំនួន៦ខ្សែ ប្រវែងសរុប១៣៤.២៩០ម និងសាងសង់លូកាត់ផ្លូវចំនួន៥កន្លែង ចំនួន៤លើក
- បានសហការជាមួយក្រុមការងារទីប្រឹក្សាគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ ចុះបើកវគ្គបណ្តុះបណ្តាលស្តីពីកិច្ចគាំពារសុវត្ថិភាពសង្គមដល់អាជ្ញាធរមូលដ្ឋានភូមិ ឃុំ ប្រជាពលរដ្ឋ និងសិស្សានុសិស្សដែលរស់នៅ និងធ្វើដំណើរតាមផ្លូវ(បឹងព្រាវ-ជ្រោយស្វាយ)១ខ្សែ ប្រវែង១៩.៨៣៧ម ដែលកំពុងសាងសង់ឱ្យមានការប្រុងប្រយ័ត្នចំពោះការធ្វើដំណើរ ចំនួន១លើក
- បានចែកសម្ភារបង្គន់អនាម័យដល់ប្រជាពលរដ្ឋចំនួន២៣៣គ្រួសារ នៅក្នុងស្រុកថ្មបាំង និងស្រុកកោះកុង ចំនួន២លើក
- បានចុះត្រួតពិនិត្យ តាមដាន វាយតម្លៃ និងជំរុញគ្រួសារដែលទទួលសម្ភារបង្គន់អនាម័យជាលក្ខណៈគ្រួសារ នៅឃុំប្រឡាយ និងឃុំគគីរជ្រុំ ស្រុកថ្មបាំង ចំនួន២លើក
- បានចុះប្រជុំផ្សព្វផ្សាយអប់រំពីអនាម័យតាមសហគមន៍នៅឃុំគគីរជ្រុំ និងឃុំជីផាត ស្រុកថ្មបាំង ចំនួន២លើក
- បានចុះសិក្សាទីតាំងអណ្តូងស្នប់ និងត្រួតពិនិត្យការងារស្រះទឹកសហគមន៍ និងប្រព័ន្ធចែកចាយទឹក នៅស្រុកកោះកុង ស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ចំនួន២០លើក
- បានសហការជាមួយគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ ក្រោមហិរញ្ញប្បទានរបស់ធនាគារវិនិយោគហេរចនាសម្ព័ន្ធអាស៊ី ចុះសិក្សាទីតាំងស្រះសហគមន៍ ចំនួន១៣ស្រះ នៅក្នុងស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង ដែលបានស្នើសុំដោយអាជ្ញាធរភូមិ ឃុំ តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំនួន១លើក
- បានចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)ចំនួន៧លើក។

## ២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈ ក្នុងក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ចំនួន៣៨មូលដ្ឋាន មានដៃបាញ់ប្រេងចំនួន៣០៤ដៃ
- បានផ្ទៀងផ្ទាត់ជញ្ជីងក្រោមទម្ងន់១.០០០គីឡូក្រាម នៅស្រុកគិរីសាគរ និងផ្សារដងទង់ ក្រុងខេមរភូមិន្ទ ចំនួន ១៧៥គ្រឿង
- បានដាក់ជញ្ជីងគំរូ នៅក្នុងផ្សារដងទង់ ក្រុងខេមរភូមិន្ទ ចំនួន១គ្រឿង សម្រាប់បម្រើជាសាធារណៈជូនប្រជាពលរដ្ឋធ្វើការថ្លឹងផ្ទៀងផ្ទាត់
- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត ទំនិញវេចខ្ចប់ បានចំនួន១០មូលដ្ឋាន
- បានចុះត្រួតពិនិត្យដំណើរការបច្ចេកទេសខ្សែសង្វាក់ផលិតកម្ម និងផលិតផល នៅស្រុកមណ្ឌលសីមា ស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកគិរីសាគរ និងស្រុកថ្មបាំង បានចំនួន១២មូលដ្ឋាន
- បានសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចុះត្រួតពិនិត្យឧបករណ៍បច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ទៅលើផ្នែកម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមខ្យល់ និងឧបករណ៍លើកដាក់ របស់ក្រុមហ៊ុនយ៉ាហ្សាគី (ខេមបូឌា) ប្រដាក់ខូអិលធីឌី YAZAKI (CAMBODIA) PRODUCTS CO.,LTD
- បានចុះស្រង់ទិន្នន័យ អំពីការស្ទង់មតិពីផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ទៅលើសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ក្នុងក្រុងខេមរភូមិន្ទ ស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ បានចំនួន១៥ មូលដ្ឋាន
- បានសហការជាមួយរដ្ឋបាលស្រុកមណ្ឌលសីមា រដ្ឋបាលឃុំប៉ាក់ខ្លង និងរដ្ឋបាលឃុំពាមក្រសោប ចុះធ្វើបច្ចុប្បន្នភាពសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មប្រចាំឆ្នាំ២០២៣ ក្នុងនោះ នៅឃុំប៉ាក់ខ្លងមានចំនួន៧៤មូលដ្ឋាន និងឃុំពាមក្រសោបមានចំនួន៦មូលដ្ឋាន
- បាននាំយកផលិតផលចំនួន៥មុខ រួមមាន៖ ១.ប្រេងខ្យល់ប្រេងកូឡា ២.ស្ក្រាប់មុខ ស្ក្រាប់ខ្លួន ៣.សាប៊ូលាងចាន សាប៊ូបោកគក់ ៤.គ្រាប់ស្វាយចន្ទី ៥.ស្រាចេក ដើម្បីតាំងបង្ហាញលក់ផលិតផលក្នុងពិធីបណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកប្រចាំឆ្នាំ២០២៣ នៅស្រុកស្រែអំបិល និងតាំងបង្ហាញលក់ផលិតផលក្នុងពិធីបុណ្យសមុទ្រលើកទី១០ ឆ្នាំ២០២៣ ក្រោមប្រធានបទ «យើងទាំងអស់គ្នាដើម្បីទេសចរណ៍» នៅខេត្តកែប
- បានចុះត្រួតពិនិត្យស្រះទឹកដើម្បីជីកពង្រីកបន្ថែម ស្នើសុំដោយអាជីវករ អាន សំឡាន សម្រាប់ផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋប្រើប្រាស់ក្នុងភូមិកោះស្ដេច ឃុំកោះស្ដេច ស្រុកគិរីសាគរ។ ក្រុមការងារជំនាញមន្ទីរបានយកសំណាកទឹកទៅវិភាគគុណភាព នៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ លទ្ធផលទឹកអនុលោមតាមគុណភាពស្តង់ដារបានកំណត់
- បានចុះអធិការកិច្ចលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ស្ថិតនៅស្រុកស្រែអំបិល និងស្រុកបូទុមសាគរ បានចំនួន២ មូលដ្ឋាន
- បានយកសំណាកផលិតផលវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ បានចំនួន៥៩មូលដ្ឋាន ស្មើនឹង៦៤ប៉ាន់គំរូ (ទឹកពិសាដប ទឹកស្អាត ទឹកកកដើម ទឹកកកអនាម័យ និងចំណីអាហារ) អនុលោមតាមគុណភាពស្តង់ដារបានកំណត់
- បានចេញសេចក្តីសម្រេចបង្កើតសហគ្រាស/សិប្បកម្ម (ថ្មី) ចំនួន៨មូលដ្ឋាន និងវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ (បន្ត)ចំនួន១មូលដ្ឋាន ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ (បន្ត) ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ ជូនម្ចាស់សហគ្រាស/សិប្បកម្ម បានចំនួន១៣មូលដ្ឋាន
- បានចេញវិញ្ញាបនបត្រផ្លាស់ប្តូរឈ្មោះម្ចាស់សិប្បកម្ម បានចំនួន១មូលដ្ឋាន
- បានចេញលិខិតបញ្ជាក់លើការស្នើសុំពង្រីកមុខផលិតផល បានចំនួន១មូលដ្ឋាន ។

## ២.១.៨-ការងាររ៉ែ និងថាមពល

- បានចុះណែនាំដល់ក្រុមហ៊ុន ដែលមានច្បាប់អនុញ្ញាតធ្វើអាជីវកម្មកាយ និងដឹកជញ្ជូនអាចម៍ដី ដើម្បីស្ថាបនាផ្លូវជាតិលេខ៤៨ ចាប់ពីចំណុចស្រុកស្រែអំបិល រហូតដល់ឃុំត្រពាំងរូង ស្រុកកោះកុង ចំនួន១២លើក ជាលទ្ធផលក្រុមហ៊ុនបានអនុវត្តតាមនីតិវិធីបច្ចេកទេសត្រឹមត្រូវ
- បានចូលរួមជាមួយរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ ចុះពិនិត្យទីតាំងចាក់បំពេញអាចម៍ដី ចំនួន៩លើក រួមមាន នៅស្រុកស្រែអំបិលចំនួន៣លើក ស្រុកមណ្ឌលសីមាចំនួន២លើក និងក្រុងខេមរភូមិន្ទចំនួន៤លើក
- បានចុះពិនិត្យទីតាំងបោះបង្គោលព្រំ និងដាក់ពោងនៅដងព្រែកនានាតាមការដ្ឋានបូមខ្សាច់របស់ក្រុមហ៊ុនឱ្យអនុវត្តតាមលក្ខណៈបច្ចេកទេសបានចំនួន១៣លើក
- បានផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់-អាចម៍ដី) ចំនួន១៥មូលដ្ឋាន។
- អាជីវកម្មធនធានរ៉ែ មានច្បាប់អនុញ្ញាតសរុបចំនួន២៤មូលដ្ឋាន ក្នុងនោះរួមមាន៖
  - ក្រសួងអនុញ្ញាតមានចំនួន៤អាជ្ញាប័ណ្ណ
  - រដ្ឋបាលខេត្តអនុញ្ញាតមានចំនួន១៤អាជ្ញាប័ណ្ណ
  - រដ្ឋបាលស្រុកអនុញ្ញាតមានចំនួន៦អាជ្ញាប័ណ្ណ
- បានចូលរួមសហការជាមួយបុគ្គលិកស្នាក់ការអគ្គិសនីកោះកុង ដាក់ត្រង់ហ្វ៉ូរ និងចុះពិនិត្យខ្សែបណ្តាញអគ្គិសនីដើម្បីរៀបចំឱ្យមានសោភណ្ឌភាព និងរបៀបរៀបរយនៅ ក្រុងខេមរភូមិន្ទ ចំនួន១២លើក
- បានទទួលពិនិត្យ និងឯកភាពលើពាក្យស្នើសុំដាក់បណ្តាញអគ្គិសនីរបស់ប្រជាពលរដ្ឋ រួមមាន៖
  - ប្រពលរដ្ឋនៅភូមិនាងកុក និងភូមិវង់កាថាក់ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ប្រជាពលរដ្ឋនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង និងនៅភូមិ២ ភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ បានបញ្ជូនទៅស្នាក់ការអគ្គិសនីកោះកុង ពិនិត្យសម្រេច
- បានចុះត្រួតពិនិត្យ ណែនាំ និងផ្សព្វផ្សាយថ្លៃប្រេងឥន្ធនៈលក់រាយដល់អាជីវករស្ថានីយប្រេងទាំងអស់ក្នុងខេត្តឱ្យលក់តាមសេចក្តីជូនដំណឹង របស់ក្រសួងពាណិជ្ជកម្ម
- បានចុះពិនិត្យ និងណែនាំដល់ម្ចាស់ស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ ក្នុងកិច្ចការពារហានិភ័យ ផ្សេងៗដែលកើតឡើងជាថាហេតុ នៅតាមបណ្តាក្រុង/ស្រុក ចំនួន១៥លើក
- បានចូលរួមសហការជាមួយក្រុមការងារជំនាញរបស់អគ្គនាយកដ្ឋានប្រេងកាតចុះពិនិត្យ និងកែសម្រួលលក្ខណៈបច្ចេកទេសតាមស្ថានីយប្រេងឥន្ធនៈនៅតាមបណ្តាស្រុក/ក្រុង ចំនួន១៣លើក
- បានទទួលពាក្យស្នើសុំអនុញ្ញាតបន្តសុពលភាពស្ថានីយប្រេងជូនអាជីវករចំនួន៩មូលដ្ឋាន
- ស្ថានីយប្រេងឥន្ធនៈក្នុងខេត្ត មានចំនួន៤៥ស្ថានីយ ក្នុងនោះ មានច្បាប់ចំនួន៣៥ស្ថានីយ និងពុំមានច្បាប់ចំនួន១០ស្ថានីយលើទឹក (ពុំទាន់មានគោលការអនុញ្ញាតច្បាប់ពីក្រសួង)
- បានចុះពិនិត្យ និងវាយតម្លៃតាមការដ្ឋានធ្វើអាជីវកម្មបូមខ្សាច់សំណង់របស់អាជីវករ ដើម្បីកំណត់សួយសារធនធានរ៉ែបង់ចូលថវិការដ្ឋសម្រាប់ឆ្នាំ២០២៣ បានចំណូលចំនួន១៦២.៦៥៩,៩៩ដុល្លា
- ក្រុមហ៊ុន/សេវាករអគ្គិសនី ក្នុងខេត្តមានចំនួន១១មូលដ្ឋាន និងមានអ្នកប្រើប្រាស់ចំនួន២៦.៧៩៦កុងទ័រ
- វារីអគ្គិសនីក្នុងខេត្តមានចំនួន៤ទីតាំង រួមមាន៖
  - ស្ទឹងឫស្សីជ្រុំក្រោម មានអនុភាព៣៣៨មេហ្គាសវ៉ាត់
  - ស្ទឹងតាតៃ មានអនុភាព២៤៦មេហ្គាសវ៉ាត់
  - ស្ទឹងគីរីរម្យ៣ មានអនុភាព១៨មេហ្គាសវ៉ាត់
  - ស្ទឹងតាទៃលើ មានអនុភាព១៥០មេហ្គាសវ៉ាត់។

## ២.១.៦-ការងារពាណិជ្ជកម្ម

- បានផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម នៅមន្ទីរពាណិជ្ជកម្មខេត្តដល់ក្រុមហ៊ុន/សហគ្រាសចំនួន៦
- ប្រតិវេទន៍ពាណិជ្ជកម្មប្រចាំឆ្នាំចំនួន៥ក្រុមហ៊ុន
- បានចុះតាមដានស្រង់តម្លៃទំនិញសំខាន់ៗទាំង៣២មុខជារៀងរាល់ថ្ងៃ នៅក្នុងផ្សារដងទង់ ក្រុងខេមរភូមិន្ទ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលខេត្ត
- បានចុះចែកសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈចំនួន៣លើក តាមស្ថានីយ និងដេប៉ូលក់រាយ ប្រេងឥន្ធនៈ សរុបចំនួន២២ស្ថានីយ/ដេប៉ូ
- បានចុះតាមដានតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូលក់ប្រេងឥន្ធនៈរៀងរាល់ថ្ងៃ ក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា។ ជាលទ្ធផល បានពិនិត្យឃើញថា ម្ចាស់ស្ថានីយ/ដេប៉ូ មិនបានលក់លើសពីតម្លៃដែលក្រសួងបានកំណត់ឡើយ
- បានដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងបេក្ខជនឈរឈ្មោះចាប់ពីថ្ងៃទី២១ ខែកុម្ភៈ រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ នៅមន្ទីរពាណិជ្ជកម្មខេត្ត។ ជាលទ្ធផល អ្នកចុះឈ្មោះបោះឆ្នោតមានសរុបចំនួន២៩៤នាក់ ស្រី ១៨៤នាក់ និងបេក្ខជនឈរឈ្មោះសរុបចំនួន១១នាក់ ស្រី៣នាក់
- បានសហការជាមួយក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលខេត្តកោះកុង ដើម្បីរៀបចំការបោះឆ្នោត សភាពាណិជ្ជកម្មខេត្តកោះកុង អាណត្តិទី៣ លើកទី១ នៅសាលប្រជុំមន្ទីរពាណិជ្ជកម្មខេត្ត។ ជាលទ្ធផល បេក្ខជនដែលជាប់ជាសមាជិកជ្រើសតាំងអាណត្តិទី៣ លើកទី១មានចំនួន៨នាក់ ស្រី៣នាក់
- បានធ្វើការបោះឆ្នោតជ្រើសរើសប្រធានសភាពាណិជ្ជកម្មខេត្តកោះកុងសម្រាប់អាណត្តិទី៣ លើកទី១ ដោយបានជាប់ លោក ចាង ជីវិញ ជាប្រធានក្នុងអាណត្តិថ្មី
- បានចូលរួមក្នុងព្រឹត្តិការណ៍ផ្គូផ្គងពាណិជ្ជកម្មរវាងសហគ្រិនដែលអញ្ជើញមកពីខេត្តត្រាត និងសហគ្រិនដែលអញ្ជើញមកពីខេត្តបាត់ដំបង និងខេត្តកោះកុង នៅខេត្តត្រាត ប្រទេសថៃ
- បានចុះសិក្សាពីផលិតផលដែលមានសក្តានុពលក្នុងខេត្ត រួមមាន ក្តាមថ្ម បង្គាក្រៀម គ្រុំចំពុះទា និងទឹកត្រីបុក កោះកុង នៅសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប ដើម្បីត្រៀមយកទៅចូលរួមការ ដាក់តាំងបង្ហាញ ក្នុងកម្មវិធីទិវាកម្មសិទ្ធិបញ្ញាពិភពលោក និងព្រឹត្តិការណ៍ពិព័រណ៍″ ទេសចរណ៍ និងកីឡា″ នៅខេត្តព្រះសីហនុ
- បានចូលរួមបើកដំណើរការ និងតាំងផលិតផល មាន់ស្រែ បន្លែសុវត្ថិភាព និងស្រូវ-អង្ករប្រណិត នៅផ្សារចុងសប្តាហ៍នៃគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) ខេត្តតាកែវ និងខេត្តព្រៃវែង
- បានចុះពិនិត្យ និងសិក្សានៅសិប្បកម្មកែច្នៃគ្រុំចំពុះទា និងបង្គាក្រៀមវង្សតារា ស្ថិតនៅទីតាំង ភូមិបាងកាយ៉ាក ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ចំនួន២លើក
- បានចុះសិក្សាពីផលិតផលផលិតពីឫស្សី និងផ្តៅ នៅសហគមន៍តំបន់ការពារធនធានធម្មជាតិភ្នំទ័ពជាង ស្ថិតនៅក្នុងភូមិព្រះអង្គកែវ និងភូមិបាក់អង្រុត ឃុំជងពែង ស្រុកស្រែអំបិល ចំនួន១លើក
- បានចូលរួមពិធីសម្ពោធ និងនាំយកផលិតផលខេត្ត ចូលរួមតាំងពិព័រណ៍ផលិតផលខ្មែរ និងផលិតផលប្រើប្រាស់ទូទៅនៅខេត្តកំពង់ចាម ខេត្តព្រះវិហារ និងខេត្តសៀមរាប
- បានសហការជាមួយរដ្ឋបាលខេត្ត ដើម្បីរៀបចំពិព័រណ៍ដាក់តាំងបង្ហាញផលិតផលដែលមានសក្តានុពលក្នុងខេត្ត ចូលរួមកម្មវិធី ″កោះកុងសង្ក្រាន″ ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅមុខបរិវេណសាលាខេត្តកោះកុង
- បានចូលរួមការតាំងពិព័រណ៍ទេសចរណ៍ផ្លែឈើ និងផលិតផលភូមិ១ផលិតផល១ ខេត្តកោះកុង នៅមុខសាលាខេត្តកោះកុង

- បានសហការជាមួយរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ ចូលរួមពិធីពិព័រណ៍ផលិតផលខ្មែរ ក្នុងឱកាសនៃពិធីបុណ្យសមុទ្រលើកទី១០ ជុំទី៣ នៅក្រុងកែប ខេត្តកែប
- បានចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត(ក.ប.ប) ចុះត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ និងទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ចំនួន៤២លើក ក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា
- បានចុះតាមដានស្ថានភាពជួញដូរទំនិញ នៅតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមប្រចាំសប្ដាហ៍ ដើម្បីរាយការណ៍ជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម។

### ២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

#### ២.១.៧.១-ការងារហិរញ្ញវត្ថុ

- ចំណូលថវិកាពីមន្ទីរជំនាញ មានចំនួន ១.១៤៣.៦៥៥.៦០៧រៀល
- ចំណាយថវិការបស់មន្ទីរជំនាញ មានចំនួន ៦៥.៤៣៥.៦៤០.៨២២រៀល
- ចំណូលមិនមែនសារពើពន្ធ មានចំនួន ១៦៦.៩១០.៨៣៨រៀល
- ចំណូលថវិការបស់ក្រុង ស្រុក មានចំនួន ៩.៤៤៤.២៩១.៣១០រៀល
- ចំណាយថវិការបស់ក្រុង ស្រុក មានចំនួន ៧.៩០៩.៥៦០.៣៧៣រៀល
- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុតាមបណ្តាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ
- បានពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈជាប្រចាំ
- បានរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាប្រចាំ។

#### ២.១.៧.២-ការងារពន្ធដារ

- បានប្រមូលចំណូលពន្ធដើម្បីបែងចែកចូលថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន១៤.៣៨១.៦៣៥.៦៧១រៀល ស្មើនឹង១០៨,៤៤% នៃផែនការឆ្នាំ ក្នុងនោះ៖
  - ចំណូលបង់ចូលថវិកាថ្នាក់ជាតិមានចំនួន៤.៣២៧.១៧៩.៤៥៩រៀល ស្មើនឹង៩៣,៥៦% នៃផែនការឆ្នាំ
  - ចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិមានចំនួន១០.០៥៤.៤៥៦.២១២រៀល ស្មើនឹង១១៦,៤១% នៃផែនការឆ្នាំ។

#### ២.១.៧.៣-ការងារគយ និងរដ្ឋាករ

- សរុបចំណូលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី១៤ខែធ្នូ ឆ្នាំ២០២៣ មានចំនួន១៥៥.១៣៧.១១២.០០០រៀល ស្មើនឹង៩២,៩០% នៃផែនការប្រចាំឆ្នាំ ប្រៀបធៀបនឹង ឆ្នាំ២០២២ ១២០.០៨៦.៨៨៧.៣០០រៀល មានការកើនឡើង២៩,១៩%
- ការងារបង្ការ និងបង្ក្រាបបទល្មើសមានដូចខាងក្រោម៖
  - ទោចក្រយានយន្តចំនួន៨.៨០៣គ្រឿង
  - បន្ទះប្លាស្ទិកកែច្នៃជាថ្មម៉ាបសិប្បនិម្មិត (3,680mm x 760mm x 12mm) ចំនួន២៤០កេស
  - រថយន្តចង្កូតស្តាំចំនួន៧គ្រឿង
  - រថយន្តចង្កូតឆ្វេងចំនួន១៧គ្រឿង
  - ប្រេងឆា(1000ml*12btl) ចំនួន១១០០កេស
  - ទឹកត្រី(725ml*4btl) ចំនួន១៤០កេស

- មីកញ្ចប់(60g*6*30packs/ctn) ចំនួន៥០កេស
- ទឹកខ្មេះ (700ml*12glass bottle) ចំនួន១៥០កេស
- ទឹកប្រេងខ្យង(600ml*12glass bottle) ចំនួន៨០កេស
- ស៊ីម៉ងត៍ចំនួន៣២០បាវ
- ក្រដាសចំនួន១៥ដុំ
- កេសជ្ជៈចំនួន១៦១កេស
- នំសូកូឡាចំនួន២៥០កេស
- ម៉ូទ័រកាត់ចំនួន២៥កេស
- ម៉ាស៊ីនបូមទឹកចំនួន២៥គ្រឿង
- សៀវភៅសរសេរចំនួន១០០កេស។

– បានពង្រឹងការគ្រប់គ្រងឯកសារប្រតិវេទន៍គយ គ្រប់គ្រងការបិទតែមគយ និងត្រួតពិនិត្យទំនិញបានហ្មត់ចត់
– បានពង្រឹងការធ្វើប្រតិវេទន៍គយឱ្យបានសុក្រឹតតាមការណែនាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

## ២.១.៨-ការងារទេសចរណ៍

– បានផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តតាមរយៈសៀវភៅផ្នត់ គេហទំព័រ Mobile App (Visit Cambodia) និងហ្វេសប៊ុក ដល់ភ្ញៀវទេសចរ
– បានចុះស្រង់ទិន្នន័យស្ថិតិភ្ញៀវទេសចរមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត៖
  - ភ្ញៀវទេសចរជាតិស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៤៥០.៤៥៦នាក់ កើនឡើង ២០.៤១៤នាក់ ស្មើនឹង៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
  - ភ្ញៀវទេសចរបរទេសស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន១០.៣៦២នាក់ កើនឡើង ៤.៩០១នាក់ ស្មើនឹង៨៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
  - ➢ សរុបភ្ញៀវទេសចរជាតិ និងបរទេសចំនួន៤៦០.៨១៨នាក់ កើនឡើង២៤.៩១៥នាក់ ស្មើនឹង៥%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
– ភ្ញៀវទេសចរមកកម្សាន្តតាមសហគមន៍៖
  - ភ្ញៀវទេសចរជាតិ មានចំនួន១៣៩.០៧២នាក់ ថយចុះ៣.១៦៩នាក់ ស្មើនឹង២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
  - ភ្ញៀវទេសចរបរទេស មានចំនួន៤.៨០០នាក់ កើនឡើង១.៧៨១នាក់ ស្មើនឹង៥៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
  - ➢ សរុបភ្ញៀវទេសចរជាតិ និងបរទេស ចំនួន១៤៣.៨៧២នាក់ ថយចុះ១.៣៨៨នាក់ ស្មើនឹង១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២
– បានផ្តល់អាជ្ញាប័ណ្ណជូនអាជីវកម្ម ចំនួន២២១កន្លែង តាមរយៈក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ខេត្ត អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុងស្រុក ក្នុងនោះមាន ៖
  - ក្រសួងទេសចរណ៍ ចំនួន៩កន្លែង (បន្ត៨ និងថ្មី១)
  - អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត៖ អាជ្ញាប័ណ្ណបន្តចំនួន៤៣ និងថ្មីចំនួន៥
  - ការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ៖ អាជ្ញាប័ណ្ណបន្តចំនួន២៦ និងថ្មីចំនួន៥
  - ការិយាល័យច្រកចេញចូលតែមួយស្រុកស្រែអំបិល៖ អាជ្ញាប័ណ្ណបន្តចំនួន២៤ និងថ្មីចំនួន១២
  - ការិយាល័យច្រកចេញចូលតែមួយស្រុកមណ្ឌលសីមា៖ អាជ្ញាប័ណ្ណបន្តចំនួន១៨ និងថ្មីចំនួន១១

- ការិយាល័យច្រកចេញចូលតែមួយស្រុកថ្មបាំង៖ អាជ្ញាប័ណ្ណបន្តចំនួន១ និងថ្មីចំនួន៣
- ការិយាល័យច្រកចេញចូលតែមួយស្រុកបូទុមសាគរ៖អាជ្ញាប័ណ្ណបន្តចំនួន៧ និងថ្មីចំនួន១៤
- ការិយាល័យច្រកចេញចូលតែមួយស្រុកគិរីសាគរ៖ អាជ្ញាប័ណ្ណបន្តចំនួន២៦ និងថ្មីចំនួន៩
- ការិយាល័យច្រកចេញចូលតែមួយស្រុកកោះកុង៖ អាជ្ញាប័ណ្ណបន្តចំនួន៣ និងថ្មីចំនួន៦

- បានផលិតសម្ភារសម្រាប់ផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្នុងខេត្ត ដែលមានដូចជា វីដេអូ ប័ណ្ណផ្ទត់ព័ត៌មានទេសចរណ៍ និងសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍
- បានសហការជាមួយរដ្ឋបាលស្រុកគិរីសាគរ ចុះសាកសួរព័ត៌មានអាជីវកម្ម អាហារដ្ឋាន ដែលមានភ្ញៀវទេសចរបានផុសក្នុងបណ្តាញសង្គម Facebook ថាបានគិតថ្លៃសេវាកម្មថ្លៃហួសហេតុ។ ក្រោយការសម្របសម្រួល ភាគីខាងភ្ញៀវក៏បានលុបការផុសវិញ
- បានសហការចូលរួមជាមួយរដ្ឋបាលស្រុកគិរីសាគរ និងឃុំភ្ញីមាស ដើម្បីរៀបចំនិតិវិធីក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍ទេសចរណ៍ធម្មជាតិឃុំភ្ញីមាស
- បានសហការជាមួយរដ្ឋបាលខេត្ត និងអង្គភាពអនុវត្តគម្រោងក្រសួងទេសចរណ៍ បើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការជំរុញវិនិយោគ និងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ" នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្ត
- បានសហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត រដ្ឋបាលស្រុកស្រែអំបិល រដ្ឋបាលឃុំដងពែង និងរដ្ឋបាលឃុំជ្រោយស្វាយ ចុះប្រមូលទិន្នន័យសហគមន៍បម្រើសេវាកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ បូជនីយដ្ឋាន និងកន្លែងទីសក្ការៈបូជា និងរៀបចំជាលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ បានចំនួន១៥កន្លែង
- បានចូលរួមរៀបចំការដាក់តាំងពិព័រណ៍ ផ្សព្វផ្សាយតំបន់ទេសចរណ៍ និងផលិតផលទេសចរណ៍ថ្មីៗ ក្នុងខេត្តកោះកុង ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅគល់ស្ពានស្រែអំបិល
- បានបោះពុម្ពខិត្តប័ណ្ណរូបភាព និងផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹងអំពីអនាម័យបរិស្ថាន ការទុកដាក់សំរាមឱ្យបានត្រឹមត្រូវដើម្បីលើកកម្ពស់សោភណ្ឌភាពខេត្ត
- បានសហការរៀបចំទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ២០២៣ ក្រោមប្រធានបទ "ទីក្រុងស្អាត បដិសណ្ឋារកិច្ចល្អ ម្ចាស់ផ្ទះផ្តល់ភាពកក់ក្តៅ" នៅសួនច្បារទល់មុខវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែនកោះកុង ដែលមានអ្នកចូលរួមសរុបប្រមាណ២០០នាក់
- បានចុះផ្សព្វផ្សាយតំបន់គោលដៅទេសចរណ៍ តាមរយៈប័ណ្ណផ្ទត់ព័ត៌មានទេសចរណ៍ និងសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ និងបានបិទខិត្តប័ណ្ណអប់រំអនាម័យបរិស្ថាន ស្តីពីការទុកដាក់សំរាមឱ្យបានត្រឹមត្រូវជូនដល់អាជីវកម្មទេសចរណ៍ ចំនួន១១ទីតាំង
- បានសហការរៀបចំកម្មវិធី "ទិវាពិភពលោកស្អាតលើកទី៦ ឆ្នាំ២០២៣ The 6th World Cleanup Day 2023" មានអ្នកចូលរួមប្រមាណ ៣០០នាក់ នៅទីធ្លាសួនច្បារទល់មុខវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែនកោះកុង
- បានសហការរៀបចំកម្មវិធី អបអរសាទរទិវាទេសចរណ៍ពិភពលោកឆ្នាំ២០២៣ ក្រោមប្រធានបទ "ទេសចរណ៍ និងការវិនិយោគបៃតង Tourism and Green Investment" នៅសួនច្បារទល់មុខសាលាខេត្តកោះកុង ដែលមានអ្នកចូលរួមប្រមាណ២៣០នាក់
- បានបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី បដិសណ្ឋារកិច្ច និងទេសចរណ៍ស្របតាមបទដ្ឋានទេសចរណ៍អាស៊ាន លើជំនាញគេហកិច្ច និងការបញ្ជ្រាបយេនឌ័រ លើកកម្ពស់ស្ត្រី ក្នុងវិស័យទេសចរណ៍ ចំនួន៣លើក

- បានចុះស្រង់ទិន្នន័យ និងស្ថិតិអាជីវកម្ម សេវាកម្ម ចំនួនភ្ញៀវទេសចរ និងផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការប្រឡងប្រណាំងទូកខ្សាច់កម្សាន្តស្អាតលើកទី៤ និងព្រែកកម្សាន្តស្អាតលើកទី១ ឆ្នាំ២០២៣ ដើម្បីត្រៀមចូលរួមចលនាប្រឡងប្រណាំង តាមបណ្តាក្រុង ស្រុក ក្នុងខេត្ត
- បានចុះដាក់ស្លាក "ក្រមប្រតិបត្តិឆ្នេរសមុទ្រកម្ពុជា" ចំនួន២ផ្ទាំង នៅមណីយដ្ឋានឆ្នេរប៉ាក់ខ្លង ស្ថិតក្នុងភូមិប៉ាក់ខ្លង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានចូលរួមរៀបចំស្តង់ពិព័រណ៍ និងអបអរពិធីបុណ្យសមុទ្រលើកទី១០ ជុំទី៣ ឆ្នាំ២០២៣ នៅខេត្តកែប។

## ២.១.៩-ការងារផែនការ

- បានប្រមូល និងបញ្ចូលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅផ្សារដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ប្រចាំខែក្នុងឆ្នាំ២០២៣ រួចរាល់១០០%
- បានផលិតឯកសារព័ត៌មានស្ថានភាពខេត្ត ក្រុង-ស្រុក ឃុំ-សង្កាត់រួចរាល់១០០%
- បានផលិតឯកសារស្ថានភាពពិន្ទុវិស័យខេត្ត និងស្រុក ក្រុងរួចរាល់១០០%
- បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការប្រមូល និងកត់ត្រាទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣
- បានចុះសម្ភាសន៍ប្រមូលទិន្នន័យជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២ ជាលទ្ធផល គ្រួសារកសិកម្មមានចំនួន ៤៥% ក្នុងនោះមានៈ
    - ចំនួនគ្រួសារ ក្នុងឃុំ/សង្កាត៣៣.០៣៤គ្រួសារ
    - ចំនួនគ្រួសារចុះបញ្ជី៣២.៤៦៧គ្រួសារ
    - ចំនួនគ្រួសារកសិកម្ម១៤.២៨៧គ្រួសារ
    - ចំគ្រួសារចំណាស្រុក៣០៨គ្រួសារ
- បានផលិតប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រ ចំនួន១២ប័ណ្ណ ក្នុងនោះមាន ស្រុកស្រែអំបិលចំនួន៣ប័ណ្ណ ស្រុកកោះកុងចំនួន៣ប័ណ្ណ ស្រុកថ្មបាំងចំនួន៤ប័ណ្ណ ស្រុកគិរីសាគរចំនួន១ប័ណ្ណ ស្រុកបូទុមសាគរចំនួន១ប័ណ្ណ
- បានកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ ចំនួន២៩៤គ្រួសារ ក្នុងនោះៈ ស្រុកបូទុមសាគរ ចំនួន៥៥គ្រួសារ ស្រុកគិរីសាគរ ចំនួន២៥គ្រួសារ ស្រុកកោះកុង ចំនួន១៥គ្រួសារ ក្រុងខេមរភូមិន្ទ ចំនួន៨២គ្រួសារ ស្រុកមណ្ឌលសីមា ចំនួន៨៩គ្រួសារ ស្រុកស្រែអំបិល ចំនួន២០គ្រួសារ និងស្រុកថ្មបាំង ចំនួន៨គ្រួសារ
- បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ចុះប្រមូលនិងកត់ត្រាទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣ ចំនួន៤ភូមិនៅខេត្តកោះកុង ២ភូមិនៅខេត្តព្រះសីហនុ និង៤ភូមិ នៅខេត្តកំពត
- បានចុះតាមដានត្រួតពិនិត្យ និងសម្ភាសន៍គ្រួសារក្រីក្រ
    - ស្រុកមណ្ឌលសីមា៥គ្រួសារ
    - ស្រុកស្រែអំបិល១០គ្រួសារ
    - ស្រុកគិរីសាគរ៥គ្រួសារ
    - ស្រុកកោះកុង១០គ្រួសារ។

## ២.១.១០-ការងារផ្សេងៗ

### ២.១.១០.១-ការងារសាខាធនាជាតិនៃកម្ពុជា

- ចំណូលជាប្រាក់រៀលសរុបចំនួន៨៣.១៥១.៦៩៤.៣២២រៀល បើប្រៀបធៀបទៅនឹងឆ្នាំមុនកើន២៥,១៨%
- ចំណូលជាប្រាក់ដុល្លារសរុបចំនួន១០៤.៤៨៣.០៩១ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំមុនកើន៣៧,៣៦%
- ចំណាយជាប្រាក់រៀលសរុបចំនួន១៤៤.២០៤.២០៦.៣២២រៀល បើប្រៀបធៀបទៅនឹងនាំមុនកើន១,០៧%

- ចំណាយជាប្រាក់ដុល្លារចំនួន៧.៧៧០.០០០ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំមុនថយចុះ៧៨,៣៧%
- ប្តូរប្រាក់រៀល ចាស់ រហែក ទក់ សរុបចំនួន១៨.៨២៣.៦០០.០០០រៀល
- បានផ្តល់លិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពដើមគ្រាសរុបចំនួន៥៧ច្បាប់
- បានផ្តល់លិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់អស់សុពលភាពសរុបចំនួន៥៧ច្បាប់
- បានផ្តល់លិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់បន្តសុពលភាពដើមគ្រាសរុបចំនួន៥២ច្បាប់
- បានផ្តល់លិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពចុងគ្រាសរុបចំនួន៥២ច្បាប់។

## ២.១.១០.២-ការងាររតនាគារ

- បានពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS ជូនមន្ត្រីជំនាញជាបន្តបន្ទាប់
- បានពង្រឹងការអនុវត្តការកត់ត្រាចំណូលចំណាយតាមប្រព័ន្ធ FMIS ជូនមន្ត្រីបានកាន់តែប្រសើរ
- បានពង្រឹងការអនុវត្តសារាចរណែនាំស្តីពីការអនុវត្តនីតិវិធីបើកផ្តល់ប្រាក់បៀវត្សរ៍រាល់២សប្តាហ៍ម្តង ក្នុងខែនីមួយៗ ជូនមន្ត្រីរាជការបានទាន់ពេលវេលា
- បានពង្រឹងការទូទាត់ចំណាយដែលមានហានិភ័យទាបតាមទម្រង់នីតិវិធីថ្មីក្នុងប្រព័ន្ធFMIS
- បានពង្រឹងការណែនាំមន្ត្រីជំនាញទទួលបន្ទុកពិនិត្យការអនុវត្តចំណាយថវិកា ស្តីពីលិខិតបទដ្ឋានគតិយុត្តដែល
- បានធ្វើបច្ចុប្បន្នភាពថ្មីៗ ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ និងលិខិតគតិយុត្តការចំណាយដើម្បីទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា និងបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ
- បានសហការជាមួយអង្គភាពក្នុងការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនិងការអនុវត្តចំណាយថវិកាជាពិសេសលើការអនុវត្តរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី
- បានពង្រឹងការអនុវត្តប្រព័ន្ធទូទាត់អេឡិចត្រូនិច( E-Fund Transfer)
- បានពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal)ជូនដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ឱ្យកាន់តែប្រសើរ
- ចំណូលសរុបមានចំនួន២៩៤.៤៦៧លានរៀល ក្នុងនោះ៖
  - ចំណូលពីអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន១០៦.៨០៥លានរៀល
  - ចំណូលមូលដ្ឋានមានចំនួន១៨៧.៦៦២លានរៀល
- ចំណាយសរុបមានចំនួន២៩៩.៣០១លានរៀល ក្នុងនោះ៖
  - ផ្ទេរទៅអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន១៨៥.៣៨១លានរៀល
  - ចំណាយមូលដ្ឋានមានចំនួន១១៣.៩២០លានរៀល។

## ២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បានចុះត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារនៅតាមបណ្តារទីផ្សារហាងទំនិញ និងម៉ាតបានចំនួន៦៨លើក ក្នុងនោះ ទីផ្សារចំនួន១៦លើក ហាងទំនិញ និងម៉ាត៤៧លើក និងអប់រំតាមសាលារៀន និងផ្សារ៥លើក ដោយបាន៖
  - ដកហូតទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ រួមមាន គ្រឿងឧបភោគបរិភោគ និងភេសជ្ជៈចម្រុះស្មើនឹង ៣.៤៣៦,៦គ.ក្រ
  - ធ្វើតេស្តគំរូសរុបចំនួន១៥១គំរូ ដែលក្នុងនោះ ៣០គំរូ មិនមានអនុលោមភាព
  - ធ្វើតេស្តបឋមដើម្បីរកសារធាតុគីមីហាមឃាត់(Formalin)សរុប៣៧គំរូ ជាលទ្ធផល អវត្តមានសារធាតុ Formalin
  - ធ្វើតេស្តបឋមដើម្បីរកសារធាតុគីមីហាមឃាត់(Borax) សរុប៥៩គំរូ ជាលទ្ធផល អវត្ត៣៣គំរូ និង២៦គំរូ មានពពុះសណ្តែក និងបបែលស្នូតមានផ្ទុកសារធាតុបូរ៉ាក់

- ធ្វើតេស្តបឋមដើម្បីរកសារធាតុគីមីហាមឃាត់(Sodium Hydrosulfite) សរុប៤០គំរូ ជាលទ្ធផលអវត្តមាន
- ធ្វើតេស្តអំបិលអ៊ីយ៉ូដ៨គំរូ ជាលទ្ធផល មានវត្តមានអ៊ីយ៉ូដ
- ធ្វើតេស្តអំបិលអ៊ីយ៉ូដ ៧គំរូ ជាលទ្ធផល មាន៤គំរូ មានអ៊ីយ៉ូដមិនអនុលោមតាមស្តង់ដារកំណត់
- ធ្វើកិច្ចសន្យាបញ្ឈប់ការតាំងលក់ផលិតផលបំពានសិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន ខេមបូឌា បេវើរេជ ខមប៉ានី លីមីតធីតបានចំនួន១៦ទីតាំង

- ប្រាក់ចំណូល បានមកពីការពិន័យអន្តរការណ៍ប្រចាំឆ្នាំ២០២៣ មានចំនួន២៣ករណី ដែលមានទឹកប្រាក់សរុប ១៣.៦០០.០០០៛ ក្នុងនោះ បានមកពីពិន័យអន្តរការណ៍ភាពមិនអនុលោមនឹងគុណភាពលើផលិតផលទំនិញ ចំនួន១០.១០០.០០០៛
- បានចុះអង្កេតតម្លៃលក់រាយប្រេងឥន្ធនៈនៅតាមបណ្តាស្ថានីយ/ដេប៉ូបានចំនួន២១លើក ស្មើនឹង១៥០ស្ថានីយ/ដេប៉ូ ក្នុងនោះ ស្ថានីយ/ដេប៉ូចំនួន៣៥ បានលក់តាមតម្លៃត្រឹមត្រូវ និងចំនួន១១៥លក់តម្លៃទាបជាងសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម
- បានចុះប្រតិបត្តការត្រួតពិនិត្យជាក់ស្តែងនៅតាមបណ្តាស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈបានចំនួន២០ស្ថានីយ/ដេប៉ូ ជាលទ្ធផល មានអនុលោមភាព១៨ស្ថានីយ/ដេប៉ូ និងមិនមានអនុលោមភាពចំនួន២ស្ថានីយ/ដេប៉ូ
- បានចុះអប់រំផ្សព្វផ្សាយអំពីសុវត្ថិភាពម្ហូបអាហារដល់សិស្សតាមសាលារៀនចំនួន៤លើក ដែលមានសិស្សសរុប ចំនួន៤៣០នាក់
- បានចែកសេចក្តីជូនដំណឹង១០២០ ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទចំនួន៧៧ច្បាប់
- បានពន្យល់ និងចែកប្រកាសលេខ២១៦ ស្តីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទចំនួន៨០ ច្បាប់
- បានពន្យល់ និងចែកប្រកាសលេខ០០៦៤ ស្តីពីលក្ខខណ្ឌតម្រូវលើការចែកចាយគ្រឿងសម្អាងចំនួន៨៩ច្បាប់
- បានពន្យល់ និងចែកប្រកាសលេខ ១៨៥ ស្តីពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ចំនួន៩៩ច្បាប់
- បានពន្យល់ និងចែកប្រកាសអន្តរក្រសួងលេខ៣៣៨ ស្តីពីនីតិវិធីពិន័យអន្តរការណ៍លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ចំនួន១០៤ច្បាប់
- បានបិទ និងចែកផ្ទាំងរូបភាពផ្សព្វផ្សាយពីសុវត្ថិភាពម្ហូបអាហារបានចំនួន៥០២ផ្ទាំង។

## ២.២-ផ្នែកសង្គមកិច្ច

### ២.២.១-ការងារអប់រំ យុវជន និងកីឡា

- បានសហការ និងរៀបចំពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៣-២០២៤
- បានរៀបចំបញ្ជីដកបេក្ខភាព ពីបញ្ជីពិន្ទុប្រឡងឆមាសទី២ និងប្រចាំឆ្នាំ សិស្សថ្នាក់ទី១២ តាមវិទ្យាល័យ និងសិស្សស្វែរិន បញ្ជូនទៅនាយកដ្ឋានកិច្ចការប្រឡង
- បានបើកវគ្គបំប៉នដល់សិស្សានុសិស្សដែលត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០២២-២០២៣ នៃវិទ្យាល័យទាំង១២ សិស្សសរុបចំនួន៩៤៣នាក់ ស្រី៤៩៧នាក់
- បានសហការជាមួយមន្ទីរអង្គភាពពាក់ព័ន្ធ រៀបចំការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីចំណាត់ថ្នាក់លេខ១ ប្រចាំថ្នាក់ខេត្ត លើវិញ្ញាសាតែងនិពន្ធ និងសូត្រកំណាព្យ ក្រោមប្រធានបទ«គ្រូបង្រៀនជាសសរស្តម្ភនៃកំណែទម្រង់សាលារៀនឆ្ពោះទៅរកឧត្តមភាព» ដោយទទួលបានបេក្ខជនជាប់ជ័យលាភី ចំនួន២រូប និងបន្តចូលរួមប្រឡងប្រណាំងជ្រើសរើសជ័យលាភីនៅថ្នាក់ជាតិ
- បានដឹកនាំក្រុមកីឡាករចូលរួមការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ នៅរាជធានីភ្នំពេញ ដោយទទួលបានមេដាយ សរុបចំនួន៥គ្រឿង មេដាយមាស២គ្រឿង មេដាយប្រាក់១គ្រឿង និងមេដាយសំរឹទ្ធ២គ្រឿង

- បានដឹកនាំក្រុមកីឡាករចូលរួមប្រកួតកីឡាសិស្សបឋមសិក្សា សិស្សមធ្យមថ្នាក់ជាតិឆ្នាំ២០២៣ ចំនួន២លើក
- បានរៀបចំការប្រកួតកីឡាបាល់ទាត់សិស្សបឋមសិក្សា សិស្សមធ្យមសិក្សា និងការប្រកួតកីឡាបាល់ទាត់មហាជនជ្រើសរើសជើងឯកថ្នាក់ខេត្ត
- បានសហការចូលរួមជាមួយអាជ្ញាធរពាក់ព័ន្ធរៀបចំទិវាអក្ខរកម្មជាតិ ០៨ កញ្ញា លើកទី២៣ ក្រោមប្រធានបទ « អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃសហគ្រិនភាព និងសង្គមសេដ្ឋកិច្ច»
- បានចុះរៀបចំធ្វើថ្នាក់និទស្សន៍ និងផលិតវីដេអូ នៅកម្រិតថ្នាក់ទី៨ ទី៩ និងទី១២ លំនាំនៃការបង្រៀន សម្រាប់ upload ចូលក្នុង Link នាយកដ្ឋានធានាគុណភាពអប់រំ ចំនួន១លើក
- បានប្រជុំការងារបច្ចេកទេសពាក់ព័ន្ធការងារការិយាល័យជំនាញទាំង១០ ចំនួន២១លើក
- បានចុះពិនិត្យតាមដាន និងជួយនាយក និងគ្រូ លើការងារបច្ចេកទេសផ្សេងៗ ចំនួន១៩លើក
- ការចុះអធិការកិច្ចតាមកាលកំណត់ ចំនួន៦លើក និងបើកវគ្គបណ្តុះបណ្តាល ដល់លោកនាយក លោកគ្រូ អ្នកគ្រូ ចំនួន៥លើក
- បានជ្រើសរើសបេក្ខភាពចូលរួមវគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ៤ក្រេឌីត បានចំនួន១៦នាក់ ស្រី៩នាក់ សម្រាប់ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានរៀបចំបញ្ជីឈ្មោះគ្រូបង្រៀនថ្នាក់ទី២ ចូលរួមវគ្គបណ្តុះបណ្តាលកញ្ចប់អំណានថ្នាក់ទី២ លើកទី១សរុប១៥១ នាក់ ស្រី៨០នាក់
- បានសហការជាមួយក្រុមការងារតំណាងស្ថានទូតជប៉ុន ក្រុមការងារសហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលា ចុះពិនិត្យវាយតម្លៃគម្រោង គូសាណូនិ របស់ស្ថានទូតជប៉ុន កំពុងសាងសង់បានរួចរាល់បាន៨០% នៅអនុវិទ្យាល័យតានី ក្នុងស្រុកស្រែអំបិល
- បានបង្ហាត់ជាប្រចាំដល់ក្រុមកីឡាបាល់ទាត់បុរសអាយុក្រោម១៨ឆ្នាំ និងនារីអាយុក្រោម១៥ឆ្នាំ
- បានសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងសិក្សាលើដី២ទីតាំង សម្រាប់សាងសង់មជ្ឈមណ្ឌលមត្តេយ្យសិក្សាសហគមន៍ នៅភូមិគគីរជ្រុំ ឃុំឫស្សីជ្រុំ និងភូមិកោះ ឃុំថ្មដូនពៅ ក្នុងស្រុកថ្មបាំង
- បានចូលរួម និងដឹកនាំគណៈកម្មការ សិស្សានុសិស្ស ដើម្បីប្រកួតប្រជែងភាសាអង់គ្លេស ក្នុងកម្មវិធីខ្រសវ៉ឺដហ្គេម នៅសាលារៀនខ្លងយ៉ៃវិទ្យាគម នៃព្រះរាជាណាចក្រថៃឡង់ដ៏
- បានដឹកនាំក្រុមកីឡាករទូកនាគ ទូកប្រពៃណី ចូលរួមប្រកួតពានរង្វាន់ សម្តេចក្រឡាហោម ស ខេង លើកទី១០ នៅខេត្តបាត់ដំបង
- បានដឹកនាំកាយរឹទ្ធិប្អូនចូលរួមកម្មវិធីបោះជំរំ ថ្នាក់ជាតិលើកទី១ ក្រោមប្រធានបទ«កុមារសតវត្សទី២១» នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល់ ខេត្តកំពង់ធំ និងចូលរួមកម្មវិធីបោះជំរំមេដឹកនាំកាយរឹទ្ធលើកទី២ ក្រោមប្រធានបទ "អ្នកនាំសារសន្តិភាព ដើម្បីសហគមន៍ខ្ញុំ" នៅខេត្តព្រះសីហនុ
- បានដឹកនាំសិស្សពូកែថ្នាក់ខេត្តចូលរួមការប្រកួតប្រជែងសិស្សពូកែទូទាំងប្រទេស លើមុខវិជ្ជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងទី១២ នៅខេត្តបាត់ដំបង
- បានសម្របសម្រួលដឹកនាំសិស្សឆ្នើមនិទ្ទេសA ចំនួន៥រូប ដែលបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០២១-២០២២ និងនាយកសាលាចំនួន៤រូប ទៅចូលរួមក្នុងពិធីសំណេះសំណាល និងទទួលអំណោយពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងម្នាក់ៗនូវថវិកា ២.០០០.០០០រៀល និងនាយកគ្រឹះស្ថានមធ្យមសិក្សាចំនួន៤រូប ក្នុងម្នាក់ៗថវិកា១.០០០.០០០រៀល និងសាលារៀបចំនួន៤ ក្នុង១សាលាចំនួន៣.០០០.០០០រៀល

- បានសហការជាមួយមន្ទីរមុខងារសាធារណៈខេត្ត និងរដ្ឋបាលក្រុង/ស្រុក រៀបចំក្រុមការងារចុះជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ តាមគ្រឹះស្ថានសិក្សាដែលមានតម្រូវការ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ ដោយទទួលបានគ្រូជាប់កិច្ចសន្យាចំនួន២៦នាក់
- បានចុះសម្របសម្រួលដោះស្រាយបញ្ហាកង្វះគ្រូបង្រៀននៅអនុវិទ្យាល័យថ្មដូនពៅ ក្នុងស្រុកថ្មបាំង និងបានសម្របសម្រួលលោកគ្រូ អ្នកគ្រូ ក្នុងមូលដ្ឋានចំនួន៤នាក់ ស្រី២នាក់ មកជួយបង្រៀនលើមុខវិជ្ជាដែលកំពុងខ្វះគ្រូឯកទេស
- បានទទួលសម្ភារព័ត៌មានវិទ្យា ពីក្រសួងអប់រំ យុវជន និងកីឡាសម្រាប់បែងចែកជូនដល់សាលាគោលដៅអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ(GEIP)ក្នុងនោះមានសាលាបឋមសិក្សាចំនួន២១ ទទួលសម្ភារចំនួន៣មុខក្នុង១សាលាមានដូចជាៈកុំព្យូទ័រយួរដៃ១គ្រឿង ម៉ាស៊ីនព្រីន១គ្រឿង និងម៉ាស៊ីនLCD Projector ១គ្រឿង
- បានសម្របសម្រួលដឹកនាំសិស្សឆ្នើមនិទ្ទេសA ចំនួន៩រូប ដែលបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០២១-២០២២ ចូលរួមក្នុងពិធីសំណេះសំណាល និងទទួលអំណោយពីលោកជំទាវអភិបាល នៃគណៈអភិបាលខេត្តកោះកុង ដោយសិស្សម្នាក់ៗទទួលបាននូវម៉ូតូចំនួន១គ្រឿង (អំណោយរបស់សម្តេចពិជ័យសេនា) កុំព្យូទ័រយួរដៃចំនួន១គ្រឿង ថវិកាចំនួន៤.០០០.០០០៛ និងលោកនាយកសាលា ក្នុងម្នាក់ៗទទួលបានថវិកា ១.០០០.០០០៛
- លទ្ធផលសិក្សារបស់សិស្ស ក្នុងកម្មវិធីពន្លឿនការសិក្សាដំណាច់ឆ្នាំសិក្សា២០២២-២០២៣ សរុបចំនួន៣២៦នាក់ ស្រី១៣០នាក់ ក្នុងនោះមានៈ
    - ជាប់មធ្យមភាគ ២៧៧នាក់ ស្រី១១៦នាក់
    - ធ្លាក់មធ្យមភាគ ៤៩នាក់ ស្រី១៤នាក់
    - បោះបង់ការសិក្សា ១៣នាក់ ស្រី៤នាក់។
- លទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សា ឆ្នាំសិក្សា២០២២-២០២៣ ដែលបានឆ្លងភូមិសិក្សាមានដូចខាងក្រោមៈ
    - សិស្សជាប់មធ្យមភាគ ១៥.១៥៩នាក់ ស្មើ៨៥,៥% ស្រី៧.៤៥៦នាក់ ស្មើ៨៨%
    - សិស្សធ្លាក់មធ្យមភាគ១.៨១៦នាក់ ស្មើ១០,២% ស្រី៦៩៣នាក់ ស្មើ៨,២%
    - សិស្សបោះបង់ការសិក្សា ៧៥៩នាក់ ស្មើ៤,៣% ស្រី៣១៩នាក់ ស្មើ៣,៨%។
- ស្ថិតិបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ សម័យប្រឡងៈ០២ តុលា ២០២៣

| **ចំនួនបន្ទប់** | **បេក្ខជនចុះឈ្មោះប្រឡង** | | **ចំនួនបេក្ខជនមកប្រឡង** | | **បេក្ខជនប្រឡងជាប់** | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ៨២ | ១.៦២៨ | ៨៦១ | ១.៦០០ | ៨៤៥ | ១.៤៨១ | ៨១៨ |

- បេក្ខជនប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ សម័យប្រឡងៈ២០ តុលា ២០២៣ នៅមណ្ឌលវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស តេជោសែន កោះកុង

| បរិយាយ | **ឆ្នាំទី១** | | **ឆ្នាំទី២** | | **ឆ្នាំទី៣** | | សរុប | ស្រី |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | |
| ជំនាញមេកានិច | ០ | ០ | ១ | ០ | ១៤ | ៣ | ១៥ | ៣ |
| ជំនាញអគ្គីសនី | ១៨ | ០ | ៧ | ២ | ៨ | ០ | ៣៣ | ២ |
| **សរុប** | **១៨** | **០** | **៨** | **២** | **២២** | **៣** | **៤៨** | **៥** |

- បានរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៦ វិច្ឆិកា ២០២៣ សម្រាប់ខេត្តកោះកុង មាន៣មណ្ឌលសំណេរ ក្នុងនោះ មានមណ្ឌលវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស តេជោសែន កោះកុង មណ្ឌលអនុវិទ្យាល័យជាស៊ីម ស្មាច់មានជ័យ និងមណ្ឌលសាលាបឋមសិក្សាទីរួមខេត្ត។ ជាលទ្ធផលៈ
  - **ថ្នាក់វិទ្យាសាស្ត្រ**
    - បេក្ខជនក្នុងបញ្ជី ចំនួន៤២៤នាក់ ស្រី២២៩នាក់
    - បេក្ខជនមកប្រឡង ចំនួន៤២២នាក់ ស្រី២២៨នាក់
    - បេក្ខជនប្រឡងជាប់ ចំនួន២៦០នាក់ ស្រី១៣០នាក់
    - បេក្ខជនទទួលបាននិទ្ទេសA ចំនួន៣នាក់ ស្រី២នាក់
    - បេក្ខជនទទួលបាននិទ្ទេសB ចំនួន៤២នាក់ ស្រី១៧នាក់
    - បេក្ខជនទទួលបាននិទ្ទេសC ចំនួន៧៥នាក់ ស្រី៣៣នាក់
    - បេក្ខជនទទួលបាននិទ្ទេសD ចំនួន៥៨នាក់ ស្រី៣២នាក់
    - បេក្ខជនទទួលបាននិទ្ទេសE ចំនួន៨២នាក់ ស្រី៤៦នាក់
    - បេក្ខជនទទួលបាននិទ្ទេសF ចំនួន១៦៤នាក់ ស្រី៩៩នាក់
  - **ថ្នាក់វិទ្យាសាស្ត្រសង្គម**
    - បេក្ខជនក្នុងបញ្ជី ចំនួន៨៣៣នាក់ ស្រី៤២៤នាក់
    - បេក្ខជនមកប្រឡង ចំនួន៧៩៥នាក់ ស្រី៤០៩នាក់
    - បេក្ខជនប្រឡងជាប់ ចំនួន៥៩១នាក់ ស្រី៣១៧នាក់
    - បេក្ខជនទទួលបាននិទ្ទេសA ចំនួន០០នាក់ ស្រី០០នាក់
    - បេក្ខជនទទួលបាននិទ្ទេសB ចំនួន៩នាក់ ស្រី៧នាក់
    - បេក្ខជនទទួលបាននិទ្ទេសC ចំនួន៧០នាក់ ស្រី៤៣នាក់
    - បេក្ខជនទទួលបាននិទ្ទេសD ចំនួន២១៤នាក់ ស្រី១១៦នាក់
    - បេក្ខជនទទួលបាននិទ្ទេសE ចំនួន២៩៨នាក់ ស្រី១៥១នាក់
    - បេក្ខជនទទួលបាននិទ្ទេសF ចំនួន២៤២នាក់ ស្រី១០៧នាក់

- សមិទ្ធផលសំខាន់ៗដែលទទួលបាន ក្នុងឆ្នាំ២០២៣

| បរិយាយ | ខ្នង | ជាន់ | បន្ទប់ | ប្រភេទ | សាងសង់ដោយ | ស្ថិតក្នុងស្រុក | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ទីលានកីឡាបាល់ទាត់ | | | | | ក្រសួង.អយក. | ខេមរភូមិន្ទ | វិ.ចបតេជោសែន កោះកុង |
| អគារសិក្សា | ១ | ១ | ៣ | ថ្មី | លោកឧកញ៉ា លឹម បុក | ស្រែអំបិល | បឋម.ប្រកាំ |
| អគារសិក្សា | ១ | ២ | ១២ | | សម្តេចពិជ័យ សេនា | បូទុមសាគរ | កំពុងសាងសង់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទីចាត់ការ | ១ | | | ឬ | ទៀ បាញ់ | | |
| បណ្ណាល័យ | ១ | | | | | | |
| អគារសិក្សា | ១ | ២ | ១២ | | អ្នកឧកញ៉ា លី យ៉ុងផាត់ | | |

## ២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានសហការជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងអាជ្ញាធរឃុំ សង្កាត់ អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ គ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ ទូទាំងខេត្ត មានចំនួនដូចខាងក្រោម ៖

  ក.ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ សរុបចំនួន៤.៤៨៣នាក់ ក្នុងនោះ ៖
  - ស្ត្រីមានផ្ទៃពោះសរុបចំនួន១.២៩៤នាក់
  - កុមារសរុបចំនួន២.៧០៤នាក់
  - សម្រាលកូនសរុបចំនួន៤៨៥នាក់
  - ថវិកាចំណាយសរុប៣៦៧.៣២៦.០០០រៀល

  ខ. គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ មានចំនួនដូចខាងក្រោម ៖
  - គ្រួសារមកផ្ទៀងផ្ទាត់ឈ្មោះសរុបចំនួន១០គ្រួសារ ក្នុងនោះមាន ក្រីក្រ១ ចំនួន៣គ្រួសារ និងក្រីក្រ២ ចំនួន៧គ្រួសារ ថវិកាចំណាយសុរបចំនួន១.៥៨៤.០០០រៀល
  - គ្រួសារមកបើកប្រាក់បន្តប្រចាំខែចំនួន៩.០៥១គ្រួសារ ក្នុងនោះមាន ក្រីក្រ១ចំនួន៣.៤៤១គ្រួសារ និងក្រីក្រ២ ចំនួន៥.៦១០គ្រួសារ ថវិកាចំណាយសរុបចំនួន១៧.៩៨២.៩១២.០០០រៀល

  គ. បានផ្តល់កាតវីងជូនដល់រដ្ឋបាលឃុំ/សង្កាត់ ដើម្បីផ្តល់ជូនអ្នកទទួលផល សរុបចំនួន៧៤៥កាត ក្នុងនោះ សង្កាត់១៥៥កាត និងឃុំ៥៩០កាត

  ឃ.គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា ទាំងបីដំណាក់កាល មានចំនួនដូច ខាងក្រោម៖
  - ចំនួនអ្នកទទួលផលដែលត្រូវមកបើកថវិកា
  - គ្រួសារចំនួន ២.៣១០គ្រួសារ
  - សមាជិកសរុបចំនួន ១.៩៩៩នាក់
  - ស្ត្រីចំនួន ៤.៧០៩នាក់
  - ថវិកាឧបត្ថម្ភសរុបចំនួន ៩៩៩.៧៩០.០០០រៀល

- ចំនួនអ្នកទទួលផលដែលបានមកបើកថវិកាពីគណនីវីងរួចរាល់
  - គ្រួសារចំនួន ១.៥០១គ្រួសារ
  - សមាជិកសរុបចំនួន ៤.៥៥១នាក់
  - ស្ត្រីចំនួន ៣.០៦៧នាក់
  - ថវិកាឧបត្ថម្ភសរុបចំនួន ៧០២.០៦០.០០០រៀល

- បានបញ្ជូនជនមានវិប្បល្លាសស្មារតីឱ្យទៅស្នាក់នៅ និងព្យាបាលក្នុងមជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទា ស្ថិតនៅភូមិបាគូរ ឃុំបាគូរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំនួន២នាក់ ស្រី១នាក់
- បានចុះអង្កេតរហ័សជនពិកលចរិក ចំនួន១៧នាក់ ស្រី៤នាក់
- បានសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ INTERNATIONAL JUSTICE MISSION (IJM) ដើម្បីបិទករណីជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្ម ចំនួន២នាក់ស្រី
- បានចុះត្រួតពិនិត្យលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ និងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនរងគ្រោះ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ ចំនួន៣សង្កាត់ និង១២ឃុំ
- បានចុះបើកផ្តល់ប្រាក់សម្រាលកូន ជូនដល់អ្នកទទួលផលដែលមិនបានទទួលទឹកប្រាក់ចំនួន២០០.០០០រៀល ក្នុងមួយនាក់ នៅថ្ងៃសម្រាលជាក់ស្តែង សរុបចំនួន៥០នាក់
- បានចុះអង្កេតរហ័សជនអនាថា ចំនួន១៦នាក់ ស្រី៥នាក់
- បានផ្តល់កញ្ចប់ឧបត្ថម្ភដល់កុមាររងគ្រោះ និងងាយរងគ្រោះក្នុងសហគមន៍ សរុបចំនួន៤០នាក់ ស្រី១៥នាក់
- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបញ្ជូនកុមារស្ថិតក្នុងគ្រួសារក្រីក្រ កុមារកំព្រា និងកុមារតាមម្តាយក្នុងពន្ធនាគារ ឱ្យទៅស្នាក់នៅ រៀនសូត្រក្នុងមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋខេត្តកោះកុង និងអង្គការបម្រើសេវាសង្គមដើមឈើសប្បាយ (Happy Tree) រាជធានីភ្នំពេញ សរុបចំនួន៣នាក់ ស្រី២នាក់
- បានឧបត្ថម្ភថវិកា និងជួយគាំទ្រសេវាផ្លូវច្បាប់ដល់កុមារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈចំនួន១នាក់
- បានសហការជាមួយអង្គការហាហ្គា (HAGAR) និង អង្គការការីតាស់កម្ពុជា (Caritas Cambodia) ដើម្បីធ្វើសមាហរណកម្មស្ត្រីរងគ្រោះ មករស់នៅជាមួយគ្រួសារក្នុងសហគមន៍វិញ សរុបចំនួន២នាក់
- បានប្រគល់ផ្ទះចំនួន១ខ្នង និងឧបត្ថម្ភថវិកា ព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួន ដែលជាអំណោយរបស់មូលនិធិជនពិការ ជូនដល់គ្រួសារជនមានពិការភាពក្រីក្រចំនួន១នាក់ ស្ថិតនៅភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីមា
- ក្រុមការងារសាខាមូលនិធិជនពិការខេត្តកោះកុង បានចុះពិនិត្យ សម្អាតហិបសប្បុរសធម៌មូលនិធិជនពិការ និងរាប់ប្រាក់ក្នុងហិបនៅតាមវត្តអារាម ភោជនីយដ្ឋាន ផ្ទះសំណាក់ និងរមណីយដ្ឋាននានាក្នុងខេត្តកោះកុង ចំនួន២១លើក សរុប៣១ទីតាំង ទទួលបានថវិកាសរុបចំនួន៧.៤៣០.២០០រៀល
- បានប្រារព្ធពិធីបើកប្រាក់របបគោលនយោបាយជូនជនពិការក្រីក្រនៅតាមសហគមន៍ ក្នុងខេត្តកោះកុង សម្រាប់ឆ្នាំ២០២២ ដែលជនមានពិការភាពចូលរួមសរុបចំនួន ៣៦៧នាក់ នៅសាលមហោស្រពខេត្ត
- បានសហការជាមួយសាខាមូលនិធិជនពិការខេត្តកោះកុង ចុះសួរសុខទុក្ខ និងនាំយកកញ្ចប់ឧបត្ថម្ភរបស់មូលនិធិជនពិការទៅចែកជូនជនមានពិការភាពជួបការលំបាកក្រីក្រ ចំនួន១៦នាក់ ស្រី១១នាក់
- បានសហការជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ស្ពឺ ចុះជួសជុលអវយវៈសិប្បនិម្មិត និងរទេះរុញចល័តជូនជនមានពិការភាព ក្នុងខេត្តកោះកុង ចំនួន១លើក ដែលមានអ្នកមកទទួលសេវាសរុបចំនួន៩៤នាក់ ស្រី២៨នាក់ ក្នុងនោះ មានទទួលសេវាដូចជា៖ ជួសជុលដៃសិប្បនិម្មិត, ជួសជុលរទេះរុញ, ជួសជុលឈើច្រត់, ផ្តល់រទេះរុញថ្មី ឈើច្រត់ថ្មី និងស្បែកជើង
- បានបើកវគ្គបណ្តុះបណ្តាល លើការអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មជនមានពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់មន្ត្រីបង្គោលថ្មីចំនួន២៩ឃុំ សង្កាត់ ដោយមានសិក្ខាកាមចូលរួមចំនួន២៩នាក់ ស្រី១៥នាក់

- បានចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ជូនដល់គ្រួសារចាស់ជរាក្រីក្រ ចំនួន ៥គ្រួសារ
- បានចុះពង្រឹង និងធ្វើការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសមាគមមនុស្សចាស់ និងផ្តល់បច្ចេកទេសជូនដល់សមាគម មនុស្សចាស់ ចំនួន៧លើក
- បានចុះប៉ាន់ប្រមាណគ្រួសារមនុស្សចាស់ក្រីក្រ និងចាស់ជរាគ្មានទីពឹងដែលកំពុងជួបការលំបាកខ្លាំង ចំនួន៣ គ្រួសារ
- បានចុះជួបប្រធានសមាគមមនុស្សចាស់ចំនួន២ភូមិ ក្នុងសង្កាត់ស្មាច់មានជ័យ និងសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ដើម្បីធ្វើបច្ចុប្បន្នភាពចំនួនសមាជិកភាព និងចំនួនថវិកាតំកល់ក្នុងសមាគម ជាលទ្ធផល មានសមាជិកភាពសរុប ចំនួន២៣១នាក់ ស្រី១០០នាក់ ថវិកាតំកល់សរុបចំនួន៣.៨០២.០០០រៀល
- បានប្រារព្ធទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៥ ដែលមានអ្នកចូលរួមប្រមាណ ២៥០នាក់
- បានបើកផ្តល់របបគោលនយោបាយអ្នកនៅក្នុងបន្ទុករបស់សពនិវត្តជនចំនួន១១នាក់
- បានបើកប្រាក់នៅសល់ក្នុងគណនីរបស់សពនិវត្តជនចំនួន២នាក់
- បានសហការជាមួយក្រុមការងារមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ) ថ្នាក់កណ្តាល ចុះធ្វើបច្ចុប្បន្នភាពនិវត្តជន ផ្ទេរចូលថ្មីចំនួន៧នាក់ អ្នកនៅក្នុងបន្ទុកចំនួន៥នាក់។ បើកផ្តល់របបគោលនយោបាយអ្នកនៅក្នុងបន្ទុករបស់ សពនិវត្តជនចំនួន៣នាក់ និងបើកផ្តល់របបសន្តិសុខសង្គមរបស់និវត្តជនជូនគ្រួសារសពចំនួន២នាក់
- បានចូលរួមបើកប្រាក់បេឡាមរណៈសង្គ្រោះជូនគ្រួសារសពអតីតយុទ្ធជនគ្រប់ប្រភេទ ដែលបានទទួលមរណភាព ចំនួន១៤គ្រួសារ
- បានប្រារព្ធពិធីអបអរសាទរខួបលើកទី១៦ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ២០០៧ - ២១ មិថុនា ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន៣៦០នាក់ នៅសាលមហោស្រពខេត្តកោះកុង
- បានសហការជាមួយក្រុមការងារមូលនិធិជាតិជំនួយសង្គមថ្នាក់កណ្តាល ធ្វើបច្ចុប្បន្នភាពជូនមុខសញ្ញាអតីតយុទ្ធ ជនគ្រប់ប្រភេទសរុបចំនួន២៧នាក់ ក្នុងនោះ គ្រួសារដែលមាននិវត្តជនចំនួន២០នាក់ គ្រួសារជនពលីចំនួន១នាក់ និងគ្រួសារជនមរណៈចំនួន៦នាក់
- បានសហការជាមួយតំណាងសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត (ស.អ.ក) ចុះបើកប្រាក់ជានារ៉ាប់រងសង្គម ប្រាក់បូជាសព និងប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនដល់គ្រួសារនៃសពចំនួន៧គ្រួសារ ស្មើទឹកប្រាក់សរុបចំនួន ៥៨.៩៣៣.៨០០រៀល។

## ២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

### ២.២.៣.១-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

- នៅក្នុងឆ្នាំ២០២៣នេះ ស្ថិតិ សហគ្រាស គ្រឹះស្ថានក្នុងខេត្តសរុបចំនួន៧៦ ដែលមានកម្មករនិយោជិតកំពុងបម្រើ ការងារសរុបចំនួន១៤.៦១៦នាក់ ស្រី៨.៩៥៨នាក់ ក្នុងនោះមាន៖
    - កម្មករនិយោជិតខ្មែរចំនួន១២.៥៧៤នាក់ ស្រី៧.៧៥៨នាក់
    - ពលករបរទេសចំនួន២.០៤២នាក់ ស្រី១.២០០នាក់
- ចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក(ចេញ-ចូល)បានចំនួន៤៩ រោងចក្រ មានកម្មករសរុប៖
    - ចលនាចេញ៣.៨៣៧នាក់ ស្រី២.៤៩២នាក់
    - ចលនាចូល៣.៥២៧នាក់ ស្រី២.០២២នាក់

- បានសម្របសម្រួលជូននាយករោងចក្រ/សហគ្រាស/គ្រឹះស្ថាន ធ្វើសៀវភៅការងារជូនកម្មករនិយោជិតខ្មែរបាន ចំនួន១.៧៦៥នាក់ និងបរទេសបានចំនួន២១០នាក់
- បានផ្តល់លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោងចំនួន២គ្រឹះស្ថាន គឺធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាខេត្តកោះកុង និងធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាស្រុកស្រែអំបិល
- បានចូលរួមសហការរៀបចំទិវាបរិស្ថានអន្តរជាតិប្រចាំឆ្នាំ២០២៣ ប្រារព្ធធ្វើឡើងនៅក្រុមហ៊ុនយ៉ាហ្សាគិ ដែលមានអ្នកចូលរួមចំនួន១២០នាក់ ស្រី៩០នាក់
- បានចុះផ្សព្វផ្សាយលិខិតបទដ្ឋាននានាដល់នាយករោងចក្រ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុងចំនួន៧លើក
- បានដោះស្រាយវិវាទការងារបុគ្គលចំនួន៤ករណី បានសះជា(ទាក់ទងលក្ខខណ្ឌការងារ) មកពីគ្រឹះស្ថានហិរញ្ញវត្ថុក្នុងខេត្ត
- បានសហការជាមួយរដ្ឋបាលខេត្ត រៀបចំពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៧ ទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ "សន្តិភាព ស្ថិរភាព មុខរបរ និងការងារ" នៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង មានអ្នកចូលរួមប្រមាណ៥០០នាក់
- បានសហការជាមួយរដ្ឋបាលខេត្ត និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុងបានរៀបចំពិធី ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៦ ឆ្នាំ២០២៣ ក្រោមជានបទ"TVET ផ្តល់ជំនាញ និងការងារសមរម្យ"
- បានចុះត្រួតពិនិត្យប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង បានចំនួន៧លើក
- បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីសហជីពនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង ដែលមានតំណាងរោងចក្រទាំង៥ ចូលរួមសរុបចំនួន១៥នាក់ ស្រី៧នាក់។

## ២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បានចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសេវាសន្តិសុខសង្គមទាំងបួនផ្នែកដូចជា៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំ ផ្នែកសោធន (បង់ភាគទានផ្នែកសោធនស្ម័គ្រចិត្ត) និងស្វ័យនិយោជន៍ មានដូចខាងក្រោម ៖
  - សហគ្រាស/គ្រឹះស្ថាន ដែលបានចុះបញ្ជីផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងស្វ័យនិយោជន៍ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ
  - បានធ្វើបច្ចុប្បន្នភាពសហគ្រាស/គ្រឹះស្ថាន ដែលបានជាប់វិភាគទានប្រចាំ ឆ្នាំ២០២៣ មានចំនួន៧១ សហគ្រាស/គ្រឹះស្ថាន សមាជិកសរុបមានចំនួន១៣.៣៥៧នាក់ ស្រី៨.០៣៩នាក់
  - បានទទួលសមាជិកដែលជាបុគ្គលស្វ័យនិយោជន៍ និងបានបង់វិភាគទានមានចំនួន២៣.០៦៩នាក់ ស្រី៤៩នាក់ និងសមាជិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន៣៦នាក់ ស្រី៩នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកហានិភ័យការងារទទួលបានតាវកាលិកមានចំនួន៤១នាក់ ស្រី១៧នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកថែទាំសុខភាព ទទួលបានតាវកាលិកមានចំនួន៦១៩នាក់ ស្រី៥៩៩នាក់
  - បានសម្របសម្រួលដល់សមាជិកប.ស.ស.ទាំងវិស័យសាធារណៈ និងវិស័យឯកជនជាស្ត្រីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋា- ភិបាល មុនសម្រាល និងក្រោយសម្រាលកូន មានចំនួន២.៥៣៥នាក់
  - បានស្នើសុំធ្វើប័ណ្ណទុតិយតាវិស័យសាធារណៈមានចំនួ១៤នាក់ ស្រី៤នាក់ និងវិស័យឯកជនមានចំនួន២០៤នាក់ ស្រី១៣១នាក់
  - បានចុះបញ្ជិកាសមាជិក ប.ស.ស.ជាមន្ត្រីសាធារណៈមានចំនួន២៨នាក់ ស្រី ១៦នាក់។

## ២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- ការតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ ខេត្តកោះកុង មានភ្ញៀវចូលទស្សនា ចំនួន៣៨៤នាក់ ស្រី១៣៣នាក់ ក្នុងនោះភ្ញៀវបរទេស ចំនួន៣នាក់ប្រុស
- ក្រុមមន្ត្រីផ្ទាំបានថែរក្សាសណ្តាប់ធ្នាប់ សោភណ្ឌភាព អនាម័យស្ថានីយ ចេតិយ និងបូជនីយដ្ឋាន ចំនួន១៨លើក
- បានចេញច្បាប់អនុញ្ញាតអាជីវកម្ម តាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត បណ្ណាគារចំនួន១កន្លែង និងការិយាល័យច្រកចេញចូលតែមួយនៃក្រុងខេមរភូមិន្ទ ចំនួន១២កន្លែង ក្នុងនោះ ស្លាកយីហោចំនួន៩កន្លែង អ៊ុតសក់កាត់សក់លម្អក្រចកចំនួន២កន្លែង និងផ្ទះថតរូបចំនួន១កន្លែង ស្ថិតក្នុងក្រុងខេមរភូមិន្ទ
- បានចុះត្រួតពិនិត្យ និងស្រង់ស្លាកយីហោដែលលើកថ្មីចំនួន៥០កន្លែង ក្នុងនោះ ៣៤កន្លែង ស្ថិតក្នុងក្រុងខេមរ-ភូមិន្ទ និង១៦កន្លែង ស្ថិតក្នុងស្រុកមណ្ឌលសីមា
- បានបន្តបណ្តុះបណ្តាលផ្នែករាំរបាំដល់សមាជិក ស.ស.យ.ក ខេត្តកោះកុង ចំនួន២០នាក់ ស្រី១០នាក់ នៅសាលហាត់រៀនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- បានសហការជាមួយរដ្ឋបាលខេត្ត រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងរៀបចំពិធីមហោស្រពសិល្បៈយុវជនថ្នាក់ខេត្ត ឆ្នាំ២០២៣ ផ្នែកល្ខោននិយាយឈុតខ្លី និងផ្នែកចម្រៀងសម័យ នៅសាលមហោស្រពខេត្តកោះកុង
- បានចេញសម្តែង៧របាំ ស្ថិតក្នុងក្រុងខេមរភូមិន្ទ និងចេញប្រគំភ្លេងចំនួន៧កន្លែង ក្នុងនោះ ២កន្លែង ស្ថិតក្នុងក្រុងខេមរភូមិន្ទ និង៥កន្លែង ស្ថិតក្នុងស្រុកមណ្ឌលសីមា
- បានចុះសិក្សាស្រាវជ្រាវចងក្រងអំពីការផលិតស្រាចេក និងពិធីបុណ្យអភិសេក ឬបុណ្យបើកព្រះនេត្រ ស្ថិតនៅស្រុកថ្មបាំង
- បានចុះលើកស្លាកសញ្ញាសម្គាល់តំបន់ការពារស្ថានីយវាលភ្លេចប្រណាក ចំនួន២កន្លែង ស្ថិតនៅភូមិទ័ពឃ្លៃ ឃុំប្រឡាយ ស្រុកថ្មបាំង
- បានចុះសិក្សាស្រាវជ្រាវរុករកឃើញស្ថានីយថ្មី ភ្នំគន្លាក់ដៃ ស្ថិតនៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង
- បានចុះត្រួតពិនិត្យអាជីវកម្មកាហ្វេវីដេអូ១កន្លែង នៅក្រុងខេមរភូមិន្ទ ដែលផុតសុពលភាពច្បាប់អនុញ្ញាត និងបានណែនាំឱ្យអាជីវករមកសុំច្បាប់បន្តនៅការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ
- បានចុះស្រង់ស្ថិតិអាជីវកម្មកាហ្វេវីដេអូចំនួន៦កន្លែង ក្នុងនោះ ៥កន្លែងស្ថិតក្នុងក្រុងខេមរភូមិន្ទ និង១កន្លែងស្ថិតក្នុងស្រុកមណ្ឌលសីមា
- បានចុះពិនិត្យការសាងសង់វត្តគិរីមាលីជលសារធម្មទស្សនា ដែលស្ថិតនៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ដោយពិនិត្យមើលស្ថានភាពសាងសង់វត្តឃើញថា មិនមានផលប៉ះពាល់ដល់ទីតាំងសំណល់វត្ថុបុរាណផ្សេងៗ និងទីទួលបុរាណនោះទេ
- បានចុះពង្រឹងបង្ហាត់រឿងល្ខោននិយាយឈុតខ្លី ដល់សិស្សវិទ្យាល័យ និងអនុវិទ្យាល័យ ៣កន្លែង ក្នុងនោះមានវិទ្យាល័យចំណេះដឹងទូទៅ និងបច្ចេកទេសតេជោសែនកោះកុង វិទ្យាល័យប៉ាក់ខ្លង និងអនុវិទ្យាល័យ ជា ស៊ីម ស្មាច់មានជ័យ
- បានដឹកនាំក្រុមសិល្បៈចូលរួមសម្តែងរាំ ១របាំ ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ប្រចាំឆ្នាំ២០២៣ នៅស្រុកស្រែអំបិល ខេត្តកោះកុង។

### ២.២.៥-ការងារព័ត៌មាន

- បានពិនិត្យ និងផ្តល់សេវាបើក និងផ្តល់ថ្មីជូនអតិថិជន ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន៥៣សេវា ក្នុងនោះ ផ្ទាំងប៉ាណូ៣២សេវា អាហ្វីស១៦សេវា ប្រព័ន្ធអនឡាញ អេឡិចត្រូនិកអនឡាញ៤សេវា និងមធ្យោបាយដឹកជញ្ជូនផ្សេងៗ១សេវា
- ទទួលអ្នកសារព័ត៌មានមកយកព័ត៌មានក្នុងខេត្តកោះកុងសរុបចំនួន៣៤នាក់ ក្នុងនោះ មកពីផ្នែកកាសែត១៤នាក់ និងផ្នែកគេហទំព័រ២០នាក់
- បានចូលរួមជាមួយរដ្ឋបាលខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យទីតាំងស្នើសុំដំឡើងផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្មចំនួន១កន្លែង ដែលមានទីតាំងស្ថិតនៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល។
- **ការចុះជំរុញយកព័ត៌មានតាមរយៈការថតវីដេអូ បានចំនួន២៨៥ព័ត៌មាន និងបានផ្សាយ ៖**
    - តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) បានចំនួន១១៩ព័ត៌មាន
    - តាមរយៈទូរទស្សន៍បាយ័នបានចំនួន១៦៦ព័ត៌មាន
- **ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិ៖**
    - ព័ត៌មានជាតិបានចំនួន៧៥៣ព័ត៌មាន
    - ព័ត៌មានអន្តរជាតិបានចំនួន២៥១ព័ត៌មាន
    - កម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង" បានចំនួន២៤១លើក
- **ព័ត៌មានផ្សាយរបស់វិទ្យុសាគរកោះកុង៖**
    - ព្រឹត្តិការណ៍សំខាន់ៗចំនួន១១៤ព័ត៌មាន
    - សារសំឡេងខ្លីសំខាន់ៗរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** ចំនួន៦ព័ត៌មាន
    - ទំព័រហ្វេសប៊ុកផេកវិទ្យុសាគរកោះកុងចំនួន៣១៨ព័ត៌មាន
    - សន្និសីទសារព័ត៌មានចំនួន១អត្ថបទ
    - ផ្សាយផ្ទាល់អំពីកម្មវិធីសន្ទនាមតិចំនួន១១លើក
    - ព័ត៌មានក្នុងខេត្តចំនួន២២២ព័ត៌មាន
    - ព័ត៌មានជាតិចំនួន៤៤៣ព័ត៌មាន
    - ព័ត៌មានអន្តរជាតិចំនួន៣០៥ព័ត៌មាន
    - ព័ត៌មានថតផ្សាយជាសំឡេងចំនួន៦២៧ព័ត៌មាន
    - ព័ត៌មានពេលព្រឹករយៈពេល៣០នាទីចំនួន៨៦៦ព័ត៌មាន
    - សេចក្តីជូនដំណឹងផ្សេងៗចំនួន១៤៩អត្ថបទ
    - នាទីព្រះពុទ្ធសាសនាចំនួន១៨០ម៉ោង
    - នាទីកម្សាន្តមរតកដើមរួមមាន អាយ៉ៃ យីកេ ល្ខោនបាសាក់ និងល្ខោននិយាយបានចំនួន៣៦០ម៉ោង
- **អំពីការផ្សាយតាមរយៈផេកហ្វេសប៊ុកទូរទស្សន៍ជាតិខេត្តកោះកុង នៃមន្ទីរព័ត៌មានខេត្ត៖**
    - ផ្សាយព័ត៌មានដែលបានចុះយកក្នុងខេត្តចំនួន២៨៧ព័ត៌មាន
    - ផ្សាយប្រសាសន៍**សម្តេចតេជោ ហ៊ុន សែន និងសម្តេចធិបតី ហ៊ុន ម៉ាណែត** ចំនួន២៧៩លើក
    - ផ្សាយព័ត៌មានបន្ត សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗចំនួន៦៤៤លើក
    - ផ្សាយតាមរយៈផេកហ្វេសប៊ុករបស់មន្ទីរព័ត៌មានខេត្តកោះកុងចំនួន១.៥០៥ព័ត៌មាន
- **ឆ្លើយឆ្លងព័ត៌មានពេលព្រឹក និងរាយការណ៍គ្រឿងញៀនតាមវិទ្យុសាគរកោះកុង ៖**
    - ព័ត៌មានតាម WhatsApp ជូនលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ២៥៣លើក

- ព័ត៌មានតាមហ្វេសប៊ុកចំនួន៧៩លើក
- ឆ្លើយឆ្លងព័ត៌មានទទក ព័ត៌មានពេលព្រឹកចំនួន១៣លើក

- **ផ្សព្វផ្សាយសារអប់រំ និងស្ប៉ុតៈ**
  - សារអប់រំ និងស្ប៉ុតស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន៧.២០០លើក
  - សារអប់រំ និងស្ប៉ុតស្តីពី ពិសាគ្រឿងស្រវឹងសូមកុំបើកបរ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចំនួន ៧.២០០លើក
  - សារអប់រំអំពីបញ្ហាជំងឺអេដស៍បានចំនួន៣.៦០០លើក
  - សារអប់រំអំពីជំងឺគ្រុនចាញ់បានចំនួន៣.៦០០លើក
  - ស្ប៉ុតសុខភាព (ញ៉ាំសាប) បានចំនួន១.៨០០លើក
  - ស្ប៉ុតស្តីពី ការបញ្ឈប់អំពើហិង្សាលើស្ត្រីបានចំនួន៣.៦០០លើក
  - ស្ប៉ុតអប់រំក៏ដូចជាវិធីការពារជំងឺកូវីដ-១៩ បានចំនួន៥.៤០០លើក
  - សារអប់រំស្តីពី ការជួញដូរមនុស្សជាអំពើខុសច្បាប់បានចំនួន២.១៦០លើក
- **ទីភ្នាក់ងារសារព័ត៌មានកម្ពុជាៈ**
  - បានបញ្ជូនព័ត៌មានជូនអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជានៃក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយ តាម APP ចំនួន៧៩ព័ត៌មាន
  - បានផ្សាយព័ត៌មានតាមរយៈផេកហ្វេសប៊ុក AKP របស់មន្ទីរព័ត៌មានខេត្តចំនួន៩១៤ព័ត៌មាន
  - បានចុះចែកទស្សនាវដ្តីជូនរដ្ឋបាលខេត្តកោះកុងចំនួន១០លើក
- បានជំរុញដល់មន្ត្រីជំនាញសិក្សាស្រាវជ្រាវលើបច្ចេកទេសថ្មីៗ
- បានជំរុញ និងពង្រឹងដល់មន្ត្រីជំនាញទទួលបន្ទុកក្នុងការកែលម្អកម្មវិធីផ្សាយឱ្យបានល្អប្រសើរ។

## ២.២.៦-ការងារកិច្ចការនារី

- បានចុះផ្សព្វផ្សាយជ្រើសរើសសិស្សដើម្បីចូលរៀន ជំនាញធ្វើអំបោសស្មៅត្រែង សំអាងកាយ និងកាត់ដេរ សំលៀកបំពាក់ ចំនួន១លើក នៅសង្កាត់ស្មាច់មានជ័យ និងសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
- បានបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញធ្វើអំបោសស្មៅត្រែង ដល់ស្ត្រីក្រីក្រ ក្មេងស្រីបោះបង់ការសិក្សា និងស្ត្រីរងគ្រោះដោយអំពើហិង្សា ចំនួន១លើក នៅមន្ទីរកិច្ចការនារីខេត្ត មានអ្នកចូលរួមសរុប១៥នាក់ស្រី
- បានរៀបចំផលិតផលរបស់ក្រុមស្ត្រីតាមសហគមន៍ ដាក់តាំងលក់នៅស្តង់ពិព័រណ៍ចំនួន១លើក នៅសួនច្បារ មុខសាលាខេត្ត
- បានសហការជាមួយអាជ្ញាធរក្រុង និងនាយកសាលា ចុះផ្សព្វផ្សាយស្តីពី ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ដល់សិស្សានុសិស្សនៅអនុវិទ្យាល័យដងទង់ ចំនួន១លើក មានអ្នកចូលរួមសរុប៥៨នាក់ ស្រី៣៥នាក់
- បានសហការជាមួយអាជ្ញាធរស្រុក និងនាយកសាលា រៀបចំការផ្សព្វផ្សាយស្តីពី ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់សិស្សានុសិស្ស ចំនួន១លើក នៅវិទ្យាល័យ ហ៊ុន សែន ចាំយាម ស្រុកមណ្ឌលសីមា មានអ្នកចូលរួមសរុប៥៨នាក់ ស្រី៣៤នាក់
- បានសហការជាមួយអាជ្ញាធរស្រុក និងអង្គការសង្គ្រោះកុមារ ចុះតាមដាន និងវាយតម្លៃទាក់ទងនឹងកិច្ចការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមានរបស់ប្រជាកសិករ តាមរយៈការចុះសម្ភាសន៍តាមខ្នងផ្ទះ ចំនួន៦១គ្រួសារ នៅឃុំតាទៃលើ និងឃុំជីផាត ស្រុកថ្មបាំង
- បានសហការជាមួយអាជ្ញាធរស្រុក និងអង្គការសង្គ្រោះកុមារ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ស្តីពី ការលើកកម្ពស់សុខភាពអនាម័យ អាហារូបត្ថម្ភ និងការចិញ្ចឹមកូនបែបវិជ្ជមាន ដល់ប្រជាពលរដ្ឋចំនួន៤ភូមិ មានៈ

ភូមិតានួន ឃុំតានួន ស្រុកបូទុមសាគរ, ភូមិតានី ឃុំភ្ញីមាស ស្រុកគិរីសាគរ , ភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង និង ភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ដែលមានអ្នកចូលរួមសរុប១៧០នាក់ ស្រី១៤៧នាក់

- បានសហការជាមួយរដ្ឋបាលស្រុក និងមណ្ឌលសុខភាព រៀបចំការផ្សព្វផ្សាយ ស្តីពីសុខភាពបន្តពូជ និងអាហារូបត្ថម្ភ ដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អ្នកទ្រទ្រង់សុខភាពភូមិ និងប្រជាពលរដ្ឋ ចំនួន៣លើក នៅស្រុកបូទុមសាគរ ស្រុកកោះកុង និងស្រុកគិរីសាគរ ដែលមានអ្នកចូលរួមសរុប១៥០នាក់ ស្រី១១៩នាក់
- បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់កម្មករ និងកម្មការិនី ចំនួន១លើក នៅរោងចក្រកាត់ដេរ KKN III នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង ដែលមានអ្នកចូលរួមសរុប៦៥នាក់ ស្រី៣៨នាក់
- បានចុះផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ការចំណាកស្រុក និងការជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ចំនួន៣លើក នៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ, ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ដែលមានអ្នកចូលរួមសរុប៣៥នាក់ ស្រី២៣នាក់
- បានរៀបចំយុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក្រោមប្រធានបទ " រួមគ្នាលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី" ដល់ប្រជាពលរដ្ឋ ក្នុងគោលបំណង បញ្ឈប់អំពើហិង្សាគ្រប់រូបភាពមកលើស្ត្រី និងក្មេងស្រី ដើម្បីលើកកម្ពស់ភាពសុខដុមរមនា និងភាពរុងរឿងក្នុងគ្រួសារ សហគមន៍ សង្គម និងកន្លែងធ្វើការ ចំនួន១លើក ដែលមានអ្នកចូលរួមសរុបចំនួន៧១នាក់ ស្រី៥៣នាក់ នៅមន្ទីរកិច្ចការនារីខេត្ត
- បានរៀបចំមីទ្ទិញអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ " ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" ដែលមានអ្នកចូលរួមសរុប២៥០នាក់ ស្រី ១៨៧នាក់ នៅសាលមហោស្រពខេត្ត
- បានរៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ចំនួន៣លើក នៅស្រុកស្រែអំបិល និងស្រុកថ្មបាំង ដែលមានអ្នកចូលរួមសរុប១៣៤នាក់ ស្រី៨១នាក់
- បានរៀបចំកិច្ចប្រជុំស្តីពី ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ជាមួយមន្ត្រីបង្គោលយេនឌ័រ តាមមន្ទីរ/អង្គភាព ចំនួន១លើក នៅសាលមហោស្រពខេត្ត មានអ្នកចូលរួមសរុប៤០នាក់ ស្រី៣៨នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការប្រឹក្សាយោបល់ និងកិច្ចការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង/ស្រុក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំចំនួន៤លើក នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកកោះកុង និងស្រុកថ្មបាំង ដែលមានអ្នកចូលរួមសរុប៩៣នាក់ ស្រី៣៩នាក់
- បានរៀបចំសិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង/ស្រុក ឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ ចំនួន៣លើក នៅក្រុងខេមរភូមិន្ទ ស្រុកស្រែអំបិល និងស្រុកមណ្ឌលសីមា ដែលមានអ្នកចូលរួមសរុប៧៩នាក់ ស្រី៤៦នាក់។
- បានសហការជាមួយមន្ទីរទេសចរណ៍ខេត្ត និងលោកនាយកសាលា រៀបចំសិក្ខាសាលាស្តីពី " បញ្ជ្រាបការយល់ដឹងអំពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ក្នុងវិស័យទេសចរណ៍ " ដល់សិស្សានុសិស្ស ចំនួន១លើក នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែនកោះកុង ដែលមានអ្នកចូលរួមសរុប៨២នាក់ ស្រី៤៨នាក់

- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី ការស្វែងរកការគាំទ្រមតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ថ្នាក់ធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយចំនួន១លើក នៅសាលមហោស្រពខេត្ត ដែលមានអ្នកចូលរួមសរុប៨០នាក់ ស្រី៦២នាក់
- បានសម្របសម្រួល ករណីចំណាកស្រុកមិនស្របច្បាប់ទៅប្រទេសចិន១ករណី
- បានសម្របសម្រួល ករណីអំពើហិង្សា៣ករណី (១ករណី បានស្នើសុំមេធាវីជួយការពារសិទ្ធិជូនជនរងគ្រោះ)
- បានសម្របសម្រួល ករណីរំលោភសេពសន្ថវៈចំនួន២ករណី
- បានស្នើសុំមេធាវីជួយការពារសិទ្ធិជូនជនរងគ្រោះ(អនីតិជន) ករណីរំលោភសេពសន្ថវៈចំនួន១ករណី។

## ២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បានចូលរួមជាមួយប្រតិភូក្រសួងអធិការកិច្ច ចុះធ្វើអធិការកិច្ចស្ដីពី (១)ការអនុវត្តតួនាទី ភារកិច្ច (២)ការគ្រប់គ្រងចំណូល ចំណាយមិនមែនសារពើពន្ធ (៣)ការគ្រប់គ្រងការផ្ដល់សេវាសាធារណៈ (៤)ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្ដាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក ពន្ធនាគារ ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក មន្ទីរ អង្គភាព និងអង្គភាពពាក់ព័ន្ធ
- បានចូលរួមជាមួយប្រតិភូក្រសួងអធិការកិច្ច ចុះតាមដានការអនុវត្តច្បាប់ លើការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅក្នុងខេត្ត មានចំនួន៧ក្រុង-ស្រុក និង៤អង្គភាព
- បានចូលរួមជាមួយប្រតិភូក្រសួងអធិការកិច្ច ចុះអង្កេតស្រាវជ្រាវបណ្ដឹងទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋដែលស្ថិតនៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល
- បានជួបម្ចាស់បណ្ដឹងដែលបានមកស្នើសុំជួយអន្តរាគមន៍ ករណីត្រូវបានចុងចម្លើយកាប់ឆ្ការ និងឈូសឆាយដីទំនាស់លេខៈ០៦០/២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្មឹងវែង ក្រុងខេមរភូមិន្ទ
- បានចូលរួមកិច្ចប្រជុំជួបពិភាក្សាការងារជាមួយគណៈប្រតិភូ គណៈកម្មការទី៣ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា កម្មវិធីប្រព្រឹត្តទៅនៅសាលប្រជុំ(ខ)សាលាខេត្ត។

## ២.២.៨-ការងារធម្មការនិងសាសនា

- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែ និងលើកទិសដៅអនុវត្តការងារបន្តឆ្នាំ២០២៣ ចំនួន៨លើក
- បានដឹកនាំកិច្ចប្រជុំពិភាក្សាលើកិច្ចការងារចាំបាច់មួយចំនួន៧លើក
- បានដឹកនាំកិច្ចប្រជុំលើកិច្ចការព្រះពុទ្ធសាសនាចំនួន៤លើក
- បានចូលរួមកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តកោះកុង ចំនួន១២លើក
- បានចូលរួមសកម្មភាពនានាតាមបណ្ដាវត្តចំនួន២២លើក
- បានចូលរួមសកម្មភាពនានាជាមួយកិច្ចការពាហិរសាសនា (ឥស្លាម-គ្រឹស្ទ)ចំនួន៤លើក
- បានចូលរួមពិធីចែកអំណោយពីសប្បុរសជនក្នុងខេត្តកោះកុង ចំនួន៥លើក
- បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាផ្សព្វផ្សាយ នៅទីស្ដីការក្រសួងធម្មការ និងសាសនា ចំនួន១៤លើក
- បានចូលរួមកិច្ចប្រជុំ និងសកម្មភាពនានាជាមួយថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ចំនួន៥២លើក
- បានចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន ចំនួន១លើក
- បានចូលរួមក្នុងពិធីបើក និងបិទជាផ្លូវការការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ចំនួន២លើក
- បានចូលរួមក្នុងពិធីបើក និងបិទព្រឹត្តិការណ៍កីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ចំនួន២លើក
- បានរៀបចំ និងសម្របសម្រួលទិវាអង្គការសហប្រជាជាតិ ស្ដីពីសប្ដាហ៍សុខុមនីយកម្ម អន្តរជំនឿសាសនាពិភពលោក ក្រោមប្រធានបទ អន្តរជំនឿសាសនា ដើម្បីកិច្ចការពារបរិស្ថាន និងទេសចរណ៍សាសនា ចំនួន១លើក

- បានចូលរួមកម្មវិធីដង្ហែបុណ្យមាឃបូជា ចំនួន២វត្ត
- បានដឹកនាំមន្ត្រីក្រោមឱវាទចូលរួមកម្មវិធីដង្ហែបុណ្យពិសាខបូជា ចំនួន២វត្ត
- បានដឹកនាំមន្ត្រីក្រោមឱវាទចូលរួមពិធីបុណ្យកាន់បិណ្ឌ ព.ស.២៥៦៧ គ.ស.២០២៣ ចំនួន៥លើក
- បានចូលរួមក្នុងពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣១ព.ស.២៥៦៧ គ.ស.២០២៣ ចំនួន១លើក ។

## ២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បានបញ្ជូនបញ្ញើក្នុង និងក្រៅប្រទេសចំនួន៩៣.៨៦០បញ្ញើ ស្មើនឹង៩០៤.៦៨៩,៥៩គ.ក្រ
- បានទទួលបញ្ញើក្នុង និងក្រៅប្រទេសចំនួន១៣.៥០៧ ស្មើនឹង២២០.៤៦៩,២០គ.ក្រ
- បានចេញលិខិតអនុញ្ញាត សេវាបញ្ញើឆាប់រហ័សជាតិ-អន្តរជាតិ បើកថ្មីចំនួន១ទីតាំង ជូនតំណាងសាខាក្រុមហ៊ុន វីរៈប៊ុនថាំ ស្ថិតនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេរភូមិន្ទ និងបើកបន្តចំនួន៤ទីតាំង ជូន(១).តំណាងសាខាក្រុមហ៊ុន គ្លូបិល ដេត អេចប្រេស ស្ថិតនៅនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ (២).តំណាងសាខាក្រុមហ៊ុន វីរៈប៊ុនថាំ ស្ថិតនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេរភូមិន្ទ (៣). តំណាងសាខាក្រុមហ៊ុន ហ្សេត ធី អូ អេចប្រេស នៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា (៤).លោក នី សើអ៊ី តំណាងសាខាក្រុមហ៊ុន ស៊ីអ៊ី អេចប្រេស នៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានចុះសួរព័ត៌មាន អំពីករណីបង្កប់គ្រឿងញៀនតាមបញ្ញើប្រៃសណីយ៍ពីនគរបាលបង្ក្រាបគ្រឿងញៀនខេត្ត នៅសាខាក្រុមហ៊ុនកាពីតូល ស្ថិតនៅភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ចំនួន១លើក
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ដល់ទីតាំងបើកសេវាកម្មបញ្ញើ ឆាប់រហ័សជាតិ-អន្តរជាតិដែលមិនទាន់មានច្បាប់ និងធ្វើការណែនាំដល់បុគ្គលិកក្រុមហ៊ុននៅតាមសាខាបណ្តាក្រុងស្រុក ឱ្យមកស្នើសុំលិខិតអនុញ្ញាតបើកធ្វើអាជីវកម្មប្រចាំឆ្នាំពីមន្ទីរ ចំនួន៤ក្រុមហ៊ុន មាន១៥ទីតាំង
- បានតាមដានត្រួតពិនិត្យសារធាតុញៀនតាមរយៈបញ្ញើ របស់សាខាប្រៃសណីយ៍កម្ពុជាខេត្តកោះកុងជាប្រចាំ (គ្មានអ្វីគួរឱ្យសង្ស័យទេ)
- បានចេញលិខិតអនុញ្ញាតបើកអាជីវកម្មសាលបម្រើអ៊ិនធឺណែតកាហ្វេជូនអតិថិជន ចំនួន២ទីតាំង ស្ថិតនៅសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ និងឃុំស្រែអំបិល ស្រុកស្រែអំបិល
- បានចេញលិខិតអនុញ្ញាតប្រើប្រាស់ប្រេកង់វិទ្យុទាក់ទង ICOM ចំនួន១២គ្រឿង ជូនក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានចុះកំណត់យកនិយាមកាសាងសង់ស្ថានីយ៍បង្គោលអង់តែន នៅតំបន់សហគមន៍ទេសចរណ៍ដាច់ស្រយាលឃុំដែលមិនមានបង្គោលអង់តែន និងមិនមានសេវាអ៊ីធឺណែតប្រើប្រាស់ ចំនួន៧លើក
- បានចុះពិនិត្យខ្សែកាប្លិ៍អុបទិកកប់ក្រោមដីតាមបណ្តោយផ្លូវ៣០៣ ធ្វើការរុះរើឬអូសខ្សែកាប្លិ៍អុបទិកដែល រងផលប៉ះពាល់ពីគម្រោងក្នុងការពង្រីកផ្លូវជាតិលេខ៤៨ និងធ្វើការជួសជុលខ្សែកាប្លិ៍អុបទិកខូចរបស់ក្រុមហ៊ុនស៊ីហ្វុក (CFOCN) ចំនួន៣លើក
- បានចុះត្រួតពិនិត្យក្រុមហ៊ុនវៀតធេល ធ្វើការដំឡើងស្ថានីយ៍បង្គោលអង់តែនទូរស័ព្ទ និងខ្សែកាប្លិ៍អុបទិក ដែលត្រូវឡានស្ទូចទាក់ដាច់ភ្ជាប់ជូនអតិថជនប្រើប្រាស់និងធ្វើការផ្លាស់ប្តូរឧបករណ៍សែល (អង់តែន) ចំនួន៤លើក
- បានចុះពិនិត្យក្រុមហ៊ុន អ៊ីហ្សីខមភ្ជាប់អ៊ិនធឺណែតជូនអតិថជន និងធ្វើការជួជុលខ្សែកាប្លិ៍អ៊ុបទិក ចំនួន៧លើក
- បានចុះពិនិត្យក្រុមហ៊ុនម៉ាយក្រូម៉េកស៍ សាងសង់បណ្តាញខ្សែកាប្លិ៍អុបទិក ចំនួន២លើក
- បានចុះត្រួតពិនិត្យក្រុមហ៊ុនអនឡាញ (ONLINE) មកជួសជុលខ្សែកាប្លិ៍អុបទិកខូច ចំនួន២លើក
- បានចុះពិនិត្យ និងជូនដំណឹងដល់ក្រុមហ៊ុនវៀតធេល ស្មាត ទូរគមនាគមន៍ និងអ៊ីហ្សីខម ធ្វើការរុះរើ និងសាងសង់ខ្សែកាប្លិ៍អុបទិកដែលបំពាក់លើបង្គោលភ្លើងរបស់ក្រុមហ៊ុនអគ្គិសនី ចំនួន២លើក

- បានចុះពិនិត្យក្រុមហ៊ុន អង្គរដាតាសាងសង់ខ្សែកាប្លិ៍អ៊ីនធឺណេត ជូនដល់ក្រុមហ៊ុនមេគង្គណេត ចំនួន១លើក
- បានចុះត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ សេវាសាងសង់ ស្ថាបនា ជួសជុល ផ្លាស់ប្តូរ និងដំឡើងបន្ថែមគ្រឿង សម្ភារ បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍ របស់ប្រតិបត្តិករទូរគមនាគមន៍កម្ពុជានៅក្នុងខេត្ត ចំនួន ៣៦លើក តាមលិខិតចម្លងជូនរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានចេញលិខិតអនុញ្ញាតបើកលក់ និងជួសជុលគ្រឿងសម្ភារបរិក្ខាវិទ្យុគមនាគមន៍និងទូរគមនាគមន៍ សរុបចំនួន ២៤ទីតាំង។

## ២.២.១០-ការងារមុខងារសាធារណ:

- គិតត្រឹមថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ តាមតារាងទូទាត់បៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២៣ មន្ត្រីរាជការស៊ីវិលនៅខេត្តកោះកុង មានចំនួន២.៦៨២នាក់ ស្រី៩៩៥នាក់
  - ចំនួនរាយតាមប្រភេទក្របខណ្ឌ៖
    - ក្របខណ្ឌប្រភេទ "ក" ចំនួន៦៣៥នាក់ ស្ត្រី១៦២នាក់
    - ក្របខណ្ឌប្រភេទ "ខ" ចំនួន១.០២១នាក់ ស្ត្រី៣៥៨នាក់
    - ក្របខណ្ឌប្រភេទ "គ" ចំនួន១.០២៦នាក់ ស្ត្រី៤៧៥នាក់
  - ចំនួនមន្ត្រីរាជការរាយតាមមុខតំណែង៖
    - អភិបាលខេត្ត ចំនួន ១ នាក់ (ស្ត្រី ១ នាក់)
    - អភិបាលរងខេត្ត ចំនួន ១០ នាក់ (ស្ត្រី ២ នាក់) (មិនមានក្នុងតារាងបៀវត្សចំនួន២នាក់ ស្រី១នាក់)
    - នាយករដ្ឋបាល ចំនួន ១ នាក់ (ស្ត្រី ០ នាក់)
    - នាយករងរដ្ឋបាល ចំនួន ៤ នាក់ (ស្ត្រី ១ នាក់ )
    - អភិបាលក្រុង/ស្រុក ចំនួន ៧ នាក់ (ស្ត្រី ១ នាក់)
    - អភិបាលរងក្រុង/ស្រុក ចំនួន ៣៦ នាក់ (ស្ត្រី ៨ នាក់)
    - ប្រធានមន្ទីរ ចំនួន ២៣ នាក់ (ស្ត្រី ២ នាក់)
    - អនុប្រធានមន្ទីរ ចំនួន ៥៦ នាក់ (ស្ត្រី ១៨ នាក់)
    - ប្រធានសាលាដំបូង ចំនួន ១ នាក់ (ស្ត្រី ០ នាក់)
    - អនុប្រធានសាលាដំបូង ចំនួន ១ នាក់ (ស្ត្រី ០ នាក់)
    - ចៅក្រម ចំនួន ៦ នាក់ (ស្ត្រី ១ នាក់)
    - ព្រះរាជអាជ្ញា ចំនួន ១ នាក់ (ស្ត្រី ១ នាក់)
    - ព្រះរាជអាជ្ញារង ចំនួន ៣ នាក់ (ស្ត្រី ០ នាក់)
    - ក្រឡាបញ្ជី ចំនួន ១១ នាក់ (ស្ត្រី ២ នាក់)
    - ប្រធានលេខាធិការដ្ឋាន ចំនួន ០ នាក់ (ស្ត្រី ០ នាក់)
    - អនុប្រធានលេខាធិការដ្ឋាន ចំនួន ៣ នាក់ (ស្ត្រី ១ នាក់)
    - នាយកទីចាត់ការ/ប្រធានអង្គភាព/ផ្នែក ចំនួន ៩ នាក់ (ស្ត្រី ០ នាក់)
    - នាយករងទីចាត់ការ/អនុប្រធានអង្គភាព/ផ្នែក ចំនួន ១៦ នាក់ (ស្ត្រី ២ នាក់)
    - ប្រធានការិយាល័យ ចំនួន ១២៥ នាក់ (ស្ត្រី ២៧ នាក់)
    - អនុប្រធានការិយាល័យ ចំនួន ១៥៦ នាក់ (ស្ត្រី ៤៥ នាក់)
    - នាយករដ្ឋបាលក្រុង/ស្រុក ចំនួន ៦ នាក់ (ស្ត្រី ១ នាក់)

- នាយករងរដ្ឋបាលក្រុង/ស្រុក ចំនួន ១៤ នាក់ (ស្ត្រី ៣ នាក់)
- ប្រធានការិយាល័យក្រុង/ស្រុក ចំនួន ៦៧ នាក់ (ស្ត្រី ១៤ នាក់)
- អនុប្រធានការិយាល័យក្រុង/ស្រុក ចំនួន ៤៦ នាក់ (ស្ត្រី ៧ នាក់)
- មន្ត្រី ចំនួន ២.០៨១ នាក់ (ស្ត្រី ៨៦០ នាក់)
- សហព័ន្ធមន្ត្រីរាជការស៊ីវិល ចំនួន ៧៧៤ នាក់
- កូនមន្ត្រីរាជការស៊ីវិល ចំនួន ២.០១៤ នាក់
- មន្ត្រីជាប់កិច្ចសន្យា ចំនួន ២៦៦ នាក់ (ស្រី ១៣៣ នាក់)

– បានត្រួតពិនិត្យទិដ្ឋាការលើសំណើសុំឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ២០២៣ ជូនមន្ទីរ អង្គភាពជុំវិញខេត្ត ដូចខាងក្រោម ៖

| ល.រ. | បរិយាយ | ដើមគ្រា | ក្នុងគ្រា | បូកយោង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ក្របខ័ណ្ឌថ្មី | ០ | ៨៧ | ៨៧ | |
| ២ | តាំងស៊ប់ | ០ | ៨២ | ៨២ | |
| ៣ | ប្តូរប្រភេទក្របខ័ណ្ឌ | ០ | ០ | ០ | |
| ៤ | ឡើងថ្នាក់/និយ័តកម្មថ្នាក់ | ០ | ២.១៥៥ | ២.១៥៥ | |
| ៥ | តែងតាំង/ប្តូរប្រាក់មុខងារ | ០ | ១០៥ | ១០៥ | |
| ៦ | ឡើងឋានន្តរស័ក្តិ | ០ | ០ | ០ | |
| ៧ | បញ្ចូលកូន | ០ | ៣២៤ | ៣២៤ | |
| ៨ | បញ្ចូលប្រពន្ធ | ០ | ៤០ | ៤០ | |
| ៩ | ចូលនិវត្តន៍ | ០ | ២៤ | ២៤ | |
| ១០ | ផ្ទេរចូល | ០ | ៣៧ | ៣៧ | |
| ១១ | ផ្ទេរចេញ | ០ | ៧២ | ៧២ | |
| ១២ | នៅក្រៅក្របខ័ណ្ឌដើម | ០ | ០ | ០ | |
| ១៣ | ទំនេរគ្មានបៀវត្ស | ០ | ៦ | ៦ | |
| ១៤ | លុបឈ្មោះ | ០ | ១០ | ១០ | |
| ១៥ | ប្តូរកន្លែងការងារ | ០ | ០ | ០ | |
| ១៦ | តំបន់ដាច់ស្រយាល | ០ | ១៣ | ១៣ | |
| ១៧ | ចូលបម្រើការងារវិញ | ០ | ៥ | ៥ | |
| ១៨ | រំលឹកប្រាក់ | ០ | ០ | ០ | |
| ១៩ | ថ្នាក់ពីរពេល | ០ | ០ | ០ | |
| ២០ | ថ្នាក់គួបពីរកម្រិត | ០ | ២៤១ | ២៤១ | |
| ២១ | ថ្នាក់គួបបីកម្រិត | ០ | ០ | ០ | |
| ២២ | បញ្ចូលប្រាក់មុខងារ | ០ | ០ | ០ | |
| ២៣ | លំហែមាតុភាព | ០ | ៦៣ | ៦៣ | |
| ២៤ | ប្តូរប្រអប់ | ០ | ៣ | ៣ | |
| | **សរុបរួម** | **០** | **៣.២៦៧** | **៣.២៦៧** | |

- ការបង់សំណែសចំណាយមន្ទីរ/អង្គភាពដែលបានបើកបៀវត្សលើសចូលថវិការដ្ឋវិញសម្រាប់ឆ្នាំ២០២៣៖

| ល.រ | មន្ទីរ/អង្គភាព | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|
| ១ | មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត | ៣៤.០៦៩.១២៥ | |
| ២ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ៤៩.១០៥.៨៧៥ | |
| ៣ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ៤.៣៦០.០០០ | |
| ៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | ២០.១២០.៥០០ | |
| ៥ | មន្ទីរមុខងារសាធារណៈខេត្ត | ៧១០.០០០ | |
| ៦ | មន្ទីរធម្មការ និងសាសនាខេត្ត | ៤.៨៣៧.៥០០ | |
| ៧ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ២.៩០៥.០០០ | |
| ៨ | មន្ទីរបរិស្ថានខេត្ត | ១១.៣៤២.៨៧៥ | |
| ៩ | មន្ទីរផែនការខេត្ត | ៣.៣០៥.០០០ | |
| ១០ | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ១៦០.០០០ | |
| ១១ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ៣.១៥២.៥០០ | |
| ១២ | មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | ២.៧៨៣.៤២២ | |
| ១៣ | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | ៥.៨៩០.០០០ | |
| ១៤ | រដ្ឋបាលខេត្ត | ២.៦៤៥.០០០ | |
| ១៥ | រដ្ឋបាលក្រុងខេមរភូមិន្ទ | ៤.៣៨០.០០០ | |
| ១៦ | រដ្ឋបាលស្រុកគិរីសាគរ | ១៧.២១៧.៥០០ | |
| ១៧ | រដ្ឋបាលស្រុកថ្មបាំង | ១៥.០៣២.៥០០ | |
| ១៨ | រដ្ឋបាលស្រុកកោះកុង | ៦.៤៤០.០០០ | |
| ១៩ | រដ្ឋបាលស្រុកមណ្ឌលសីមា | ១៤.៥៩៧.៥០០ | |
| **សរុប** | | **២០៣.០៥៤.២៩៧៖** | |

- ការចេញលិខិតជូនមន្ទីរ/អង្គភាពដែលត្រូវបង្វែរថវិកាចូលរដ្ឋវិញប្រចាំឆ្នាំ២០២៣

| ល.រ | មន្ទីរ/អង្គភាព | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|
| ១ | មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត | ៣៤.០៦៩.១២៥ | |
| ២ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ៤៩.១០៥.៨៧៥ | |
| ៣ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ៤.៣៦០.០០០ | |
| ៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | ២៩.១៤៥.៥០០ | |
| ៥ | មន្ទីរមុខងារសាធារណៈខេត្ត | ៧១០.០០០ | |
| ៦ | មន្ទីរធម្មការ និងសាសនាខេត្ត | ៤.៨៣៧.៥០០ | |

| | | | |
|---|---|---|---|
| ៧ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ៨.៩៨៥.០០០ | |
| ៨ | មន្ទីរបរិស្ថានខេត្ត | ១៣.៨៤២.៨៧៥ | |
| ៩ | មន្ទីរផែនការខេត្ត | ៣.៣០៥.០០០ | |
| ១០ | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ១៦០.០០០ | |
| ១១ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ៣.១៥១.៥០០ | |
| ១២ | មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | ២.៧៨៣.៤២២ | |
| ១៣ | មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | ៥.៨៩០.០០០ | |
| ១៤ | រដ្ឋបាលខេត្ត | ២.៦៤៥.០០០ | |
| ១៥ | រដ្ឋបាលក្រុងខេមរភូមិន្ទ | ៤.៣៨០.០០០ | |
| ១៦ | រដ្ឋបាលស្រុកគិរីសាគរ | ៥.០៤០.០០០ | |
| ១៧ | រដ្ឋបាលស្រុកថ្មបាំង | ១៥.០៣២.៥០០ | |
| ១៨ | រដ្ឋបាលស្រុកកោះកុង | ៧.៤៤០.០០០ | |
| | **សរុប** | **១៩៤.៨៨៣.២៩៧៛** | |

– ការចេញនីត្យានុកូលភាពឆ្លើយតបដីកាសម្រាប់ឆ្នាំ២០២៣៖

| ល.រ | ប្រភេទគំរូដីកា | ចំនួនដីកា | ចំនួនករណី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ដីកាតែងតាំងប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការ | ១៣ | ៧៣ | - រដ្ឋបាលខេត្ត ១០ដីកា<br>- ស្រុកកោះកុង ២ដីកា<br>- ស្រុកបូទុមសាគរ ១ដីកា |
| ២ | ដីកា ផ្ទេរចេញ | ១ | ១ | - រដ្ឋបាលខេត្ត ១ដីកា |
| ៣ | ដីកា ផ្ទេរបញ្ចូល | ២ | ២ | - រដ្ឋបាលខេត្ត ២ដីកា |
| ៤ | ដីកា ដាក់ឱ្យចូលនិវត្តន៍ | ១ | ១ | - ក្រុងខេមរភូមិន្ទ ១ដីកា |
| | **សរុប** | **១៧** | **៧៧** | |

## ២.២.១១-ការងារផ្សេងៗ

### ២.២.១១.១-ការងារសាលាដំបូង

– **ផ្នែកចៅក្រមស៊ើបសួរ**
  - សំណុំរឿងសល់ពីមុន ចំនួន ១៧៥រឿង
  - សំណុំរឿងចូលថ្មី ចំនួន ២៤៧រឿង
  - សំណុំរឿងចាត់ការរួច ចំនួន ៣៤៨រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន ៧៤រឿង។

– **ផ្នែកចៅក្រមជំនុំជម្រះ**
  - សំណុំរឿងសល់ពីមុន ចំនួន ៣៥រឿង
  - សំណុំរឿងចូលថ្មី ចំនួន ២០២រឿង

- សំណុំរឿងចាត់ការរួច ចំនួន ១៦៧រឿង
- សំណុំរឿងកំពុងចាត់ការ ចំនួន ៧០រឿង។

– **ផ្នែកតុលាការរដ្ឋប្បវេណី**
  - សំណុំរឿងសល់ពីមុន ចំនួន ១១០រឿង
  - សំណុំរឿងចូលថ្មី ចំនួន ២១១រឿង
  - សំណុំរឿងចាត់ការរួច ចំនួន ២១៩រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន ១០២រឿង។

– **ការងារអយ្យការអមសាលាដំបូង**
  - សំណុំរឿងសល់ពីមុន ចំនួន ៩៤រឿង
  - សំណុំរឿងចូលថ្មី ចំនួន ៣៨៥រឿង
  - សំណុំរឿងចាត់ការរួច ចំនួន ៤១០រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន ៦៩រឿង។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

– បានទទួលកម្រៃសេវាសាធារណៈ (អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត) ដូចខាងក្រោម ៖
  - ការងារសំណង់ ទទួលបានកម្រៃសេវា ចំនួន១២៣.៩៦៩.៩០០រៀល
    - ឯកសារចូលសរុប ចំនួន៤៥ច្បាប់
    - ឯកសារចេញសរុប ចំនួន២៧ច្បាប់
  - ការងារសុរិយោដី ទទួលបានកម្រៃសេវា ចំនួន១.៦៣៦.៨៥៦.៤២៩រៀល
    - ឯកសារចូលសរុប ចំនួន៣.៨១០ច្បាប់
    - ឯកសារចេញសរុប ចំនួន៣.៨៤០ច្បាប់

– ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖
  - ក្រុមទី១ បំពេញការងារនៅភូមិស្នាច់មានជ័យ សង្កាត់ស្នាច់មានជ័យ ក្រុងខេមរភូមិន្ទ និងភូមិសុវណ្ណាបៃតង ឃុំកណ្តាល ស្រុកបូទុមសាគរ
  - ក្រុមទី២ បំពេញការងារនៅភូអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
  - ក្រុមទី៣ បំពេញការងារនៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
  - ក្រុមទី៤ បំពេញការងារនៅភូមិវាលត្បូង និងភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល

– ការងារចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ៖
  - ដីឯកជនចំនួន១១៩ក្បាលដី
  - ដីឯកជនរបស់រដ្ឋចំនួន១៦ក្បាលដី

– ការងារចុះបញ្ជីដីបន្ត ៖
  - អចលនវត្ថុចុះបញ្ជីជាប្រព័ន្ធ
    - ចុះបញ្ជីផ្ទេរសិទ្ធិបាន ចំនួន៩០៣ក្បាលដី
    - ចុះបញ្ជីប្រាតិភោគបាន ចំនួន៣៩៦ក្បាលដី
  - អចលនវត្ថុចុះបញ្ជីដាច់ដោយដុំ
    - ចុះបញ្ជីផ្ទេរសិទ្ធិបាន ចំនួន៦២ក្បាលដី
    - ចុះបញ្ជីប្រាតិភោគបាន ចំនួន៥៨ក្បាលដី

- ការងារសំណង់ ៖
  - បានផ្តល់លិខិតអនុញ្ញាតសាងសង់ ចំនួន២៣គម្រោង
  - បានផ្តល់លិខិតអនុញ្ញាតបើកការដ្ឋាន ចំនួន១៤គម្រោង
- ការងារលំនៅឋាន ៖
  - បានចុះស្រង់ទិន្នន័យ និងចុះអង្កេតប្រជាពលរដ្ឋដល់ខ្នងផ្ទះតាមបញ្ជីឈ្មោះប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំដីសម្បទានសង្គមកិច្ច នៅស្រុកស្រែអំបិល បានចំនួន៥ឃុំ ១៩ភូមិ ស្មើនឹង២.៣០០គ្រួសារ
- ក្រុមការងាររបស់មន្ទីរ នៅតែបន្តបំពេញការងារដូចខាងក្រោម៖
  - បានបំពេញទម្រង់បែបបទចំនួន៥.២៤៣ក្បាលដី
  - បានគូសក្រាហ្វិកចំនួន៤.៧៧៣ក្បាលដី
  - បានបញ្ចូលទិន្នន័យចំនួន៥.៩៧៧ក្បាលដី
  - បានចេញប័ណ្ណចំនួន៥.៤៥៤ប័ណ្ណ
  - បានចែកប័ណ្ណចំនួន៤.៣៩៤ប័ណ្ណ។

## ២.៣.២-ការងារបរិស្ថាន

- បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកោះកុង ចំនួន៤៣ករណី
- បានពិន័យអន្តរការណ៍លើការប្រមូលដឹកជញ្ជូនផល អនុផលធនធានធម្មជាតិ ចំនួន១១ករណី
- បានចាប់ឃាត់ឈើអារចំនួន៤៦.៧៦៣ម$^{3}$ ដើមឈើគគីរ០.៤០៥ម$^{3}$ ដើមឈើធ្នង់២.១៧៨គ.ក្រ ឈើអារ៤០សន្លឹក ឈើ៨៩ដើម ទោចក្រយានយន្ត១០គ្រឿង រថយន្ត៣គ្រឿង ឡានស្ទូច១គ្រឿង រឡូកិនថ្ម១គ្រឿង រទេះ៣គ្រឿង ទូកយន្ត៣គ្រឿង អេស្កាវ៉ាទ័រ៨គ្រឿង អាបុល៣គ្រឿង រណារយន្ត២៦៤គ្រឿង ធ្យូង៤៧២បាវ កាំភ្លើងកែច្នៃ២២ដើម កាំភ្លើងAK១ដើម ឧបករណ៍ឆក់ត្រី៣គ្រឿង អន្ទាក់ចាប់សត្វព្រៃ៨គ្រឿង ឧបករណ៍បំពងសំឡេង៣ និងផ្លែសន្ទូច១៣០ផ្លែ
- បានរុះរើអន្ទាក់សត្វព្រៃចំនួន១៧.៦២៦ខ្សែ មងចាប់សត្វព្រៃប្រវែង៨.២៦៥ម បង្គោលរបង១៥២បង្គោល ខ្ទម៥៨ កូនដើមដូង៨៧១ដើម កូនដើមចេក១៣៤ដើម និងកូនដើមគគីរខ្យាច់១៦ដើម។
- បានបោះស្លាកសញ្ញាហាមឃាត់ការកាប់រានដីព្រៃចំនួន១៩៥ស្លាក
- បានលែងសត្វព្រៃចូលក្នុងព្រៃធម្មជាតិចំនួន១៨៧ក្បាល
- បានពន្លត់ភ្លើងឆេះព្រៃចំនួន៥ករណី(ឃុំត្រពាំងរូង៣ករណី ឃុំដងពែង១ករណី និងឃុំអណ្តូងទឹក១ករណី)
- បានដាំកូនដើមក្រញូង កូនដើមកកោះ កូនដើមធ្នង់ និងកូនដើមនាងនួន ចំនួន២.៥០០ដើម
- បានធ្វើកិច្ចសន្យា និងអប់រំផ្សព្វផ្សាយផ្នែកច្បាប់ចំនួន១០៧ករណី (ដែនជម្រកសត្វព្រៃតាតៃចំនួន២៦ករណី ដែនជម្រកសត្វព្រៃពាមក្រសោបចំនួន២៤ករណី ឧទ្យានជាតិជួរភ្នំក្រវាញចំនួន២១ករណី ឧទ្យានជាតិបទុមសាគរចំនួន១២ករណី និងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងចំនួន២៤ករណី)
- បានពិនិត្យ និងបញ្ជាក់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុកចំនួន៤៤គម្រោង (ពិនិត្យលើផលប៉ះពាល់នៅក្នុងតំបន់ការពារធម្មជាតិ) ក្នុងនោះមាន គម្រោងសាងសង់ផ្លូវបេតុងអាមេ និងគម្រោងជួសជុលផ្លូវក្រួសក្រហម
- បានធ្វើកិច្ចសន្យាការពារបរិស្ថានចំនួន២៤ទីតាំង (ពិនិត្យលើផលប៉ះពាល់នៅក្នុងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងបំពុលបរិស្ថាន) ក្នុងនោះមាន៖
  - អាជីវកម្មខ្សាច់សំណង់ចំនួន៩ទីតាំង
  - សំណង់ផ្ទះចិញ្ចឹមសត្វត្រចៀកកាំចំនួន៩ទីតាំង
  - អាជីវកម្មទិញ ប្រមូលសំណល់អេតចាយចំនួន៦ទីតាំង

- បានលើកស្លាកសញ្ញាផ្សព្វផ្សាយអនុក្រឹត្យលេខ ១១៣អនក្រ.បកចំនួន២៥ស្លាក
- បានផ្សព្វផ្សាយដោយលើកបដាក្រោមប្រធានបទ «ការស្តារឡើងវិញប្រព័ន្ធអេកូឡូស៊ី» ក្នុងឱកាសប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា នៅពីមុខមន្ទីរ
- បានបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានាៗពាក់ព័ន្ធវិស័យបរិស្ថានជូនដល់ម្ចាស់ក្រុមហ៊ុន និងរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង នៅមន្ទីរបរិស្ថានខេត្ត ចំនួន១លើក
- បានផ្សព្វផ្សាយស្តីពីការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» ដល់ម្ចាស់អាជីវកម្ម សិប្បកម្មក្នុងសង្កាត់ទាំង៣នៃក្រុងខេមរភូមិន្ទ នៅមន្ទីរបរិស្ថានខេត្ត ចំនួន១លើក និងនៅតាមសាលារៀនបឋមសិក្សាចំនួន១១៣ វិទ្យាល័យចំនួន៧ អនុវិទ្យាល័យចំនួន២៦ សាលាមត្តេយ្យសិក្សាចំនួន១៦ និងសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង មានអ្នកចូលរួមពីលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ចំនួន២៤.០៤៤នាក់ ស្រី១១.៥៣៤នាក់។

## ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- ផ្លូវក្រាលកៅស៊ូ លើផ្លូវជាតិ និងផ្លូវខេត្ត ចំនួន៦ខ្សែ មានប្រវែងសរុប៧១,៦៩គ.ម ឆ្នាំ២០២៣
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវជាតិលេខ៤៨ ប្រភេទផ្ទៃផ្លូវបេតុង ប្រវែង៦,៨៦គ.ម ចាប់ផ្តើមពីចុងស្ពានកោះកុង គ.ម១៥១+៩០០ ដល់ចាំយាម (ព្រំដែនថៃ) គ.ម១៥៩+៤៦០ អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវជាតិលេខ៤៨ចាស់ ប្រភេទផ្ទៃផ្លូវក្រាលកៅស៊ូ២ជាន់DBST ប្រវែង៥,១០គ.ម ចាប់ផ្តើមពីផ្លូវបំបែកផ្លូវជាតិលេខ៤៨(គ.ម១៤៥) គ.ម0+000 ដល់ស្តូបគោរពវិញ្ញាណក្ខន្ធ គ.ម៥+១០០ អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវជាតិលេខ៤៨-៥ ប្រភេទផ្ទៃផ្លូវក្រាលកៅស៊ូ២ជាន់DBST ប្រវែង៤៥,២៦គ.មចាប់ផ្តើមពីផ្លូវជាតិលេខ៤៨ (អូរម្កាក់) គ.ម១+000 ដល់កោះស្តេច គ.ម៥0+៥៥0 អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៣ ប្រភេទផ្ទៃផ្លូវក្រាលកៅស៊ូ២ជាន់DBST ប្រវែង៦,៨៤គ.ម ចាប់ផ្តើមពីផ្លូវបំបែកផ្លូវជាតិលេខ៤៨(គ.ម៨) គ.ម0+000 ដល់ឃុំបឹងព្រាវ គ.ម៨+៣៤0 អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៥អា ប្រភេទផ្ទៃផ្លូវក្រាលកៅស៊ូ២ជាន់DBST ប្រវែង៥.៣០គ.ម ចាប់ផ្តើមពីភូមិចំការលើ(ឃុំថ្មស) គ.ម១៥+២០០ ដល់ភូមិថ្មស(ឃុំថ្មស) គ.ម២០+៥០០ អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៩អា ប្រភេទផ្ទៃផ្លូវក្រាលកៅស៊ូ២ជាន់DBST ប្រវែង២,៣៣គ.ម ចាប់ផ្តើមពីផ្លូវជាតិលេខ៤៨(គ.ម១៥៥) គ.ម0+000 ដល់ឃុំប៉ាក់ខ្លង គ.ម៨+៦៣0 អនុវត្តបាន១០០%
- ផ្លូវក្រាលដីល្បាយថ្ម លើផ្លូវខេត្ត ចំនួន៣ខ្សែ មានប្រវែងសរុប ៧៧,១០គ.ម ឆ្នាំ២០២៣
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៥អា ប្រភេទផ្ទៃផ្លូវក្រាលដីល្បាយថ្ម ប្រវែង២៤,៥0គ.ម ចាប់ផ្តើមពីភូមិជីត្រេះ(ផ្លូវ១៤៨៥) គ.ម0+000 ដល់ស្ពានចម្លងគោ(ថ្មស) គ.ម៣៣+៣00 អនុវត្តបាន១០០%
  - ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៦ ប្រភេទផ្ទៃផ្លូវក្រាលដីល្បាយថ្ម ប្រវែង៤០,២០គ.ម ចាប់ផ្តើមពីផ្លូវបំបែកផ្លូវជាតិលេខ៤៨ គ.ម0+000 ដល់ទីរួមស្រុកថ្មបាំង គ.ម៤០+២០០ អនុវត្តបាន១០០%

- ការងារថែទាំជាប្រចាំលើកំណាត់ផ្លូវខេត្តលេខ១៤៨៩ ប្រភេទផ្ទៃផ្លូវក្រាលដីល្បាយថ្ម ប្រវែង១២,៤០គ.ម ចាប់ផ្តើមពីផ្លូវបំបែកផ្លូវជាតិលេខ៤៨ គ.ម0+000 ដល់ឃុំទួលគគីរ គ.ម១២+៤០០ អនុវត្តបាន១០០%

– ការងារថែទាំខួប ឆ្នាំ២០២៣

- គម្រោងកាត់ជួសជុលផ្លូវជាតិលេខ៤៨ (៦១) ដោយចាក់ក្រាលបេតុងសរសៃដែក ទំហំ៥.០០០ម² កម្រាស់ 0,២៣ម ចន្លោះគ.ម១៥៧+៣០០ ដល់គ.ម១៥៩+២៣៣ ស្ថិតនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា សម្រេចបាន៦៦,៥៨%
- គម្រោងកាត់ជួសជុលផ្លូវខេត្តលេខ១៤៨៥អា (៦១) ដោយក្រាលកៅស៊ូពីរជាន់DBST ប្រវែង១.៣០០ម ទទឹង៨ម ចន្លោះគ.ម២៧+៣០០ ដល់គ.ម២៨+៦០០ ស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ សម្រេចបាន ៥៩,៦១%

– ការងារដឹកជញ្ជូនផ្លូវគោក

- ចុះបញ្ជីប្រភេទរថយន្តដឹកទំនិញធុនធំ ចំនួន១៧គ្រឿង
- ចុះបញ្ជីប្រភេទរថយន្តបែនធុនធ្ងន់ ចំនួន៤គ្រឿង
- ចុះបញ្ជីប្រភេទរថយន្តបែនធុនធ្ងន់(ស្តាំ) ចំនួន៦គ្រឿង
- ចុះបញ្ជី ប្រភេទរថយន្តដឹកអ្នកដំណើរធុនធំ ចំនួន៤គ្រឿង
- ផ្ទេរកម្មសិទ្ធិក្នុងខេត្ត ប្រភេទទោចក្រយានយន្ត ចំនួន១៩គ្រឿង
- ផ្ទេរកម្មសិទ្ធិក្នុងខេត្ត ប្រភេទរថយន្តគ្រួសារ ចំនួន៨គ្រឿង
- ផ្ទេរកម្មសិទ្ធិក្នុងខេត្ត ប្រភេទរថយន្តដឹកទំនិញធុនតូច ចំនួន៣គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទត្រីចក្រយានយន្ត ចំនួន១គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តគ្រួសារ ចំនួន៣៣គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តដឹកទំនិញ(គ្រួសារ)ចំនួន១៥គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តដឹកទំនិញធុនស្រាល ចំនួន១គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តដឹកអ្នកដំណើរធុនតូច ចំនួន១គ្រឿង
- ផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តដឹកទំនិញធុនធ្ងន់ ចំនួន៣គ្រឿង
- ការងារទុតិយតាប័ណ្ណសម្គាល់រថយន្តដឹកទំនិញធុនធំ ចំនួន១ប័ណ្ណ
- ការងារប្តូរព័ត៌មានយានយន្ត (ក្បាលសណ្តោង) ចំនួន១ប័ណ្ណ
- ពន្យារសុពលភាពប័ណ្ណបើកបរប្រភេទ (គ) ចំនួន១០ប័ណ្ណ
- ពន្យារសុពលភាពប័ណ្ណបើកបរប្រភេទ (ឃ២) ចំនួន៩ប័ណ្ណ
- ប្តូរប័ណ្ណបើកបរប្រភេទ (ឃ២) (រលុបមើលមិនឃើញ) ចំនួន១ប័ណ្ណ
- ទុតិយតាប័ណ្ណបើកបរប្រភេទ (គ) ចំនួន១ប័ណ្ណ
- ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត (ឆៀក)ចំនួន១.៧១៩គ្រឿង

– ការងារដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ

- ផ្តល់ប័ណ្ណសម្គាល់ជលយានយន្តដឹកទំនិញ ចំនួន១ប័ណ្ណ
- ផ្តល់ប័ណ្ណជលយានយន្តនេសាទ ចំនួន១ប័ណ្ណ
- ផ្តល់ច្បាប់អនុញ្ញាតធ្វើអាជីវកម្មជលយានយន្តដឹកទំនិញ ចំនួន២គ្រឿង
- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានយន្តដឹកទំនិញ ចំនួន២គ្រឿង
- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានយន្តនេសាទ ចំនួន៥០គ្រឿង

- ការងារសុវត្ថិភាពចរាចរណ៍
  - ចុះអប់រំផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកតាមទីសាធារណៈ និងចងបដាផ្សព្វផ្សាយពាក់ព័ន្ធច្បាប់ចរាចរណ៍ចំនួន៥លើក
  - បើកវគ្គបណ្តុះបណ្តាលស្តីពី ច្បាប់ចរាចរណ៍ផ្លូវគោកជូនដល់យុវជនកាកបាទក្រហមកម្ពុជាខេត្ត និងសិស្សានុសិស្សចំនួន១លើក
  - ចូលរួមផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកក្នុងកម្មវិធីភូមិ-ឃុំ មានសុវត្ថិភាពចំនួន១លើក
  - ចូលសហការជាមួយសមាគមសិស្ស និងនិស្សិតអាហារូបករណ៍ (អ.ម.ត) ផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ជូនប្រជាពលរដ្ឋ និងអ្នករត់ម៉ូតូឌុប ចំនួន១លើក
- បានចុះត្រួតពិនិត្យយានយន្ត និងយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសតាមក្រុង-ស្រុក ចំនួន៤៧លើក
  - បានត្រួតពិនិត្យរថយន្តសរុបចំនួន៣០៨គ្រឿង
  - រថយន្តត្រឹមត្រូវចំនួន២៨៣គ្រឿង
  - រថយន្តហួសសុពលភាពឆៀកចំនួន៨គ្រឿង
  - ទម្លាក់ទ្រុងរថយន្តខុសលក្ខណៈបច្ចេកទេសចំនួន១គ្រឿង
  - រថយន្តមិនមានលិខិតអាជីវកម្ម ចំនួន១គ្រឿង
  - អ្នកបើកបរប្រើប័ណ្ណបើកបរខុសប្រភេទយានយន្ត ចំនួន១២ប័ណ្ណ
  - ប័ណ្ណបើកបរហួសសុពលភាព ចំនួន២នាក់
  - អ្នកបើករថយន្តគ្មានប័ណ្ណបើកបរ ចំនួន១នាក់។

#### ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

### ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

#### ២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

**១.ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ៖**

**ការពង្រឹងតួនាទី និងភារកិច្ច ៖** ការងារនេះថ្នាក់ដឹកនាំខេត្ត បានពង្រឹងតួនាទី និងភារកិច្ច តាំងពីថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក រហូតដល់ថ្នាក់មូលដ្ឋាន ពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង សំដៅឆ្លុះបញ្ចាំងពីគុណភាព ប្រសិទ្ធភាព តម្លាភាព។ បន្ទាប់ពីបានអនុវត្តកន្លងមកនេះ ឃើញថាប្រជាពលរដ្ឋមានការសប្បាយចិត្ត និងមានជំនឿទុកចិត្តកាន់តែច្រើនឡើង។

**២.សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ ៖** បទល្មើសព្រហ្មទណ្ឌកើតឡើង ចំនួន៦៤លើក បើធៀបនឹងឆ្នាំ២០២២ (កើន៩លើក ស្មើនឹង១៦%) ក្នុងនោះមាន៖

- បទល្មើសឧក្រិដ្ឋ ៖ ១១លើក (ថយ៥លើក ស្មើនឹង៣១%)
- បទល្មើសមជ្ឈិម ៖ ៥៣លើក (កើន១៤លើក ស្មើនឹង៣៦%)
- ការខូចខាតបាត់បង់ ៖ បណ្តាលឱ្យស្លាប់មនុស្ស៧នាក់ ស្រី១នាក់ របួសធ្ងន់ ស្រាល១៩នាក់ ស្រី២នាក់ រងគ្រោះ៤២នាក់ ស្រី២២នាក់ បាត់រថយន្ត១គ្រឿង ម៉ូតូ៩គ្រឿង និងសម្ភារ មាស ប្រាក់មួយចំនួន

**លទ្ធផលបង្ក្រាប ៖** បទល្មើសដែលបានកើតឡើងខាងលើ កម្លាំងមានសមត្ថកិច្ចបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្ម បង្ក្រាបបានចំនួន៦០ករណី ស្មើនឹង៩៤% នៃបទល្មើសដែលបានកើតឡើង ឃាត់ខ្លួនជនសង្ស័យបានចំនួន១០៨នាក់ ស្រី៨នាក់ ក្នុងនោះ បទល្មើសឧក្រិដ្ឋ១០ករណី ឃាត់ខ្លួនជនសង្ស័យ១៣នាក់ប្រុស បទល្មើសមជ្ឈិម

៥០ករណី ឃាត់ខ្លួនជនសង្ស័យ៩៥នាក់ ស្រី៨នាក់ ដកហូតវត្ថុតាង រថយន្ត៣គ្រឿង ម៉ូតូ២១គ្រឿង និងសម្ភារ មាស ប្រាក់មួយចំនួន និងបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**ខ. បទល្មើសគ្រឿងញៀន៖** បានធ្វើការបង្ក្រាបបទល្មើស រក្សាទុក ជួញដូរ និងប្រើប្រាស់នូវសារធាតុញៀន ខុសច្បាប់ ចំនួន៧៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន១៣៧នាក់ ស្រី១៧នាក់

- ដកហូតវត្ថុតាង៖ ថ្នាំញៀនប្រភេទ ICE=៨៥០,៤២ក្រាម WY=១៩,៧២ក្រាម កញ្ឆា១៣,២៣ក្រាម ម៉ូតូ ១៨គ្រឿង ជញ្ជីងថ្លឹងថ្នាំញៀន៦គ្រឿង អាវុធខ្លី១ដើម អាវុធកែច្នៃ៥ដើម ទូរស័ព្ទ១០២គ្រឿង ទូកកន្ទុយវែង ៤គ្រឿង សម្ភារវេចខ្ចប់ និងឧបករណ៍ជក់ថ្នាំញៀនមួយចំនួន។ វត្ថុតាង និងមុខសញ្ញាជនសង្ស័យខាងលើ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**គ. ល្បែងស៊ីសងខុសច្បាប់ ៖** បង្ក្រាបល្បែងស៊ីសង(មាន់ប្រជល់ បៀរ អាប៉ោង) ចំនួន១១លើក ឃាត់ខ្លួនធ្វើកិច្ចសន្យាអប់រំចំនួន២០នាក់ ស្រី៩នាក់ និងដកហូតវត្ថុតាង ម៉ូតូ៦គ្រឿង មាន់ប្រជល់១៦ក្បាល បៀរ ៤ហ៊ូ អាប៉ោង ៥គ្រាប់ និងសម្ភារមួយចំនួន។

**ឃ. បទល្មើសផ្សេងៗ ៖** ពុំមានអ្វីកត់សម្គាល់។

➢ *វិធានការបង្ការ ៖* កម្លាំងជំនាញនៅតាមបណ្តាប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់ បានចុះធ្វើការអប់រំណែនាំប្រជាពលរដ្ឋ ក្នុងតំបន់ណាដែលមានការសង្ស័យថាមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ឱ្យមានការប្រុងប្រយ័ត្ន ហើយបើបានប្រទះឃើញត្រូវរាយការណ៍ជូនកម្លាំងសមត្ថកិច្ច ដើម្បីមានវិធានការការពារ ក្នុងនោះ ប្រជាពលរដ្ឋនៅស្រុកគិរីសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង បានប្រទះឃើញ និងបានរាយការណ៍ជូនសមត្ថកិច្ចនូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន១៥លើក មានចំនួន៥៧គ្រាប់ កម្លាំងជំនាញបានចងខ្សែហ៊ុមព័ទ្ធការពារគ្រោះថ្នាក់ និងបានប្រគល់ជូនអង្គភាពកម្ចាត់មីនCMAC និងHALLOTRUS យកទៅកម្ទេចចោល។ ចំណែកក្រុមការងារ CMAC បានប្រកាសរកឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២៣ មានចំនួន៨២គ្រាប់ និងបានធ្វើការកម្ទេចចោលអស់៥៦គ្រាប់។

**៣. សភាពការណ៍សណ្តាប់ធ្នាប់ និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍គ្រោះថ្នាក់ចរាចរណ៍ ៖** កើតឡើងចំនួន២៤លើក បើធៀបនឹងឆ្នាំ២០២២ (កើន៦លើក ស្មើនឹង ៣៣%) បណ្តាលឱ្យស្លាប់មនុស្ស២៦នាក់ របួស១៧នាក់ និងខូចខាតមធ្យោបាយ សម្ភារ មួយចំនួន។

➢ *វិធានការបង្ការ ៖* បានបញ្ចុះកម្លាំងជំនាញសហការជាមួយកម្លាំងពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ នៅតាមទីប្រជុំជន តាមដងផ្លូវកែងសំខាន់ៗ និងចុះអប់រំអាជីវករលក់ដូរជុំវិញផ្សារ លក់ដូរអមសងខាងផ្លូវឱ្យរៀបចំអីវ៉ាន់លក់ដូរឱ្យមានសណ្តាប់ធ្នាប់ល្អ សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដាយថាហេតុ។

**៤. បទល្មើសជួញដូរមនុស្ស ជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ៖** ពុំមានអ្វីកត់សម្គាល់។

**ខ. អំពើហិង្សាក្នុងគ្រួសារ ៖** កើតឡើងចំនួន៣លើក ក្នុងនោះ នៅក្នុងឃុំត្រពាំងរូង១លើក ឃុំបឹងព្រាវ១លើក និង ឃុំឫស្សីជ្រុំ ១លើក កើតឡើងពីការផឹកស្រវឹង និងការប្រច័ណ្ឌ(ជនសង្ស័យត្រូវបានឃាត់ខ្លួន)។

**គ. សកម្មភាពក្មេងទំនើង ៖** កើតឡើងចំនួន៨លើក ក្នុងនោះ៖

- អនុវត្តវិធានការរដ្ឋបាលចំនួន ២លើក នៅក្នុងឃុំអណ្តូងទឹក១លើក បង្កឡើងដោយ ក្មេងទំនើង១ក្រុម មានគ្នា ៦នាក់ប្រុស ធ្វើសកម្មភាពបង្កការអុកឡុកក្នុងមូលដ្ឋាន និងនៅក្នុងឃុំប៉ាក់ខ្លង១លើក ក្មេងទំនើង៣នាក់ ធ្វើសកម្មភាពបង្ហោះម៉ូតូ បង្កឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ។ ករណីនេះកម្លាំងជំនាញឃាត់ខ្លួន ធ្វើកិច្ចសន្យាអប់រំណែនាំប្រគល់ជូនអាណាព្យាបាលយកទៅអប់រំបន្ត។

- អនុវត្តវិធានការច្បាប់ចំនួន៦លើក ឃាត់ខ្លួន១៤នាក់ប្រុស ដែលបានធ្វើសកម្មភាពវាយតប់គ្នា គប់ និងវាយបំផ្លាញកញ្ចក់រថយន្តអ្នកដទៃ កើតឡើងនៅក្នុងសង្កាត់ស្ពាន់មានជ័យ២លើក សង្កាត់ស្ទឹងវែង១លើក ឃុំប៉ាក់ខ្លង១លើក ឃុំបឹងព្រាវ១លើក និងឃុំឫស្សីជ្រុំ ១លើក។ ករណីនេះ កម្លាំងជំនាញបានបំពេញសំណុំរឿងបញ្ជូនទៅសាលាដំបូង ខេត្តចាត់ការបន្ត។

*វិធានការការពារ៖* បានពង្រឹងកម្លាំងនៅថ្នាក់មូលដ្ឋាន ចុះល្បាតត្រួតពិនិត្យឃ្លាំមើលជាប្រចាំក្នុងមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កឡើងដោយក្មេងទំនើង ឬជនទំនើង។

**៥. ការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

រដ្ឋបាលខេត្ត ក្រុង ស្រុក បានខិតខំយកចិត្តទុកដាក់ពិនិត្យ និងដោះស្រាយជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ជាមួយគម្រោងវិនិយោគក្រុមហ៊ុនយូញៀន និងកំពុងធ្វើការសម្របសម្រួលលើទំនាស់ដីធ្លីដែលនៅសេសសល់បន្តិចបន្តួចបន្តទៀត។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

ការងារនេះត្រូវបានពង្រឹងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់មូលដ្ឋាន សំដៅគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ បរិស្ថាន និងអនាម័យក្នុងភូមិ ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព ពិសេសយើងបានអប់រំប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានាក្នុងការថែរក្សាបរិស្ថាន សុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារទាំងអស់គ្នា ដើម្បីធ្វើឱ្យមូលដ្ឋានខេត្តទាំងមូលមានសោភ័ណភាពស្អាត រមណីយដ្ឋានល្អ ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មកកម្សាន្តបានកាន់តែច្រើន។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖**

**I. គ្រោះមហន្តរាយបង្កឡើងដោយធម្មជាតិ**

**១.ខ្យល់កន្ត្រាក់៖** កើតឡើងចំនួន៦លើក បណ្តាលឱ្យប៉ះពាល់ប្រជាពលរដ្ឋចំនួន៧២០គ្រួសារ ស្មើនឹង៧២០ខ្នងផ្ទះ បង្កឱ្យមានមនុស្សស្លាប់ចំនួន១នាក់ប្រុស របួសធ្ងន់ចំនួន២នាក់ ស្រី១នាក់ និងរបួសស្រាលចំនួន៧នាក់ ស្រី៣នាក់ រលំផ្ទះទាំងស្រុង១៣ខ្នង វត្ត១កន្លែង វិហារសាសនា១កន្លែង សាលារៀន២ខ្នង និងអគាររដ្ឋបាលរបស់យោធា២កន្លែង ធ្វើឱ្យខូចខាតស័ង្កសីចំនួន២.៧៥១សន្លឹក និងហ្វីប្រូស៊ីម៉ងត៍ចំនួន ៧.៦០១សន្លឹក ព្រំហ្វីប្រូស៊ីម៉ងត៍ចំនួន៣៣គូ និងលិចទូក១២គ្រឿង។

**២.ទឹកជំនន់៖** មានករណីជំនន់ទឹកភ្លៀងកើតឡើងចំនួន៥លើក ក្នុងស្រុកចំនួន៥ និងឃុំចំនួន១៨ មានប្រជាពលរដ្ឋរងផលប៉ះពាល់ចំនួន៧៩៨គ្រួសារ បង្កឱ្យមានការខូចខាតទ្រព្យសម្បត្តិ ដីស្រែចម្ការ ហេដ្ឋារចនាសម្ព័ន្ធ និងសត្វចិញ្ចឹម

**៣.រន្ទះបាញ់៖** ករណីរន្ទះបាញ់កើតឡើង១លើក នៅភូមិឈូក ឃុំដីឧលើ ស្រុកស្រែអំបិល បណ្តាលឱ្យងាប់សត្វគោចំនួន៦ក្បាល។

**II. គ្រោះមហន្តរាយបង្កឡើងដោយមនុស្ស**

**១.អគ្គិភ័យ៖** កើតឡើងចំនួន១៣លើក បណ្តាលឱ្យប៉ះពាល់ប្រជាពលរដ្ឋចំនួន១៧គ្រួសារ មានមនុស្សចំនួន៣នាក់ រងរបួសធ្ងន់ស្រាល ក្នុងនោះ ឆេះផ្ទះទាំងស្រុងចំនួន១៣ខ្នង ខូចខាត១ខ្នង ខូចនាវាដឹកប្រេង១គ្រឿង ខូចទូកនេសាទ១គ្រឿង ឆេះដំណាំកៅស៊ូអស់ទំហំ៤ហិកតា ស្មើនឹង១.២០០ដើម រួមជាមួយនឹងទ្រព្យសម្បត្តិ និងសម្ភារប្រើប្រាស់មួយចំនួន។

**២.លង់ទឹក៖** កើតឡើងចំនួន១៨លើក បណ្តាលឱ្យស្លាប់មនុស្សចំនួន១៩នាក់ ស្រី១នាក់។

**III. ការឆ្លើយតប**

– លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានដឹកនាំក្រុមការងារ អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកា គ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់មួយចំនួន ចែកជូនគ្រួសាររងគ្រោះដោយករណីទឹកជំនន់នៅស្រុកថ្មបាំងចំនួន១លើក ស្រុកស្រែអំបិល

១លើក និងគ្រួសាររងគ្រោះដោយករណីខ្យល់កន្ត្រាក់ នៅស្រុកស្រែអំបិលចំនួន១លើក ចំណាយថវិកាអស់ចំនួន ៦៣.៥៩០.០០០រៀល។

– ក្រុមការងារលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានចុះពិនិត្យស្ថានភាពទឹកជំនន់ និងជួយជម្លៀសប្រជាពលរដ្ឋទៅកាន់ទីទួលបណ្ដោះអាសន្ន ព្រមទាំងបាននាំយកថវិកា គ្រឿងឧបភោគបរិភោគមួយចំនួន ចុះសួរសុខទុក្ខគ្រួសាររងគ្រោះ ដែលបានស្នាក់នៅបណ្ដោះអាសន្ននៅវត្តសិលាគិរីរង្សី (ហៅវត្តលើ) ក្នុងស្រុកថ្មបាំង ព្រមទាំង បានដឹកនាំក្រុមការងារចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកា ចំនួន២៦.០០០.០០០រៀល គ្រឿងឧបភោគបរិភោគមួយចំនួន ចែកជូនគ្រួសាររងគ្រោះដោយករណីលង់ទឹកសរុបចំនួន១៨លើក។

– សាខាកាកបាទក្រហមកម្ពុជា ខេត្តកោះកុង បានចុះសួរសុខទុក្ខ និងផ្ដល់អំណោយមនុស្សធម៌ ជូនប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយ សរុបចំនួន៣០០គ្រួសារ រួមមាន៖

- ខ្យល់កន្ត្រាក់ចំនួន ១៥៤គ្រួសារ (ក្រុងខេមរភូមិន្ទ១គ្រួសារ, ស្រុកមណ្ឌលសីមា៣៩គ្រួសារ, ស្រុកស្រែអំបិល៣០គ្រួសារ និងស្រុកគិរីសាគរ៨៤គ្រួសារ/១វត្ត)។
- អគ្គិភ័យចំនួន៩គ្រួសារ (ស្រុកបូទុមសាគរ៦គ្រួសារ, ស្រុកគិរីសាគរ១គ្រួសារ និងស្រុកស្រែអំបិល ២ គ្រួសារ)
- ជំនន់ទឹកភ្លៀងចំនួន១៣៧គ្រួសារ (ស្រុកថ្មបាំង៣៧គ្រួសារ និងស្រុក ស្រែអំបិល១០០គ្រួសារ)
- ➢ ថវិកាចំណាយសរុបចំនួន១២១.៨២៣.២០០រៀល។

– អនុសាខាកាកបាទក្រហមកម្ពុជាក្រុង-ស្រុកទាំង ៧ បានអនុវត្តជុំវិញការងារគ្រប់គ្រងគ្រោះមហន្តរាយ និងបានចុះសួរសុខទុក្ខ ព្រមទាំងផ្ដល់អំណោយមនុស្សធម៌ ជូនជនរងគ្រោះដោយគ្រោះមហន្តរាយ សរុបចំនួន ៣៩៤គ្រួសារ/នាក់ រួមមាន៖

- ផ្ដល់អំណោយប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ ចំនួន៣៧៦គ្រួសារ
- ផ្ដល់អំណោយប្រជាពលរដ្ឋរងគ្រោះ ដោយអគ្គិភ័យ ចំនួន១៤គ្រួសារ
- ផ្ដល់អំណោយដល់គ្រួសារសព រងគ្រោះថ្នាក់ចរាចរណ៍ ចំនួន៤នាក់។
- ➢ ថវិកាសរុបចំនួន១៤.៣៩៩.០០០រៀល

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ បានយកចិត្តទុកដាក់តាមដានអំពីស្ថានភាពជំនន់ទឹកភ្លៀង និងបានចុះសួរសុខទុក្ខ នាំយកអំណោយចែកជូនប្រជាពលរដ្ឋរងគ្រោះដោយគ្រោះមហន្តរាយជាបន្តបន្ទាប់។

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានធ្វើផ្សព្វផ្សាយអំពីបញ្ហាអាកាសធាតុ និងគ្រោះមហន្តរាយនានា ជូនប្រជាពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

### IV. ការត្រៀមបង្ការ

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានរៀបចំកែសម្រួលសមាសភាព ហើយរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បានរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្របតាម អនុក្រឹតលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ

– លេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បាន៖

- ធ្វើបច្ចុប្បន្នភាពផែនការឆ្លើយតបសង្គ្រោះបន្ទាន់ទឹកជំនន់ឆ្នាំ២០២៣
- សហការរៀបចំវគ្គបណ្ដុះបណ្ដាល ជូនដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ឃុំ សង្កាត់ អំពីយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ឃុំ សង្កាត់

- សហការ និងសម្របសម្រួលជាមួយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយស្រុក ចុះពិនិត្យស្ថានភាពគ្រោះមហន្តរាយជំនន់ទឹកភ្លៀង ប្រតិបត្តិការជម្លៀសជនរងគ្រោះទៅកាន់ទីទួលសុវត្ថិភាព និងសម្របសម្រួលក្នុងកិច្ចប្រតិបត្តិការក្នុងហេតុការ ដូចជា អគ្គិភ័យ ខ្យល់កន្ត្រាក់ និងឧបទ្ទវហេតុផ្សេងៗ ជាច្រើនទៀត
- សហការយ៉ាងជិតស្និទជាមួយអង្គការដៃគូ ដើម្បីអនុវត្តសកម្មភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការបម្រែបម្រួលអាកាសធាតុ
- ចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំ និងវគ្គ បណ្តុះបណ្តាលនានា ដែលរៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការដៃគូនានា
- បើកវគ្គបណ្តុះបណ្តាល រំលឹកឡើងវិញអំពីការប្រើប្រាស់ប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤ ជូនដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងវិទ្យាល័យ អនុវិទ្យាល័យ ទូទាំងខេត្ត ចំនួន២លើក
- ប្រារព្ធទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣ ក្រោមប្រធានបទ **"វិនិយោគពីថ្នាក់ជាតិនូវភាពធន់សហគមន៍"** ក្រោមអធិបតីភាព **លោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្ត** ដោយមានអ្នកចូលរួមចំនួន២៦៥នាក់ នៅសាលមហោស្រពខេត្តកោះកុង
- សហការជាមួយក្រុមការងារថ្នាក់ជាតិ អង្គការ People in Need រដ្ឋបាលស្រុក និងឃុំ ចុះដំឡើងឧបករណ៍វាស់កម្ពស់ទឹកជំនាន់ថ្មី (សេនស័រ Version5) នៅស្ពានតាតៃ ក្នុងស្រុកកោះកុង
- បានផ្សព្វផ្សាយអំពីបញ្ហាអាកាសធាតុ និងគ្រោះមហន្តរាយនានា ជូនប្រជាពលរដ្ឋតាមរយៈប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ (EWS1294)

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក បានរៀបចំបញ្ចូលទិន្នន័យ ទៅក្នុងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ និងអង្កេតតាមដានស្ថានការណ៍គ្រោះមហន្តរាយ (PRISM)

– សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានចុះផ្សព្វផ្សាយស្តីពី វិធានការការពារខ្លួនមុនគ្រោះមហន្តរាយធម្មជាតិកើតឡើងជូនដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋសរុបចំនួន២លើក ក្នុងស្រុកកោះកុង និងស្រុកបូទុមសាគរ មានអ្នកចូលរួមចំនួន១០៤នាក់ ស្រី៦៨នាក់

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានត្រៀមលក្ខណៈជាប្រចាំ ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលមានគ្រោះមហន្តរាយកើតមានឡើង

– កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ បានចុះបំផុសអប់រំប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្ន ចំពោះគ្រោះថ្នាក់អគ្គិភ័យ និងខ្យល់កន្ត្រាក់តាមរយៈវេទិកាផ្សព្វផ្សាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពក្នុងមូលដ្ឋាន។ល។

– **ឆ្លើយតបរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖** បានត្រៀមសម្ភារ បរិក្ខារ និងកម្លាំងសមត្ថកិច្ចសហការជាមួយជំនាញ ក្នុងការចុះអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ ករណីមានការរីករាលដាលជំងឺឆ្លងកាចសាហាវណាមួយ។

## ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

– ***សភាពការណ៍សន្តិសុខនៅតាមព្រំដែន ៖*** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨២៧ ដើរល្បាតម្ចាស់ការចំនួន៤១៧លើក និងល្បាតសហការជាមួយកងយោធពលខេមរភូមិន្ទ២៧លើក (ក្នុង១លើកៗ មានកម្លាំងពី៦នាក់ ទៅ១២នាក់) ប្រដាប់ដោយអាវុធគ្រប់ដៃ ជាពិសេសបានដាក់កម្លាំងតាមគោលដៅសំខាន់ៗចំនួន ១៣ចំណុច។

– ***សកម្មភាពសហគមន៍-ពលរដ្ឋតវ៉ាផ្សេងៗ ៖*** ការប្រមូលផ្តុំតវ៉ារបស់ប្រជាពលរដ្ឋមានចំនួន ៤៨លើក ដូចខាងក្រោម៖

○ *ការប្រមូលផ្តុំនៅថ្នាក់មូលដ្ឋានចំនួន១៨លើក* សហគមន៍តវ៉ាដីធ្លីរស់នៅក្នុងស្រុកស្រែអំបិល ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកកោះកុង បានប្រមូលផ្តុំគ្នានៅមូលដ្ឋាន សុំឱ្យអាជ្ញាធរឃុំ ស្រុក ជួយពន្លឿនការដោះស្រាយបញ្ហាដីធ្លីជូនពួកគាត់

○ *ការប្រមូលផ្តុំនៅមុខសាលាដំបូងខេត្តចំនួន១១លើក* សហគមន៍តវ៉ាដីធ្លី រស់នៅក្នុងស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ប្រមូលផ្តុំគ្នានៅមុខសាលាដំបូងខេត្ត ក្នុងមួយលើកៗ មានគ្នាពី១៩នាក់ ទៅ៨០នាក់ ស្រី៩នាក ទៅ៦១នាក់ មកគាំទ្រតំណាងរបស់ពួកគាត់ចូលខ្លួនតាមការកោះហៅរបស់តុលាការ និងចូលខ្លួនបំភ្លឺក្នុងសវនាការ

○ *ការប្រមូលផ្តុំនៅសាលាខេត្តចំនួន៧លើក* សហគមន៍តវ៉ាដីធ្លីរស់នៅក្នុងស្រុកស្រែអំបិល និងស្រុកបូទុមសាគរ បានប្រមូលផ្តុំគ្នានៅមុខសាលាខេត្ត ក្នុងមួយលើកៗមានគ្នាពី១៣នាក់ ស្រី៨នាក់ ទៅ១៤៣នាក់ ស្រី៩៩នាក់ ដើម្បីសុំឱ្យអាជ្ញាធរខេត្តជួយពន្លឿនការដោះស្រាយបញ្ហាដីធ្លីជូនពួកគាត់។

○ *ការប្រមូលផ្តុំឡើងទៅរាជធានីភ្នំពេញចំនួន៨លើក* សហគមន៍តវ៉ាដីធ្លីរស់នៅក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង បានប្រមូលផ្តុំគ្នាក្នុងមួយលើកៗ មានគ្នាពី ចំនួន៥នាក់ ស្រី៣នាក់ ទៅ១៤នាក់ ស្រី១១នាក់ ឡើងទៅរាជធានីភ្នំពេញ គោលបំណងទៅដាក់ញត្តិនៅខុទ្ទកាល័យសម្តេចតេជោ ទៅដាក់ញត្តិនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងទៅប្រជុំសហគមន៍ប្រចាំត្រីមាស នៅរាជធានីភ្នំពេញ។

○ *ការប្រមូលផ្តុំឡើងទៅសាលាឧទ្ធរណ៍ខេត្តព្រះសីហនុចំនួន៤លើក* សហគមន៍តវ៉ាដីធ្លីរស់នៅក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង មានគ្នាពី៦០នាក់ទៅ១០០នាក់ គោលបំណងទៅគាំទ្រតំណាងរបស់ពួកនៅខេត្តព្រះសីហនុ ដែលត្រូវសាលាឧទ្ធណ៍បើកសវនាការ។

– **សកម្មភាពគណបក្សនយោបាយ ៖** គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅខេត្តកោះកុង មានចំនួន១៣គណបក្ស បានដំណើរការឃោសនាគោលនយោបាយរបស់គណបក្សរៀងៗខ្លួន ដោយរលូនគ្មានការភ័យខ្លាច ឬបំភិតបំភ័យ គ្មានការគំរាមកំហែង គ្មានអំពើហិង្សា អ្វីកើតឡើងឡើយ និងក្រោយពេល គ.ជ.ប ប្រកាសលទ្ធផលបឋម និងលទ្ធផលជាស្ថាពរ គ្រប់គណបក្សនយោបាយ ទាំងអស់បានទទួលយកលទ្ធផល និងរក្សាភាពស្ងៀមស្ងាត់ ពុំមានសកម្មភាពអ្វីគួរឱ្យកត់សម្គាល់ឡើយ។

– **សកម្មភាពអង្គការ-សមាគម និងគ្រឹះស្ថានអប់រំ៖** មានចំនួន១៧លើក ក្នុងនោះ

- អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ចំនួន២លើក
- អង្គការ save the children ( សង្គ្រោះកុមារ ) ចំនួន២លើក
- អង្គការលីការដូ-អាដហុក ចំនួន២លើក
- អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ ចំនួន២លើក
- អង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ ចំនួន២លើក
- អង្គការកាត់តា អង្គការខាណា និង អង្គការខ៊ុំមិត ចំនួន១លើក
- អង្គការដៃគូសម្រាប់អភិវឌ្ឍន៍( PFDA ) ចំនួន១លើក
- អង្គការ CBN.Cambodia ចំនួន១លើក
- អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា( YCC ) ចំនួន១លើក
- អង្គការ យូ ដាប់បែលយូ អេស កម្ពុជា( UWS ) ចំនួន១លើក
- អង្គការដើម្បីអភិវឌ្ឍន៍សុខភាព ចំនួន១លើក។

– **សកម្មភាពសហគមន៍ ពលរដ្ឋ និងសាសនា៖** សភាពការណ៍សាសនាព្រះពុទ្ធ សាសនាគ្រឹះ និងអ៊ីស្លាមសាសនា បាននិងកំពុងប្រព្រឹត្តទៅតាមជំនឿសាសនានីមួយៗយ៉ាងល្អប្រសើរ និងមានសកម្មភាពគួរកត់សម្គាល់ចំនួន២២លើក ក្នុងនោះ៖ ក្រុមសាសនាយេស៊ូ បានធ្វើការផ្សព្វផ្សាយសាសនាព្រះយេស៊ូ នៅភូមិតានី ឃុំភ្ញីមាស ស្រុកគិរីសាគរ និងបានចែកនំ ចំណីជូនដល់ក្មេងៗ និងមនុស្សចាស់ ចំនួន២១លើក និងក្នុងស្រុកថ្មបាំង ចំនួន១លើក។

តារាងទី២៣៖ការគ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់ និងចរាចរណ៍

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គ្រោះថ្នាក់ចរាចរណ៍ | ០ | ២៤ | ២៤ |
| ២ | គ្រោះថ្នាក់ផ្សេងៗ | ០ | ៧៤ | ៧៤ |
| ៣ | បទល្មើសគ្រឿងញៀន | ០ | ៧៣ | ៧៣ |
| ៤ | បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | ០ | ០ | ០ |
| ៥ | បទល្មើសសេដ្ឋកិច្ច | ០ | ៣ | ៣ |
| ៦ | ល្បែងស៊ីសង | ០ | ១១ | ១១ |
| ៧ | ក្មេងទំនើង | ០ | ៨ | ៨ |
| ៨ | បទល្មើសផ្សេងៗ | ០ | ៦៤ | ៦៤ |

២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត

- **ការគ្រប់គ្រងតាមកំពង់ផែសមុទ្រ (តាមច្រកកំពង់ផែសមុទ្រស្រែអំបិល និងប៉ាក់ខ្លង)៖**
  - នាវិកជាជនបរទេសចេញ ចំនួន៦៣នាក់ ស្រី១៧នាក់ មាន១សញ្ជាតិថៃ ស្មើនឹងជលយានយន្តចំនួន១២គ្រឿង អូសស្រឡាងចំនួន៤៩គ្រឿង
  - នាវិកជាជនបរទេសចូល ចំនួន៦៣នាក់ ស្រី១៧នាក់ មាន១សញ្ជាតិថៃ ស្មើនឹងជលយានយន្តចំនួន១២គ្រឿង អូសស្រឡាងចំនួន៤៩គ្រឿង
  - នាវិកកម្ពុជាចូលចំនួន៣.២២៦នាក់ ស្រី០នាក់ ស្មើនឹងជលយានយន្ត១៤៩គ្រឿង
  - នាវិកកម្ពុជាចេញចំនួន៣.២២៦នាក់ ស្រី០នាក់ ស្មើនឹងជលយានយន្ត១៤៩គ្រឿង។
- **ការគ្រប់គ្រង ការស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ៖**
  - ជនបរទេសស្នាក់នៅរយៈពេលខ្លី សរុបចំនួន៦.៦០០នាក់ ស្រី២.៥១៤នាក់ មាន៥៤សញ្ជាតិ
  - ជនបរទេសស្នាក់នៅរយៈពេលវែង សរុបចំនួន២.៤០៩នាក់ ស្រី៦៣១នាក់ មាន៣៥សញ្ជាតិ។
- **ការគ្រប់គ្រងប្រព័ន្ធវត្តមានជនបរទេស (FPCS)៖**
  - កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស សហការជាមួយផ្នែកអន្តោប្រវេសន៍នៃអធិការដ្ឋាននគរបាលស្រុក បានផាកពិន័យតាមប្រកាសអន្តរក្រសួងលេខ១៧៥០ប្រ.កចំណុច(៨) ពីម្ចាស់លំនៅឋានផ្ទះជួល១កន្លែងស្ថិតនៅស្រុកមណ្ឌលសីមា ដែលមានជនបរទេសស្នាក់នៅចំនួន៦នាក់ ស្រី២នាក់ មាន២សញ្ជាតិ(ចិននិងហ្វីលីពីន)។ ចំណូលដែលទទួលបានពីការផាកពិន័យមានចំនួន៤.៥០០.០០០រៀល និងបានបញ្ជូនទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្តរួចរាល់
  - កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស សហការជាមួយកម្លាំងផ្នែកអន្តោប្រវេសន៍ នៃអធិការដ្ឋាននគរបាលក្រុង/ស្រុក បានចុះធ្វើបច្ចុប្បន្នភាពជនបរទេសក្នុងប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS) បានចំនួន១៩គោលដៅ ដែលមាន៖ សណ្ឋាគារ១គោលដៅ ហាងទំនិញ២គោលដៅ អាហារដ្ឋាន៣គោលដៅ ផ្ទះសំណាក់៤គោលដៅ ក្រុមហ៊ុន១គោលដៅ ផ្ទះជួល៦គោលដៅ ភោជនីដ្ឋាន១គោលដៅ និងសួនកម្សាន្ត១គោលដៅ ដោយពិនិត្យឃើញជនបរទេសស្នាក់នៅសរុបចំនួន២៤នាក់ ស្រី៥នាក់ មាន៤សញ្ជាតិ (ចិនវៀតណាម ថៃ ម៉ាឡេស៊ី) និងបានស្នើសុំបង្កើតគណនីថ្មីចំនួន១២គណនី
  - កម្លាំងផ្នែកអន្តោប្រវេសន៍ នៃអធិការដ្ឋាននគរបាលស្រុកមណ្ឌសីមា និងស្រុកបូទុមសាគរ បានចុះចែកសេចក្ដីជូនដំណឹងលេខ០៩២ស.ជ.ណា/អអ ចុះថ្ងៃទី១៧/០២/២០២៣ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ស្ដីពីការអនុវត្ត

វិធានការពិន័យអន្តរការណ៍ចំពោះម្ចាស់ឬអ្នកកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទ ដែលមិនបានជូនដំណឹងដល់កម្លាំងមានសមត្ថកិច្ចក្នុងរយៈពេល២៤ម៉ោង អំពីវត្តមានជនបរទេសដែលមកស្នាក់នៅក្នុងលំនៅដ្ឋានរបស់ខ្លួន។ ចែកជូនបានចំនួន១០គោលដៅ រួមមាន វីសត៣គោលដៅ និងផ្ទះសំណាក់៧គោលដៅ។

– **ការងារអធិការកិច្ចហត្ថពលកម្មបរទេស៖**

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស បានចូលរួមជាមួយក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មបរទេសរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមានកិច្ចសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចហត្ថពលករបរទេសបានចំនួន២៥គោលដៅ ក្នុងនោះ ក្រុមហ៊ុន និងរោងចក្រចំនួន១៣គោលដៅ កាស៊ីណូចំនួន២គោលដៅ ផ្ទះសំណាក់ចំនួន២គោលដៅ សណ្ឋាគារចំនួន១គោលដៅ ហាងកាត់សក់ចំនួន១គោលដៅ ភោជនីដ្ឋានចំនួន១គោលដៅ សាលារៀនចំនួន៣គោលដៅ ផ្សារចំនួន១គោលដៅ និងខារ៉ាអូខេចំនួន១គោលដៅ មានពលករសរុបចំនួន១៤.០៨៨នាក់ ស្រី៧.៨២៥នាក់ (ពលករខ្មែរចំនួន១១.៨៤៥នាក់ ស្រី៧.២៣៥នាក់ និងពលករបរទេសចំនួន២២៤៣នាក់ ស្រី៥៩០នាក់ ស្មើនឹង១៦សញ្ជាតិ)។

– **ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ៖**

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស និងផ្នែកគ្រប់គ្រងជនបរទេសនៃអធិការដ្ឋាននគរបាលក្រុង-ស្រុក បានប្រគល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេសអន្តោប្រវេសន្តសរុបចំនួន១៣៥គ្រួសារ មនុស្សរួមចំនួន២៣០នាក់ ស្រី១១១នាក់ ស្មើនឹង២៣០ប័ណ្ណ ស្រី១១១នាក់ មាន៤សញ្ជាតិ វៀតណាម-ចិន-មីយ៉ាន់ម៉ា-តង់ហ្សានៀ

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស បានទទួលពាក្យស្នើសុំប័ណ្ណស្នាក់នៅអន្ត្រៃយ៍ពីជនបរទេសអន្តោប្រវេសន្ត សរុបចំនួន១១៥គ្រួសារ មនុស្សរួមចំនួន១៩០នាក់ ស្រី៨៧នាក់ ស្មើនឹង៣សញ្ជាតិ វៀតណាម តង់ហ្សានៀ និងមីយ៉ាន់ម៉ា។ ថវិកាអាករដែលទទួលបានពីប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចំនួន៤៧.៥០០.០០០រៀល

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស បានធ្វើការផាកពិន័យអន្តរការចំពោះជនបរទេសអន្តោប្រវេសន្តស្នាក់នៅហួសសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ល្មើសមាត្រា២១ និងពិន័យតាមប្រកាសលេខ១៧៥០ ចំណុច(៥) ចំនួន១.០០០.០០០រៀល ចំពោះជនបរទេសចំនួន១នាក់ ជនជាតិតង់ហ្សានៀ កាន់ប័ណ្ណស្នាក់នៅលេខ2075303ហួសសុពលភាពថ្ងៃទី២៤.០១.២០២៣ និងបានណែនាំឱ្យបន្តនីតិវិធីសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្ត និងបានបញ្ជូនថវិកាទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្តរួចរាល់

○ កម្លាំងជំនាញផ្នែកគ្រប់គ្រងជនបរទេស និងផ្នែកអត្តសញ្ញាណកម្មនៃអធិការដ្ឋាននគរបាលស្រុកកោះកុង បានចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី របស់ជនបរទេសអន្តោរប្រវេសន្ត ជាជនជាតិវៀតណាម មានទីលំនៅភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង។ ឯកសាររួមមាន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន១សន្លឹក សបុត្របញ្ជាក់កំណើតចំនួន១ច្បាប់ និងសៀវភៅស្នាក់នៅ ក២ ចំនួន១ក្បាល

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស បានបញ្ជូនពាក្យស្នើរសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចំនួន១៧១នាក់ ស្រី៧៨នាក់ និងថវិកាចំនួន៤២.៧៥០.០០០រៀល ទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្តរួចរាល់

○ កម្លាំងការិយាល័យគ្រប់គ្រងជនបរទេស បានទទួលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ពីនាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត បានចំនួន២៣០ប័ណ្ណ ស្រី១១០ប័ណ្ណ

○ មានជនបរទេសបែបអន្តោប្រវេសន្តស្លាប់ចំនួន៦នាក់ ស្រី៣នាក់ មាន១សញ្ជាតិវៀតណាម។

– **ជនបរទេសរងគ្រោះដោយបទល្មើសផ្សេងៗ៖** ពុំមាន។

– **ជនបរទេសរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍៖** មាន៥លើក មនុស្សរួមចំនួន៥នាក់ប្រុស មាន៣សញ្ជាតិ (ឥណ្ឌាស្លាប់១នាក់ប្រុស ចិន៣នាក់ប្រុស និងកូរ៉េ១នាក់ប្រុស)។

– **ជនបរទេសល្មើសច្បាប់អន្តោប្រវេសន៍ ៖**

○ កម្លាំងនគរបាលការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី បានកសាងសំណុំរឿងចាប់បញ្ជូនជនជាតិចិន ចំនួន២នាក់ប្រុស ទៅស្នាក់ការត្រៀមបណ្តេញចេញខេត្តព្រះសីហនុ ពីបទលួចឆ្លងដែនដោយខុសច្បាប់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

○ កម្លាំងជំនាញនៃអធិការដ្ឋាននគរបាលស្រុកបូទុមសាគ បានចុះសាកសួរជនបរទេសចំនួន១នាក់ (ជនជាតិថៃ) ដែលមកស្នាក់នៅភូមិថ្មស ឃុំថ្មស ស្រុកបូទុមសាគរ (គ្មានលិខិតឆ្លងដែនជាប់ខ្លួន) ដែលមករស់នៅជាមួយគ្រួសារ។ក្រោយពីពិនិត្យឃើញថាជនបរទេសខាងលើស្នាក់នៅដោយគ្មានឯកសារគ្រប់គ្រាន់កម្លាំងជំនាញ បានណែនាំ និងធ្វើកិច្ចសន្យាឱ្យគាត់ត្រឡប់ទៅប្រទេសថៃវិញ ដើម្បីបំពេញបែបបទតាមច្បាប់ស្តីពីអន្តោប្រវេសន៍ នៃព្រះរាជណាចក្រកម្ពុជា។

– **ជនបរទេសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ៖** ពុំមាន។

– **ជនបរទេសប្រព្រឹត្តិបទល្មើសផ្សេងៗ ៖** កើតឡើងចំនួន២លើក

○ កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកមណ្ឌលសីមា នៅចំណុចព្រែក២ ស្ថិតនៅភូមិ៣ ឃុំប៉ាក់ខ្លង បានឃាត់ខ្លួនជនជាតិវៀតណាមចំនួន១នាក់ស្រី គ្មានលិខិតឆ្លង និងមានទីលំនៅមិនពិតប្រាកដករណីជួញដូររក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

○ កម្លាំងងនគរបាលនៃអធិការដ្ឋាននគរបាលក្រុងខេមរភូមិន្ទ បានឃាត់ខ្លួនជនសង្ស័យចំនួន១នាក់ប្រុស ជនជាតិវៀតណាម មានប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លេខ០០៩៥៣៦ ផុតកំណត់ថ្ងៃទី១២-០៤-២០២៥ និងបានដកហូតវត្ថុតាងរួមមាន ម្សៅក្រាមសថ្លាសង្ស័យជាសារធាតុញៀន១កញ្ចប់ធំ ៩កញ្ចប់តូចទូរស័ព្ទដៃ២គ្រឿង និងឧបករណ៍សម្រាប់ប្រើប្រាស់មួយចំនួន ស្ថិតក្នុងភូមិ២ សង្កាត់ស្មាច់មានជ័យ

– **ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុផ្សេងៗ៖** មាន១៨លើក មនុស្សរួមចំនួន១៨នាក់ ស្រី១នាក់ មាន៥សញ្ជាតិ ក្នុងនោះ ហូឡង់ស្លាប់១នាក់ប្រុស ចិន១៤នាក់ប្រុស(ស្លាប់១២ របួស២នាក់) ថៃស្លាប់១នាក់ប្រុស អាមេរិចស្លាប់១នាក់ប្រុស និងវៀតណាមស្លាប់១នាក់ស្រី។

– **កិច្ចប្រតិបត្តិការ ៖**

○ បានជួយសង្គ្រោះជនបរទេសតាមបណ្តឹងចំនួន៤៩លើក មនុស្សរួមចំនួន១៣៥នាក់ ស្រី៤នាក់ មាន៧សញ្ជាតិ ក្នុងនោះ មានចិន៩៧នាក់ ស្រី៣នាក់ ម៉ាឡេស៊ី១នាក់ប្រុស ហ្វីលីពីន២៦នាក់ ស្រី១នាក់ ឥណ្ឌា៧នាក់ប្រុស ប៉ាហ្គីស្ថាន២នាក់ប្រុស តៃវ៉ាន់១នាក់ប្រុស និងកូរ៉េ១នាក់ប្រុស។ តាមបណ្តឹងក្នុងទំព័រហ្វេសប៊ុករបស់ **សម្តេចក្រឡាហោម ស ខេង** និងតាមបណ្តឹងទំព័រហ្វេសប៊ុករបស់ អគ្គស្នងការដ្ឋាននរគបាលជាតិ

➢ **បញ្ជាក់៖** ជនបរទេសដែលត្រូវបានជួយសង្គ្រោះតាមបណ្តឹងខាងលើត្រូវបាននគរបាលផែនការងារសន្តិសុខនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង កសាងសំណុំរឿងបញ្ជូនទៅនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិដើម្បីបន្តនីតិវិធី ។

○ មាននាវាចំនួន១គ្រឿង បានចតនៅកំពង់ផែកោះកុងផតមេនេចម៉ិន(KOH KONG PORT MANAGEMENT CO.,LTD) ស្ថិតនៅស្រុកគិរីសាគរ បាននាំទំនិញជីប្រភេទPANDAMANចេញពីប្រទេសចិនមកកម្ពុជា មានទំងន់សរុប ៤.១៥០.៥៩៦,១០គ.ក្រ ដើម្បីដឹកបញ្ជូនទៅរាជធានីភ្នំពេញ។

### ២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ

– បានសម្របសម្រួលជូនក្រុមការងាររបស់អង្គការសម្ព័ន្ធភាពជួយសហគមន៍ឲ្យរីកចម្រើនអន្តរជាតិ(CEAI) សហការជាមួយក្រុមគ្រូពេទ្យមកពីប្រទេសសឹង្ហបុរីចុះមកពិនិត្យព្យាបាលជំងឺដល់មន្ត្រីចំនួន៧នាក់ស្ត្រី៣នាក់ និងជនជាប់ឃុំចំនួន១៧១នាក់ ស្ត្រី១៨ នាក់ នៅពន្ធនាគារខេត្តកោះកុង

- បានសម្របសម្រួលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មកចែកអំណោយដល់ជនជាប់ឃុំជាស្ត្រីដែលមានកូនតាមម្តាយ ចំនួន៥លើក
- បានអប់រំមន្ត្រីឱ្យយល់ដឹងអំពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ រៀងរាល់ខែ
- បានធ្វើការអប់រំជនជាប់ឃុំឱ្យយល់ដឹងពី ក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល រៀងរាល់ខែ
- បានបង្រៀនថ្នាក់អក្ខរកម្មដល់ទណ្ឌិត ចំនួន១៥នាក់បុរស (គ្រូបង្គោលជាមន្ត្រីពន្ធនគារ)សហការសម្របសម្រួលពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ រយៈពេល៨ខែ
- បានបណ្តុះបណ្តាល វគ្គកុំព្យូទ័រ ដល់ទណ្ឌិតចំនួន១២នាក់បុរស និងថ្នាក់ភាសាអង់គ្លេសចំនួន៨នាក់ បុរសចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ រយៈពេល៦ខែ ក្រោមកាឧបត្ថម្ភពីអង្គការសម្ព័ន្ធភាពជួយសហគមន៍ឱ្យរីកចម្រើន (CEAI )
- បានបណ្តុះបណ្តាលដល់ទណ្ឌិតចំនួន៤ជំនាញ ស្មើនឹង១០វគ្គ រយៈពេល៤ខែ ក្នុងនោះមាន៖ ជំនាញជួសជុលអគ្គិសនី៣វគ្គ ជាងកំបោរ២វគ្គ ជួសជុលម៉ូតូ២វគ្គ ជួសជុលបរិក្ខារអេឡិចត្រូនិក៣វគ្គ ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រក្រោមកាឧបត្ថម្ភពីវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជាខេត្តកោះកុង
- បានសម្របសម្រួលដល់ក្រុមគ្រូពេទ្យអង្គការលីកាដូមកពិនិត្យព្យាបាល និងផ្តល់ឱសថដល់ជនជាប់ឃុំចំនួន១២លើក និងផ្តល់ប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំចំនួន១៥នាក់ ចំនួន១២លើក
- បានសម្របសម្រួលដល់អង្គការលីកាដូ ឱ្យមកចែកអំណោយដល់ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ និងកូនតាមម្តាយចំនួន១២លើក
- បានបណ្តុះបណ្តាលជនជាប់ឃុំឱ្យមានជំនាញកាត់សក់ ដេរប៉ាក់ ជាងឈើជាងសំណង់ ជាងជួសជុលរថយន្តនិងផលិតឥដ្ឋបុកជារៀងរាល់ខែ
- បានពិនិត្យ និងឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំឃាំង រៀងរាល់សប្តាហ៍
- បានពិនិត្យ និងថែទាំគ្រប់សំណង់អគារក្នុងពន្ធនាគារជាប្រចាំ
- បានពិនិត្យ និងតាមដានគ្រប់ប្រព័ន្ធភ្លើងក្នុងពន្ធនាគាររៀងរាល់សប្តាហ៍
- ជនជាប់ឃុំជាក់ស្តែងមានចំនួន៥៦៥ នាក់ ស្ត្រី៣៦នាក់ ដោយចែកចេញជា៖
    - ជនត្រូវចោទ មានចំនួន៩៩នាក់ ស្ត្រី៥នាក់
    - ជនជាប់ចោទ មានចំនួន៩២នាក់ ស្ត្រី១២នាក់
    - ពិរុទ្ធជន មានចំនួន១៦៤នាក់ ស្ត្រី១៥នាក់
    - ទណ្ឌិត មានចំនួន២១០នាក់ ស្ត្រី៤នាក់

ក្នុងនោះមាន៖

- ជនជាតិបរទេស មានចំនួន១៦នាក់ ស្ត្រី៣នាក់ (វៀតណាមចំនួន១១នាក់ ស្ត្រី២នាក់ ថៃ២នាក់ ចិន១នាក់ ម៉ាឡេស៊ី២នាក់ ស្ត្រី១នាក់)
- អនីតិជនមានចំនួន៣៥នាក់ ស្ត្រី១នាក់
- កូនតាមម្តាយមានចំនួន២នាក់ប្រុស

- ជនជាប់ឃុំចូលថ្មីប្រចាំឆ្នាំ២០២៣ មានចំនួន៣៩២នាក់ ស្ត្រី៣៦នាក់
- ជនជាប់ឃុំថយចុះប្រចាំឆ្នាំ២០២៣ មានចំនួន៣៩៤នាក់ ស្ត្រី២៩នាក់
- ទណ្ឌិតស្លាប់នៅមន្ទីរពេទ្យបង្អែកស្មាច់មានជ័យខេត្តកោះកុងមានចំនួន២នាក់ (បុរស)
- ផ្ទេរចេញចំនួន១២នាក់ ស្ត្រី៥នាក់
- ដោះលែងជនជាប់ចោទចំនួន៤៨នាក់ ស្ត្រី៩នាក់

– ដោះលែងជនជាប់ចោទចំនួន២០នាក់ ស្ត្រី១នាក់
– ដោះលែងពិរុទ្ធជនចំនួន៤៦នាក់ ស្ត្រី៩នាក់
– ដោះលែងទណ្ឌិតចំនួន២១៦នាក់ ស្ត្រី៥នាក់។

## ២.៤.៥-ការងារផ្សេងៗ

– (ពុំមាន)។

## ផ្នែកទី៣-បញ្ហាប្រឈម និងសំណើដោះស្រាយ

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| ១ | ទម្រង់ពាក្យស្នើសុំសេវា និងឯកសារភ្ជាប់ក្នុងអង្គភាពច្រកចេញ ចូលតែមួយ មិនទាន់ឯកភាពគ្នាជាស្តង់ដាររួមក្នុងក្របខ័ណ្ឌទូទាំងប្រទេស | ស្នើសុំក្រសួងមហាផ្ទៃ ជួយជំរុញ និងរៀបចំដាក់ចេញឱ្យប្រើប្រាស់ជាស្តង់ដាររួមតែមួយ |
| ២ | ក្រុមហ៊ុនមួយចំនួន ទទួលបានសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ | -ស្នើឱ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| ៣ | ដីចម្ការឈើអាកាស្យា ស្ថិតនៅភូមិ១ សង្កាត់ស្មាច់-មានជ័យ ក្រុងខេមរភូមិន្ទ នៅតែមានការរំលោភទន្ទ្រាន កាន់កាប់ ពីសំណាក់ប្រជាពលរដ្ឋដោយខុសច្បាប់ | ស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់នីតិវិធីក្នុងការដោះស្រាយ |
| ៤ | មន្ទីរធនធានទឹក និងឧតុនិយម ខ្វះខាតគ្រឿងចក្រដែលបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រក្នុងខេត្ត | ស្នើសុំគ្រឿងចក្របន្ថែមពីក្រសួងធនធានទឹក និងឧតុនិយម |
| ៥ | សមត្ថភាពមន្ត្រីជំនាញរបស់មន្ទីរផែនការនៅមានកម្រិតក្នុងការវិភាគទិន្នន័យ ចងក្រង និងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ស្របពេលដែលបច្ចេកវិទ្យាកាន់តែទំនើប | ស្នើសុំក្រសួងផែនការ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមតាមជំនាញ ផែនការ ស្ថិតិ និងវិធីសាស្ត្រវិភាគការបម្រែបម្រួលប្រជាជន និងកាអភិវឌ្ឍន៍ និងការរៀបចំចងក្រងទិន្នន័យ |
| ៦ | មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខ្វះមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីបំពេញការងារនៅក្នុងមន្ទីរ | ស្នើសុំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងផ្តល់មន្ត្រីជាប់កិច្ចសន្យាបន្ថែមទៀត |
| ៧ | មន្ទីរធម្មការ និងសាសនាខេត្តៈ<br>-ខ្វះមន្ត្រីជាច្រើននាក់ដើម្បីបម្រើការងារ<br>-អគារមន្ទីរធម្មការ និងសាសនា សម្រាប់បម្រើការងារសព្វថ្ងៃ មានសភាពចាស់ អាយុកាលតាំងពីសម័យទសវត្សរ៍ទី៦០ | ស្នើសុំក្រសួងធម្មការ និងសាសនាៈ<br>- បន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែម<br>- ជួយសាងសង់អគារមន្ទីរធម្មការ និងសាសនាខេត្តថ្មី |

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| | -លិខិតបទដ្ឋាននានានៃការគ្រប់គ្រងពាហិរសាសនានៅមិនទាន់មានភាពច្បាស់លាស់ | - ធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការអនុវត្តការងារពាហិរសាសនា |
| ៨ | វិសាលភាពផ្សព្វផ្សាយវិទ្យុរបស់មន្ទីរព័ត៌មានខេត្តពុំទាន់បានគ្របដណ្តប់ទូទាំងខេត្ត | ស្នើសុំក្រសួងព័ត៌មាន ជួយដំឡើងកម្លាំងផ្សាយរបស់វិទ្យុឱ្យបានទូលំទូលាយ |
| ៩ | ជំនាញបច្ចេកទេសរបស់មន្ត្រី នៅក្នុងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍មួយចំនួននៅមានកម្រិត | ស្នើសុំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បើកវគ្គបណ្តុះបណ្តាលអំពីជំនាញបច្ចេកទេស និងវគ្គបំប៉ននានា |
| ១០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខ្វះមន្ត្រីរាជការបម្រើការងារ | ស្នើសុំទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជ្រើសរើសមន្ត្រីក្របខ័ណ្ឌ |
| ១១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ អនុវិទ្យាល័យព្រែកខ្សាច់ស្ថិតក្នុងឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ពុំមានអគារសិក្សាសម្រាប់បង្រៀន និងរៀនបានត្រឹមត្រូវ ហើយបច្ចុប្បន្នបានខ្ចីបន្ទប់ និងថ្នាក់រៀនរបស់សាលាបឋមសិក្សាព្រែកខ្សាច់ ដើម្បីបង្រៀន | ស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ជួយដោះស្រាយ |
| ១២ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ សាលាឧបសម្ព័ន្ធវង់កាថាក់ ស្ថិតក្នុងឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ពុំមានអគារសិក្សាសម្រាប់ដំណើរការបង្រៀន និងរៀន ដោយបច្ចុប្បន្នសាលាបានខ្ចីអគារសិក្សាសាលាឥស្លាម | ស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ជួយដោះស្រាយ |
| ១៣ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ សាលាបឋមសិក្សាព្រែកខ្យងមាន៣បន្ទប់ ស្ថិតក្នុងឃុំតានូន ស្រុកបូទុមសាគរ ប៉ុន្តែអគារសិក្សាមានសភាពចាស់ទ្រុឌទ្រោម ពុំមានសុវត្ថិភាពដល់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ | ស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ជួយដោះស្រាយ |
| ១៤ | មន្ទីរកិច្ចការនារីខេត្តៈ ខ្វះមន្ត្រីបម្រើការងារក្នុងមន្ទីរ | ស្នើសុំទៅក្រសួងកិច្ចការនារី ជ្រើសរើសមន្ត្រីក្របខ័ណ្ឌបន្ថែម |

## ផ្នែកទី៤÷ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់

### ៤.១-រដ្ឋបាលខេត្ត

#### ៤.១.១-ការងាររដ្ឋបាល

- សម្របសម្រួលរៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- សម្របសម្រួលរៀបចំវេទិការបស់ក្រុមប្រឹក្សាខេត្តតាមបណ្តា ក្រុង ស្រុក
- សម្របសម្រួលរៀបចំកិច្ចប្រជុំអឌ្ឍមាស ប្រចាំខែ និងកិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាល
- កត់ត្រាសកម្មភាពការងារប្រចាំថ្ងៃរបស់គណៈអភិបាល

- ប្រមូលចងក្រងរបាយការណ៍អនុវត្តការងាររបស់គណៈអភិបាលខេត្តប្រចាំខែ
- រៀបចំរបាយការណ៍របស់រដ្ឋបាលខេត្ត
- ចុះយកព័ត៌មានក្នុងកម្មវិធីផ្សេងៗរបស់ខេត្ត
- សម្របសម្រួលរៀបចំសន្និបាតប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២៥
- សហការសម្របសម្រួលរៀបចំពិធីសម្ពោធស្ពាន **សម្តេចតេជោ ហ៊ុន សែន កោះយ៉** និងពិធីសំណេះសំណាលជាមួយកម្មករកម្មការនីនៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- សហការសម្របសម្រួលរៀបចំពិធីបុណ្យសមុទ្រលើកទី១១ ជុំទី៣ ឆ្នាំ២០២៤
- សហការសម្របសម្រួលរៀបចំពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យសាសនា នានា
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬ ខូចខាតដោយយថាហេតុ តាមរយៈការស្នើសុំរបស់សាមីខ្លួន
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈរដ្ឋបាលឃុំ សង្កាត់
- បញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.cdepart.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋ។

### ៤.១.២-ការងារផែនការ និងវិនិយោគ

- ចុះសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងអភិវឌ្ឍន៍មូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៤
- ចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០២៣ និងឆ្នាំ២០២៤
- ចូលរួមសម្របសម្រួលកិច្ចប្រជុំរៀបចំបើកសំណើដេញថ្លៃគម្រោងឃុំ សង្កាត់ ឆ្នាំ២០២៤
- ចូលរួមសម្របសម្រួលកិច្ចប្រជុំរៀបចំកិច្ចសន្យាអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៤
- គាំទ្រការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាល ឃុំ សង្កាត់
- រៀបចំបញ្ជីឈ្មោះអ្នកទទួលការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឆ្នាំ២០២៤
- រៀបចំបញ្ជីសម្ភារស្តង់ដារសម្រាប់គ្រោងហេដ្ឋារចនាសម្ព័ន្ធឆ្នាំ២០២៤
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្នាំ២០២៥-២០២៧
- រៀបចំផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ២០២៤-២០២៨ របស់រដ្ឋបាលខេត្ត
- គាំទ្រ ការរៀបចំផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ២០២៤-២០២៨ របស់ក្រុង ស្រុក
- ត្រៀមរៀបចំសេចក្តីសម្រេចរួមស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)
- ចងក្រងទិន្នន័យ និងរបាយការណ៍ស្តីពីការវិនិយោគនានាក្នុងខេត្តកោះកុង
- គាំទ្រ និងសម្របសម្រួលការអនុវត្តគម្រោងអាហារូបត្ថម្ភកម្ពុជា ខេត្តកោះកុង។

### ៤.១.៣-ការគ្រប់គ្រងធនធានមនុស្ស

- ត្រៀមរៀបចំធ្វើផែនការក្របខ័ណ្ឌសម្រាប់ឆ្នាំ២០២៥
- ត្រៀមជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០២៤ តាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ត្រៀមរៀបចំធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៤ ជូនក្រសួងមហាផ្ទៃ
- ត្រៀមរៀបចំធ្វើសំណើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនអតីតភាពការងារ និងតាមកម្រិតសញ្ញាបត្រ ជូនគណៈអភិបាលខេត្ត ក្រុង ស្រុក នាយករដ្ឋបាលខេត្ត ក្រុង ស្រុក និងស្មៀនឃុំ សង្កាត់ទូទាំងខេត្តកោះកុង

- ត្រៀមរៀបចំធ្វើជីកានានាពាក់ព័ន្ធការងារគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលខេត្ត ក្រុង ស្រុក
- ត្រៀមសហការសម្របសម្រួលតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៤។

### ៤.១.៤-ការងារអន្តរវិស័យ

- បន្តសហការជាមួយ ក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីនៅសេសសល់ជូនប្រជាពលរដ្ឋ
- បន្តសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម និងសហគមន៍មូលដ្ឋាននានា ដែលមានប្រតិបត្តិការក្នុងភូមិសាស្ត្រខេត្ត
- បន្តចូលរួមសហការសម្របសម្រួលចុះស្រង់ទិន្នន័យប្រជាពលរដ្ឋស្នើសុំដីសម្បទានសង្គមកិច្ចក្នុងស្រុកស្រែអំបិល។

### ៤.១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ

- បន្តការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ
- សម្របសម្រួលកិច្ចការប្រចាំថ្ងៃក្នុងអង្គភាព និងធ្វើរបាយការណ៍ជូនក្រសួងពាក់ព័ន្ធ
- ត្រៀមរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីការអនុវត្តលើការផ្តល់សេវារដ្ឋបាល តាមរយៈអង្គភាពច្រកចេញចូលតែមួយខេត្ត ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក និងយន្តការច្រកចេញចូលតែមួយឃុំ សង្កាត់។

### ៤.១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

- ប្រចាំការនៅគុពិសេស ក្នុងអង្គភាពច្រកចេញចូលតែមួយចំនួន១២ម៉ោង ក្នុង១សប្តាហ៍
- ចុះបើកប្រអប់សំបុត្រការិយាល័យប្រជាពលរដ្ឋខេត្ត នៅតាមមុខមន្ទីរមួយចំនួន និងក្រុង ស្រុក ឃុំ សង្កាត់
- ចាត់វិធានការដោះស្រាយបណ្តឹងក្នុងសមត្ថកិច្ចឱ្យបានឆាប់បំផុត ដើម្បីបង្កើនទំនុកចិត្តជូនប្រជាពលរដ្ឋ
- រៀបចំកិច្ចប្រជុំប្រចាំខែនីមួយៗ ឆ្នាំ២០២៤ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងារ
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច សមត្ថកិច្ច និងសិទ្ធិអំណាច របស់ការិយាល័យប្រជាពលរដ្ឋខេត្ត នៅតាមបណ្តាមូលដ្ឋានភូមិ ឃុំ សង្កាត់ក្នុងខេត្តកោះកុង

### ៤.១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បន្តសិក្សា និងគាំទ្រដោះស្រាយបញ្ហាផ្នែកច្បាប់ជូនរដ្ឋបាលខេត្ត។

### ៤.១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

- បន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម
- បន្តសហការទប់ស្កាត់នូវរាល់អំពើរត់គេចពន្ធតាមច្រកទ្វារ ដូចជា ទំនិញគ្រប់ប្រភេទ ឬការជួញដូរមនុស្សឆ្លងដែន ជួញដូរគ្រឿងញៀន អាវុធជាតិផ្ទុះ និងវត្ថុបុរាណផ្សេងៗ
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសជិតខាង ដោយឈរលើគោលជំហរ គោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរ ក្នុងតំបន់ព្រំដែន
- បន្តពង្រឹងការយាមល្បាតការពារគ្រប់គោលដៅ ដើម្បីរក្សាសន្តិសុខសុវត្ថិភាពក្នុងភូមិសាស្ត្រព្រំដែនឱ្យបានល្អប្រសើរ
- បន្តអនុវត្តជាប្រចាំ នូវការងារសន្តិសុខ សណ្តាប់ធ្នាប់ និងថែរក្សាអនាម័យបរិស្ថាន នៅបរិវេណច្រកទ្វារព្រំដែនអន្តរជាតិចាំយាម
- បន្តត្រួតពិនិត្យលិខិតស្នាម មនុស្ស មធ្យោបាយ ទំនិញចេញចូល និងទប់ស្កាត់បទល្មើសជ្រៀតចូលដោយខុសច្បាប់។

### ៤.១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

- រៀបចំអាណត្តិបើកបៀវត្សប្រចាំខែនីមួយៗ ឆ្នាំ២០២៤
- ត្រៀមរៀបចំទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ត្រៀមរៀបចំនីតិវិធីជម្រុះទ្រព្យសម្បត្តិខូចគុណភាពចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៤។

### ៤.១.១០-ការងារលទ្ធកម្ម

- ត្រៀមរៀបចំសេចក្តីជូនដំណឹងដេញថ្លៃលទ្ធកម្មសំណង់ឆ្នាំ២០២៤
- ត្រៀមបើកឯកសារដេញថ្លៃលទ្ធកម្មទំនិញ និងសំណង់ឆ្នាំ២០២៤
- ត្រៀមចរចាថ្លៃលទ្ធកម្មសំណង់ឆ្នាំ២០២៤
- ត្រៀមបញ្ចប់សុពលភាពសំណង់ឆ្នាំ២០២២ និង២០២៣។

### ៤.១.១១-ការងារសុខាភិបាល

- បន្តផ្តល់សេវាពិនិត្យ និងពិគ្រោះព្យាបាលជំងឺនៅមន្ទីរពេទ្យ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព
- បន្តផ្តល់សេវាជូនដល់ស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះមុន-ក្រោយសម្រាល និងមកសម្រាលកូននៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ
- បន្តផ្តល់សេវាផ្តល់ថ្នាំបង្ការ ១១មុខដល់កុមារ និងផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះ នៅតាមមណ្ឌលសុខភាពទាំង១៣
- បន្តផ្តល់សេវាព្យាកំណើតនៅតាមមណ្ឌលសុខភាពទាំង១៣
- បន្តចាត់ក្រុមការងារចត្តាឡីស័កប្រចាំការច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ដើម្បីពិនិត្យកម្តៅ លើអ្នកធ្វើដំណើរ អ្នកបើកបររថយន្តចេញ-ចូលច្រកព្រំដែនជារៀងរាល់ថ្ងៃព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគទៅលើរថយន្តដឹកទំនិញចេញ-ចូល
- បន្តការចាក់វ៉ាក់សាំងកូវីដ-១៩ដូសមូលដ្ឋាន និងដូសជំរុញជូនប្រជាជននៅតាមទីតាំងចាក់មណ្ឌលសុខភាពទាំង១៣ និងប៉ុស្តិ៍សុខភាពទាំង១០
- បន្តអប់រំផ្សព្វផ្សាយបង្ការ និងព្យាលជំងឺឆ្លងផ្សេងៗ ដូចជា គ្រុនឈាម គ្រុនឈឹក គ្រុនចាញ់ របេង និងជំងឺអេដស៍
- បន្តធ្វើតេស្តដើម្បីស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងបន្តពង្រឹងការព្យាបាលប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ស្តីពីការចូលរួមការងារលុបបំបាត់ជំងឺគ្រុនចាញ់ជាអន្តរវិស័យ
- បន្តអប់រំសុខភាពស្តីពីវិធានការការពារជំងឺគ្រុនឈាមតាមរយៈបុគ្គលិកសុខាភិបាល នៅពេលប្រជាពលរដ្ឋមកទទួលសេវានៅមូលដ្ឋាន និងសិស្សានុសិស្សនៅតាមសាលារៀន។

### ៤.១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

- បន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីឈ្វេងយល់អំពីកង្វល់ និងតម្រូវការនានា នៅក្នុងមូលដ្ឋាន
- ប្រមូលចងក្រងរាល់សំណួរ និងសំណូមពរទាំងអស់របស់ប្រជាពលរដ្ឋ ដែលមានការពាក់ព័ន្ធជាមួយនឹងក្រសួងស្ថាប័នសាមី ដែលក្រុមការងារ និងអាជ្ញាធរមូលដ្ឋានក្រុង ស្រុក ខេត្ត ពុំមានសមត្ថកិច្ច និងលទ្ធភាពដោះស្រាយ ដើម្បីផ្តល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាល មានវិធានការដោះស្រាយជូនប្រជាពលរដ្ឋទាន់ពេលវេលា និងសមស្រប
- បន្តខិតខំដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង នៅតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់។

### ៤.១.១៣-ការងារផ្សេងៗ

- (ពុំមាន)។

## ៤.២-មន្ទីរ និងអង្គភាពជំនាញ

### ៤.២.១-ផ្នែកសេដ្ឋកិច្ច

#### ៤.២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះតាមដាន ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្មតាមបណ្ដាក្រុង ស្រុក
- ត្រៀមអន្តរាគមន៍ពីការបំផ្លាញ របស់សត្វល្អិតចង្រៃ និងជំងឺលើដំណាំតាមបណ្ដាក្រុង/ស្រុក
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ ចលនាដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វទូទាំងខេត្ត
- តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វតាមបណ្ដាក្រុង/ស្រុក
- បន្តតាមដានត្រួតពិនិត្យទីតាំងអាជីវកម្ម និងការចរាចរណ៍ជី-ថ្នាំកសិកម្មក្នុងខេត្ត
- បន្តជំរុញការអប់រំ ផ្សព្វផ្សាយពីវិធានបច្ចេកទេសនៃការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ព្រមទាំងវិធានសុវត្ថិភាពដល់អាជីវករ និងកសិករ
- ចុះអង្កេតតាមដាន និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការ
- ចុះបណ្ដុះបណ្ដាលការជួសជុល និងការថែទាំគ្រឿងយន្តកសិកម្ម ដល់ប្រជាកសិករ
- ចុះបណ្ដុះបណ្ដាលនីតិវិធីស្រង់ស្ថិតិគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មតាមមូលដ្ឋាន
- ចុះបណ្ដុះបណ្ដាលបច្ចេកទេសបើកមុខចៀរជ័រកៅស៊ូដំបូង ដល់កសិករដាំដុះកៅស៊ូនានាក្នុងខេត្ត
- ចុះតាមដាន ត្រួតពិនិត្យ និងស្រង់ស្ថិតិដំណាំកៅស៊ូ ដែលកើតមានជំងឺជ្រុះស្លឹក តាមបណ្ដាទីតាំងដាំដុះនានា ក្នុងខេត្ត
- ចុះតាមដានវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត
- បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលដែលស្ថិតក្នុងតំបន់ ស្ថាប័នពាក់ព័ន្ធ និងកម្លាំងល្បាតរបស់សហគមន៍ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យបានទាន់ពេលវេលា
- បន្តចុះតាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ករណីរំលោភទន្ទ្រានកាន់កាប់ សាងសង់ផ្ទះ ពីសំណាក់ប្រជាពលរដ្ឋនៅលើដីចម្ការឈើអាកាស្យា ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- សហការជាមួយអង្គការ Save The Children (គម្រោងស្បៀរ = STEER) ចុះផ្សព្វផ្សាយ បណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម ការអភិវឌ្ឍកុមារតូច និងសមភាពយេនឌ័រ ដល់កសិករតាមមូលដ្ឋាននានាក្នុងស្រុកគោលដៅ។

#### ៤.២.១.២-ការងារធនធានទឹក និងឧតុនិយម

- បន្តពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្ពង ស្ថិតនៅភូមិខ្ពង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្ដោល ស្ថិតនៅភូមិធ្មង់ និងភូមិកណ្ដោល ឃុំកណ្ដោល ស្រុកបូទុមសាគរ
- ពង្រឹងការងារប្រមូលទិន្នន័យឧតុនិយម នៅតាមបណ្ដាស្រុកដែលមានស្ថានីយឧតុនិយមឱ្យកាន់តែឆាប់រហ័ស និងសុក្រឹតដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម
- ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតានី ក្នុងឃុំជីខលើ និងទំនប់បឹងព្រាវ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល
- ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតាំកន់ និងទំនប់កណ្ដោល ក្នុងឃុំកណ្ដោល ស្រុកបូទុមសាគរ
- ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃជីត្រេះ និងទំនប់ជីមាល ក្នុងឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ
- ជួសជុល ថែទាំប្រចាំទំនប់ការពារទឹកប្រៃជ្រោយស្វាយ ក្នុងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
- ជួសជុល ថែទាំប្រចាំទំនប់ការពារទឹកប្រៃដងពែង-០១ ក្នុងឃុំដងពែង ស្រុកស្រែអំបិល
- ជួសជុលលូដោះទឹកជំនន់ដងពែង-០១ ក្នុងឃុំដងពែង ស្រុកស្រែអំបិល
- ស្តារប្រឡាយដោះទឹកជំនន់តាមបណ្ដោយទំនប់ការពារទឹកប្រៃជីត្រេះ ក្នុងឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ។

### ៤.២.១.៣-ការងារអភិវឌ្ឍជនបទ

- បន្តចុះធ្វើបច្ចុប្បន្នភាពផ្លូវជនបទ និងសំណង់សិល្បៈការ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទផ្លូវដែលទើបសាងសង់ថ្មី តាមបណ្តាឃុំ ស្រុក ក្នុងខេត្ត
- បន្តចុះស្រង់ទិន្នន័យរាប់ចំនួនចរាចរណ៍យានយន្ត លើផ្លូវជនបទ តាមបណ្តាឃុំ ស្រុក ក្នុងខេត្ត
- បន្តចុះត្រួតពិនិត្យតាមដានការអនុវត្តគម្រោងផ្លូវថែទាំប្រចាំ ផ្លូវថែទាំខួប និងផ្លូវជួសជុលបន្ទាន់ឆ្នាំ២០២៤
- បន្តចុះសិក្សាទីតាំងអណ្តូងស្នប់នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ សម្រាប់ផែនការឆ្នាំ២០២៤
- បន្តចុះត្រួតពិនិត្យតាមដានការងារការដ្ឋានសាងសង់ប្រព័ន្ធចែកចាយទឹកស្អាត និងស្រះសហគមន៍ នៅឃុំជ្រោយ-ប្រស់ ស្រុកកោះកុង
- បន្តចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)នៅតាមបណ្តាឃុំ ស្រុក ខេត្តកោះកុង។

### ៤.២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ចុះអនុវត្តការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ និងដៃបាញ់ប្រេង នៅតាមបណ្តាក្រុង/ស្រុក
- ចុះអនុវត្តការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ នៅតាមបណ្តាក្រុង/ស្រុក
- ចុះអនុវត្តការងារផ្ទៀងផ្ទាត់ជញ្ជីងក្រោមទម្ងន់១.០០០គីឡូក្រាម នៅតាមផ្សារក្នុងខេត្ត
- ដាក់ញ្ជីងគំរូ នៅក្នុងផ្សារ ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ សម្រាប់បម្រើជាសាធារណៈជូនប្រជាពលរដ្ឋដើម្បីថ្លឹងផ្ទៀងផ្ទាត់
- ចុះត្រួតពិនិត្យដំណើរការបច្ចេកទេសខ្សែសង្វាក់ផលិតកម្ម និងផលិតផល នៅតាមបណ្តាក្រុង/ស្រុក
- បន្តជំរុញដល់ម្ចាស់សហគ្រាស/សិប្បកម្ម ឱ្យយកចិត្តទុកដាក់អនុវត្តគោលការណ៍ អនាម័យល្អ ផលិតកម្មល្អ និងគោលការណ៍ស៥ (សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដារ ស្ថិតស្ថេរ)
- ចុះស្រង់ស្ថិតិរោងចក្រ សហគ្រាស/សិប្បកម្ម ដែលបានបិទទ្វារឈប់ដំណើរការ និងផ្អាកដំណើរការបណ្តោះអាសន្ន
- ចុះអធិការកិច្ចលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅតាមបណ្តាក្រុង/ស្រុក
- ជំរុញម្ចាស់សហគ្រាស/សិប្បកម្ម ឱ្យយកសំណាកផលិតផល ទៅវិភាគគុណភាព នៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- ពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយរបស់មន្ទីរលើការផ្តល់សេវាសាធារណៈជូនម្ចាស់សហគ្រាស/សិប្បកម្មដូចជា៖
  - សេចក្តីសម្រេចបង្កើតសហគ្រាស/សិប្បកម្ម
  - វិញ្ញាបនបត្រថ្មី និងបន្ត
  - សហគ្រាស/សិប្បកម្ម បិទទ្វារ និងព្យួរ
  - សហគ្រាស/សិប្បកម្មពង្រីកមុខផលិតផលថ្មី ឬពង្រីកដើមទុន ប្តូរទីតាំង ឬ ប្តូរម្ចាស់។

### ៤.២.១.៥-ការងាររ៉ែ និងថាមពល

- បន្តផ្សព្វផ្សាយដល់អាជីវករឱ្យយល់ពីច្បាប់ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់ និងកាយយកអាចម៍ដី)
- បន្តផ្សព្វផ្សាយសារាចរ និងសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ជូនដល់អាជីវករពាក់ព័ន្ធក្នុងខេត្ត
- ជំរុញ និងគាំទ្រដល់ក្រុមហ៊ុនផលិត ផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនី ទាំងអស់ឱ្យបន្តពង្រីកបណ្តាញជូនប្រជាពលរដ្ឋ ដើម្បីប្រើប្រាស់

- តាមដាន និងត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ទាំងគុណភាព ប្រសិទ្ធភាព និងសោភណ្ឌភាពនៅទីប្រជុំជន ក្នុងក្រុងខេមរភូមិន្ទ ដើម្បីចៀសវាងកើតឧបទ្ទវហេតុផ្សេងៗ
- បន្តខិតខំកៀរគរចំណូលសួយសារធនធានរ៉ែ ដើម្បីបង់ចូលថវិការដ្ឋ។

## ៤.២.១.៦-ការងារពាណិជ្ជកម្ម

- ផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បន្តការងារផ្តល់ប្រឹក្សាយោបល់ដល់អាជីវករ សេវាករ ដែលមានបំណងចង់បើកអាជីវកម្ម សេវាកម្ម (ជាអាជីវកម្ម សេវាកម្មដែលមិនជាប់ពន្ធលើប្រាក់ចំណេញ) អំពីបែបបទនៃការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម និងការដាក់ស្លាកយីហោអាជីវកម្ម
- តាមដានស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន១១៩មុខប្រចាំថ្ងៃ
- តាមដានការផ្គត់ផ្គង់ តម្រូវការ និងតម្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រៀងរាល់២ដងក្នុងមួយសប្តាហ៍
- ចុះពិនិត្យតម្លៃលក់រាយប្រេងឥន្ទនៈតាមស្ថានីយ និងដេប៉ូលក់ប្រេងឥន្ទនៈក្នុងក្រុង ស្រុកទូទាំងខេត្ត
- ចុះសិក្សាផលិតផលសក្តានុពលនៅតាមបណ្តាក្រុង ស្រុក ទូទាំងខេត្ត
- សហការជាមួយសភាពាណិជ្ជកម្មខេត្ត ក្នុងការអភិវឌ្ឍន៍ពាណិជ្ជកម្ម
- រៀបចំ ផ្សារផលិតផលចុងសប្តាហ៍ខេត្តកោះកុង
- ចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្មថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ខេត្ត
- បន្តចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ដើម្បីចុះត្រួតពិនិត្យគុណភាពទំនិញ និងសុវត្ថិភាពម្ហូបអាហារ
- តាមដានស្ថានភាពលក់ដូរប្រកបរបរប្រចាំថ្ងៃនៅតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម។

## ៤.២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

### ៤.២.១.៧.១-ការងារហិរញ្ញវត្ថុ

- ពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការត្រួតពិនិត្យចំណូល ចំណាយតាមបណ្តាអង្គភាព ក្រុង និងស្រុក ឱ្យបានត្រឹមត្រូវ
- ត្រៀមបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុតាមបណ្តាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ
- ពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈ
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាបន្តបន្ទាប់
- ជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើសារពើភណ្ឌ (ទាំងដីមានកម្មសិទ្ធិ និងដីបម្រុងរដ្ឋ)។

### ៤.២.១.៧.២-ការងារពន្ធដារ

- បន្តកៀរគរចំណូលពន្ធ ដើម្បីសម្រេចបានតាមផែនការចំណូលពន្ធសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់សាខាពន្ធដារខេត្តកោះកុង និងបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ។

### ៤.២.១.៧.៣-ការងារគយ និងរដ្ឋាករ

- បន្តពង្រឹងការងារគ្រប់គ្រងការប្រមូលពន្ធឱ្យបានតាមផែនការកំណត់ និងពង្រឹងការអនុវត្តវិមជ្ឈការតម្លៃឱ្យបានល្អ
- ជំរុញឱ្យមានការជម្រះបញ្ជីប្រាក់កក់លើស្រឡាង និងម៉ាស៊ីនបូមខ្សាច់ដែលនាំចូលដោយក្រុមហ៊ុន LYP Group Co.,Ltd តាំងពីឆ្នាំ២០០៨ តាមរបបប្រវេសន៍កាលិក

- បន្តធ្វើប្រតិបត្តិការបង្ក្រាបរថយន្តចង្កូតឆ្វេង និងចង្កូតស្តាំ ដែលគ្មានពន្ធ
- បង្កើនប្រសិទ្ធភាពការងារបង្ការ បង្ក្រាបអំពើរត់គេចពន្ធ និងបន្លំពន្ធ ជាពិសេសតាមរយៈការអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- ពង្រឹងប្រសិទ្ធភាពនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាមួយក្រុមអន្តរាគមន៍ពិសេស និងក្រុមអនុលោមភាព ដើម្បីចូលរួមប្រសិទ្ធភាពការងារនៅតាមការិយាល័យមាត់ច្រកក្រោមឱវាទ និងបន្តកែលម្អ និងខិតខំប្រមូលចំណូលពីក្រុមទំនិញចម្រុះបន្ថែមឱ្យអស់តាមសក្តានុពលជាក់ស្តែង
- សម្របសម្រួល ពាណិជ្ជកម្មអន្តរជាតិឱ្យបានសមស្របតាមបទប្បញ្ញត្តិជាធរមាន ជានាឱ្យបានកាន់តែល្អប្រសើរថែមទៀត និងចាត់វិធានការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនចេញ និងចូលឱ្យកាន់តែសុក្រឹត
- ជំរុញសកម្មភាពគ្រប់គ្រងផលនេសាទនាំចេញនាំចូលឱ្យមកបង់ពន្ធតាមនីតិវិធីគយ
- ពង្រឹងអភិបាលកិច្ច គុណភាពសេវារបស់អង្គភាពគយ និងរដ្ឋាករ និងបន្តបំពេញការងារ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពទាំងការងាររដ្ឋបាល និងការងារប្រតិបត្តិការគយ ពិសេសកែសម្រួលកម្លាំង ដើម្បីបំពេញភារកិច្ចមានការទទួខុសត្រូវច្បាស់លាស់តាមទង្វានគយ និងរដ្ឋាករ។

### ៤.២.១.៨-ការងារទេសចរណ៍

- បន្តផ្សព្វផ្សាយអំពីសក្តានុពល និងគោលដៅទេសចរណ៍ទាក់ទាញសំខាន់ៗក្នុងខេត្តដល់ភ្ញៀវទេសចរ
- ចុះថតរូបភាព និងវីដេអូនៅតំបន់គោលដៅទាក់ទាញទេសចរណ៍ នៅស្រុកគិរីសាគរ សម្រាប់ផលិតជាវីដេអូផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តកោះកុង
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និងរដ្ឋបាលស្រុកស្រែអំបិល ចុះប្រមូលទិន្នន័យសហគមន៍បម្រើសេវាកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ បូជនីយដ្ឋាន និងកន្លែងទីសក្ការៈបូជា និងរៀបចំជាលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងឃុំបឹងព្រាវ ឃុំស្រែអំបិល ឃុំជីខលើ ឃុំជីខក្រោម ស្រុកស្រែអំបិល
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និងរដ្ឋបាលស្រុកថ្មបាំង ចុះប្រមូលទិន្នន័យសហគមន៍បម្រើសេវាកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ បូជនីយដ្ឋាន និងកន្លែងទីសក្ការៈបូជា និងរៀបចំជាលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងស្រុកថ្មបាំង
- ចុះធ្វើបច្ចុប្បន្នភាពស្ថិតិអាជីវកម្ម និងសេវាកម្មទេសចរណ៍
- ផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ សារាចរ គោលការណ៍ និងសេចក្តីជូនដំណឹងផ្សេងៗរបស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត តាមបណ្តាអាជីវកម្មទេសចរណ៍
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បដិសណ្ឋារកិច្ច និងទេសចរណ៍ ស្របតាមបទដ្ឋានទេសចរណ៍អាស៊ាន និងការបញ្ច្រាបយេនឌ័រក្នុងវិស័យទេសចរណ៍"
- សហការរៀបចំ ទិវាជាតិទីក្រុងស្អាត
- សហការរៀបចំ ទិវាទេសចរណ៍ពិភពលោក និងទិវាពិភពលោកស្អាត
- ផលិតខិត្តប័ណ្ណរូបភាព និងផ្សព្វផ្សាយអំពីអនាម័យ បរិស្ថាន និងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ តាមតំបន់គោលដៅទេសចរណ៍ក្នុងខេត្ត។

### ៤.២.១.៩-ការងារផែនការ

- បញ្ចូលគម្រោងកិច្ចសន្យាបណ្តោះអាសន្ន ឆ្នាំ២០២៤ ទៅក្នុងកម្មវិធីSPD Program (ប្រព័ន្ធ ទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ)

- ប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក ឆ្នាំ២០២៤
- បញ្ចូលទិន្នន័យមូលដ្ឋានទៅក្នុងកម្មវិធីប្រព័ន្ធគ្រប់គ្រងទិន្នន័យឃុំ-សង្កាត់ CDB8 (Commune Database8) ២០២៤
- ផលិតឯកសាព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យឃុំ-សង្កាត់ ក្រុង-ស្រុក ខេត្ត ឆ្នាំ២០២៤
- បញ្ចូលគម្រោងអាទិភាពតាមបណ្តាឃុំសង្កាត់និងរបាយការណ៍ លទ្ធផល ទៅក្នុងកម្មវិធី SPD Program (ប្រព័ន្ធទិន្នន័យគម្រោង ថ្នាក់ក្រោមជាតិ)
- រៀបចំសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ-សង្កាត់ ថ្នាក់ក្រុង-ស្រុក
- ប្រមូលទិន្នន័យពីបណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត សម្រាប់ចងក្រងផលិតផលសរុបក្នុងស្រុក ខេត្តកោះកុង (GDP)
- ប្រមូលទិន្នន័យតាមផ្សារ ដើម្បីចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ប្រចាំខែ (CPI)
- រៀបចំ និងផលិតទិន្នន័យគម្រោងអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ
- បន្តធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រ ដើម្បីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ និងជនងាយរងគ្រោះដោយប្រើប្រាស់ឧបករណ៍តាប្លេត (Tablet) App OD ID-Poor
- ចូលរួមសហការក្នុងការធ្វើជំរឿន និង អង្កេតផ្សេងៗ របស់វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ។

### ៤.២.១.១០-ការងារផ្សេងៗ

#### ៤.២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- ផ្តល់សេវាបើក និងបង់ប្រាក់ជូនអតិថិជន
- ប្តូរប្រាក់ចាស់ ទក់ រហែក ជូនអតិថិជន
- ស្រាល់ជ្រើសក្រដាសប្រាក់ចាស់ ទក់ រហែក។

#### ៤.២.១.១០.២-ការងាររតនាគារ

- បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធFMIS នូវជំហានបន្ត
- បន្តពង្រឹងការកត់ត្រាចំណូល ចំណាយ តាមប្រព័ន្ធFMIS ឱ្យកាន់តែប្រសើរ
- បន្តការអនុវត្តតាមសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សរៀងរាល់២សប្តាហ៍ម្តង ក្នុងខែនីមួយៗ
- បន្តពិនិត្យផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ចំណូល ចំណាយ និងតារាងតុល្យភាពឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា
- បន្តការអនុវត្តការទូទាត់ចំណាយដែលមានហានិភ័យទាបតាមទម្រង់នីតិវិធីថ្មីក្នុងប្រព័ន្ធFMIS
- បន្តព្រងឹង និងណែនាំមន្ត្រីជំនាញទទួលបន្ទុកពិនិត្យការអនុវត្តចំណាយថវិកា ស្តីពីលិខិតបទដ្ឋានគតិយុត្ត
- បានធ្វើបច្ចុប្បន្នភាពថ្មីៗ ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាព ក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ និងលិខិតគិតយុត្តការចំណាយ ដើម្បីទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា
- បន្តការណែនាំដល់មន្ទីរ អង្គភាព ស្ថាប័នថវិកាកម្មវិធី ជាពិសេសអង្គភាពថវិកាលើការងារពាក់ព័ន្ធ និងការអនុវត្តចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាត់ថ្នាក់ទាំង៧នៃមាតិកាថវិកា
- បន្តដំណើរការអនុវត្តប្រព័ន្ធអេឡិចត្រូនិក (E-Fund Transfer)
- ពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal)ជូនដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាល ឃុំ សង្កាត់ ឱ្យកាន់តែប្រសើរ
- រៀបចំអនុវត្តនូវសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីគណនេយ្យនៃថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ សម្រាប់ឆ្នាំ២០២៣ និងទិសដៅអនុវត្តឆ្នាំ២០២៤។

### ៤.២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បន្តចុះត្រួតពិនិត្យទំនិញនៅទីផ្សារ ក៏ដូចជាតាមផ្ទះ ហាងលក់ទំនិញ(ម៉ាត) ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលាចំពោះទំនិញណាដែលចរាចរ តាមទីផ្សារខុសពីលក្ខខណ្ឌ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ រួមទាំងបទបញ្ញាតិពាក់ព័ន្ធផ្សេងៗទៀតជាធរមាន
- បន្តចុះអង្កេតជាប្រចាំនូវតម្លៃ តាមសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈ របស់ក្រសួងពាណិជ្ជកម្មតាមបណ្តាស្ថានីយ៍/ដេប៉ូ ក្នុងខេត្តកោះកុង ដើម្បីមានវិធានការណ៍បន្ទាន់ចំពោះស្ថានីយ/ដេប៉ូណាដែលមិនគោរពតាមសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម
- បន្តផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិក្រោមច្បាប់ដល់អាជីវករ និងពាណិជ្ជករក្នុងខេត្ត
- បន្តផ្សព្វផ្សាយ សុវត្ថិភាពម្ហូបអាហារដល់សិស្សានុសិស្ស ក្នុងសាលារៀនទូទាំងខេត្តកោះកុង
- ណែនាំអាជីវករអំពីរបៀបតាំងលក់ទំនិញឱ្យបានសមស្របជៀសវាងខូច និងប្រែប្រួលគុណភាព មុនកាលបរិច្ឆេទកំណត់។

## ៤.២.២-ផ្នែកសង្គមកិច្ច

### ៤.២.២.១-ការងារអប់រំ យុវជន និងកីឡា

- រៀបចំសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងលើកទិសដៅឆ្នាំសិក្សា២០២៣-២០២៤
- ចុះពិនិត្យតាមដានវាយតម្លៃការងារ និងណែនាំលើការងារបច្ចេកទេសតាមជំនាញការិយាល័យពាក់ព័ន្ធទាំង១០ នៅតាមគ្រឹះស្ថានសិក្សា ក្នុងខេត្តកោះកុង
- រៀបចំវិញ្ញាបនបត្រផ្តាច់ប្រាក់បៀវត្ស និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនបុគ្គលិកអប់រំក្របខ័ណ្ឌ ដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង/ស្រុក
- រៀបចំ និងចូលរួមការប្រឡងប្រណាំង និងប្រកួតប្រជែងផ្សេងៗនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ
- រៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតយភូមិ។

### ៤.២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តកិច្ចសហការជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងអាជ្ញាធរឃុំ សង្កាត់ ចុះដោះស្រាយបញ្ហានានាលើការអនុវត្តៈ
    - កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ
    - កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩
- បន្តចូលរួមប្រកាសសាលក្រមអនីតិជនទំនាសនឹងច្បាប់សរុបចំនួន៧នាក់ (ប្រុស) អាយុចាប់ពី១៤ឆ្នាំ-១៧ឆ្នាំ ជាប់ចោទពីបទលួចមានស្ថានទម្ងន់ទោសចំនួន៣នាក់ ជាប់ពីបទធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងជាប់ចោទពីបទប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន១នាក់ នៅសាលាដំបូងខេត្ត
- បន្តចុះត្រួតពិនិត្យ និងបើកហិបមូលនិធិជនពិការនៅតាមវត្តអារាម ភោជនីយដ្ឋាន ផ្ទះសំណាក់ និងរមណីយដ្ឋាននានាទូទាំងខេត្តកោះកុង
- បន្តចុះសួរសុខទុក្ខចាស់ជរាគ្មានទីពឹង និងចាស់ជរារស់នៅក្នុងគ្រួសារក្រីក្រ ក្នុងសហគមន៍
- បន្តចុះពង្រឹងសមាគមមនុស្សចាស់ដែលបានបង្កើតរួចឱ្យដំណើរការ
- បន្តចុះសហការ និងផ្តល់បច្ចេកទេសជូនប្រធានសមាគមមនុស្សចាស់តាមភូមិ ឃុំ
- បន្តសហការជាមួយសមាគមអតីតយុទ្ធជន ដើម្បីបើកផ្តល់ប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គ្រួសារសពអតីតយុទ្ធជនដែលទទួលមរណភាពឱ្យបានទាន់ពេលវេលា។

### ៤.២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

#### ៤.២.២.៣.១-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តជំរុញដល់នាយកសហគ្រាស/គ្រឹះស្ថាន ដែលប្រើប្រាស់កម្មករ និយោជិតខ្មែរ និងបរទេសមុនចូលបម្រើការងារ និងកំពុងបម្រើការងារឱ្យមកធ្វើសៀវភៅ និងប័ណ្ណការងារឱ្យស្របតាមនីតិវិធី និងដើម្បីប្រមូលអាករបង់ចូលថវិកាជាតិ
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង
- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងាររួម និងវិវាទបុគ្គល
- ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារតាមបណ្តាសហគ្រាស/គ្រឹះស្ថានក្នុងខេត្ត
- ពង្រឹងប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈ
- បន្តពង្រឹងភាពសុខដុមរមនា នៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត។

#### ៤.២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បន្តផ្សព្វផ្សាយគោលនយោបាយសន្តិសុខសង្គម ដល់ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យសាធារណៈ និងឯកជន
- បន្តស្រាវជ្រាវ និងចុះបញ្ជិកាសហគ្រាសថ្មីៗ។

### ៤.២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- បន្តតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្ត
- ពង្រឹងការអភិរក្សស្ថានីយ ចេតិយ និងបូជនីយដ្ឋានប្រវត្តិសាស្ត្រនានា ក្នុងភូមិសាស្ត្រខេត្តកោះកុង
- ចុះត្រួតពិនិត្យ និងស្រង់ស្លាកយីហោគ្រប់ប្រភេទ ក្នុងក្រុងខេមរភូមិន្ទ
- បណ្តុះបណ្តាលរបាំ ភ្លេងប្រពៃណី  ភ្លេងពិណពាទ្យ និងឆៃយ៉ាំ ដល់សិស្សានុសិស្ស និស្សិត និងយុវជននានា
- ចុះសិក្សាស្រាវជ្រាវ និងប្រមូលស្ថិតិវប្បធម៌រូបី-អរូបីនៅស្រុកថ្មបាំង និងស្រុកស្រែអំបិល
- ធ្វើស្លាកសញ្ញាកំណត់សម្គាល់នៅតាមស្ថានីយ ចេតិយ និងបូជនីដ្ឋាននានាក្នុងខេត្ត
- សហការជាមួយរដ្ឋបាលខេត្តកោះកុង រៀបចំពិធីបុណ្យជាតិ និងពិធីផ្សេងៗ នូវផ្ទាំងសិល្បទស្សនីយភាព ដើម្បីបម្រើសាធារណជនក្នុងខេត្ត
- សហការជាមួយរដ្ឋបាលខេត្តកោះកុង រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៦ ឆ្នាំ២០២៤ និងរៀបចំពិធីមហោស្រពសិល្បៈយុវជនថ្នាក់ខេត្ត ផ្នែកល្ខោននិយាយឈុតខ្លី និងផ្នែកចម្រៀងសម័យ។

### ៤.២.២.៥-ការងារព័ត៌មាន

- ជំរុញការផ្សព្វផ្សាយផ្នែកឯកជននានាឱ្យគោរពច្បាប់ និងបទដ្ឋានបច្ចេកទេសវិស័យព័ត៌មាន
- បន្តផ្សព្វផ្សាយសេចក្តីជូនដំណឹង  ស្តីពីការដាក់ពាក្យស្នើសុំបើក  និងបន្តសុពលភាពអាជ្ញាប័ណ្ណ  វិស័យព័ត៌មានជូនដល់ម្ចាស់អាជីវកម្ម  សេវាកម្មនៅក្នុងខេត្តកោះកុងទាំងអស់ដែលពុំទាន់មានអាជ្ញាប័ណ្ណ  និងអាជ្ញាប័ណ្ណផុតសុពលភាព ត្រូវមកស្នើសុំអាជ្ញាប័ណ្ណរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងទាន់ពេលវេលា
- ជំរុញការចុះយកព័ត៌មានតាមរយៈថតវីដេអូ និងបង្កើនទំនាក់ទំនងតាមបណ្តាក្រុង ស្រុកដើម្បីទទួលបានព័ត៌មាន
- ស្រាវជ្រាវលើបច្ចេកវិទ្យា និងកម្មវិធីថ្មីៗស្របតាមកាលៈទេសៈសង្គម
- បង្កើនការផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ ទូរទស្សន៍បាយ័ន និងទូរទស្សន៍ផ្សេងៗទៀត
- បង្កើនការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម ឱ្យកាន់តែទូលំទូលាយជាងមុន
- បង្កើនការយកចិត្តទុកដាក់កែលម្អកម្មវិធីផ្សាយរបស់វិទ្យុផ្សាយសំឡេង
- បន្តផ្សព្វផ្សាយព័ត៌មាន ស្ប៉តអប់រំផ្សេងៗ ពិសេសស្ប៉តស្តីពីជំងឺកូវីដ-១៩
- បន្តផ្សព្វផ្សាយរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំជាតិ និងខេត្តឱ្យកាន់តែទូលំទូលាយ។

### ៤.២.២.៦-ការងារកិច្ចការនារី

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖
  - ជំនាញកាត់ដេរ និងសម្អាងកាយ ដល់ស្ត្រីក្រីក្រ នៅស្រុកស្រែអំបិល
  - ការកែច្នៃផលិតផលឬស្សី រំពាក់ (ចង្កេរ កញ្ជើ.) ដល់ស្ត្រីក្រីក្រ នៅស្រុកស្រែអំបិល
  - ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ សម្រាប់ស្ត្រី និងក្មេងស្រី ដល់ប្រជាពលរដ្ឋ នៅស្រុកថ្មបាំង និងស្រុកស្រែអំបិល
- រៀបចំមីទ្ទិញអន្តរជាតិនារី ០៨ មីនា ខួបលើកទី១១៣ ឆ្នាំ២០២៤ នៅក្រុងខេមរភូមិន្ទ
- រៀបចំផ្សព្វផ្សាយច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការចំណាកស្រុក និងការជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅស្រុកស្រែអំបិល
- រៀបចំវគ្គផ្សព្វផ្សាយស្តីពី ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់សិស្សានុសិស្ស នៅតាមសាលារៀន នៅស្រុកមណ្ឌលសីមា
- រៀបចំកិច្ចប្រជុំស្តីពី ការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ជាមួយមន្ត្រីបង្គោល យេនឌ័រតាមមន្ទីរ/អង្គភាព ជំនាញ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែម អំពីការកែច្នៃ វេចខ្ចប់ និងការរក្សាគុណភាពចេកឆាបឱ្យ រក្សាទុកបានយូរ ដល់ក្រុមស្ត្រី នៅស្រុកថ្មបាំង
- រៀបចំវគ្គផ្សព្វផ្សាយស្តីពី ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ដល់សិស្សានុសិស្សតាមសាលារៀន នៅក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា
- ចុះតាមដាន និងវាយតម្លៃ ទាក់ទងនឹងការអនុវត្តន៍ តួនាទី ភារកិច្ច របស់ គ.ក.ន.ក ពីការផ្តល់សេវាសង្គម ដល់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអំពីការផ្តល់សេវាមេធាវីស្ម័គ្រចិត្ត(សម្តេចតេជោ) ជួយដល់ស្ត្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សាធ្ងន់ធ្ងរ
- សហការជាមួយអង្គការសង្គ្រោះកុមារ ចុះតាមដាន និងវាយតម្លៃ ទាក់ទងនឹងកិច្ចការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន របស់ប្រជាកសិករ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង។

### ៤.២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បន្តសហការជាមួយមន្ទីរជំនាញចុះតាមដានការអនុវត្តច្បាប់ របស់រាជរដ្ឋាភិបាលនៅតាមក្រុង ស្រុក ទូទាំងខេត្តកោះកុង
- បន្តទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងមជ្ឈដ្ឋាននានា ដើម្បីពិនិត្យដោះស្រាយតាមនីតិវិធី
- បន្តសម្របសម្រួល និងទំនាក់ទំនងរាល់ការងាររវាងអាជ្ញាធរខេត្ត និងទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តកោះកុង។

### ៤.២.២.៨-ការងារធម្មការនិងសាសនា

- ត្រៀមសហការរៀបចំជាមួយរដ្ឋបាលខេត្ត ទិវាចូលឆ្នាំសាកល
- ត្រៀមសហការរៀបចំជាមួយរដ្ឋបាលខេត្ត ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ៧មករា
- ត្រៀមសហការរៀបចំជាមួយរដ្ឋបាលខេត្ត និងព្រះមេគណ ទាំងពីរគណៈ រៀបចំពិធីបុណ្យមាឃបូជា
- ត្រៀមចូលរួមសហការរៀបចំពិធីបុណ្យចូលឆ្នាំថ្មី
- ត្រៀមសហការរៀបចំជាមួយរដ្ឋបាលខេត្ត និងព្រះមេគណទាំងពីរគណៈ ពិធីបុណ្យវិសាខបូជា
- ត្រៀមសហការរៀបចំជាមួយរដ្ឋបាលខេត្ត និងព្រះមេគណទាំងពីរគណៈ ចូលព្រះវស្សា
- ត្រៀមចូលរួមសហការរៀបចំពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

- ត្រៀមចូលរួមសហការរៀបចំប្រារព្ធពិធីបុណ្យគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"
- ត្រៀមសហការរៀបចំពិធីបុណ្យចេញព្រះវស្សា
- ត្រៀមសហការរៀបចំពិធីបុណ្យកឋិនទាន
- ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈដើម្បីរៀបចំអបអរសាទរពិធីគ្រងរាជព្រះបរមរាជសម្បត្តិ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- ត្រៀមសហការដើម្បីអបអរសាទរពិធីបុណ្យឯករាជ្យជាតិ
- ត្រៀមកិច្ចសហការដើម្បីរៀបចំអបអរសាទរពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក
- ត្រៀមសហការជាមួយសាលាគណព្រះអនុគណ និងព្រះចៅអធិការ ទាំងពីរគណៈនៃព្រះពុទ្ធសាសនា ថ្នាក់ដឹកនាំពាហិសាសនា និងរដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ ដើម្បីប្រារព្ធពិធីបុណ្យទាន ទៅតាមប្រពៃណីទំនៀមទម្លាប់។

### ៤.២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បន្តសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ទីរអង្គភាពនានាជុំវិញខេត្ត និងបណ្តាក្រុមហ៊ុនបម្រើសេវាទូរគមនាគមន៍ ប្រតិបត្តិករប្រៃសណីយ៍កម្ពុជា និងទូរគមនាគមន៍កម្ពុជា ដើម្បីអនុវត្តការងារឱ្យបានស្របតាមនីតិវិធី
- ចុះត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងគោលនយោបាយលើការប្រើប្រាស់ ការធ្វើសេវាលើវិស័យប្រៃសណីយ៍ វិស័យទូរគមនាគមន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគ្រប់ប្រភេទនៅក្នុងខេត្ត។

### ៤.២.២.១០-ការងារមុខងារសាធារណៈ

- បន្តត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណើសុំទូទាត់ប្រាក់បៀវត្សប្រចាំខែ របស់មន្ត្រីរាជការស៊ីវិល នៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តពិនិត្យផ្ទៀងផ្ទាត់ រៀបចំរបាយការណ៍ និងបែងចែកតារាងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តត្រួតពិនិត្យ ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុកជុំវិញខេត្តឱ្យបានត្រឹមត្រូវ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការ និងបន្តត្រួតពិនិត្យ តាមដាន និងជំរុញការបង្វែរប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលបើកមិនប្រក្រតីចូលថវិការដ្ឋវិញ។

### ៤.២.២.១១-ការងារផ្សេងៗ

#### ៤.២.២.១១.១-ការងារសាលាដំបូង

- ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរ ដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះដែលនៅសល់ ឱ្យបានសម្រេចពី៥០%ទៅ៨០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងរដ្ឋប្បវេណីជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- ពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ និងប្រមូលចំណូលជូនរដ្ឋ
- បន្តអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ
- ពង្រឹង និងយកចិត្តទុកដាក់ការងារគ្រប់គ្រងសំណង់
- បន្តចែកវិញ្ញាបនបត្រសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ។

### ២.៣.២-ការងារបរិស្ថាន

- រៀបចំប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា
- រៀបចំបណ្តុះកូនដើមឈើចំនួន១០០.០០០ដើម
- ចុះពិនិត្យទីតាំង និងស្រង់ស្ថិតិផ្ទះចិញ្ចឹមសត្វត្រចៀកកាំតាមបណ្តាក្រុង ស្រុក និងផ្តល់យោបល់លើការរៀបចំកិច្ចសន្យាការពារបរិស្ថានលើអាជីវកម្ម និងសិប្បកម្ម និងជំរុញការបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ
- ចុះអធិការកិច្ចត្រួតពិនិត្យប្រភពបំពុលបរិស្ថានលើទីតាំងអាជីវកម្ម សិប្បកម្ម សណ្ឋាគារ ផ្ទះសំណាក់ក្នុងក្រុង ស្រុក
- ចុះផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដល់ម្ចាស់អាជីវកម្ម-សិប្បកម្មក្នុងខេត្ត
- ចុះផ្សព្វផ្សាយអនុក្រឹត្យលេខ ១៦៨អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិកនៅក្រុងខេមរភូមិន្ទ និងស្រុកទាំង៦
- ចុះល្បាតទប់ស្កាត់បង្ក្រាបរាល់បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ
- ចុះស៊ើបអង្កេត និងរៀបចំកសាងសំណុំរឿងបទល្មើសទៅសាលាដំបូងខេត្ត
- ចុះផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋបញ្ឈប់ការទន្ទ្រានដីព្រៃយកដីធ្វើកម្មសិទ្ធិ និងការបរបាញ់ ការចាប់សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ
- បើកវគ្គផ្សព្វផ្សាយ ស្តីពីការរៀបចំ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិចំនួន១២លើក
- បើកវគ្គផ្សព្វផ្សាយច្បាប់ ស្តីពីតំបន់ការពារធម្មជាតិដល់អាជ្ញាធរមូលដ្ឋាននិងសហគមន៍ចំនួន១០លើក
- បើកវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីក្នុងការល្បាត និងរបៀបសរសេររបាយការណ៍ និងកំណត់ហេតុចំនួន២វគ្គ
- បោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន១៥០បង្គោល
- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានការគ្រប់គ្រងសមុទ្រ តំបន់ឆ្នេរ និងកោះ
- ចុះសិក្សាពីជីវចម្រុះ និងពិនិត្យតាមដានប្រភេទសត្វ រុក្ខជាតិសំខាន់ៗនៅក្នុងសមុទ្រតំបន់ឆ្នេរ និងកោះ
- ចុះពិនិត្យតាមដានរាល់សកម្មភាពរំលោភចាក់បំពេញយកដីចំណីឆ្នេរសមុទ្រធ្វើជាកម្មសិទ្ធិ
- ចុះផ្សព្វផ្សាយអំពីគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសមុទ្រ តំបន់ឆ្នេរ និងកោះ
- ចុះសិក្សាស្រាវជ្រាវរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ងាយរងគ្រោះ និងជិតផុតពូជក្នុងដែនសមុទ្រ តំបន់ឆ្នេរ និងកោះ
- ចុះពិនិត្យ និងតាមដានរាល់សកម្មភាពរំលោភដីនៅតាមតំបន់សមុទ្រ ឆ្នេរ និងកោះ
- ត្រៀមបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិដែលផុតអាណត្តិចំនួន៥ (ជ្រោយស្វាយ តាទៃលើ ព្រាំងចំការក្រោម កោះកាពិ និងកោះស្រឡៅ)
- ត្រៀមរៀបចំសហគមន៍តំបន់ការពារធម្មជាតិថ្មីចំនួន៥ (ពោធិ៍បឹង ជីផាត ប្រឡាយ ជំនាប់ ថ្មដូនពៅ)
- រៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិភ្នំទ័ពជាង កណ្តោល និងជ្រោយស្វាយ
- រៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ពោធិ៍បឹង និងភ្នំទ័ពជាង
- ចុះអប់រំផ្សព្វផ្សាយ និងទប់ស្កាត់ភ្លើងឆេះព្រៃនៅតាមតំបន់ការពារធម្មជាតិ
- រៀបចំសាងសង់ស្នាក់ការសម្រាប់ឈរជើងនៅតំបន់រ៉ាមសាកោះកាពិ និងដែនជម្រកសត្វព្រៃភ្នំសំកុស

- រៀបចំថ្នាលបណ្តុះកូនដើមកោងកាង និងកូនដើមឈើចម្រុះ
- ចុះផ្សព្វផ្សាយយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

### ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- បន្តការងារជួសជុល និងការងារថែទាំជាប្រចាំផ្លូវនានាក្នុងខេត្ត ស្ថិតក្នុងដែនការងារមន្ទីរ
- បន្តផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋលើវិស័យដឹកជញ្ជូនផ្លូវគោក ផ្លូវសមុទ្រ និងកំពង់ផែ
- បន្តកិច្ចសហការជាមួយកម្លាំងសមត្ថកិច្ចក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ចុះត្រួតពិនិត្យយានយន្ត និងយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស រួមទាំងយានយន្តដឹកសំពីងសំពោង និងបន្តអប់រំ ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់ម្ចាស់យានយន្ត និងអ្នកបើកបរ។

### ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

## ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

- បន្តការផ្សព្វផ្សាយគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" លេខ ០១ គ.ន.ប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់ភូមិ ឃុំ សង្កាត់ និងបណ្តាអង្គការសង្គមស៊ីវិលទូទាំងខេត្ត
- រៀបចំកសាងផែនការ និងកម្មវិធីការងារប្រចាំខែសម្រាប់ចុះអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលក្រុមនីមួយៗទទួលខុសត្រូវ
- បង្កើនកម្មវិធីធ្វើវេទិកាសាធារណៈឱ្យបានគ្រប់ភូមិ ឃុំ សង្កាត់ ទូទាំងខេត្ត ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមយោបល់ដោះស្រាយបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន និងទិតៀនកែលម្អរាល់សកម្មភាពអសកម្មរបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលមានកន្លងមក សំដៅបង្កើនសកម្មភាពអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែមានប្រសិទ្ធភាព
- ដឹកនាំអនុវត្តឱ្យបានទៀងទាត់នូវរបបប្រជុំប្រចាំខែដើម្បីត្រួតពិនិត្យលទ្ធផលកិច្ចប្រតិបត្តិការ និងដាក់ចេញផែនការវិធានការ អនុវត្តជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន
- យកចិត្តទុកដាក់ចាត់តាំងអនុវត្តនូវបណ្តាវិធានការស្តីពីការលុបបំបាត់បទល្មើស និងគ្រោះថ្នាក់សង្គម ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិទាំង៧យ៉ាង នៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យមានប្រសិទ្ធភាពខ្ពស់
- ជំរុញចលនាប្រឡងប្រណាំងបង្កើតស្នាដៃនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានផុលផុសក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" សម្រាប់ទទួលការសរសើរ និងជូនរង្វាន់ប្រចាំឆ្នាំនីមួយៗ។

### ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

- ជំរុញការអនុវត្តផែនការលេខ ០១៦ ផ.ក របស់អគ្គស្នងការដ្ឋាននគរបាលជាតិ
- ស្រាវជ្រាវក្តាប់សភាពការណ៍ ឧបាយកលរបស់បណ្តាភាគីអមិត្ត និងចលនាប្រឆាំងផ្សេងៗចំពោះរាជរដ្ឋាភិបាល ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- ពង្រឹងការងារត្រួតពិនិត្យវត្តមានជនបរទេសឆ្លងកាត់ និងស្នាក់នៅក្នុងខេត្តដើម្បីទប់ស្កាត់ការលួចជ្រៀតចូលរបស់ក្រុមភេរវជន
- ក្តាប់សភាពការណ៍បាតុកម្ម កូដកម្ម និងអំពើភេរវកម្មផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- ប្រមូលផ្តុំក្តាប់រាល់សភាពការណ៍ បទល្មើសព្រហ្មទណ្ឌទូទាំងខេត្ត និងធ្វើការវិភាគវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវវិធានការបង្ការ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព

- បន្តជំរុញវិធានការ និងបង្ក្រាបក្រុមក្មេងទំនើងនៅទូទាំងខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងកាត់បន្ថយបទល្មើសក្នុងសង្គម
- បន្តពង្រឹងបំប៉នជំនាញដល់មន្ត្រីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព
- បន្តសហការជាមួយអាជ្ញាធរដែនដី ដើម្បីបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមប្រឆាំងទប់ស្កាត់បទល្មើសគ្រឿងញៀន
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយភ្នាក់ងារប្រឆាំងគ្រឿងញៀនភាគីថៃ ដើម្បីដកបទពិសោធន៍ និងផ្តល់ព័ត៌មានជូនគ្នាទៅវិញទៅមក សំដៅធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនឱ្យមានប្រសិទ្ធភាព
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ដើម្បីអប់រំឱ្យស៊ីជម្រៅដល់ប្រជាពលរដ្ឋ សំដៅកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានវិធានការផាកពិន័យតាមច្បាប់កំណត់
- បង្កើនការគ្រប់គ្រងបណ្តាគោលដៅដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច ដូចជា សណ្ឋាគារ ផ្ទះសំណាក់។ល។ ដោយធ្វើកិច្ចសន្យា និងតាមដានកុំឱ្យគោលដៅទាំងនោះ ក្លាយជាកន្លែងប្រព្រឹត្តបទល្មើស
- បន្តចុះស្រង់ទិន្នន័យ និងស្រាវជ្រាវប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់។

### ២.៨.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន៍

- បន្តទទួលពាក្យស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំពោះអ្នកគ្រប់អាយុ និងស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ តាមនីតិវិធី
- រៀបចំបញ្ជីទទឹងជនបរទេសអន្តោប្រវេសន្ត ដែលមិនមកបន្តសុពលភាពប័ណ្ណស្នាក់នៅ
- បន្តសហការជាមួយម្ចាស់ផ្ទះសំណាក់ ផ្ទះជួល និងសណ្ឋាគារ ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យជនបរទេសស្នាក់នៅរយៈពេលខ្លី ដើម្បីមានមូលដ្ឋានរាយការណ៍ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
- បន្តសហការជាមួយអធិការក្រុង ស្រុក និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងវត្តមានជនបរទេស និងពិនិត្យស្រាវជ្រាវរកជនបរទេសដែលចេញចូលស្នាក់នៅ និងប្រកបមុខរបរដោយស្របច្បាប់
- បន្តចែកប្រកាសទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន្ត និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេសអន្តោប្រវេសន្ត ប្រើប្រាស់តាមនីតិវិធីច្បាប់
- បន្តសហការជាមួយអង្គភាពពន្ធនាគារ ដើម្បីគ្រប់គ្រង និងប្រមូលទិន្នន័យជនបរទេសឱ្យបានជាប់ជាប្រចាំ
- ជំរុញអធិការនគរបាលក្រុង ស្រុក អនុវត្តផែនការលេខ ០៩៥៨.ក របស់ស្នងការដ្ឋាននគរបាលខេត្ត ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីស្រាវជ្រាវរកឯកសារលិខិតឆ្លងដែនរបស់ជនបរទេសដែលស្នាក់នៅលើសទិដ្ឋាការ ដើម្បីបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ធ្វើការផាកពិន័យ និងបន្តនីតិវិធីបណ្តេញចេញពីប្រទេស។

### ២.៨.៤-ការងារគ្រប់គ្រងពន្ធនាគារ

- អប់រំមន្ត្រីឱ្យយល់ដឹងអំពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ
- អប់រំជនជាប់ឃុំឱ្យយល់ដឹងពី ក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល
- រៀបចំវគ្គបណ្តុះបណ្តាលដល់ជនជាប់ឃុំឱ្យមានជំនាញ កាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្ត និងផលិតឥដ្ឋបុក
- ពិនិត្យរៀបចំកម្មវិធីផែនការកសិកម្ម និងឧស្សាហកម្មក្នុងពន្ធនាគារ
- លើកគោលការណ៍ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្គត់ផ្គង់ជីវភាពសេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារ

- ពិនិត្យ និងឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំឃាំង
- សហការជាមួយអង្គការលីកាដូ ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ ការពិនិត្យព្យាបាលជំងឺ និងផ្តល់ថ្នាំពេទ្យ ជូនជនជាប់ឃុំ និងចែកអំណោយជូនកូនតាមម្តាយ។

## ផ្នែកទី៥÷សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០២៣នេះ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត បានរៀបចំរចនាសម្ព័ន្ធ ដឹកនាំ គ្រប់គ្រង ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន និងបានអនុវត្តការងារ ស្របតាមការបែងចែក តួនាទីភារកិច្ច របស់សមាជិកក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។ ជាមួយគ្នានេះ ការិយាល័យប្រជាពលរដ្ឋ ទីចាត់ការ និងអង្គភាពនៃរដ្ឋបាលខេត្ត បានបំពេញការងារជូនអង្គភាពរបស់ខ្លួន និងប្រជាពលរដ្ឋ សំដៅលើកកម្ពស់ការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវា និងដំណោះស្រាយនានា កាន់តែឆាប់រហ័ស ប្រកបដោយសមធម៌ តម្លាភាព សុចរិតភាព ប្រសិទ្ធភាព និងទំនួលខុសត្រូវ ដើម្បីជានានិរន្តរភាពនៃថ្នាក់រដ្ឋបាលមួយនេះ។

ក្នុងការអនុវត្តតួនាទីភារកិច្ច ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាល បានផ្តោតការយកចិត្តទុកដាក់លើកិច្ចការប្រជុំ ស្របតាមគោលការណ៍ច្បាប់ និងប្រតិទិនដែលបានកំណត់ ព្រមទាំងពិនិត្យ ដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយឆន្ទៈ និងទំនួលខុសត្រូវខ្ពស់។

ដោយឡែក តាមរយៈសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការងារសេដ្ឋកិច្ច សង្គម និងការដោះស្រាយបញ្ហា មានភាពល្អ ប្រសើរ។ សមិទ្ធផលដែលសម្រេចបានទាំងអស់ អាស្រ័យដោយក្រុមការងារគ្រប់ថ្នាក់គ្រប់ផ្នែក បានយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការអនុវត្តបទបញ្ជា សេចក្តីណែនាំ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជាមួយកិច្ចសហការគាំទ្រទៅវិញទៅមក ក្នុងគោលដៅច្បាស់លាស់ ធ្វើឱ្យការដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានទទួលបានជោគជ័យ។

របាយការណ៍ប្រចាំឆ្នាំ២០២៣ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃចន្ទ ១៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣។

**អភិបាល**

**ម៉ិថុនា ភូថង**

**ចម្លងជូន÷**
- ក្រសួងមហាផ្ទៃ
- មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធទី១៖ ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំ ឆ្នាំ២០២៣

| ល.រ | ឈ្មោះ ក្រុង/ស្រុក | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋទូទៅ | | | | | | ចំនួនប្រជាពលរដ្ឋអាយុ ១៨ ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក្នុងនោះ: | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | | |
| | | | អចិន្ត្រៃយ៍ | ប.អាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| ១ | ក្រុងខេមរភូមិន្ទ | 7,799 | 6,655 | 1,144 | 36,608 | 18,150 | 32,438 | 15,853 | 4,170 | 2,297 | 21,980 | 11,554 | 19,361 | 10,221 | 2,619 | 1,333 | 93 | 31 |
| ២ | ស្រុកមណ្ឌលសីមា | 4,342 | 4,176 | 166 | 18,267 | 9,162 | 17,731 | 8,893 | 536 | 269 | 13,438 | 6,783 | 13,068 | 6,586 | 370 | 197 | 535 | 454 |
| ៣ | ស្រុកកោះកុង | 2,431 | 2,387 | 44 | 9,185 | 4,413 | 9,014 | 4,343 | 171 | 70 | 6,067 | 2,930 | 5,937 | 2,879 | 130 | 51 | 577 | 277 |
| ៤ | ស្រុកគិរីសាគរ | 2,505 | 2,395 | 110 | 9,167 | 4,375 | 8,635 | 4,182 | 532 | 193 | 6,237 | 3,027 | 5,851 | 2,887 | 386 | 140 | 203 | 284 |
| ៥ | ស្រុកបូទុមសាគរ | 6,097 | 6,083 | 14 | 23,705 | 11,649 | 23,673 | 11,635 | 32 | 14 | 14,955 | 7,894 | 14,924 | 7,880 | 31 | 14 | 1,736 | 132 |
| ៦ | ស្រុកថ្មបាំង | 2,172 | 2,100 | 72 | 8,191 | 4,047 | 7,941 | 3,951 | 250 | 96 | 4,948 | 2,290 | 4,788 | 2,230 | 160 | 60 | 383 | 26 |
| ៧ | ស្រុកស្រែអំបិល | 10,280 | 10,229 | 51 | 46,225 | 23,508 | 46,035 | 23,411 | 190 | 97 | 29,772 | 15,375 | 29,640 | 15,310 | 132 | 65 | 1,837 | 183 |
| **សរុបទូទាំងខេត្ត** | | 35,626 | 34,025 | 1,601 | 151,348 | 75,304 | 145,467 | 72,268 | 5,881 | 3,036 | 97,397 | 49,853 | 93,569 | 47,993 | 3,828 | 1,860 | 5,364 | 1,387 |

## ឧបសម្ព័ន្ធទី២៖ ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំឆ្នាំ២០២៣

- ថវិកាគ្រោងសម្រាប់សកម្មភាពសេវាសង្គមនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ៖២២.៦០០.០០០រៀល ស្មើនឹង ១០០.% នៃថវិកាសរុប
- ចំណាយជាក់ស្តែងដែលបានបូកយោងសម្រាប់សកម្មភាពសេវាសង្គម៖ ២៥.២៥៨.៥០០ ស្មើនឹង១១២% ( គិតត្រឹមថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ )

| ល.រ. | ឈ្មោះសកម្មភាព | ថវិកាគ្រោង | %សកម្មភាពសម្រេចបាន | អ្នកទទួលផល | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ក )-សុខភាពមាតា កុមារ និងអាហារូបត្ថម្ភ | | | | | |
| ១.១ | បានធ្វើវេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ស្តីពីការលើកកម្ពស់អនាម័យ បរិស្ថាន អាហារូបត្ថម្ភ និងការចិញ្ចឹមកូនបែបវិជ្ជមាន ចំនួន៤លើក | ៧.៣២៤.០០០ | ១០០% | ១៧០ | ១៣៦ |
| ១.២ | | | | | |
| ខ )-ទឹកស្អាតនិងអនាម័យ | | | | | |
| ១.១ | ពុំមានសកម្មភាព | | | | |
| ១.២ | | | | | |
| គ )-ការអប់រំកុមារតូច | | | | | |
| ១.១ | ពុំមានសកម្មភាព | | | | |
| ១.២ | | | | | |
| ឃ )-ការអប់រំបឋមសិក្សា និងមធ្យមសិក្សា | | | | | |
| ១.១ | ពុំមានសកម្មភាព | | | | |
| ១.២ | | | | | |
| ង )-ការការពារស្ត្រី និងកុមារ | | | | | |
| ១.១ | បានចុះធ្វើសិក្ខាសាលាបូកសរុបលទ្ធផលការងារគ.ក.ស.ក ខេត្ត ក្រុង ស្រុកសរុប ៤លើក | ៥.៥៨០.០០០ | ១០០% | ១៣០ | ៩៤ |
| ១.២ | បានបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រឹក្សាយោបល់ជូនស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានចំនួន៤លើក | ៤.៦៩៩.០០០ | ១០០% | ៩៦ | ៤៣ |
| ច )-កិច្ចគាំពារសង្គម | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.១ | បានធ្វើវគ្គបណ្តុះបណ្តាលស្តីពីការស្វែងរកការគាំទ្រមតិ ក្នុងការលើកកម្ពស់សមភាព យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីថ្នាក់ធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយរបស់រដ្ឋបាលខេត្តកោះកុង ចំនួន១លើក | ៤.០៦០.០០០ | ១០០% | ៨០ | ៦២ |
| ១.២ | | | | | |
| ឆ )-លំនៅដ្ឋាន | | | | | |
| ១.១ | ពុំមានសកម្មភាព | | | | |
| ១.២ | | | | | |
| **សរុប** | | ២១.៦៦៣.០០០ (មិនគិតលុយប្រជុំចូលទេ) | | ៤៧៦ | ២៩២ |

ឧបសម្ព័ន្ធទី៣ វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនៃរដ្ឋបាលខេត្ត ប្រចាំឆ្នាំ២០២៣(ថវិកាភាជន៍ពីរដ្ឋបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

| ល.រ | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផលគម្រោង | តម្លៃ(លានរៀល) | ទីតាំង អនុវត្ត | អ្នកទទួលផល | | វិធីសាស្ត្រលទ្ធកម្ម | អ្នកទទួលការ | %អនុវត្ត | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | | | | |
| ក.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ១ | គម្រោងជួសជុលស្ពានបេតុង ០១កន្លែង ប្រវែង ១០ម ទទឹង ១១ម កម្ពស់ ២,៥០ម | គ្រោង | ១កន្លែង | 1,260 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១កន្លែង | 1,256 | | | | | | | |
| ២ | គម្រោងជួសជុលផ្លូវក្រាលកៅស៊ូ DBST(ជួសជុលសំបុកមាន់) ចំនួន ០៥ខ្សែ | គ្រោង | ២៨៣៣ម២ | 490 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 487 | | | | | | | |
| ៣ | គម្រោងជួសជុលផ្លូវបេតុងអាមេ ០១ខ្សែ ប្រវែង ៤៥០ម៉ែត្រ ទទឹង ៧ម៉ែត្រ កម្រាស់ ០,១៥ម៉ែត្រ និងដាក់លូលូមូលដោះទឹក អមសងខាងផ្លូវ ប្រវែង ៩៦០ម៉ែត្រ អង្កត់ផ្ចិត ០,៨ម៉ែត្រ និងរឺហ្គា ចំនួន ៨០កន្លែង ប្រវែងសរុប ១០០០ម៉ែត្រ | គ្រោង | ៤៥០ម | 1,323 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 1,319 | | | | | | | |
| ៤ | រៀបចំកែលម្អសួនច្បារ | គ្រោង | ១កន្លែង | 495 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ២កន្លែង | 492 | | | | | | | |
| ៥ | ជួសជុលថែទាំអគាររដ្ឋបាលខេត្ត | គ្រោង | ១កន្លែង | 218 | សង្កាត់ ស្មាច់មានជ័យ | - | - | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១កន្លែង | 216 | | | | | | | |
| ៦ | គម្រោងជួសជុល និងថែទាំបណ្តាញអគ្គិសនី | គ្រោង | ២១៥បង្គោល | 450 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 448 | | | | | | | |
| ៧ | គម្រោងស្ពារលូដោះទឹក ប្រវែង ២៧៣២ម៉ែត្រ អង្កត់ផ្ចិត ០,៨០ម៉ែត្រ និងស្ពារប្រឡាយធម្មជាតិ ប្រវែង ៧២៩ម៉ែត្រ ទទឹង ៤ម៉ែត្រ | គ្រោង | ៣៤៦១ម | 490 | សង្កាត់ ស្មាច់មានជ័យ | 6,816 | 6,574 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 489 | | | | | | | |
| ៨ | គម្រោងស្ថាបនា ពង្រីកផ្លូវបេតុងសរសៃដែក (ដោយពង្រីកទទឹង ១ម៉ែត្រ) កម្រាស់ ០.២ម៉ែត្រ ក្រាលកៅស៊ូAC មានប្រវែង ២,៣៥០ម៉ែត្រ ទទឹង៧ម៉ែត្រ កម្រាស់ ០.០៧ម៉ែត្រ និងចិញ្ចើមគ្រួសក្រហមចំនួន ១ម៉ែត្រ សងខាងផ្លូវ | គ្រោង | ២៣៥០ម | 6,000 | សង្កាត់ ស្ទឹងវែង | 4,267 | 3,336 | រូចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 5,992 | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៩ | គម្រោងជួសជុលផ្លូវបេតុងអាមេ ០១ខ្សែ ប្រវែង ២១៥០ម៉ែត្រ ទទឹង ៧ម៉ែត្រ កម្រាស់ ០,១៥ម៉ែត្រ | គ្រោង | ២១៥០ម | 4,000 | ឃុំប៉ាក់ខ្លង | 6,816 | 6,574 | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 3,999 | | | | | | | |
| ១០ | គម្រោងសាងសង់លូមូលដោះទឹក ចំនួន២ខ្សែ ប្រវែងសរុប ១២០២ម៉ែត្រ | គ្រោង | ១២០២ម | 988 | សង្កាត់ស្មាច់មានជ័យ | 6,816 | 6,574 | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 987 | | | | | | | |
| ១១ | គម្រោងសាងសង់សួនច្បារចិញ្ចើមផ្លូវដោយចាក់បេតុងចំនួន០១កន្លែង ប្រវែង ៣១៧ម៉ែត្រ ទទឹង ៣៤ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ និងរៀបខឿនបេតុងជុំវិញ ប្រវែង ៩៩៦ម៉ែត្រ | គ្រោង | ១កន្លែង | 2,642 | សង្កាត់ស្មាច់មានជ័យ | 6,816 | 6,574 | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 2,641 | | | | | | | |
| ១២ | គម្រោងសាងសង់សួនកម្សាន្តសម្រាប់កុមារ ទំហំ ១២៧៨ ម៉ែត្រការ៉េ និងរបងប្រវែង ៧៨ម៉ែត្រ កំពស់ ១,២ម៉ែត្រ | គ្រោង | ១២៧៨ម២ | 370 | សង្កាត់ស្មាច់មានជ័យ | 6,816 | 6,574 | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 370 | | | | | | | |
| ១៣ | ការងារជួសជុលផ្លូវដោយចាក់បេតុងអាមេ ប្រវែង ១.០៩០ម ទទឹង ៦ម កម្រាស់ ០,១៥ម | គ្រោង | ១០៩០ម | 1,500 | ឃុំស្រែអំបិល | 6,473 | 7,370 | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | - | 1,499 | | | | | | | |
| ១៤ | គម្រោងសាងសង់អគារសាលាខេត្តកោះកុង (ជំហានទី០៥) ដែលមានបណ្តោយ ៤២ម៉ែត្រ ទទឹង ១៤.៥ម៉ែត្រ និងច្រកចូលខាងមុខ២.៥ម៉ែត្រ x ៦ម៉ែត្រ | គ្រោង | ១កន្លែង | 500 | សង្កាត់ស្មាច់មានជ័យ | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១កន្លែង | 498 | | | | | | | |
| ខ.ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| ១ | ការរៀបចំ និងជូនរង្វាន់ដល់សិស្សពូកែ | គ្រោង | ១ឆ្នាំ | 15 | ៧ក្រុង ស្រុក | - | - | - | - | 0% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 0 | | | | | | | |
| ២ | ឧបត្ថម្ភកីឡា | គ្រោង | ១ឆ្នាំ | 20 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 18.75 | | | | | | | |
| ៣ | ផ្សព្វផ្សាយពីការបញ្ជូនកុមារអោយចូលសាលា | គ្រោង | ១ឆ្នាំ | 5 | ៧ក្រុង ស្រុក | - | - | | - | 0% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 0 | | | | | | | |
| ៤ | ឧបត្ថម្ភដល់អ្នកជំងឺក្រីក្រសម្រាកព្យាបាលនៅមន្ទីរពេទ្យ | គ្រោង | ១ឆ្នាំ | 20 | ៧ក្រុង ស្រុក | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 19.1 | | | | | | | |
| ៥ | ជួយជនរងគ្រោះដោយធម្មជាតិ | គ្រោង | ១ឆ្នាំ | 44.8 | ៧ក្រុង ស្រុក | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 44.2 | | | | | | | |
| ៦ | [illegible] | គ្រោង | ១២ខែ | 68.7 | [illegible] | - | - | - | - | 100% | រដ្ឋ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| [illegible] | [illegible] | ជាក់ស្តែង | ១២ខែ | 45.2 | [illegible] | | | | | [illegible] | [illegible] |
| ៧ | ជំនួយសង្គមផ្សេងៗ | គ្រោង | ១ឆ្នាំ | 165 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 161.5 | | | | | | | |
| ៨ | ជួយសហគមន៍ និងវប្បធម៌ | គ្រោង | ១ឆ្នាំ | 10 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 9.8 | | | | | | | |
| ៩ | ឧបត្ថម្ភដល់អង្គភាពផ្សេងៗ | គ្រោង | ១ឆ្នាំ | 15 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១ឆ្នាំ | 15 | | | | | | | |
| ១០ | ឧបត្ថម្ភដល់សមាជិកភាពសមាគមក្រុមប្រឹក្សាខេត្ត | គ្រោង | ១លើក | 15 | ៧ក្រុង ស្រុក | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១លើក | 15 | | | | | | | |
| ១១ | វេទិកាសាធារណៈ | គ្រោង | ១២ខែ | 80 | ៧ក្រុង ស្រុក | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 79.9 | | | | | | | |
| ១២ | ផ្សព្វផ្សាយ និងការបង្ក្រាបជួញដូរគ្រឿងញៀន និងការជួញដូរស្ត្រី និងកុមារ | គ្រោង | ១២ខែ | 40 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 29.73 | | | | | | | |
| ១៣ | គាំទ្រសកម្មភាព ផអ៣ | គ្រោង | ១២ខែ | 150 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 86.9 | | | | | | | |
| ១៤ | យុទ្ធនាការប្រយុទ្ធការរីករាលដាលជំងឺកូវីដ-១៩ | គ្រោង | ១២ខែ | 50 | ៧ក្រុង ស្រុក | - | - | - | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 0 | | | | | | | |
| គ.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | | | | | | | | |
| ១ | ការអនុវត្តការផ្ទេរមុខងារបរិស្ថាន | គ្រោង | ១លើក | 219 | ក្រុងខេមរភូមិន្ទ | - | - | រួចរាល់ | - | 100% | រដ្ឋ |
| | | ជាក់ស្តែង | ១លើក | 219 | | | | | | | |
| ឃ.ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| ១ | គាំទ្រដល់សកម្មភាពការងារគណៈបញ្ជាការឯកភាពខេត្ត | គ្រោង | ១២ខែ | 200 | ៧ក្រុង ស្រុក | - | - | - | - | 92% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 140.8 | | | | | | | |
| ២ | គាំទ្រដល់កម្លាំងនគរបាលត្រួតពិនិត្យ សណ្តាប់ធ្នាប់ចរាចរសាធារណៈ និង (ភូមិ ឃុំ មានសុវត្ថិភាព ប្រជាការពារ) | គ្រោង | ១២ខែ | 33 | ៧ក្រុង ស្រុក | - | - | - | - | 92% | រដ្ឋ |
| | | ជាក់ស្តែង | ១២ខែ | 18.83 | | | | | | | |
| ព័ត៌មានខាងលើនេះ គិត្រឹមឆ្នាំ២០២៣ | | | | | | | | | | | |